ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## ក្រសួងសុខាភិបាល

# គោលការណ៍ណែនាំជាតិសម្រាប់ការបង្ការការចម្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ ពីម្តាយទៅកូន

បោះពុម្ពលើកទី ៦

ខែតុលា ឆ្នាំ ២០២១

**មាតិកា**

**អក្សរកាត់ និងពាក្យកាត់**........................................................................................1

**បុព្វកថា**..........................................................................................................................5

**ជំពូកទី ១ ៖ សេចក្តីផ្តើម និងសាវតារ** ..........................................................................7

1.1 **សេចក្តីផ្តើម** ..........................................................................................................7

**1.2 សាវតារ**...................................................................................................................7

*1.2.1 មេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា*..................................................................7

*1.2.2 ជំងឺស្វាយនៅក្នុងប្រទេសកម្ពុជា*........................................................................8

*1.2.3 ជំងឺរលាកថ្លើមប្រភេទបេ (HBV) នៅក្នុងប្រទេសកម្ពុជា*.....................................8

*1.2.4 ការថែទាំសុខភាពមាតានៅក្នុងប្រទេសកម្ពុជា*....................................................9

**ជំពូកទី ២ ៖ ទិដ្ឋភាពរួមនៃកម្មវិធី** PMTCT ..................................................................11

**ជំពូកទី ៣ ៖ ការផ្តល់ប្រឹក្សា ការធ្វើតេស្ត និងការអប់រំ**...................................................15

ស្ត្រីមានផ្ទៃពោះទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យមកទទួលការថែទាំផ្ទៃពោះ )ANC( យ៉ាងតិចចំនួន ៤ ដង ដោយចាប់ផ្តើមពីត្រីមាសទីមួយ និងទៅសម្រាលកូននៅមណ្ឌលសុខភាព ។ ផ្នែកនេះផ្តោតលើខ្លឹមសារដែលជាក់លាក់ទៅនឹង PMTCT ។ សូមមើលគោលការណ៍ណែនាំស្តីពីមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព និងមន្ទីរពេទ្យ សម្រាប់ការផ្តល់ប្រឹក្សាពេញលេញដែលត្រូវផ្តល់ដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយពេលសម្រាលកូន ។.......................................................................................15

3.1 ការផ្តល់ប្រឹក្សាអំពីការធ្វើតេស្តមេរោគអេដស៍ មេរោគស្វាយ និង HBV សម្រាប់ស្ត្រីមានផ្ទៃពោះ ........15

*3.1.1 ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត*......................................................................................18

*3.1.2 ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត*..................................................................................21

3.2 ទម្រង់ការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ........................................................................28

*3.2.1 ការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ ក្នុងពេលមានផ្ទៃពោះ*.......................................28

*3.2.2 ការធ្វើតេស្តមេរោគអេដស៍និងស្វាយក្នុងពេលឈឺពោះសម្រាល*...........................................32

*3.2.3 ការធ្វើតេស្តមេរោគអេដស៍សម្រាប់ទារកដែលប្រឈមមុខនឹងមេរោគអេដស៍*..........................35

*3.2.4 ការធ្វើតេស្តមេរោគរលាកថ្លើមប្រភេទបេសម្រាប់ទារកដែលប្រឈមមុខនឹងមេរោគនេះ*............35

3.3 ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង (IEC)........................................................................35

**ជំពូកទី ៤ ៖ ការព្យាបាលស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូន ដែលមានមេរោគអេដស៍ ស្វាយ ឬមេរោគរលាកថ្លើមប្រភេទបេ សម្រាប់បង្ការការចម្លងពីម្តាយទៅកូន** ............. 38

4.1 ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូនដែលផ្ទុកមេរោគអេដស៍ ..................................................38

4.2. ការបង្ការការចម្លងពីម្តាយទៅកូននៃជំងឺស្វាយ.............................................................................44

*4.2.1 ការព្យាបាលជំងឺស្វាយចំពោះម្តាយ ៖*..............................................................................44

*4.2.2. ការព្យាបាលជំងឺស្វាយសម្រាប់ដៃគូ ៖*...........................................................................46

*4.2.3 ការប្រើ Benzathine ឬ Procaine Penicillin:*...................................................................46

*4.2.4 ប្រតិកម្មអាឡែរស៊ីចំពោះ Penicillin*................................................................................48

*4.2.5 ការព្យាបាលជំងឺស្វាយសម្រាប់ទារក ៖*...........................................................................50

4.3 ការបង្ការការចម្លងពីម្តាយទៅកូននៃជំងឺរលាកថ្លើមប្រភេទបេ ...................................................51

4.4. ផលរំខាននៃឱសថប្រឆាំងនឹងវីរុស ត្រូវបានប្រើប្រាស់ក្នុងពេលមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន ...54

4.5. ការពិចារណាពិសេសអំពីសុវត្ថិភាពនៃ ART មុនពេលមានគភ៌ ...55

4.6. **ការព្យាបាលបង្ការសម្រាប់ការឆ្លងជំងឺឱកាសនិយម** (OI) ...60

*4.6.1. ការព្យាបាលបង្ការដោយថ្នាំ Co-trimoxazole សម្រាប់ស្ត្រីមានផ្ទៃពោះវិជ្ជមានមេរោគអេដស៍..60*

*4.6.2. ការព្យាបាលបង្ការដោយថ្នាំ Co-trimoxazole សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍...61*

**ជំពូកទី ៥ ៖ ការសម្រាលកូនដោយសុវត្ថិភាពសម្រាប់ស្ត្រីដែលឆ្លងមេរោគអេដស៍ ស្វាយ និងរោគស្វាយប្រភេទបេ ... 66**

5.1 ការប្រុងប្រយ័ត្នជាសកល ...66

5.2 ការព្យាបាលបង្ការសម្រាប់មេរោគអេដស៍ និងរលាកថ្លើមប្រភេទបេសម្រាប់បុគ្គលិកសុខាភិបាល ......67

*5.2.1 ការព្យាបាលបង្ការសម្រាប់មេរោគអេដស៍ ...67*

*5.2.2. ការព្យាបាលបង្ការសម្រាប់មេរោគរលាកថ្លើមប្រភេទបេ ...68*

5.3 វិធីសាស្ត្រជាអនុសាសន៍សម្រាប់ការសម្រាលកូនដោយសុវត្ថិភាពសម្រាប់ស្ត្រីដែលផ្ទុកមេរោគអេដស៍ ឬ មេរោគរលាកថ្លើមប្រភេទបេ ...68

5.4 ការថែទាំក្រោយពេលសម្រាល និងការគាំទ្រដោយផ្តល់ការអប់រំ ...69

**ជំពូកទី ៦ ៖ ការចិញ្ចឹមទារក និងការតាមដានបន្ត ... 74**

6.1 ការចិញ្ចឹមទារកក្នុងបរិបទមេរោគអេដស៍ ...75

6.2 ការតាមដានទារកដែលប្រឈមនឹងមេរោគអេដស៍ ...77

*6.2.1.ការផ្តល់ថ្នាំបង្ការ និងសេវាបង្ការជាប្រចាំផ្សេងទៀត...77*

*6.2.2. ការតាមដានទារកដែលប្រឈមចំពោះមេរោគអេដស៍...78*

6.3 ការតាមដានសម្រាប់ទារកដែលប្រឈមនឹងមេរោគស្វាយ ....79

6.4 ការតាមដានទារកដែលប្រឈមនឹងមេរោគរលាកថ្លើមប្រភេទបេ ....81

**ជំពូកទី ៧ ៖ ផែនការគ្រួសារ .... 82**

7.2 ផលិតផល និងសម្ភារពន្យារកំណើត ....83

7.3 មធ្យោបាយពន្យារកំណើត និងការការពារពីរមុខ ....83

**ជំពូកទី ៨ ៖ ទិដ្ឋភាពរួមនៃកម្មវិធីបង្ការការចម្លងពីម្ដាយទៅកូន (PMTCT) រួមបញ្ចូលទាំងការគ្រប់គ្រងនិងការតភ្ជាប់ខ្សែរវាងកម្មវិធីសុខភាពមាតានិងទារក និងកម្មវិធីមេរោគអេដស៍/ជំងឺអេដស៍ .... 92**

8.1 ការគ្រប់គ្រងកម្មវិធី PMTCT ....92

8.2 កញ្ចប់សេវា PMTCT ទាំងមូល ....94

8.3. ការឆ្លើយតបរួមគ្នានៅក្នុងល្បាក់សេវា PMTCT ....95

8.4. ធនធានមនុស្សដែលពាក់ព័ន្ធក្នុងការផ្ដល់សេវា PMTCT ៖ ....97

8.5. ការបណ្ដុះបណ្ដាល ....97

8.6. ការអភិបាល ....98

8.7. ការត្រួតពិនិត្យគុណភាព ....99

8.8. ភ័ស្តុភារ និងការផ្គត់ផ្គង់សម្ភារ ....100

**ជំពូកទី ៩ ៖ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ .... 103**

9.1 ការកត់ត្រា ការប្រមូលទិន្នន័យ និងការរាយការណ៍ ....103

9.2 សូចនាករថ្នាក់ជាតិនៃ PMTCT ....103

9.3 ការវាយតម្លៃ ...... 104

**សេចក្តីបន្ថែម ...... 109**

**សេចក្តីបន្ថែមទី ១ ៖ ទម្រង់ធ្វើតេស្តមេរោគអេដស៍/ស្វាយ...... 109**

1.1 លទ្ធផលតេស្តមេរោគអេដស៍ស្វាយនៅមណ្ឌលសុខភាព/ ( ANC ) និងអគារសម្ភព ...... 109

1.2 លទ្ធផលតេស្តមេរោគអេដស៍ ( VCCT ) ...... 110

1.3 ប័ណ្ណបញ្ជូនសម្រាប់ការធ្វើតេស្តបញ្ជាក់មេរោគអេដស៍និងស្វាយនៅទីតាំង VCCT /FHC ...... 110

**សេចក្តីបន្ថែមទី ២ ៖ ប័ណ្ណកំណត់ត្រាមុនពេលចុះឈ្មោះ PMTCT ( សាលកបត្រ ) ...... 111**

2.1 ការចុះឈ្មោះជាមុនសម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ លើទម្រង់កំណត់ត្រាសម្ភព ...... 111

2.2 ព័ត៌មានអំពី ART សម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍ ...... 112

2.3 ការចុះឈ្មោះជាមុនសម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍ ...... 113

**សេចក្តីបន្ថែមទី ៣ ៖ ប័ណ្ណកំណត់ត្រា PMTCT ...... 114**

3.1 សៀវភៅកំណត់ត្រា ANC ...... 114

3.2 សៀវភៅកំណត់ត្រាសម្ភព ...... 115

3.3 ប័ណ្ណកំណត់ត្រា PNC ...... 117

3.4 ការសម្រាលកូននៅមណ្ឌលសុខភាព ...... 118

3.5 ប័ណ្ណកំណត់ត្រាការធ្វើតេស្តមេរោគអេដស៍និងការផ្តល់ប្រឹក្សាសម្រាប់អតិថិជនទូទៅ ...... 119

3.6 ប័ណ្ណតាមដាន PMTCT/LR ( ឧបករណ៍តាមដាន ) ...... 120

*3.6.1. ឧបករណ៍តាមដានមេរោគអេដស៍ ......120*
*3.6.1. Syphilis Tracking Tool ......121*
**សេចក្តីបន្ថែមទី ៤ ៖ សៀវភៅកំណត់ត្រារួមគ្នារវាងការពន្យារកំណើតនិងមេរោគអេដស៍** ......123
4.1 កំណត់ត្រាប្រចាំថ្ងៃ ......123
4.2 កំណត់ត្រាគោលដៅ ......123
**សេចក្តីបន្ថែមទី ៥ ៖ បញ្ជីផ្ទៀងផ្ទាត់សម្រាប់ការអភិបាលសេវា** PMTCT ( **មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក** ) ......124
**សេចក្តីបន្ថែមទី ៦ ៖ ការរាយការណ៍** PMTCT ......138
6.1 របាយការណ៍មូលដ្ឋានទិន្នន័យ PMTCT ......138
6. 2. របាយការណ៍ប្រចាំត្រីមាសអំពី HTC សម្រាប់មណ្ឌលសុខភាព ......146

# តារាង រូបភាព និងប្រអប់

តារាង


តារាងទី ១៖ ការវាយតម្លៃហានិភ័យ........................................................................ 12

តារាងទី ២៖ ការព្យាបាល ART សម្រាប់ស្ត្រីមានផ្ទៃពោះ/ស្ត្រីបំបៅដោះកូន.......................................... 24

តារាងទី ៣៖ គោលការណ៍ណែនាំស្តីពីការព្យាបាលបង្ការដោយប្រើ ARV សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍.............................................................................................................. 25

តារាងទី ៤៖ ដូស ARV សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍................................................. 26

តារាងទី ៥៖ សង្ខេបការព្យាបាលបង្ការដោយ ART សម្រាប់ម្តាយនិង ARV សម្រាប់ទារក............................ 26

តារាងទី ៦៖ ការព្យាបាលជំងឺស្វាយសម្រាប់ស្ត្រីមានផ្ទៃពោះ............................................................ 28

តារាងទី ៧៖ ការព្យាបាលសម្រាប់ទារកដែលប្រឈមនឹងមេរោគស្វាយ................................................ 32

តារាងទី ៨៖ ការព្យាបាលស្ត្រីមានផ្ទៃពោះដែលវិជ្ជមាន HBsAg Positive............................................. 33

តារាងទី ៩៖ ផលរំខានដែលពាក់ព័ន្ធនឹង ARVs ដែលប្រើទូទៅដោយស្ត្រីមានផ្ទៃពោះ............................ 35

**តារាងទី ១០៖ តើត្រូវចាប់ផ្តើម និងឈប់ប្រើការព្យាបាលបង្ការដោយថ្នាំ** Cotrimoxazole **សម្រាប់ស្ត្រីមានផ្ទៃពោះនៅពេលណា**.................................................................................................... 37

**តារាងទី ១១៖** តើត្រូវចាប់ផ្តើម និងឈប់ប្រើការព្យាបាលបង្ការដោយថ្នាំ Cotrimoxazole សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍នៅពេលណា........................................................................... 38

**តារាងទី ១២៖ អនុសាសន៍ដូសសម្រាប់ការព្យាបាលបង្ការដោយថ្នាំ** Cotrimoxazole **សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍**.................................................................................................. 38

តារាងទី ១៣៖ ការគ្រប់គ្រងកន្ទួលដែលទាក់ទងនឹងថ្នាំ Cotrimoxazole............................................... 39

**តារាងទី ១៤៖ មធ្យោបាយពន្យារកំណើត និងផែនការគ្រួសារ**.......................................................... 53

**តារាងទី ១៥៖ សូចនាករ** PMTCT **សំខាន់ៗ និងចំណុចដៅសម្រាប់ឆ្នាំ២០២៥** ...................................... 66


ប្រអប់


**ប្រអប់ទី ១៖ ចំណុចពិចារណាពិសេសក្នុងការគ្រប់គ្រងស្ត្រីយុវវ័យមានផ្ទៃពោះ**.............................. 13

**ប្រអប់ទី ២៖ គោលដៅនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត**......................................................... 13

**ប្រអប់ទី ៣៖ ទម្រង់ការធ្វើតេស្តជួសឈាមម្រាមដៃសម្រាប់មេរោគអេដស៍/ស្វាយពីរមុខ**............................ 17

**ប្រអប់ទី ៤៖ ទម្រង់ការធ្វើតេស្ត** HBsAg **ដោយជួសឈាមម្រាមដៃ**...................................................... 18

**ប្រអប់ទី ៥៖ ប្រតិករ និងសម្ភារ និងការរក្សាទុក**............................................................................ 18

**ប្រអប់ទី ៦៖ ការពិនិត្យស្រាវជ្រាវរក/ការគ្រប់គ្រងស្តុកអាណាហ្វីឡាក់ទិក**............................................. 30

**ប្រអប់ទី ៧៖ ការប្រុងប្រយ័ត្នជាសកល**.......................................................................................... 40

ប្រអប់ទី ៨៖ វិធានការដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ក្នុងពេលសម្រាលតាមទ្វារមាស... 42

**ប្រអប់ទី ៩៖ ការថែទាំក្រោយសម្រាលពិសេសសម្រាប់ស្ត្រីដែលឆ្លងមេរោគអេដស៍**.................................. 43

**ប្រអប់ទី ១០៖ ការប្រមូលសំណាកឈាមស្ងួត** (DBS) **ក្រោយពេលសម្រាលទារកដែលប្រឈមនឹងមេរោគអេដស៍**................................................................................................................ 44

**ប្រអប់ទី ១១៖ ការថែទាំក្រោយសម្រាលពិសេសសម្រាប់ស្ត្រីដែលឆ្លង** HBsAg ........................................ 44

**ប្រអប់ទី ១២៖ វិធានការសម្រាប់ការចិញ្ចឹមទារកដោយទឹកដោះគោម្សៅប្រកបដោយសុវត្ថិភាព**.................. 47

ប្រអប់ទី ១៣៖ ការណែនាំសម្រាប់ការព្យាបាលជំងឺស្វាយពីកំណើត.......................................................50

## រូបភាព

រូបភាពទី ១៖ យុទ្ធសាស្ត្រធ្វើតេស្តមេរោគស្វាយនិងការព្យាបាល.......................................................... 27

រូបភាពទី ២៖ វដ្តនៃ PMTCT សម្រាប់មេរោគអេដស៍និងមេរោគស្វាយ.................................................. 58

- រូបភាពទី ៣៖ ការផ្តល់សេវា និងការឆ្លើយតបរួមគ្នាសម្រាប់មេរោគអេដស៍/ស្វាយ រួមជាមួយល្បាក់ *PMTCT*.............. 59

**រូបភាពទី ៤៖ ការគ្រប់គ្រងអង្គការលេខសម្រាប់ការគ្រប់គ្រង** PMTCT **នៃមេរោគអេដស៍និងស្វាយ**.............. 64

# អក្សរកាត់ និងពាក្យកាត់

| | |
|---|---|
| 3TC | Lamivudine |
| ABC | Abacavir |
| ACM | Active Case Management (ការគ្រប់គ្រងករណីសកម្ម) |
| AIDS | Acquired Immunodeficiency Syndrome (ចង្កោមរោគសញ្ញាចុះខ្សោយប្រព័ន្ធភាពស៊ាំដែលឆ្លងពីខាងក្រៅ) |
| ANC | Antenatal care (ការថែទាំផ្ទៃពោះមុនពេលសម្រាល) |
| ART | Antiretroviral therapy (ការព្យាបាលដោយឱសថប្រឆាំងវីរុស) |
| ARV | Antiretroviral drug (ឱសថប្រឆាំងវីរុស) |
| AZT | Azidothymidine |
| B-IACM | Boosted-Integrated Active Case Management (ការជំរុញខ្លាំងក្លាការគ្រប់គ្រងករណីសកម្មសមាហរណកម្ម) |
| BS | Birth spacing (ការពន្យារកំណើត) |
| CBO | Community-based organization (អង្គការនៅថ្នាក់សហគមន៍) |
| CBPCS | Community based prevention care and support (ការបង្ការ ការថែទាំ និងការគាំទ្រនៅសហគមន៍) |
| CD4 | Cluster of differentiation 4 (a type of white blood cell) (កម្រងកោសិកាខុសគ្នា ៤) (ប្រភេទមួយនៃគ្រាប់ឈាមស) |
| CHAI | Clinton Health Access Initiative (គម្រោងគំនិតផ្តួចផ្តើមទទួលបានសេវាសុខភាពនៃមូលនិធិគ្លីនតុន) |
| CHB | Chronic Hepatitis B (ជំងឺរលាកថ្លើមប្រភេទបេ) |
| CK | Creatnine Kinase (ក្រេអាទីនីន គីនេស) |
| CMC | Case Management Coordinator (អ្នកសម្របសម្រួលការគ្រប់គ្រងករណី) |
| CMP | Case Management Provider (អ្នកផ្តល់សេវាគ្រប់គ្រងករណី) |
| CMS | Case Management Supporter (អ្នកគាំទ្រការគ្រប់គ្រងករណី) |
| CMS | Central Medical Supply (ឃ្លាំងឱសថកណ្តាល) |
| CMA | Case Management Assistant (ជំនួយការគ្រប់គ្រងករណី) |
| CNS | Central nervous system (ប្រព័ន្ធសរសៃប្រសាទកណ្តាល) |
| CoC | Continuum of Care (ការថែទាំបន្ត) |
| COC | Combined Oral Contraceptive (ថ្នាំគ្រាប់ពន្យារកំណើតដែលរួមបញ្ចូលគ្នាពីរមុខ) |
| CoPCT | Continuum of prevention, care and treatment (ការបង្ការ ការថែទាំ និងការព្យាបាល |

| | |
|---|---|
| | បន្ត ) |
| CSO | Community support organization ( អង្គការគាំទ្រសហគមន៍ ) |
| DBS | Dried blood spot ( សំណាកឈាមស្ងួត ) |
| DNA | Deoxyribonucleic acid ( អាស៊ីតដេអុកស៊ីរីបូនុយក្លេអ៊ិក ) |
| DTG | Dolutegravir ( ដូលុយតេក្រាវ៉ា ) |
| EFV | Efavirenz ( អេហ្វាវ៉ារេន ) |
| ELISA | Enzyme Linked Immunosorbent Assay ( តេស្តអង់ហ្ស៊ីមអ៊ីមមុយណូសូបង់ ) |
| eMTCT | Elimination of Mother-to-child Transmission ( ការលុបបំបាត់ការចម្លងពីម្តាយទៅកូន ) |
| EW | Entertainment Worker ( អ្នកធ្វើការក្នុងសេវាកម្សាន្ត ) |
| FDC | Fixed Dose combination ( ការព្យាបាលដោយឱសថរួមបញ្ចូលគ្នាតែមួយមុខ ) |
| FP | Family Planning ( ផែនការគ្រួសារ/ការពន្យារកំណើត ) |
| FTC | Emitricitabine |
| GFATM | Global Fund to Fight AIDS, Tuberculosis and Malaria ( មូលនិធិសកលដើម្បីប្រយុទ្ធនឹងជំងឺអេដស៍ របេង និងគ្រុនចាញ់ ) |
| Hb | Hemoglobin ( អេម៉ូក្លូប៊ីន ) |
| HBC | Home-based care ( ការថែទាំតាមផ្ទះ ) |
| HBeAg | Hepatitis "e" antigen ( អង់ទីហ្សែន HBe ) |
| HBsAg | Hepatitis B surface antigen ( អង់ទីហ្សែន HBs ) |
| HBV | Hepatitis B ( ជំងឺរលាកថ្លើមប្រភេទបេ ) |
| HIV | Human Immunodeficiency Virus (វីរុសដែលធ្វើឱ្យចុះខ្សោយប្រព័ន្ធភាពស៊ាំរបស់មនុស្ស ) |
| HTC | HIV Testing and Counseling ( ការផ្តល់ប្រឹក្សានិងការធ្វើតេស្តមេរោគអេដស៍ ) |
| HTN | Hypertension ( ជំងឺឡើងសម្ពាធឈាម ) |
| IUD | Intrauterine Device ( កងដាក់ក្នុងស្បូន ) |
| IEC | Information, Education and Communication ( ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង ) |
| IMCI | Integrated management of childhood illness ( សមាហរណកម្មការពិនិត្យនិងព្យាបាលជំងឺកុមារ សពជក ) |
| IRIR | Intensify Reach Intensify Retain ( បង្កើនខ្លាំងក្លាការគ្របដណ្តប់ បង្កើនខ្លាំងក្លាការថែរក្សា ) |
| KP | Key Population ( ប្រជាជនគន្លឹះ ) |

| | |
|---|---|
| LR | Linked Response (ការឆ្លើយតបរួមគ្នា) |
| MCH | Maternal and Child Health (សុខភាពមាតានិងទារក) |
| MMM | MondulMithChuoyMith (HIV/AIDS support group) (មណ្ឌលមិត្តជួយមិត្ត) (ក្រុមគាំទ្រមេរោគអេដស៍/ជំងឺអេដស៍) |
| MNCH | Maternal, Newborn and Child Health (សុខភាពមាតា ទារកទើបនឹងកើត និងកុមារ) |
| MSM | Men who have sex with Men (បុរសដែលរួមភេទជាមួយបុរស) |
| MoH | Ministry of Health (ក្រសួងសុខាភិបាល) |
| MPA | Minimum package of activities (សំណុំសកម្មភាពអប្បបរមា) |
| MTCT | Mother-to-Child Transmission (of HIV/Syphilis) (ការចម្លងពីម្ដាយទៅកូន (នៃមេរោគអេដស៍/ស្វាយ)) |
| NCHADS | National Centre for HIV/AIDS, Dermatology and STD (មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ) |
| NIPH | National Institute of Public Health (វិទ្យាស្ថានជាតិសុខភាពសាធារណៈ) |
| NMCHC | National Maternal and Child Health Centre (មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក ម.ជ.គ.ម.ទ) |
| NNRTI | Non-nucleoside reverse-transcriptase inhibitor |
| NVP | Nevirapine (នីវ៉ារ៉ាពីន) |
| OD | Operational District (ស្រុកប្រតិបត្តិ) |
| OI | Opportunistic Infection (ការឆ្លងជំងឺឱកាសនិយម) |
| PAC | Pediatric AIDS Care (ការថែទាំជំងឺអេដស៍កុមារ) |
| PASP | Provincial AIDS and STI Program (កម្មវិធីអេដស៍និងកាមរោគខេត្ត) |
| PCR | Polymerase Chain Reaction |
| PEP | Post-Exposure Prophylaxis (ការព្យាបាលបង្ការក្រោយពេលប្រឈម) |
| PHD | Provincial Health Department (មន្ទីរសុខាភិបាលខេត្ត) |
| PI | Protease Inhibitor |
| PLHIV | People Living with HIV (អ្នករស់នៅជាមួយមេរោគអេដស៍) |
| PMTCT | Prevention of Mother-to-Child Transmission (of HIV) (ការបង្ការការចម្លងពីម្ដាយទៅកូន (នៃមេរោគអេដស៍)) |
| POP | Progestin-only Pill (ថ្នាំគ្រាប់ពន្យារកំណើតដែលមានប្រូជេស្ទីនតែមួយមុខគត់) |
| PrEP | Pre-Exposure Prohylaxis (ការព្យាបាលបង្ការមុនពេលប្រឈម) |
| PWID | People Who Inject Drugs (អ្នកចាក់គ្រឿងញៀន) |
| PWUD | People Who Use Drugs (អ្នកប្រើគ្រឿងញៀន) |

| | |
|---|---|
| Rep H | Reproductive Health ( សុខភាពបន្តពូជ ) |
| RH | Referral Hospital ( មន្ទីរពេទ្យបង្អែក ) |
| RMNCH | Reproductive, Maternal, Newborn and Child Health ( សុខភាពបន្តពូជ មាតា ទារកទើបនឹងកើត និងកុមារ ) |
| SD | Single dose ( ដូសតែមួយមុខគត់ ) |
| SEI | Syphilis-Exposed Infant ( ទារកដែលប្រឈមនឹងមេរោគស្វាយ ) |
| SOP | Standard Operating Procedure ( នីតិវិធីប្រតិបត្តិស្តង់ដារ ) |
| STI | Sexually Transmitted Infection ( ជំងឺកាមរោគ ) |
| TB | Tuberculosis ( ជំងឺរបេង ) |
| TDF | Tenofovir ( តេណូហ្វូវា ) |
| TG | Transgender ( ក្រុមបំលែងភេទ ) |
| TM/SMX | Trimethoprin/sulfamethoxazole ( Co-trimaxazole ) |
| TWG | Technical Working Group ( ក្រុមការងារបច្ចេកទេស ) |
| UA | Universal Access ( ការទទួលបានសេវាជាសកល ) |
| UNAIDS | Joint United Nations Program on HIV/AIDS ( កម្មវិធីអង្គការសហប្រជាជាតិរួមគ្នាស្តីពីមេរោគអេដស៍/ជំងឺអេដស៍ ) |
| UNFPA | United Nations Population Fund ( អង្គការមូលនិធិប្រជាជនសហប្រជាជាតិ ) |
| UNICEF | United Nations Children´s Fund ( អង្គការមូលនិធិកុមារសហប្រជាជាតិ ) |
| US-CDC | United States Centers for Disease Control and Prevention ( មជ្ឈមណ្ឌលត្រួតពិនិត្យនិងបង្ការជំងឺឆ្លងនៃសហរដ្ឋអាមេរិក ) |
| VAC | Vitamin A Capsule ( ថ្នាំគ្រាប់វីតាមីនអា ) |
| VCCT | Voluntary Confidential Counseling and Testing ( ការធ្វើតេស្តនិងការប្រឹក្សាជាសម្ងាត់ដោយស្ម័គ្រចិត្ត ) |
| VHSG | Village Health Support Group ( ក្រុមទ្រទ្រង់សុខភាពភូមិ ) |
| VL | Viral Load ( បន្ទុកមេរោគ ) |
| WHO | World Health Organization ( អង្គការសុខភាពពិភពលោក ) |
| ZDV | Zidovudine ( ហ្សីដូវូឌីន ) |

# បុព្វកថា

ទោះបីជាកម្ពុជាគឺជាប្រទេស ដែលមានការរីករាលដាល នៃមេរោគអេដស៍ដ៏ធ្ងន់ធ្ងរបំផុតមួយ នៅអាស៊ីពីដំបូងក្តី ប៉ុន្តែកម្មវិធីជាតិប្រយុទ្ធនឹងមេរោគអេដស៍នៅក្នុងប្រទេសនេះ បានទទួលជោគជ័យក្នុងការកាត់បន្ថយអត្រាអ្នកផ្ទុកមេរោគអេដស៍ក្នុងចំណោមប្រជាជនទូទៅ ដែលមានអាយុចាប់ពី ១៥ ឆ្នាំឡើងទៅ ពី ១,៥% ក្នុងឆ្នាំ ១៩៩៨ ដល់ ០,៦% ក្នុងឆ្នាំ ២០១៩[1]។ ផ្អែកលើសមិទ្ធិផលទាំងនេះដែលសម្រេចបាន នៅក្នុងការប្តូរទិសដៅនិន្នាការ នៃប្រេវ៉ាឡង់មេរោគអេដស៍ និងការសម្រេចបានការទទួលបានជាសកលនូវការព្យាបាលមេរោគអេដស៍ ប្រទេសនេះបានទទួលពានរង្វាន់គោលដៅអភិវឌ្ឍន៍សហស្សវត្សរបស់អង្គការសហប្រជាជាតិកាលពីឆ្នាំ ២០១០។ ការរីករាលដាលមេរោគអេដស៍ឥឡូវនេះបានប្រមូលផ្តុំក្នុងចំណោមក្រុមមនុស្សដែលមានហានិភ័យខ្ពស់ជាចម្បង។ ទោះបីជាយ៉ាងណាក្តី បុរសដែលឆ្លងមេរោគអេដស៍តាមរយៈការទិញសេវាភេទខាងក្រៅ នៅតែអាចចម្លងមេរោគអេដស៍ទៅប្រពន្ធ និងដៃគូជាស្ត្រីជាប្រចាំរបស់ពួកគេ។ លើសពីនេះទៀត អត្រាប្រេវ៉ាឡង់មេរោគស្វាយ ថ្មីៗនេះបានកើនឡើងក្នុងក្រុមដែលមានហានិភ័យខ្ពស់ និងក្នុងចំណោមស្ត្រីមានផ្ទៃពោះ ហើយជំងឺរលាកថ្លើមប្រភេទបេគឺមានការរាតត្បាតខ្ពស់ផងដែរ។ មេរោគអេដស៍-ស្វាយ និងរលាកថ្លើមប្រភេទបេ សុទ្ធតែអាចចម្លងពីស្ត្រីមានផ្ទៃពោះទៅទារករបស់ពួកគេ ។

មជ្ឈមណ្ឌលជាតិគាំពារមាតានិងទារក (ម.ជ.គ.ម.ទ) ក្រោមការគ្រប់គ្រងរបស់ក្រសួងសុខាភិបាលនៃប្រទេសកម្ពុជា ដោយសហការជាមួយមជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជំងឺអេដស៍ សើស្បែក និងកាមរោគ (NCHADS) និងអង្គការក្នុងស្រុកនិងអន្តរជាតិនានា បានឆ្លើយតបទៅនឹងតម្រូវការរបស់ស្ត្រីមានផ្ទៃពោះ និងដៃគូរបស់ពួកគេ។ កម្មវិធីបង្ការការចម្លងពីម្តាយទៅកូន (PMTCT) ត្រូវបានដាក់បញ្ចូលទៅក្នុងប្រព័ន្ធដែលមានស្រាប់ ហើយមិនត្រឹមតែមានគោលបំណងបង្ការការចម្លងមេរោគពីម្តាយទៅកូន (MTCT) ប៉ុណ្ណោះទេ ប៉ុន្តែក៏ដើម្បីលើក កម្ពស់គុណភាពជារួមនៃសេវាសុខាភិបាលផងដែរ។ យុទ្ធសាស្ត្រជាតិទីមួយសម្រាប់ការបង្ការការចម្លងមេរោគពីម្តាយទៅកូន ឆ្នាំ ២០០៨ – ២០១៥, ផ្តោតលើការចម្លងមេរោគអេដស៍ពីម្តាយទៅកូន។ ដោយសារតែកិច្ចខិតខំប្រឹងប្រែងទាំងនេះ ការចម្លងរោគមេរោគអេដស៍ពីម្តាយទៅកូនបានធ្លាក់ចុះពីប្រមាណ ២១,០% ក្នុងឆ្នាំ២០១០ ដល់ប្រមាណ ៨,៨% ក្នុងឆ្នាំ ២០១៩។[2] ទោះបីជា យ៉ាងណាក្តី គេចាំបាច់ត្រូវការ ការខិតខំប្រឹងប្រែងបន្ថែមទៀត ដើម្បីសម្រេចបានគោលដៅនៃការលុប បំបាត់ ការចម្លងមេរោគអេដស៍ពីម្តាយទៅកូនត្រឹមឆ្នាំ ២០២៥។

យុទ្ធសាស្ត្រជាតិ PMTCT ទីពីរ ឆ្នាំ ២០១៦ - ២០២០ បានពង្រីកចំណុចផ្តោតលើការបង្ការមេរោគអេដស៍ ដោយដាក់បញ្ចូលការធ្វើតេស្តនិងការព្យាបាលជំងឺស្វាយក្នុងចំណោមស្ត្រីមានផ្ទៃពោះ ដើម្បីទប់ស្កាត់ជំងឺស្វាយពីកំណើត ហើយគោលការណ៍ណែនាំនេះ ត្រូវបានធ្វើបច្ចុប្បន្នភាពទៅតាមនោះដែរ។ គិតត្រឹមឆ្នាំ២០១៩ អតិថិជនមកថែទាំផ្ទៃពោះមុនពេលសម្រាលចំនួន ៨០% ត្រូវបានពិនិត្យរកជំងឺ

---

[1] ការអង្កេតមេរោគអេដស៍នៅកម្ពុជា ឆ្នាំ២០២០។

[2] ibid

ស្វាយ[3]។ ទោះបីជាយ៉ាងណាក៏ដោយ គេត្រូវធ្វើការខិតខំប្រឹងប្រែងបន្ថែមទៀតដើម្បីធានាថា ស្ត្រីមានផ្ទៃពោះទាំងអស់ដែលមានតេស្តប្រតិកម្មចំពោះមេរោគស្វាយនិងទារករបស់ពួកគេ ទទួលបានការព្យាបាលសមស្រប។

យុទ្ធសាស្ត្រ PMTCT ទី ២ នេះ ក៏បានរួមបញ្ចូលផងដែរនូវការសិក្សាបឋមមួយចំនួនស្តីពីវិធានការទប់ស្កាត់ ការចម្លងពីម្តាយទៅកូននូវជំងឺរលាកថ្លើមប្រភេទបេ (HBV)។ ចាប់តាំងពីពេលនោះមក ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើក្របខ័ណ្ឌថ្នាក់តំបន់របស់អង្គការសុខភាពពិភពលោក សម្រាប់ការលុបបំបាត់ការចម្លងពីម្តាយ ទៅកូននូវមេរោគអេដស៍-ស្វាយ ជំងឺរលាកថ្លើមប្រភេទបេ នៅក្នុងទ្វីបអាស៊ី ដូច្នេះ នេះគឺជាពេលវេលាត្រឹមត្រូវមួយ ដើម្បីដាក់បញ្ចូលការធ្វើតេស្តនិងការព្យាបាលស្ត្រីមានផ្ទៃពោះដែលប្រឈមមុខចំពោះការចម្លងមេរោគរលាកថ្លើមប្រភេទបេជុំវិញកំណើត ទៅក្នុងសេវា PMTCT។

មគ្គុទេសក៍នេះ ជំនួសឱ្យ*មគ្គុទេសក៍ជាតិសម្រាប់ការបង្ការការចម្លងមេរោគអេដស៍និងស្វាយពីម្តាយទៅកូន* ការបោះពុម្ពលើកទី ៥ ឆ្នាំ ២០១៧។ ឯកសារនេះផ្តល់ការណែនាំដល់អ្នកផ្តល់សេវាថែទាំសុខភាព អំពីវិធី ផ្តួចផ្តើម អនុវត្ត តាមដាន និងវាយតម្លៃសេវា HIV/syphilis/HBV PMTCT នៅមូលដ្ឋានសុខាភិបាល។ ឯកសារនេះនឹងត្រូវបានធ្វើបច្ចុប្បន្នភាពដោយក្រុមការងារបច្ចេកទេស PMTCT ជាទៀងទាត់ ដោយផ្អែកលើភស្តុតាង វិទ្យាសាស្ត្រថ្មីដែលមាន។

ថ្ងៃ...អង្គារ ៦ កើត...ខែអស្សុជ ឆ្នាំឆ្លូវត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ១២ ...ខែ តុលា ...ឆ្នាំ២០២១
**រដ្ឋមន្ត្រីក្រសួងសុខាភិបាល**

**ម៉ម ប៊ុនហេង**

[3]មូលដ្ឋានទិន្នន័យ NMCH PMTCT 2019

# ជំពូកទី ១ ៖ សេចក្ដីផ្ដើម និងសាវតារ

## 1.1 សេចក្ដីផ្ដើម

គោលការណ៍ណែនាំជាតិនេះ ផ្ដល់នូវមូលដ្ឋានដើម្បីសម្រេចបានការលុបបំបាត់ការចម្លងពីម្ដាយទៅកូន (eMTCT) នៃមេរោគអេដស៍ និងមេរោគស្វាយត្រឹមឆ្នាំ ២០២៥ និងមេរោគរលាកថ្លើមប្រភេទបេ (HBV) ត្រឹមឆ្នាំ ២០៣០ ។ គោលការណ៍ណែនាំជាតិនេះមានគោលបំណងផ្ដល់ដល់បុគ្គលិកដែលធ្វើការនៅតាមមូលដ្ឋានសុខាភិបាលទាំងអស់ដែលផ្ដល់សេវាសុខភាពដល់ស្ត្រី ជាពិសេសស្ត្រីមានផ្ទៃពោះ នូវចំណេះដឹងចាំបាច់និងការណែនាំលម្អិតស្ដីពីការប្រឹក្សា, ការធ្វើតេស្ត, កម្រិតឱសថដែលត្រូវប្រើ, ការថែទាំផ្នែកសម្ភព, ការចិញ្ចឹមទារក, ការពន្យារកំណើត និងការគ្រប់គ្រងនិងត្រួតពិនិត្យតាមដានកម្មវិធី PMTCT ។ គោលការណ៍ណែនាំជាតិនេះត្រូវបានរៀបចំឡើង ដោយផ្អែកលើបទពិសោធន៍ដែលទទួលបាននៅក្នុងប្រទេសកម្ពុជានិងអនុសាសន៍ពីថ្នាក់អន្តរជាតិ ។

## 1.2 សាវតារ

### *1.2.1 មេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា*

មេរោគអេដស៍ត្រូវបានរកឃើញដំបូងបំផុតនៅក្នុងប្រទេសកម្ពុជាក្នុងឆ្នាំ ១៩៩១ ហើយអ្នកជំងឺអេដស៍ដំបូងបំផុតត្រូវបានធ្វើរោគវិនិច្ឆ័យឃើញនៅក្នុងឆ្នាំ ១៩៩៣ ។ ការចម្លងមេរោគអេដស៍ជាចម្បងគឺតាមរយៈស្ត្រីរកស៊ីផ្លូវភេទទៅអតិថិជនរបស់ពួកគេ ។ អត្រាប្រេវ៉ាឡង់មេរោគអេដស៍បានធ្លាក់ចុះ បន្ទាប់ពីមានគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ ១០០%, ការធ្លាក់ចុះនូវអត្រាប្រេវ៉ាឡង់នៃឥរិយាបថប្រកបដោយការប្រឈមមុខខ្ពស់ និងការព្យាបាលដោយឱសថប្រឆាំងវីរុស (ART) សម្រាប់អ្នករស់នៅជាមួយមេរោគអេដស៍។ នៅក្នុងឆ្នាំ ២០១៩ អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍ក្នុងចំណោមមនុស្សពេញវ័យទូទៅដែលមានអាយុពី ១៥-៤៩ ឆ្នាំ ត្រូវបានប៉ាន់ស្មានថា មានត្រឹមតែ 0.៥% ប៉ុណ្ណោះ ដែលក្នុងនោះ ករណីភាគច្រើនបំផុតគឺជាការឆ្លងរយៈពេលយូរមកហើយចំពោះអ្នកដែលមានស្ថិរភាពក្នុងការព្យាបាលដោយឱសថប្រឆាំងវីរុស ។ គិតត្រឹមដំណាច់ឆ្នាំ ២០១៩ ប្រជាជនកម្ពុជាប្រមាណ ៨៤% ដែលរស់នៅជាមួយមេរោគអេដស៍ (PLHIV) ទទួលបានព្យាបាលដោយឱសថប្រឆាំងវីរុស ។ ផ្អែកលើជោគជ័យទាំងនេះ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្ដើមអនុវត្តគោលដៅប្រកបដោយមហិច្ឆតាមួយក្នុងការកាត់បន្ថយការចម្លងមេរោគអេដស៍ថ្មី មកត្រឹមតិចជាង ២៥០ ករណីក្នុងមួយឆ្នាំ ត្រឹមឆ្នាំ ២០២៥ ។

ការរីករាលដាលមេរោគអេដស៍នៅក្នុងប្រទេសកម្ពុជា កើតឡើងជាចម្បងតាមរយៈការរួមភេទ, ពោលគឺពីអ្នករកស៊ីផ្លូវភេទទៅអតិថិជនរបស់ពួកគេ ។ បន្ទាប់មក អតិថិជនជាបុរសជារឿយៗ ចម្លងបន្តទៅប្រពន្ធរបស់ពួកគេ ។ ស្ទើរតែគ្រប់ករណីឆ្លងមេរោគអេដស៍ចំពោះកុមារទាំងអស់ កើតឡើងពីម្តាយដែលឆ្លងមេរោគអេដស៍, ក្នុងអំឡុងពេលមានផ្ទៃពោះ, ការឈឺពោះសម្រាល, ការសម្រាលកូន ឬក្នុងអំឡុងពេលបំបៅដោះកូន ។ ការប៉ាន់ស្មានចុងក្រោយបំផុតនៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូននៅក្នុងប្រទេសកម្ពុជា គឺ ៨,៨% ក្នុងឆ្នាំ ២០១៩[4] ។ កម្ពុជាបានប្តេជ្ញាចិត្តក្នុងការសម្រេចឱ្យបានគោលដៅនៃការកាត់បន្ថយអត្រានេះឱ្យនៅក្រោម ៥% ត្រឹមឆ្នាំ ២០២៥ ។

*1.2.2 ជំងឺស្វាយនៅក្នុងប្រទេសកម្ពុជា*

បច្ចុប្បន្ននេះ ស្ត្រីមានផ្ទៃពោះប្រហែល ០,១១% មានមេរោគស្វាយ[5] ។ ទោះបីជាយ៉ាងណាក្តី អត្រានៃការព្យាបាលមានកម្រិតទាប ដែលតាមការប៉ាន់ប្រមាណគំរូនៃជំងឺស្វាយពីកំណើតគឺមានជាង ៥០ ករណី ក្នុង ១០០.០០០ កំណើត ក្នុងឆ្នាំ ២០១៩[6] ។ កម្ពុជាបានប្តេជ្ញាចិត្តសម្រេចឱ្យបានការលុបបំបាត់ការចម្លងពីម្តាយទៅកូននូវជំងឺស្វាយ (ដែលបានកំណត់ថាតិចជាង ៥០ ករណី/១០០,០០០ កំណើតរស់) ត្រឹមឆ្នាំ ២០២៥ ។ ដូចមេរោគអេដស៍ដែរ ការចម្លងជំងឺស្វាយនៅក្នុងប្រទេសកម្ពុជា គឺកើតឡើងជាចម្បងតាមរយៈអ្នករកស៊ីផ្លូវភេទចម្លងទៅអតិថិជនរបស់ពួកគេ ហើយជារឿយៗ អតិថិជនជាបុរសចម្លងបន្តទៅប្រពន្ធរបស់ពួកគេ ។ ការឆ្លងមេរោគស្វាយដោយផ្ទាល់និងជាបន្តដោយគ្មានការព្យាបាលក្នុងចំណោមស្ត្រីមានផ្ទៃពោះជារឿយៗ បណ្តាលឱ្យមានលទ្ធផលគភ៌អវិជ្ជមានធ្ងន់ធ្ងរ រួមទាំងការស្លាប់របស់ទារកនៅក្នុងករណីជាច្រើន ។ បន្ទុកនៃការមានជំងឺនិងការស្លាប់ដោយសារតែជំងឺស្វាយពីកំណើត គឺមានកម្រិតខ្ពស់ ។ មានហានិភ័យកាន់តែច្រើនផងដែរចំពោះការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ក្នុងចំណោមស្ត្រីមានផ្ទៃពោះដែលបានឆ្លងមេរោគស្វាយផងនិងមេរោគអេដស៍ផងក្នុងពេលតែមួយ ។

ជំងឺស្វាយពីកំណើតគឺអាចបង្ការបាន ប៉ុន្តែការលុបបំបាត់ការចម្លយពីម្តាយទៅកូន (eMTCT) នៃមេរោគស្វាយ អាចសម្រេចបានតាមរយៈការអនុវត្តយុទ្ធសាស្រ្តធ្វើតេស្តនិងព្យាបាលឱ្យបានទាន់ពេលវេលានិងប្រកបដោយប្រសិទ្ធភាព ចំពោះរោគស្វាយក្នុងស្ត្រីមានផ្ទៃពោះ ។ ទារកអាចត្រូវបានព្យាបាលឱ្យជាដាច់ដោយងាយស្រួល ហើយហានិភ័យនៃលទ្ធផលអវិជ្ជមានចំពោះទារក គឺមានតិចតួចបំផុត ប្រសិនបើម្តាយទទួលបានការព្យាបាលបានគ្រប់គ្រាន់អំឡុងពេលមានផ្ទៃពោះពីដំបូង - ជាពិសេស នៅមុនត្រីមាសទីពីរ ។

*1.2.3 ជំងឺរលាកថ្លើមប្រភេទបេ (HBV) នៅក្នុងប្រទេសកម្ពុជា*

4 Cambodia HIV Estimates 2020a

5 Spectrum Estimate, UNAIDs/Cambodia

6 Spectrum Estimate, UNAIDs/Cambodia

ហានិភ័យនៃការចម្លងជំងឺរលាកថ្លើមប្រភេទបេពីម្តាយទៅកូន គឺខ្ពស់ក្នុងចំណោមទារកដែលកើតពីស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគ HBV ដែលមានបន្ទុកមេរោគខ្ពស់ (≥200,000IU/mL); ក្នុងករណីខ្លះ ការចម្លងពីម្តាយទៅកូនគឺមានអត្រាដល់ទៅ ៩០% នៅពេលគ្មានអន្តរាគមន៍ ។ ការសិក្សាមួយចំនួនដែលឧបត្ថម្ភដោយអង្គការសុខភាពពិភពលោកក្នុងឆ្នាំ ២០១៧ បានរកឃើញថា សេរ៉ូប្រេវ៉ាឡង់ HBsAg គឺ ៤,៣៩% ក្នុងចំណោមម្តាយដែលមានកូនតូចនៅកម្ពុជា, ០.៥៦% ក្នុងចំណោមកុមារអាយុ ៥ ឆ្នាំ និង ១០% ក្នុងចំណោមកុមារកើតពីស្ត្រីដែលឆ្លងវីរុស HBV[7] ។

កម្ពុជាបានប្តេជ្ញាចិត្ត ចំពោះក្របខ័ណ្ឌថ្នាក់តំបន់នៃតំបន់ប៉ាស៊ីហ្វិកខាងលិចរបស់អង្គការសុខភាពពិភពលោក ដើម្បីលុបបំបាត់ការចម្លងពីម្តាយទៅកូននៃមេរោគអេដស៍, មេរោគរលាកថ្លើមប្រភេទបេ និងមេរោគស្វាយនៅក្នុងតំបន់អាស៊ីនិងប៉ាស៊ីហ្វិក ឆ្នាំ ២០១៨–២០៣០, ដែលអំពាវនាវឱ្យមានការលុបបំបាត់ការចម្លងពីម្តាយទៅកូននៃ HBV នៅឆ្នាំ ២០៣០ ដែលបានកំណត់ថា អត្រាប្រេវ៉ាឡង់ ≤0.1% នៃ hepatitis B surface antigen (HBsAg) ក្នុងចំណោមកុមារដែលមានអាយុក្រោម ៥ ឆ្នាំ ។ រហូតមកដល់ពេលនេះ អន្តរាគមន៍តែមួយគត់ដើម្បីកាត់បន្ថយការចម្លងពីម្តាយទៅកូននៃ HBV នៅក្នុងប្រទេសកម្ពុជា គឺការចាក់វ៉ាក់សាំងនៅពេលកើត បន្ទាប់មក ផ្តល់បីដូសបន្ថែម ដែលមានប្រសិទ្ធភាពតែមួយផ្នែកប៉ុណ្ណោះប្រសិនបើម្តាយមានបន្ទុកមេរោគខ្ពស់ ។ ការបន្ថែមការធ្វើតេស្តជាប្រចាំសម្រាប់ស្ត្រីមានផ្ទៃពោះ និងការព្យាបាលដោយឱសថប្រឆាំងវីរុសសម្រាប់ម្តាយដែលមានបន្ទុកមេរោគខ្ពស់ រួមជាមួយការខិតខំប្រឹកប្រែងជាបន្ត/កាន់តែហ្មត់ចត់ ដើម្បីធានាការផ្តល់ដូសវ៉ាក់សាំងពេលកើតឱ្យបានទាន់ពេលវេលា គឺជាការចាំបាច់ដើម្បីសម្រេចចំណុចដៅនៃការលុបបំបាត់ជំងឺរលាកថ្លើមប្រភេទបេ ត្រឹមឆ្នាំ ២០៣០ ។ ថ្មីៗនេះ អង្គការសុខភាពពិភពលោក បានផ្តល់អនុសាសន៍ថា ស្ត្រីមានផ្ទៃពោះដែលធ្វើតេស្តវិជ្ជមានចំពោះ HBV ដែលមាន HBV DNA ≥ 5.3 log10 IU/mL អាចទទួលការព្យាបាលបង្ការដោយឱសថ tenofovir ពីសប្តាហ៍ទី ២៨ នៃការមានគភ៌ រហូតដល់យ៉ាងហោចណាស់ពេលកើត ហើយ, ផ្អែកលើការស្រាវជ្រាវដែលបានធ្វើឡើងនៅក្នុងប្រទេសកម្ពុជា, បានគាំទ្រការប្រើ តេស្ត HB "envelope" antigen (HBeAg) ដើម្បីកំណត់ពីភាពសមស្របសម្រាប់ការព្យាបាលបង្ការដោយប្រើឱសថ tenofovir នៅទីកន្លែងណាដែលមិនមានការធ្វើតេស្ត HBV DNA ក្នុងពេលពិនិត្យផ្ទៃពោះ[8] ។

### *1.2.4 ការថែទាំសុខភាពមាតានៅក្នុងប្រទេសកម្ពុជា*

ការថែទាំមុនពេលសម្រាល (ANC), សេវាសម្រាលកូនដោយសុវត្ថិភាព និងការថែទាំក្រោយសម្រាល ត្រូវបានផ្តល់នៅក្នុងប្រព័ន្ធសុខភាពសាធារណៈតាមរយៈបណ្តាញមណ្ឌលសុខភាពនៅថ្នាក់សហគមន៍, ប៉ុស្តិ៍

[7] Ork V, Woodring J, ShafiqulHossain M, Wasley A, Nagashima S, Yamamoto C, et al. Hepatitis B surface antigen seroprevalence among pre- and post-vaccine cohorts in Cambodia, 2017. Vaccine. 2019 14;37(35):5059–66.
[8] Prevention of Mother-to-Child Transmission of Hepatitis B Virus:Guidelines on Antiviral Prophylaxis In Pregnancy. WHO 2020.

សុខភាព និងមន្ទីរពេទ្យ។ គោលការណ៍ណែនាំស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ បានដាក់ចេញនូវសេវានិងស្តង់ដារសម្រាប់ ANC, PNC និងការថែទាំពេលសម្រាល ។ ស្ត្រីមានផ្ទៃពោះទាំងអស់ ត្រូវបានណែនាំឱ្យទៅទទួលការថែទាំផ្ទៃពោះមុនពេលសម្រាលយ៉ាងហោចណាស់ ៤ ដង ដោយចាប់ផ្តើមពីត្រីមាសទី ១ នៃការមានគភ៌ ។ អត្រាគ្របដណ្តប់សម្រាប់ ANC គឺ ៩៥% ក្នុងឆ្នាំ ២០១៤ (ការអង្កេតប្រជាជន) និងត្រូវបានប៉ាន់ស្មានថាមាន ៩៨% ក្នុងឆ្នាំ ២០២០ ។ អត្រាគ្របដណ្តប់សម្រាប់ ANC ៤ ដងឡើងទៅ គឺ ៧៥,៦% ក្នុងឆ្នាំ ២០១៤ ដោយក្នុងនោះ ៧៩% នៃស្ត្រីទទួលបានសេវា ANC លើកដំបូងមុនរបស់ពួកគេមុនអាយុគភ៌ ៤ ខែ[9][10] ។

[9] ការអង្កេតប្រជសាស្ត្រនិងសុខភាពកម្ពុជា ឆ្នាំ ២០១៤ ។

[10] ប្រព័ន្ធព័ត៌មានសុខាភិបាលរបស់ក្រសួងសុខាភិបាល ២០២០, មូលដ្ឋានទិន្នន័យ NMCHC PMTCT ២០២០ និងការព្យាករប្រជាជនរបស់ក្រសួងផែនការ ឆ្នាំ ២០១៣ -២០២៣ ។ ភាគយក (ករណី ANC1 ដែលបានរាយការណ៍) ដែលបានកែតម្រូវសម្រាប់ករណីដែលអាចនឹងរាប់ស្ទួន ដោយសារតែស្ត្រីទៅរកសេវានៅមូលដ្ឋានសុខាភិបាលលើសពីមួយ ។ ភាគបែង (ចំនួនករណីសម្រាលប៉ាន់ស្មាន) ដែលបានកែតម្រូវសម្រាប់ករណីស្លាប់កើត/រំលូត (stillbirth/abortions) ។

## ជំពូកទី ២ ៖ ទិដ្ឋភាពរួមនៃកម្មវិធី PMTCT

សកម្មភាពបង្ការនិងថែទាំសម្រាប់ការបង្ការការចម្លងពីម្តាយទៅកូន ត្រូវបានដាក់បញ្ចូលទៅក្នុងសេវាសុខភាពដែលមានស្រាប់ដើម្បីជួយសម្រួលដល់ការទទួលបានសេវាសុខភាពសម្រាប់ស្ត្រី និងគ្រួសាររបស់ពួកគេ និងកាត់បន្ថយការមាក់ងាយនិងការរើសអើង ។ សំណុំសកម្មភាព PMTCT គឺផ្អែកលើសមាសភាគចំនួនបួន ដូចខាងក្រោម ៖

1. ការបង្ការបឋមនៃមេរោគអេដស៍ និងមេរោគស្វាយក្នុងចំណោមស្ត្រី និងដៃគូរបស់ពួកគេ
2. ការបង្ការការមានផ្ទៃពោះដោយអចេតនាក្នុងចំណោមស្ត្រីដែលឆ្លងមេរោគអេដស៍, មេរោគស្វាយ ឬ មេរោគរលាកថ្លើមប្រភេទបេ
3. *PMTCT* តាមរយៈកញ្ចប់សេវា ដែលរួមមានការផ្តល់ ៖

- ការធ្វើតេស្តមេរោគអេដស៍ ស្វាយ និង *HBV*
- ឱសថប្រឆាំងវីរុសសម្រាប់មេរោគអេដស៍ និង *HBV*
- ការព្យាបាលជំងឺស្វាយដោយប្រើថ្នាំអង់ទីប៊ីយ៉ូទិក
- ការអនុវត្តការសម្រាលប្រកបដោយសុវត្ថិភាព
- ការផ្តល់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេនៅពេលកើតឱ្យទាន់ពេលវេលា បន្ទាប់មក បន្ថែមបីដូសទៀត
- ការផ្តល់ប្រឹក្សានិងការគាំទ្រសម្រាប់ការចិញ្ចឹមទារកប្រកបដោយសុវត្ថិភាព
- ការធ្វើរោគវិនិច្ឆ័យឱ្យទាន់ពេលវេលានូវទារកដែលប្រឈមនឹងមេរោគអេដស៍

4. ការទទួលបានការថែទាំមេរោគអេដស៍/ជំងឺអេដស៍ និងការគាំទ្រសម្រាប់ស្ត្រីដែលឆ្លងមេរោគអេដស៍ ទារករបស់ពួកគេ និងគ្រួសារ ។

កញ្ចប់ពេញលេញនៃសកម្មភាព *PMTCT* រួមមាន ៖

សម្រាប់ស្ត្រីទាំងអស់ និងដៃគូរបស់ពួកគេ ៖

- ការអប់រំនិងព័ត៌មានអំពីការបង្ការបឋម ជាពិសេស សម្រាប់បុគ្គលដែលមានហានិភ័យខ្ពស់ ។
- ការទទួលបានសេវាពន្យារកំណើត ។

ស្ត្រីមានផ្ទៃពោះទាំងអស់ និងទារករបស់ពួកគេ ៖

- ការថែទាំមុនពេលសម្រាល ពេលសម្រាល និងក្រោយសម្រាលតាមធម្មតា យោងតាមពិធីសារមាតុភាពគ្មានគ្រោះថ្នាក់ ។

- ការផ្តល់ប្រឹក្សានិងការធ្វើតេស្តដោយស្ម័គ្រចិត្តនិងសម្ងាត់សម្រាប់មេរោគអេដស៍ មេរោគស្វាយ និងមេរោគរលាកថ្លើមប្រភេទបេ ។
- ការពិនិត្យរកភាពស្លេកស្លាំង ដោយធ្វើតេស្តអេម៉ូក្លូប៊ីន ។
- នៅក្នុងតំបន់ដែលមានរាតត្បាតជំងឺគ្រុនចាញ់, ការពិនិត្យរកជំងឺគ្រុនចាញ់, ការទទួលបានព័ត៌មានអំពីហានិភ័យនៃជំងឺគ្រុនចាញ់ក្នុងពេលមានផ្ទៃពោះ និងការប្រឹក្សាយោបល់អំពីការប្រើប្រាស់មុងជ្រលក់ថ្នាំ ។
- ការពិនិត្យរកជំងឺរបេងផ្អែកតាមរោគសញ្ញា ។
- ការពិនិត្យរកជាតិប្រៃក្នុងទឹកនោម ។
- ការសម្រាលកូននៅមូលដ្ឋានសុខាភិបាលដោយបុគ្គលិកជំនាញ ។
- ការផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភ និងការចិញ្ចឹមទារក។
- ការប្រឹក្សាពិគ្រោះអំពីការពន្យារកំណើតក្រោយពេលសម្រាល និងបញ្ជូនទៅសេវាពន្យារកំណើត ។
- ការផ្តល់ថ្នាំបង្ការតាមធម្មតាសម្រាប់ទារក រួមទាំងថ្នាំបង្ការ *HBV* ក្នុងអំឡុងពេល ២៤ ម៉ោងក្រោយពេលកើត ។

សម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ និងទារករបស់ពួកគេ ៖

- *ART (*ជម្រើស *B+)* សម្រាប់ស្ត្រីដែលឆ្លងមេរោគអេដស៍ទាំងអស់ ។
- ការសម្រាលនៅមន្ទីរពេទ្យដែលមានសេវា *ART* នៅក្នុងនោះ ។
- ការធ្វើតេស្តមេរោគអេដស៍ *HIV-DNA PCR* សម្រាប់ទារកនៅពេលកើត ។
- ការព្យាបាលបង្ការដោយប្រើ *ARV* ចំពោះទារកដែលប្រឈមមុខនឹងមេរោគអេដស៍ ។
- ការផ្តល់ថ្នាំបង្ការឱ្យទារកតាមធម្មតា រួមទាំងការផ្តល់ដូសថ្នាំបង្ការ *HBV* ពេលកើតឱ្យទាន់ពេលវេលា ។
- ការផ្តល់ប្រឹក្សានិងការគាំទ្រសម្រាប់ការអនុវត្តការចិញ្ចឹមទារកដោយសុវត្ថិភាព និងសុខភាពមាតា ។
- ការតាមដានទារកដែលប្រឈមនឹងមេរោគអេដស៍ ៖
    - ការព្យាបាលបង្ការដោយប្រើ *Cotrimoxazole (CPT)* សម្រាប់ទារកអាយុចាប់ពី ៦ ខែ ឡើងទៅ

- ការធ្វើរោគវិនិច្ឆ័យទារកភ្លាមៗក្រោយពេលកើតដោយតេស្ត *HIV-DNA PCR* និងនៅអាយុ ៦ សប្តាហ៍ ។ តេស្ត *PCR* បន្ថែម នៅ ៦ សប្តាហ៍ បន្ទាប់ពីឈប់បំបៅដោះកូន និងតេស្តអង្គទីគ័រមេរោគអេដស៍នៅអាយុ ១៨ ខែ ឡើងទៅ ។

- ផ្តល់ *ART* ភ្លាមៗសម្រាប់ការព្យាបាលពេញមួយជីវិត ដល់ទារកដែលឆ្លងមេរោគអេដស៍ទាំងអស់ ដោយមិនគិតពីចំនួន *CD4* ។
- ការបញ្ជូនទៅរកសេវាព្យាបាល ថែទាំ និងគាំទ្រ ។

សម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគស្វាយ ដៃគូ និងទារករបស់ពួកគេ ៖

- ការព្យាបាលសម្រាប់ម្តាយ ( និងទារក, ការព្យាបាលមាតាក៏នឹងព្យាបាលទារកដែលមិនទាន់កើតផងដែរ ) ដោយប្រើថ្នាំ *benzathine Penicillin* ដើម្បីលុបបំបាត់ការឆ្លងមេរោគនេះ ជាពិសេសមុនត្រីមាសទីពីរនៃការមានផ្ទៃពោះដើម្បីកាត់បន្ថយការបាត់បង់គភ៌ ។
- ការព្យាបាលពេលធ្វើតេស្តសម្រាប់ដៃគូរបស់ម្តាយ ដើម្បីចៀសវាងការឆ្លងឡើងវិញ។
- ការតាមដាន (តេស្ត *RPR titers)* ដើម្បីធានាថា ការព្យាបាលសម្រាប់ម្តាយ និងដៃគូរបស់នាងទទួលបានជោគជ័យ ។
- ការផ្តល់ប្រឹក្សាអំពីវិធានការបង្ការ ដើម្បីជៀសវាងការឆ្លងថ្មី រួមទាំងការប្រើប្រាស់ស្រោមអនាម័យ ។
- ការធ្វើតេស្តរកមេរោគអេដស៍ និង *HBV* ប្រសិនបើមិនទាន់បានធ្វើរួចហើយ ។
- ការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិកសម្រាប់ទារក ប្រសិនបើម្តាយមិនបានទទួលការព្យាបាលគ្រប់គ្រាន់ក្នុងអំឡុងពេលមានផ្ទៃពោះ ។
- ការផ្តល់ថ្នាំបង្ការឱ្យទារកតាមធម្មតា រួមទាំងការផ្តល់ដូសថ្នាំបង្ការ *HBV* ពេលកើតឱ្យទាន់ពេលវេលា ។
- ការផ្តល់ប្រឹក្សានិងការគាំទ្រសម្រាប់ការអនុវត្តការចិញ្ចឹមទារកដោយសុវត្ថិភាព និងសុខភាពមាតា ។

សម្រាប់ស្ត្រីមានផ្ទៃពោះដែលវិជ្ជមានសម្រាប់ *HBV surface antigen* និងទារករបស់ពួកគេ ៖

- ការធ្វើតេស្តបន្ថែមទៀតដើម្បីវាយតម្លៃហានិភ័យនៃការចម្លងជុំវិញកំណើត *(*បន្ទុកមេរោគ *HBV DNA* បើមាន, បើមិនដូច្នោះទេ ប្រើ *HBeAg* និង *ALT)* ។
- ប្រសិនបើ *HBV DNA > 5.3 Log* $_{10}$ *IU/mL* ឬ *(*បើគ្មាន *HBV DNA)* បើ *HBe Ag* វិជ្ជមាន ឬ *or* បើ *HBeAg* អវិជ្ជមាន ប៉ុន្តែកម្រិត *ALT* កើនឡើង *(> 40 U/L)*, ការព្យាបាលបង្ការដោយឱសថប្រឆាំងវីរុស *(Tenofovir 300* មក្រ/ថ្ងៃ *)* ចាប់ផ្តើមពីសប្តាហ៍ទី *24th-28th* នៃគភ៌[11]

[11] WHO ណែនាំឱ្យចាប់ផ្តើមនៅសប្តាហ៍ទី ២៨ ។ ប៉ុន្តែ ដោយសារការប៉ាន់ស្មានអាយុគភ៌អាចមិនត្រឹមត្រូវ ហើយអាចមានការពិបាកធានាការតាមដាននៅអាយុ ២៨ សប្តាហ៍, គេអាចចាប់ផ្តើមប្រើ ARV នៅពេលណាក៏បាន ចាប់ពីសប្តាហ៍ទី ២៤ ទៅ ។ គេ

និងបន្តរហូតដល់យ៉ាងតិច ៦ សប្តាហ៍ ក្រោយសម្រាល ។ *(ស្ត្រីដែលមានសញ្ញាខ្សោយមុខងារថ្លើម ត្រូវបន្តពេញមួយជីវិត ។)*

- ប្រសិនបើបន្ទុកមេរោគ *HBV <5.3 Log $_{10}$ IU/mL or (*ក្នុងករណីគ្មានតេស្ត *HBV DNA) HBe Ag* អវិជ្ជមាន ហើយ *ALT* ធម្មតា, បន្តតាមដានក្នុងអំឡុងពេលនិងក្រោយពេលមានផ្ទៃពោះ ។
- ការធ្វើតេស្ត *HBsAg* ទៅលើដៃគូ និងសមាជិកគ្រួសារ និងការផ្តល់ថ្នាំបង្ការ ប្រសិនបើអវិជ្ជមាន *HBsAg,* ប៉ុន្តែប្រសិនបើវិជ្ជមាន ត្រូវតាមដាន/ព្យាបាលដៃគូ/សមាជិកគ្រួសារ យោងតាមគោលការណ៍ណែនាំជាតិសម្រាប់ *HBV* ។
- ផ្តល់ប្រឹក្សាលើវិធានការនានាដើម្បីជៀសវាងការចម្លងទៅអ្នកដទៃ រួមទាំងការប្រើប្រាស់ស្រោមអនាម័យ, ការជៀសវាងប្រើរួមគ្នានូវឡាម ប្រាសដុសធ្មេញ ឬសម្ភារថែសម្រស់ផ្ទាល់ខ្លួនផ្សេងៗទៀត, ជៀសវាងការបរិច្ចាគឈាម និងអនុវត្តតាមការប្រុងប្រយ័ត្នជាសកលស្តង់ដារសម្រាប់របួសដាច់រលាត់ ឬហូរឈាម ។
- ការសម្រាលកូននៅសេវាសម្ភពនៃមន្ទីរពេទ្យបង្អែក ។
- ផ្តល់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេភ្លាមៗ ដល់ទារកក្រោយពេលសម្រាលរួច ជាពិសេស *ក្នុងអំឡុងពេល ២ ម៉ោងក្រោយពេលកើត* និង *យ៉ាងហោចណាស់ក្នុងរយៈពេល ២៤ ម៉ោង* បន្ទាប់មក ផ្តល់ដូសជំរុញនៅសប្តាហ៍ទី ៦, ទី ១០ និងទី ១៤ រួមជាមួយថ្នាំបង្ការទារកផ្សេងៗទៀតតាមធម្មតា ។
- ការប្រឹក្សានិងការគាំទ្រសម្រាប់ការអនុវត្តការបំបៅកូនដោយសុវត្ថិភាពនិងសុខភាពមាតា។
- ធ្វើការពិនិត្យតាមដានទៅលើម្តាយនៅ ៦ សប្តាហ៍ក្រោយពេលសម្រាល រួមទាំង *ALT* និងការគណនាពិន្ទុ *APRI,* បន្តផ្តល់ *ARV* ប្រសិនបើមានភស្តុតាងគ្លីនិកបង្ហាញពីជំងឺក្រិនថ្លើមដំណាក់កាលដំបូង ឬដំណាក់កាលធ្ងន់ធ្ងរ ឬពិន្ទុ *APRI* លើសពី ២ ឬមានកម្រិត *ALT* ខុសធម្មតាដដែលៗ ឬធ្លាប់មានប្រវត្តិគ្រួសារកើតជំងឺមហារីកថ្លើម, បើក្រៅពីនេះ គេអាចបញ្ឈប់ការប្រើ *ARV* ។
- ធ្វើការពិនិត្យតាមដានទៅលើទារកដែលប្រឈមនឹង *HBV* នៅអាយុ ៧-១២ ខែ[12] ដោយធ្វើតេស្ត *HBsAg* ។

---

គួរខិតខំចាប់ផ្តើមមិនឱ្យលើសពី ២៨ សប្តាហ៍ ឡើយ ប៉ុន្តែ បើគេមិនអាចធ្វើទៅបានដោយសារហេតុផលណាមួយ គេអាចចាប់ផ្តើមឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅក្រោយរយៈពេលនោះ ។

[12] គេត្រូវតាមដានទារកយ៉ាងហោចណាស់ ១ ខែ ក្រោយបញ្ចប់ថ្នាំបង្ការជំរុញ ៣ ដូសនៃ HBV ។

# ជំពូកទី ៣ ៖ ការផ្តល់ប្រឹក្សា ការធ្វើតេស្ត និងការអប់រំ

ស្ត្រីមានផ្ទៃពោះទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យមកទទួលការថែទាំផ្ទៃពោះ (ANC) យ៉ាងតិចចំនួន ៤ ដង ដោយចាប់ផ្តើមពីត្រីមាសទីមួយ និងទៅសម្រាលកូននៅមណ្ឌលសុខភាព ។ ផ្នែកនេះផ្តោតលើខ្លឹមសារដែលជាក់លាក់ទៅនឹង PMTCT ។ សូមមើលគោលការណ៍ណែនាំស្តីពីមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព និងមន្ទីរពេទ្យ សម្រាប់ការផ្តល់ប្រឹក្សាពេញលេញដែលត្រូវផ្តល់ដល់ស្ត្រីមានផ្ទៃពោះ និងស្ត្រីក្រោយពេលសម្រាលកូន ។

## 3.1 ការផ្តល់ប្រឹក្សាអំពីការធ្វើតេស្តមេរោគអេដស៍ មេរោគស្វាយ និង HBV សម្រាប់ស្ត្រីមានផ្ទៃពោះ

ស្ត្រីមានផ្ទៃពោះទាំងអស់មានសិទ្ធិដឹងអំពីស្ថានភាពមេរោគអេដស៍, HBV និងស្វាយ របស់ខ្លួន ដើម្បីអាចទទួលបានសេវា PMTCT ទាន់ពេលវេលា ប្រសិនបើពួកគេឆ្លងមេរោគទាំងនេះ ។ **ការផ្តល់ប្រឹក្សានិងការធ្វើតេស្តគួរតែមាននៅគ្រប់ទីកន្លែង** រួមទាំងមណ្ឌលសុខភាព, ប៉ុស្តិ៍សុខភាព, អគាររោគស្ត្រី, អគារសម្ភព, អគារជំងឺទូទៅ និងអគារវះកាត់នៃមន្ទីរពេទ្យ, សេវាជំងឺរបេង, គ្លីនិកសុខភាពគ្រួសារ (FHC), សហគមន៍ និងទីតាំងធ្វើតេស្តចល័ត ។

- **ស្ត្រីទាំងអស់ដែលទទួលបានការថែទាំមុនពេលសម្រាលកូន (ANC) គួរតែត្រូវបានផ្តល់ជូននូវការប្រឹក្សានិងការធ្វើតេស្តដោយសម្ងាត់និងស្ម័គ្រចិត្តសម្រាប់មេរោគអេដស៍, មេរោគស្វាយ និង HBV** ជាផ្នែកមួយនៃកញ្ចប់ថែទាំមុនពេលសម្រាលស្តង់ដារដែលផ្តួចផ្តើមឡើងដោយអ្នកផ្តល់សេវា ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេអាចបដិសេធការធ្វើតេស្តទាំងនេះ ប្រសិនបើពួកគេមិនយល់ព្រម ។
- **ការធ្វើតេស្តមេរោគអេដស៍, HBV, មេរោគស្វាយ និង និងការផ្តល់ប្រឹក្សាសម្រាប់ស្ត្រីមានផ្ទៃពោះគួរតែធ្វើឡើងដោយស្ម័គ្រចិត្ត** និងប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ 5 C's របស់អង្គការសុខភាពពិភពលោក ៖ consent, confidentiality, counselling, correct test results and connections to care, treatment and prevention services (ការយល់ព្រម, ការសម្ងាត់, ការប្រឹក្សា, លទ្ធផលតេស្តត្រឹមត្រូវ, និងការតភ្ជាប់ទៅនឹងសេវាថែទាំ, ព្យាបាល និងបង្ការ) ។ ការធានាគុណភាព ទាំងការធ្វើតេស្តនិងការប្រឹក្សា មានសារៈសំខាន់ជាសារវន្តនៅក្នុងគ្រប់វិធីសាស្ត្រទាំងអស់ចំពោះការធ្វើតេស្តនិងការប្រឹក្សាអំពីមេរោគអេដស៍, មេរោគស្វាយ និង HBV ក៏ដូចជាការយកចិត្តទុកដាក់ដល់អតិថិជនទាំងអស់ ដោយការគោរព និងក្តីមេត្តា ។
- **អ្នកផ្តល់ប្រឹក្សាគួរលើកទឹកចិត្តដល់ដៃគូរបស់ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍/មេរោគស្វាយ និងស្ត្រីមានផ្ទៃពោះដែលត្រូវបានរកឃើញថាមានជំងឺកាមរោគផ្សេងទៀត ឬធ្លាប់មានប្រវត្តិការប្រព្រឹត្តិប្រកបដោយការប្រឈមមុខខ្ពស់** ឱ្យចូលរួមក្នុងការប្រឹក្សាដោយស្ម័គ្រចិត្ត និងទទួលការធ្វើតេស្តជាសម្ងាត់ ។

ដើម្បីធានាការកំណត់អត្តសញ្ញាណស្ត្រីដែលមិនដឹងពីស្ថានភាពរបស់ពួកគេ គេគួរដាក់បញ្ចូលព័ត៌មានអំពីការធ្វើតេស្តមេរោគអេដស៍, HBV មេរោគស្វាយ ទៅក្នុងសៀវភៅកំណត់ត្រាសុខភាពមាតា ។

**តើត្រូវធ្វើតេស្តនៅពេលណា ៖**

- ស្ត្រីមានផ្ទៃពោះទាំងអស់គួរតែត្រូវបានធ្វើតេស្តរកមេរោគអេដស៍, HBV និងមេរោគស្វាយ នៅពេលមកទទួលការថែទាំមុនពេលសម្រាលលើកទីមួយ (ANC1) ពោលគឺ ក្នុងអំឡុងត្រីមាសទីមួយនៃគភ៌ ។ ប្រសិនបើដោយសារហេតុផលណាមួយ ការធ្វើតេស្តនេះមិនត្រូវបានធ្វើនៅពេលមកទទួល ANC លើកដំបូងទេ គេគួរធ្វើតេស្តនៅពេលក្រោយមានឱកាសបន្ទាប់ទៀត ។

- ស្ត្រីមានផ្ទៃពោះទាំងអស់ ដែលមិនដឹងពីស្ថានភាពមេរោគអេដស៍និងមេរោគស្វាយនៅពេលសម្រាល គួរតែត្រូវបានផ្តល់ជូននូវការប្រឹក្សានិងការធ្វើតេស្តដោយស្ម័គ្រចិត្តជាលក្ខណៈប្រព័ន្ធក្នុងអំឡុងពេលឬក្រោយពេលឈឺពោះសម្រាល ។

- ការធ្វើតេស្តឡើងវិញសម្រាប់មេរោគអេដស៍និងស្វាយ
  - ស្ត្រីមានផ្ទៃពោះត្រូវបានណែនាំឱ្យធ្វើតេស្តម្តងទៀតនៅត្រីមាសទី ៣ សម្រាប់មេរោគអេដស៍/ស្វាយ ប្រសិនបើពួកគេត្រូវបានវាយតម្លៃថា មានហានិភ័យខ្ពស់ចំពោះការឆ្លងមេរោគអេដស៍/ស្វាយ (ពីក្រុមប្រជាជនគន្លឹះ, មានដៃគូផ្ទុកមេរោគអេដស៍, ឬដៃគូដែលត្រូវបានគេដឹងថាមានឥរិយាបថប្រកបដោយការប្រឈមខ្ពស់)
  - ការធ្វើតេស្តឡើងវិញក្នុងអំឡុងពេលមានផ្ទៃពោះ មិនត្រូវបានណែនាំផ្សេងពីនេះទេ ។

- ស្ថានភាពមេរោគស្វាយរបស់ស្ត្រីគ្រប់រូបដែលមានការរលូតកូនដោយឯកឯង ដែលកើតឡើងនៅសប្តាហ៍ទី ២០ ឡើងទៅ ឬការកើតស្លាប់ គួរតែត្រូវបានពិនិត្យ ហើយប្រសិនបើស្ត្រីនោះមិនបានធ្វើតេស្តរកមេរោគស្វាយក្នុងអំឡុងពេលមានផ្ទៃពោះដដែលនោះ គេគួរតែធ្វើតេស្ត ។ ការរលូតកូននៅត្រីមាសពីរ និងការកើតស្លាប់ គឺជាផលវិបាកញឹកញាប់នៃមេរោគស្វាយក្នុងពេលមានផ្ទៃពោះ ។

**ស្ត្រីដែលបានដឹងថា ពួកគេមានវិជ្ជមានមេរោគអេដស៍** និងមកគ្លីនិក ART គួរទទួល ៖

- យ៉ាងហោចណាស់ តេស្តរាប់បន្ទុកមេរោគ (VL) មួយដងក្នុងអំឡុងពេលមានផ្ទៃពោះ ។ ប្រសិនបើស្ត្រីទើបតែចាប់ផ្តើម ART សូមពិនិត្យបន្ទុកមេរោគ នៅបីខែបន្ទាប់ ។ ប្រសិនបើនាងកំពុងប្រើ ART រួចទៅហើយ សូមពិនិត្យធ្វើតេស្ត VL នៅដំណាក់កាលដំបូងនៃការមានផ្ទៃពោះ បន្ទាប់មក អនុវត្តតាមពិធីសារតេស្ត VL តាមធម្មតា ដូចដែលពិពណ៌នានៅក្នុងគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមេរោគអេដស៍របស់ NCHADs ។

- ការផ្តល់ប្រឹក្សាអំពីសារៈសំខាន់នៃ *ANC* និងការបញ្ជូនទៅសេវា *ANC* ដើម្បីទទួលបានការថែទាំមុនពេលសម្រាលជាបន្តក្នុងអំឡុងពេលមានផ្ទៃពោះ ជាពិសេស នៅមន្ទីរពេទ្យបង្អែក រួមជាមួយទីតាំង *ART* ឬមណ្ឌលសុខភាពស្ថិតនៅក្បែរមន្ទីរពេទ្យនោះ ។ ស្ត្រីទាំងនេះគួរតែត្រូវបានលើកទឹកចិត្តឱ្យមកសម្រាលកូននៅអគារសម្ភពនៃមន្ទីរពេទ្យបង្អែក និងទទួលការព្យាបាលបង្ការដោយប្រើថ្នាំ *ARV* ដោយត្រឹមត្រូវសម្រាប់ទារករបស់ពួកគេ ដើម្បីបង្ការការចម្លងពីម្តាយទៅកូន ដោយមានការចុះឈ្មោះជាមុននៅអគារសម្ភពនៃមន្ទីរពេទ្យបង្អែក ដើម្បីតាមដានរវាង *ANC* និងការសម្រាល ។
- ការធ្វើតេស្តមេរោគស្វាយនិង *HBV* ក្នុងកំឡុងពេល *ANC* ក៏ដូចជា សេវា *ANC* ជាមូលដ្ឋានផ្សេងទៀតដូចដែលមានលម្អិតនៅក្នុងគោលការណ៍ណែនាំស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ ។
- ការផ្តល់ប្រឹក្សាអំពីការប្រកាន់ខ្ជាប់តាមការព្យាបាលដោយ *ART* គួរត្រូវបានពង្រឹងបន្ថែមជាប្រចាំក្នុងអំឡុងពេលមានផ្ទៃពោះដើម្បីរក្សាបន្ទុកមេរោគទាបដែលមិនអាចរកឃើញ យ៉ាងហោចណាស់បួនសប្តាហ៍មុនពេលសម្រាល ។

**ស្ត្រីដែលអវិជ្ជមានមេរោគអេដស៍ ប៉ុន្តែមានដៃគូដែលផ្ទុកមេរោគអេដស៍ (ប្តីប្រពន្ធដែលមានលទ្ធផលតេស្តផ្ទុយគ្នា)** ហើយមកតាមដាននៅគ្លីនិក ART ដើម្បីទទួលការព្យាបាលបង្ការមុនពេលប្រឈម (PrEP) គួរត្រូវបានបញ្ជូនទៅកាន់ទីតាំង ANC ។ ពួកគេគួរតែត្រូវធ្វើតេស្តរកមេរោគអេដស៍, មេរោគស្វាយ និង HBV និងទទួលសេវា ANC ជាមូលដ្ឋានទាំងអស់ ។ គេគួរបញ្ជាក់ប្រាប់ដល់ស្ត្រីអំពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់តាមការព្យាបាលបង្ការ PrEP និងធានាដល់ស្ត្រីថា ថ្នាំទាំងនេះមានសុវត្ថិភាពក្នុងពេលមានផ្ទៃពោះ ។

**ស្ត្រីដែលត្រូវបានគេដឹងថាមានជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ** (CHB) ដែលមានផ្ទៃពោះ គួរតែត្រូវបានពន្យល់ប្រាប់អំពីហានិភ័យនៃការចម្លងទៅទារក និងសារៈសំខាន់នៃការផ្តល់វ៉ាក់សាំងដល់ទារកភ្លាមៗនៅពេលកើតដើម្បីកាត់បន្ថយការចម្លងនេះ ។

- ស្ត្រីដែលមានជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ ដែលបានទទួលការព្យាបាលដោយឱសថប្រឆាំងវីរុសរួចហើយ គួរត្រូវបានផ្តល់ប្រឹក្សាអំពីសារៈសំខាន់នៃការប្រកាន់ខ្ជាប់តាមការព្យាបាល ។
- ស្ត្រីដែលមានជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ ដែលមិនមានទទួលឱសថប្រឆាំងនឹងវីរុស គួរត្រូវបានតាមដានយ៉ាងជិតដល់ក្នុងអំឡុងពេលមានផ្ទៃពោះ ហើយចាប់ផ្តើមប្រើថ្នាំនេះនៅសប្តាហ៍ទី ២៨ នៃគភ៌ ប្រសិនបើ HBV DNA is > 5.3 Log 10 IU/mL ឬ បើគ្មាន HBV DNA, ប្រសិនបើ HBe Agis វិជ្ជមាន ឬប្រសិនបើ HBe Ag អវិជ្ជមាន ប៉ុន្តែ ALT > 40 U/L ។
- ស្ត្រីគ្រប់ទាំងអស់គួរត្រូវបានបញ្ជូនទៅទទួលសេវា ANC ដើម្បីទទួលបានការថែទាំមុនពេលសម្រាលក្នុងអំឡុងពេលមានផ្ទៃពោះទាំងមូល ជាពិសេសនៅឯមន្ទីរពេទ្យបង្អែកដដែល ដែលពួកគេទទួលសេវា HBV ឬនៅមណ្ឌលសុខភាពនៅក្បែរមន្ទីរពេទ្យនោះ ។ ពួកគេគួរត្រូវបានលើកទឹកចិត្តឱ្យមកអគារសម្ភព

នៃមន្ទីរពេទ្យបង្អែកនោះដើម្បីសម្រាលកូនដោយសុវត្ថិភាព និងដើម្បីធានាថា ទារកទទួលបានវ៉ាក់សាំង HBV ភ្លាមៗក្រោយពេលកើត ។

- ស្ត្រីទាំងអស់គួរតែត្រូវបានផ្តល់ជូននូវការធ្វើតេស្តរកមេរោគអេដស៍ និងមេរោគស្វាយក្នុងអំឡុងពេល ANC ក៏ដូចជាសេវា ANC ជាមូលដ្ឋានផ្សេងទៀតទាំងអស់ ដូចដែលបានបញ្ជាក់លម្អិតនៅក្នុងសេចក្តីណែនាំស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ ។

*3.1.1 ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត*

- ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត គួរត្រូវបានដាក់បញ្ចូលក្នុងកិច្ចពិភាក្សាអំពីព័ត៌មានសុខភាពនិងការអប់រំតាមធម្មតា ដែលផ្តល់ដល់ស្ត្រីនិងដៃគូរបស់ពួកគេក្នុងអំឡុង**ថ្នាក់អប់រំម្តាយ**នៅពេលមកទទួលសេវា ANC ។
- ប្រសិនបើមិនមានស្ត្រីមានផ្ទៃពោះគ្រប់គ្រាន់ដើម្បីបើកថ្នាក់អប់រំម្តាយទេ គេគួរធ្វើ**ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តសម្រាប់បុគ្គលឬប្តីប្រពន្ធ** ។
- ព័ត៌មានអំពីការបង្ការការចម្លងពីម្តាយទៅកូននៃមេរោគអេដស៍, HBV, និងមេរោគស្វាយ គួរតែត្រូវបានផ្តល់ ហើយការធ្វើតេស្តមេរោគអេដស៍, HBV និងមេរោគស្វាយ គួរត្រូវបានផ្តល់ជូនជាប្រចាំនៅឯសេវា ANC ។
- ស្ត្រីអាចបដិសេធការធ្វើតេស្តប្រសិនបើពួកគេមិនចង់ធ្វើ ។ ទោះបីជាយ៉ាងណាក៏ដោយ គេគួរធ្វើការពិនិត្យឥរិយាបថប្រកបដោយការប្រឈមរបស់នាងឬដៃគូរបស់នាង ប្រសិនបើពួកគេយល់ព្រម ។
- ប្រសិនបើស្ត្រីមានផ្ទៃពោះឬដៃគូរបស់នាង ស្នើសុំឱ្យការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្តជាលក្ខណៈបុគ្គល គេគួរតែធ្វើការផ្តល់ជូនពួកគេ ។

ការផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត ផ្តល់ដល់ស្ត្រីនិងដៃគូរបស់ពួកគេ នូវព័ត៌មានជាមូលដ្ឋានអំពីមេរោគអេដស៍/ជំងឺអេដស៍, HBV និងមេរោគស្វាយ, ផ្តល់ព័ត៌មានដល់ពួកគេអំពីដំណើរការធ្វើតេស្ត, ជួយពួកគេឱ្យយល់ពីឥរិយាបថប្រកបដោយការប្រឈមផ្ទាល់ខ្លួន និងផ្តល់សារគន្លឹះអំពីវិធីរក្សាភាពអវិជ្ជមាន (មិនឱ្យឆ្លង) ។

## ប្រធានបទទាំងឡាយខាងក្រោមនេះ គួរត្រូវបានយកមកពិភាក្សាក្នុងអំឡុងពេលផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត ៖

- ព័ត៌មានជាមូលដ្ឋានអំពីមេរោគអេដស៍, HBV និងស្វាយ ទាំងការចម្លង និងការបង្ការ ។
- គុណប្រយោជន៍នៃការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ និងអត្ថប្រយោជន៍នៃការដឹងពីស្ថានភាពមេរោគអេដស៍, HBV និងស្វាយក្នុងពេលមានផ្ទៃពោះ ។
- ហានិភ័យនៃការឆ្លងមេរោគអេដស៍, HBV និងមេរោគស្វាយ និងជម្រើសនានាដើម្បីកាត់បន្ថយហានិភ័យ រួមទាំងការប្រើប្រាស់ស្រោមអនាម័យ និងការចៀសវាងការប្រើគ្រឿងញៀនដោយចាក់តាមសរសៃ (IDU) ។

- ភាពសម្ងាត់នៃការធ្វើតេស្តរកមេរោគអេដស៍, HBVនិងមេរោគស្វាយ ។
- ភាពពាក់ព័ន្ធនៃលទ្ធផលតេស្តមេរោគអេដស៍ រួមទាំងដំណើរការធ្វើតេស្តបញ្ជាក់ និង "រយៈពេលចំហ" ប្រសិនបើការធ្វើតេស្តត្រូវបានរកឃើញថា អវិជ្ជមាន ។
- ភាពពាក់ព័ន្ធនៃតេស្ត HBsAg រួមទាំងតម្រូវការដែលត្រូវធ្វើតេស្តបន្ថែម ប្រសិនបើលទ្ធផលតេស្តវិជ្ជមាន ដើម្បីកំណត់ថា តើមានហានិភ័យខ្ពស់ចំពោះការឆ្លងជុំវិញការសម្រាល ។
- ហានិភ័យនៃការចម្លងពីម្តាយទៅកូន និងជម្រើសសម្រាប់ការបង្ការ រួមទាំង ការព្យាបាលដោយប្រើឱសថប្រឆាំងនឹងវីរុស (HIV/HBV) និងការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក (សម្រាប់ជំងឺស្វាយ) និងការផ្តល់វ៉ាក់សាំង HBV ភ្លាមៗនៅពេលកើត ។
- ការផ្តល់ការព្យាបាលសម្រាប់ស្ត្រីខ្លួនឯង ៖ ART រយៈពេលមួយជីវិតសម្រាប់មេរោគអេដស៍, ថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីព្យាបាលរោគស្វាយ, ការតាមដាន និងបើចាំបាច់ ឱសថប្រឆាំងនឹងវីរុសសម្រាប់ HBV ។
- ការវាយតម្លៃហានិភ័យ ៖ ការវាយតម្លៃហានិភ័យសម្រាប់បុគ្គលម្នាក់ៗគឺមានសារៈសំខាន់ខ្លាំងណាស់នៅក្នុងរីករាលដាលមេរោគអេដស៍ដែលមានការប្រមូលផ្តុំ ។ ខាងក្រោមនេះ គឺជាតវិយាបថប្រកបដោយហានិភ័យចម្បងដែលត្រូវវាយតម្លៃ ៖

### តារាងទី ១ ៖ ការវាយតម្លៃហានិភ័យ

| ស្ត្រីមានផ្ទៃពោះ | ដៃគូ |
|---|---|
| មានដៃគូរួមភេទច្រើន | មានដៃគូរួមភេទច្រើន |
| ស្ថិតក្នុងក្រុមប្រជាជនគន្លឹះ៖ EW, PWID, PWUD | ស្ថិតក្នុងក្រុម ឬមានដៃគូជា ក្រុមប្រជាជនគន្លឹះណាមួយ៖ MSM, TG, EW, PWID, PWUD |
| ធ្លាប់មានប្រវត្តិមានជំងឺកាមរោគ ឬរលាកថ្លើម ពីមុនឬពេលបច្ចុប្បន្ន | ធ្លាប់មានប្រវត្តិមានជំងឺកាមរោគ ឬឆ្លងមេរោគអេដស៍ ឬរលាកថ្លើម ពីមុនឬពេលបច្ចុប្បន្ន |
| ស្ថិតក្នុងក្រុមប្រជាជនចំណាកស្រុក | ស្ថិតក្នុងក្រុមប្រជាជនចំណាកស្រុក |

- ប្រភព៖ កម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាល *HTC* ឆ្នាំ ២០១៤
-
-

**ប្រអប់ទី ១៖ ចំណុចពិចារណាពិសេសក្នុងការគ្រប់គ្រងស្ត្រីវ័យជំទង់ដែលមានផ្ទៃពោះ (រួមទាំងស្ត្រីវ័យជំទង់ដែលឆ្លងមេរោគអេដស៍ផងដែរ)**

នៅពេលធ្វើការជាមួយក្មេងជំទង់ មិនថាតែរៀបការរួច ឬមិនទាន់រៀបការឡើយ ជាការសំខាន់ណាស់ដែលត្រូវចងចាំចំណុចទាំងឡាយដូចខាងក្រោម ៖

- បង្កើតការប្រាស្រ័យទាក់ទងល្អជាមួយស្ត្រីនោះ និងដៃគូរបស់នាង ដោយពន្យល់ដល់នាងអំពីជម្រើសនានា និងធ្វើការសម្រេចចិត្តដែលសមស្របបំផុតទៅនឹងតម្រូវការរបស់នាង ។
- នៅរាល់ពេលពិនិត្យ ឬមុនពេលទម្រង់ការណាមួយ ត្រូវស្នើសុំការអនុញ្ញាត និងជម្រាបប្រាប់អំពីអ្វីដែលអ្នកកំពុងធ្វើ ។
- កុំបុរេវិនិច្ឆ័យ តែត្រូវដឹង និងគ្រប់គ្រងអារម្មណ៍មិនស្រួលរបស់អ្នក ជាមួយបញ្ហាផ្លូវភេទរបស់មនុស្សវ័យជំទង់ ។
- លើកទឹកចិត្តក្មេងស្រីឱ្យសួរសំណួរ ហើយប្រាប់នាងថា នាងអាចពិភាក្សាអំពីរាល់បញ្ហាទាំងអស់ដែលនាងមាន ។
- ប្រាប់ឡើងវិញ និងធានាភាពសម្ងាត់ ។
- ស្វែងយល់ពីការលំបាករបស់ក្មេងជំទង់ក្នុងការប្រាស្រ័យទាក់ទង អំពីប្រធានបទនានាដែលទាក់ទងនឹងបញ្ហាផ្លូវភេទ (ការខ្លាចឪពុកម្តាយដឹង, ការជំទាស់របស់មនុស្សពេញវ័យ, ការមាក់ងាយពីសង្គម ជាដើម) ។

### *3.1.2 ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត*

ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត គួរត្រូវបានផ្តល់ជូនអតិថិជនទាំងអស់ជាលក្ខណៈបុគ្គល ឬជាប្តីប្រពន្ធប្រសិនបើមានការស្នើសុំ, ទោះជាលទ្ធផលមេរោគអេដស៍, HBV និងស្វាយយ៉ាងណាក៏ដោយ ។ ការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្ត គួរតែត្រូវបានផ្តល់ជូននៅក្នុងបន្ទប់មួយ ដែលជានាភាពសម្ងាត់ និងភាពឯកជន ។ លទ្ធផលតេស្តគួរត្រូវបានផ្តល់ជូនដោយអ្នកផ្តល់សេវាដែលបានទទួលការបណ្តុះបណ្តាល ប្រកបដោយការគោរពនិងការយល់ចិត្ត ។

**ប្រអប់ទី ២ ៖ គោលដៅនៃការផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តគឺដើម្បី ៖**

- ផ្តល់ដល់អតិថិជននូវលទ្ធផលតេស្តមេរោគអេដស៍, *HBV,* និងស្វាយ ។
- ធានាថា អតិថិជនយល់ពីអត្ថន័យនៃលទ្ធផល ។
- ធានាថា អតិថិជនយល់ពីដំណើរការនៃការធ្វើតេស្តបញ្ជាក់ ប្រសិនបើតេស្តមេរោគអេដស៍តាមរយៈម្រាមដៃមានប្រតិកម្ម ។
- ធានាថា អតិថិជនយល់ពីតម្រូវការដែលត្រូវធ្វើតេស្តបន្ថែម និងទទួលការព្យាបាល ប្រសិនបើតេស្ត *HBsAg* វិជ្ជមាន។
- ធានាថា អតិថិជនយល់ពីតម្រូវការដែលត្រូវទទួលការព្យាបាលភ្លាមៗប្រសិនបើតេស្តមេរោគស្វាយមានប្រតិកម្ម ។
- ធានាថា អតិថិជនយល់ពីសារៈសំខាន់នៃការបន្តការថែទាំផ្ទៃពោះរហូតដល់គ្រប់ខែ ។
- លើកទឹកចិត្តដល់ការកាត់បន្ថយឥរិយាបថប្រកបដោយការប្រឈម - និងការធ្វើតេស្តដៃគូ ។
- ផ្តល់ព័ត៌មានពាក់ព័ន្ធអំពីការចម្លងពីម្តាយទៅកូន ។
- ផ្តល់ការគាំទ្រ, ព័ត៌មាន និងការបញ្ជូនទៅសេវាផ្សេងទៀត រួមទាំងសេវាសម្ភព, *ART,* គ្លីនិកសុខភាពគ្រួសារ, មន្ទីរពេទ្យបង្អែក ឬមន្ទីរពេទ្យជាតិសម្រាប់ការថែទាំ *HBV,* *PAC,* និងសេវាជំងឺកាមរោគ តាមដែលសមស្រប ។
- 

*<u>ដកស្រង់ចេញពី ៖</u> កញ្ចប់បណ្តុះបណ្តាលទូទៅស្តីពីការបង្ការការចម្លងពីម្តាយទៅកូន របស់WHO/CDC. ឆ្នាំ ២០០៨ ។*

## លទ្ធផលតេស្តអវិជ្ជមានសម្រាប់មេរោគអេដស៍, ស្វាយ និង HBV ៖

ក្នុងអំឡុងពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តដល់ស្ត្រី ដែលតេស្តមិនមានប្រតិកម្មចំពោះតេស្តទាំងបី អ្នកផ្តល់ប្រឹក្សាគួរ ៖

- ជានាថាអតិថិជនយល់ពី "រយៈពេលចំហ" សម្រាប់ការធ្វើតេស្តរកមេរោគអេដស៍ និងណែនាំឱ្យធ្វើតេស្តឡើងវិញនៅ ៤ ខែបន្ទាប់ ប្រសិនបើមានការប្រឈមមុខខ្ពស់នាពេលថ្មីៗ ឬហានិភ័យកំពុងបន្តក្នុងពេលបច្ចុប្បន្ន ។
- ពិនិត្យឡើងវិញលើផែនការរបស់អតិថិជន ដើម្បីកាត់បន្ថយការប្រឈម រួមទាំងវិធីបង្ការការឆ្លងមេរោគអេដស៍ *HBV* និងស្វាយ ដែលអាចកើតមាននាពេលអនាគត ។
- ស្វែងយល់ទស្សនៈយល់ឃើញរបស់ស្ត្រី ចំពោះឥរិយាបថរបស់ប្តីឬដៃគូ និងស្ថានភាពមេរោគអេដស៍, *HBV* និងកាមរោគរបស់គាត់ ។ ប្រសិនបើស្ត្រីនោះគិតថាប្តី ឬដៃគូរបស់គាត់ អាចមានផ្ទុកមេរោគអេដស៍, *HBV* ឬកាមរោគ ឬមានឥរិយាបថប្រឈមមុខខ្ពស់, ការធ្វើតេស្តប្តីឬដៃគូ គួរតែត្រូវបានណែនាំឱ្យពន្យល់អំពីអត្ថប្រយោជន៍ដែលពួកគេនឹងទទួលបានពីសេវានេះ ។
- ប្រសិនបើស្ត្រីមានដៃគូដែលត្រូវបានគេដឹងថា ផ្ទុកមេរោគអេដស៍ (ប្តីប្រពន្ធដែលមានលទ្ធផលតេស្តផ្ទុយគ្នា) នាងគួរតែត្រូវបានបញ្ជូនទៅទីតាំង *ART* ដើម្បីទទួលការប្រឹក្សា និងការព្យាបាលបង្ការ (*PrEP*) តាមដែលសមស្រប ។
- ពន្យល់ពីគុណប្រយោជន៍ពីរមុខនៃការប្រើប្រាស់ស្រោមអនាម័យ ជាពិសេស សម្រាប់ស្ត្រីដែលគិតថា ប្តី ឬដៃគូរបស់ពួកគេអាចមានឥរិយាបថប្រកបដោយការប្រឈមមុខខ្ពស់ ។
- ពន្យល់ពីសារៈសំខាន់នៃការផ្តល់ថ្នាំបង្ការ *HBV* ភ្លាមៗដល់ទារកទាំងអស់ក្នុងអំឡុងពេល ២៤ ម៉ោងនៃកំណើត ។
- ជម្រាប់ដល់អតិថិជនថា ពួកគេអាចទទួលការប្រឹក្សាបន្ថែមទៀត ប្រសិនបើពួកគេត្រូវការ ។

## លទ្ធផលតេស្តមេរោគអេដស៍មានប្រតិកម្ម បន្ទាប់ពីការធ្វើតេស្តតាមម្រាមដៃ ៖

ក្នុងអំឡុងពេលផ្តល់ប្រឹក្សាក្រោយពេលធ្វើតេស្តដល់ស្ត្រីដែលតេស្តមេរោគអេដស៍មានប្រតិកម្ម អ្នកផ្តល់ប្រឹក្សាគួរ ៖

- ពិភាក្សាអត្ថន័យនៃលទ្ធផលតេស្ត និងយល់ពីអារម្មណ៍ដំបូងរបស់ពួកគេក្រោយពេលដឹងលទ្ធផល ។
- សង្កត់ធ្ងន់លើតម្រូវការដែលត្រូវធ្វើតេស្តបញ្ជាក់ក្នុងថ្ងៃតែមួយនៅទីតាំង *VCCT* ដែលស្ថិតនៅជាមួយគ្លីនិក *ART* និងអត្ថប្រយោជន៍នៃការចុះឈ្មោះទទួលការព្យាបាល *ART* ភ្លាមៗ ប្រសិនបើការធ្វើតេស្តបញ្ជាក់ឃើញវិជ្ជមាន ។

- បញ្ជាក់ពីដំណើរការបញ្ជូន (រួមទាំងការដឹកជញ្ជូន) និងបុគ្គលទំនាក់ទំនងនៅទីតាំងសេវាពាក់ព័ន្ធ ដោយសម្របសម្រួលជាមួយជំនួយការគ្រប់គ្រងករណីសកម្ម / អ្នកសម្របសម្រួលការគ្រប់គ្រងករណី/អ្នកគាំទ្រការគ្រប់គ្រងករណី ។
- បញ្ជូនអតិថិជនរួមជាមួយប័ណ្ណបញ្ជូន រួមទាំងលេខកូដ *PMTCT* និងបញ្ជាក់កាលបរិច្ឆេទនៃការសម្រាលដែលរំពឹងទុក។
- ពិភាក្សាពីតម្រូវការសម្រាប់បន្តការថែទាំផ្ទៃពោះមុនពេលសម្រាលជាប្រចាំ, តេស្តផ្សេងៗទៀត និងវិធានការបង្ការ ។
- ការផ្តល់ប្រឹក្សាយោបល់បន្ថែម អាចត្រូវបានផ្តល់ជូន និងកំណត់ពេលតាមកាលវិភាគ ប្រសិនបើចាំបាច់ ។
- អ្នកផ្តល់សេវា *ANC* គួរតែតាមដានបន្ត និងធានាថា ស្ត្រីនោះបានទទួលការធ្វើតេស្តបញ្ជាក់ និងកត់ត្រាលទ្ធផលនៅក្នុងសៀវភៅកំណត់ត្រា *ANC* ។ អ្នកផ្តល់សេវាគួរជម្រាបភ្លាមៗដល់ជំនួយការគ្រប់គ្រងករណីសកម្ម (*CMA*)/អ្នកសម្របសម្រួលការគ្រប់គ្រងករណី (*CMC*) ឬអ្នកសម្របសម្រួល *OD/PHD PMTCT* ប្រសិនបើមានករណីណាមួយដែលបាត់ខ្លួនមិនបានមកតាមដានបន្តពោលគឺ មិនបានទទួលការធ្វើតេស្តបញ្ជាក់ ។
- 

## លទ្ធផលតេស្តមេរោគអេដស៍បញ្ជាក់វិជ្ជមាននៅ VCCT:

អ្នកផ្តល់ប្រឹក្សានៅ VCCT ដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជូន និងចុះឈ្មោះស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍នៅគ្លីនិក ART ។ អ្នកផ្តល់ប្រឹក្សានៅ VCCT ដែលបានទទួលការបណ្តុះបណ្តាលអំពីការផ្តល់ប្រឹក្សាជាក់លាក់អំពី PMTCT គួរតែ ៖

- ពន្យល់ពីលទ្ធផលនៃការធ្វើតេស្តបញ្ជាក់ និងផ្តល់ការគាំទ្រផ្នែកផ្លូវអារម្មណ៍ដល់ស្ត្រី ។
- ឆ្លើយសំណួរឬក្តីកង្វល់នានាដែលអតិថិជនអាចមាន ទាក់ទងនឹងលទ្ធផលតេស្ត ។
- ផ្តល់ប្រឹក្សាដល់អតិថិជនអំពីវិធីនានាដើម្បីដោះស្រាយបញ្ហាបន្ទាន់ និង/ឬក្តីកង្វល់នានា ។
- សុំការយល់ព្រមពីនាងដើម្បីធ្វើតេស្តរហ័សរកមើលការឆ្លងក្នុងពេលថ្មីៗ (*RTRI*) ជាមួយឈាមដែលនៅសល់ដើម្បីវាស់មើលតើនាងបានឆ្លងមេរោគនេះក្នុងរយៈពេល ១២ ខែចុងក្រោយ ឬ យូរជាងនេះ ។ ព័ត៌មាននេះអាចជួយស្វែងរកដៃគូផ្លូវភេទនិងកូនបង្កើតរបស់នាង ដើម្បីធ្វើតេស្ត (ការឆ្លងក្នុងពេលថ្មីៗ អាចមានលទ្ធភាពចម្លងខ្ពស់[13])
- ពិនិត្យឡើងវិញលើអន្តរាគមន៍ *PMTCT* និងផ្តល់ព័ត៌មានអំពីសេវា *ART* និង *PMTCT*។
- ពន្យល់ពីសារៈសំខាន់នៃការសម្រាលកូនប្រកបដោយសុវត្ថិភាព និងជួយអតិថិជនកំណត់ពីសេវាសម្ភពនៅមន្ទីរពេទ្យបង្អែកដើម្បីសម្រាលកូនដោយសុវត្ថិភាព ។

[13] Tracking with Recency Assay to Control the HIV Epidemic (TRACE) Training Curriculum, 2019

- ផ្តល់ព័ត៌មានអំពីសេវារំលូតកូនដោយសុវត្ថិភាព និងជួយសម្រួលការបញ្ជូន បើចាំបាច់ ។
- ពិភាក្សាអំពីអត្ថប្រយោជន៍និងហានិភ័យនៃការបង្ហាញព័ត៌មាន និងលើកទឹកចិត្តឱ្យដៃគូ និងកុមារទាំងអស់ទទួលការធ្វើតេស្ត និងការប្រឹក្សា ។ ការធ្វើតេស្តមេរោគអេដស៍ដោយខ្លួនឯង អាចត្រូវបានផ្តល់ជូន ប្រសិនបើដៃគូមិនអាចឬមិនមានឆន្ទៈមកមូលដ្ឋានសុខាភិបាល ។
- ផ្តល់ការប្រឹក្សាស្តីពីការរស់នៅជាមួយមេរោគអេដស៍ និងការគ្រប់គ្រងមេរោគនេះ (ការគាំទ្រផ្នែកចិត្តសង្គម) ។
- ផ្តល់ព័ត៌មានអំពីវិធីបង្ការការចម្លងមេរោគអេដស៍ទៅដៃគូ តាមរយៈការផ្តល់ស្រោមអនាម័យ និងការណែនាំអំពីរបៀបប្រើស្រោមអនាម័យ (ដើម្បីបង្ការការចម្លងមេរោគអេដស៍ និងការបង្ការការឆ្លងជាថ្មី) ។
- ពន្យល់យ៉ាងច្បាស់អំពីជម្រើសនៃការចិញ្ចឹមទារក និងសង្កត់ធ្ងន់លើសេវាដែលត្រូវការសម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍ ដូចជាការព្យាបាលបង្ការដោយប្រើថ្នាំ *ARV*, ការធ្វើរោគវិនិច្ឆ័យទារកភ្លាមៗក្រោយពេលកើត (ការធ្វើតេស្ត *PCR* នៅពេលកើត, ៦ ខែបន្ទាប់ពីបញ្ឈប់ការបំបៅទឹកដោះម្តាយ និងតេស្តរោគវិនិច្ឆ័យចុងក្រោយ), ការព្យាបាលបង្ការដោយប្រើថ្នាំ *Cotrimoxazole* និងការព្យាបាលដោយប្រើថ្នាំ *ARV* ភ្លាមៗ ប្រសិនបើទារកដែលប្រឈមមុខនឹងមេរោគអេដស៍ ត្រូវបានរកឃើញបានឆ្លងមេរោគនេះ ។
- អមដំណើរស្ត្រីទៅចុះឈ្មោះនៅគ្លីនិក *ART* និងចាប់ផ្តើម *ART* ភ្លាមៗ (នៅក្នុងថ្ងៃតែមួយ *ART)* ។
- ចុះឈ្មោះស្ត្រីជាមុននៅអគារសម្ភព ដែលមានថ្ងៃខែឆ្នាំសម្រាលកូនរំពឹងទុក សម្រាប់ការសម្រាលកូនដោយសុវត្ថិភាព និងតាមដានបន្តទៀត ។
- ជូនដំណឹងដល់ *CMC/CMA/*ក្រុមសកម្មភាពសហគមន៍ *(ACC)* សម្រាប់ធ្វើការតាមដានបន្តទៀតតាមរយៈល្បាក់ *B-IACM* ។

រាល់ឯកសារអ្នកជំងឺទាំងអស់ រួមទាំងលទ្ធផលតេស្តមេរោគអេដស៍ផងដែរ ត្រូវតែរក្សាទុកនៅកន្លែងសម្ងាត់ និងមានសុវត្ថិភាពគ្រប់ពេល ហើយគួរត្រូវបានប្រើប្រាស់ដោយបុគ្គលិកថែទាំសុខភាពដែលពាក់ព័ន្ធដោយផ្ទាល់ក្នុងការផ្តល់ការថែទាំដល់អ្នកជំងឺ ។ មិនត្រូវដាក់ស្លាកសម្គាល់ឯកសារទាំងនេះថា ឆ្លងមេរោគអេដស៍ទេ ។ ត្រូវយកចិត្តទុកដាក់លើស្ត្រីដោយការគោរព និងការយល់ចិត្តគ្រប់ពេល និងផ្តល់ភាពជាឯកជនពេញលេញក្នុងអំឡុងពេលពិភាក្សា ។

- អ្នកផ្តល់សេវា *ANC* គួរធ្វើការតាមដានបន្តផងដែរដើម្បីឱ្យប្រាកដថា ស្ត្រីដែលមានតេស្តប្រតិកម្មនៅឯកន្លែងទទួលសេវា *ANC* ទទួលបានការធ្វើតេស្តបញ្ជាក់ ហើយប្រសិនបើវិជ្ជមាន ចុះឈ្មោះទទួលការព្យាបាល *ART*, និងចុះឈ្មោះជាមុននៅឯអគារសម្ភពក្នុងមន្ទីរពេទ្យតែមួយ ។ នៅពេលស្ត្រីមករកសេវា *ANC* ជាបន្តបន្ទាប់ អ្នកផ្តល់សេវា *ANC* គួរតែសង្កត់ធ្ងន់ទៅលើការប្រកាន់ខ្ជាប់តាមការព្យាបាល *ART*

និងណែនាំស្ត្រីឱ្យសម្រាលកូននៅអគារសម្ភពនៃមន្ទីរពេទ្យបង្អែក ដែលមានទីតាំងនៅជាមួយសេវា *ART* របស់ពួកគេ ដើម្បីទទួលបានការថែទាំត្រឹមត្រូវសម្រាប់ទារក (*ARV*, តេស្ត *DNA PCR* ពេលកើត) ។

## លទ្ធផលតេស្តស្វាយវិជ្ជមានដោយប្រើតេស្តម្រាមដៃ ៖

- ពន្យល់ថា ជំងឺស្វាយដែលមិនបានព្យាបាលគឺមានគ្រោះថ្នាក់ខ្លាំងណាស់ចំពោះស្ត្រីនិងទារករបស់គាត់ ប៉ុន្តែជំងឺនេះអាចព្យាបាលឱ្យជាដាច់យ៉ាងងាយ ។ ផ្តល់ការគាំទ្រផ្នែកអារម្មណ៍ ។
- បញ្ជាក់ពីតម្រូវការសម្រាប់ការព្យាបាលជាបន្ទាន់ ដើម្បីការពារទារក ។
- ពន្យល់ពីតម្រូវការសម្រាប់ប្តី/ដៃគូរបស់នាង ដែលត្រូវទទួលការព្យាបាល ក៏ដូចជា ចៀសវាងការឆ្លងឡើងវិញចំពោះខ្លួនឯងនិងទារក ។ ផ្តល់ឱកាសឱ្យស្ត្រីពិភាក្សាពីការព្រួយបារម្ភនានាទាក់ទងនឹងការផ្តល់ព័ត៌មានដល់របស់ដៃគូរបស់គាត់ ។
- បញ្ជូនស្ត្រីនិងដៃគូរបស់នាងទៅកាន់ទីកន្លែងដែលជិតនៅបំផុតដើម្បីទទួលការព្យាបាល, អាចជាអគារសម្ភពក្នុងមន្ទីរពេទ្យបង្អែក ឬគ្លីនិកសុខភាពគ្រួសារ (*FHC*) ។ ការព្យាបាលអាចត្រូវបានផ្តល់ជូនភ្លាមៗនៅមន្ទីរពេទ្យបង្អែក ដោយមិនចាំបាច់ធ្វើតេស្ត *RPR* ។
- បន្ទាប់ពីទទួលបានការព្យាបាល ស្ត្រីនិងដៃគូរបស់នាងគួរតែត្រូវបានបញ្ជូនទៅកាន់គ្លីនិកសុខភាពគ្រួសារដើម្បីធ្វើតេស្ត *RPR* និងវាយតម្លៃប្រសិទ្ធភាពនៃការព្យាបាល ព្រមទាំងផ្តល់ការព្យាបាលបន្ថែមទៀត ប្រសិនបើមានការណែនាំបែបនេះ ។ ក្នុងករណីខ្លះ គ្លីនិកសុខភាពគ្រួសារមានទីតាំងស្ថិតនៅក្នុងបរិវេណទីតាំង *VCCT* ។
- ឆ្នបនៅសេវា *ANC* និងសេវាដទៃទៀត គួរផ្តល់ព័ត៌មានដល់អ្នកសម្របសម្រួលមេរោគអេដស៍និងផ្នែកសុខភាពមាតានិងទារកថ្នាក់ស្រុក ឬ *CMA* អំពីករណីតេស្តប្រតិកម្មមេរោគស្វាយ ដើម្បីធានាថាពួកគេទទួលបានការព្យាបាលពេញលេញ និងការតាមដានបន្ត ។
- អ្នកផ្តល់សេវាគួរកត់ត្រាក្នុងសៀវភៅកំណត់ត្រាសុខភាពម្តាយ នូវលទ្ធផលតេស្តមេរោគស្វាយ និងការព្យាបាលដែលផ្តល់ដល់ម្តាយ ដៃគូ និងទារក ។ ការតាមដានគឺជាការចាំបាច់ដើម្បីធានាថា អ្នកជំងឺពិតជាទទួលបានការព្យាបាលត្រឹមត្រូវ ។
- ជំនួយការគ្រប់គ្រងករណីសកម្ម/អ្នកសម្របសម្រួលការគ្រប់គ្រងករណី ឬអ្នកសម្របសម្រួល *PMTCT* នៅថ្នាក់ស្រុកប្រតិបត្តិ/*PHD* គួរតែត្រូវបានជូនដំណឹងភ្លាមៗអំពីករណីណាដែលបាត់ខ្លួនមិនបានមកតាមដាន ពោលគឺ មិនបានទទួលការព្យាបាលពេញលេញ ។
- ចុះឈ្មោះជាមុនសម្រាប់ការសម្រាលកូននៅអគារសម្ភពក្នុងមន្ទីរពេទ្យបង្អែក ជាពិសេសមន្ទីរពេទ្យដែលមានទីតាំងនៅរួមគ្នាជាមួយសេវា *ART* ។

## លទ្ធផលតេស្ត HBsAg វិជ្ជមាន ៖

- ពន្យល់ពីប្រវត្តិតាមធម្មជាតិនៃការឆ្លងមេរោគរលាកថ្លើមប្រភេទបេ និងការធ្វើតេស្តបន្ថែមដែលចាំបាច់ដើម្បីកំណត់ថា តើនាងត្រូវការការព្យាបាលសម្រាប់ខ្លួននាង និង/ឬដើម្បីការពារទារក ។ ផ្តល់ការគាំទ្រផ្នែកអារម្មណ៍ ។
- ពន្យល់ដល់នាងថា ប្រសិនបើនាងប្រឈមមុខខ្ពស់នឹងការចម្លងមេរោគទៅទារករបស់នាង នាងអាចប្រើថ្នាំដើម្បីកាត់បន្ថយហានិភ័យនេះ ។ ពន្យល់ដល់នាងទៀតថា វាជាការសំខាន់ណាស់ដែលត្រូវប្រើថ្នាំឱ្យបានទៀងទាត់តាមវេជ្ជបញ្ជា ។ ធានាដល់នាងថា ថ្នាំនេះមានសុវត្ថិភាពក្នុងពេលមានផ្ទៃពោះ ។ ត្រូវធ្វើការវាយតម្លៃក្រោយពេលសម្រាលកូន ដើម្បីសម្រេចថា តើនាងត្រូវបន្តប្រើថ្នាំ ឬត្រូវឈប់ ។
- ពន្យល់ថា ដោយមិនគិតថានាងត្រូវការថ្នាំនពេលនេះនោះឡើយ នាងនឹងត្រូវការតាមដានសុខភាពរបស់នាងជាទៀងទាត់ សូម្បីតែក្រោយពេលសម្រាលកូនក៏ដោយ។
- ពន្យល់ថា នាងត្រូវប្រុងប្រយ័ត្នចំពោះការពុលថ្លើមដែលអាចកើតឡើង ដោយសារថ្នាំមួយចំនួន (ឧទា. ប៉ារ៉ាសេតាម៉ុល) និងជៀសវាងការប្រើប្រាស់ឱសថបុរាណ និងការសេពគ្រឿងស្រវឹង ។
- សង្កត់ធ្ងន់លើសារៈសំខាន់នៃការផ្តល់វ៉ាក់សាំង HBV ភ្លាមៗក្រោយពេលកើតសម្រាប់ទារក បន្ទាប់មក ផ្តល់ជូនដូសជំរុញបន្ថែមបីដូសទៀត ។ បញ្ជាក់ថា ដូសពេលកើតចាំបាច់ត្រូវផ្តល់ជូនក្នុងរយៈពេល ២ ម៉ោង និងយ៉ាងហោចណាស់ ២៤ ម៉ោងក្រោយពេលកើត ហើយណែនាំឱ្យសម្រាលកូននៅមន្ទីរពេទ្យបង្អែក ។
- បញ្ជូនទៅកាន់មន្ទីរពេទ្យដែលនៅជិតបំផុត ដើម្បីធ្វើតេស្តបន្តទៀត និងផ្តល់ ARV ប្រសិនបើមានការណែនាំត្រូវប្រើ ។
- ណែនាំឱ្យដៃគូនិងសមាជិកគ្រួសារ អមដំណើរស្ត្រីទៅកាន់មន្ទីរពេទ្យ និងធ្វើតេស្តរក HBsAg ។
- ផ្តល់ប្រឹក្សាអំពីវិធានការនានាដើម្បីជៀសវាងការចម្លងដល់អ្នកដទៃ រួមទាំងការប្រើប្រាស់ស្រោមអនាម័យ, ការជៀសវាងប្រើរួមគ្នានូវឡាមកោរពុកមាត់, ច្រាសដុសធ្មេញ ឬរបស់របរថែរក្សាខ្លួនផ្សេងទៀត, ជៀសវាងការបរិច្ចាគឈាម ហើយអនុវត្តតាមការប្រុងប្រយ័ត្នជាសកលស្តង់ដារ សម្រាប់របួសដាច់រលាត់ ឬហូរឈាម ។

- អ្នកផ្តល់សេវាគួរកត់ត្រាក្នុងសៀវភៅសុខភាពម្តាយ នូវលទ្ធផលតេស្ត *HBV* និងការព្យាបាលដែលបានម្តាយ ដៃគូ និងទារកបានទទួល ។ ធ្វើការតាមដានបន្តតាមការចាំបាច់ ដើម្បីធានាថា ស្ត្រីមកមន្ទីរពេទ្យ និងបានទទួលការធ្វើតេស្តបន្ថែម (*HBeAg* និង *ALT)* ។ ជំនួយការគ្រប់គ្រងករណីសកម្ម/អ្នកសម្របសម្រួលការគ្រប់គ្រងករណី ឬអ្នកសម្របសម្រួល *OD/PHD PMTCT* គួរតែត្រូវបានជូនដំណឹងភ្លាមៗអំពីករណីណាដែលបាត់ខ្លួនមិនបានមកតាមដាន ពោលគឺមិនបានទៅមន្ទីរពេទ្យដើម្បីធ្វើតេស្តបន្ថែម ។

## 3.2 ទម្រង់ការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ

### *3.2.1 ការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ ក្នុងពេលមានផ្ទៃពោះ*

ការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ មានផ្តល់ជូននៅតាមទីកន្លែងផ្តល់សេវា ANC ទាំងអស់ តាមរយៈការធ្វើតេស្តម្រាមដៃរហ័សពីរមុខ គឺ ៖ តេស្តមេរោគអេដស៍/មេរោគស្វាយរួមគ្នា និងតេស្ត HBsAg ដាច់ដោយឡែក ។ ការធ្វើតេស្តមេរោគអេដស៍, HBV និងមេរោគស្វាយ គួរត្រូវបានធ្វើឡើងដោយអ្នកផ្តល់សេវាដែលបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវតែប៉ុណ្ណោះ ។ បុគ្គលិកទាំងអស់ដែលទទួលខុសត្រូវក្នុងការធ្វើតេស្តមេរោគអេដស៍និងមេរោគស្វាយ ត្រូវតែបានបញ្ចប់វគ្គបណ្តុះបណ្តាលអំពីការធ្វើតេស្តមេរោគអេដស៍និងស្វាយ និងអនុវត្តតាមគោលនយោបាយ, យុទ្ធសាស្ត្រ និងគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលសម្រាប់ការធ្វើតេស្តមេរោគអេដស៍/ស្វាយ និងការផ្តល់ប្រឹក្សា ដោយប្រើឃីតតេស្តនិងពិធីសារដែលអនុម័តដោយក្រសួងសុខាភិបាល ។

ខាងក្រោមនេះគឺជាអនុសាសន៍សម្រាប់ការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ ចំពោះស្ត្រីមានផ្ទៃពោះដោយបុគ្គលិកផ្តល់សេវា ANC ដែលគួរត្រូវបានអនុវត្តតាម ៖

1. ស្ត្រីមានផ្ទៃពោះទាំងអស់ដែលមកទទួលសេវា ANC នៅឯមូលដ្ឋានសុខាភិបាល គួរតែផ្តល់ការប្រឹក្សានិងធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ នៅពេលមកទទួល ANC លើកដំបូង ។ ប្រសិនបើដោយហេតុផលណាមួយដែលមិនបានធ្វើតេស្តនៅពេលមកទទួល ANC ដំបូង គេគួរធ្វើតេស្តនេះឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ។
2. ក្នុងករណីស្ត្រីដែលគេដឹងថាមានផ្ទុកមេរោគអេដស៍មុនពេលទទួល ANC នាងគួរតែទទួលការប្រឹក្សានិងធ្វើតេស្តរោគអេដស៍, HBV និងស្វាយ ។ តេស្តមេរោគអេដស៍/ស្វាយពីរមុខ នឹងត្រូវធ្វើឡើង ប៉ុន្តែមានតែលទ្ធផលតេស្តមេរោគស្វាយប៉ុណ្ណោះត្រូវបានរាយការណ៍ ប្រសិនបើគេបានដឹងរួចទៅហើយថាស្ត្រីមានផ្ទុកមេរោគអេដស៍ ។
3. ស្ត្រីដែលធ្វើតេស្តមានប្រតិកម្មចំពោះមេរោគអេដស៍, ស្វាយ ឬ HBV គួរត្រូវបានផ្តល់ប្រឹក្សានិងបញ្ជូនភ្លាមៗទៅទទួលការធ្វើតេស្ត/ព្យាបាលបន្ថែម ដូចដែលបានពិពណ៌នានៅក្នុងផ្នែក ៣.១.២ ខាងលើ ។

បន្ថែមពីលើការធ្វើតេស្តមេរោគអេដស៍, HBV និងស្វាយ គេគួរធ្វើការវាស់វែងអេម៉ូក្លូប៊ីននិងការធ្វើតេស្តប្រូតេអ៊ីនក្នុងទឹកនោម នៅឯសេវា ANC និងផ្តល់ការព្យាបាល យោងតាមពិធីសារស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ ប្រសិនបើរកឃើញថាមានភាពស្លេកស្លាំង ឬប្រូតេអ៊ីនក្នុងទឹកនោម ។

ប្រអប់ទី ៣ ៖ ទម្រង់ការធ្វើតេស្តពីរមុខដោយជួសម្រាមដៃសម្រាប់មេរោគអេដស៍/ស្វាយ

ទទួលការយល់ព្រមដោយផ្ទាល់មាត់ពីស្ត្រីមានផ្ទៃពោះ ក្រោយពេលផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត ។

1. រៀបចំប្រតិករនិងសម្ភារធ្វើតេស្ត, យកតេស្តមួយចេញពីឃីតតេស្ត ។ យកចេញពីផ្នែកខាងឆ្វេង ។ ត្រូវដាក់ក្នុងសីតុណ្ហភាពបន្ទប់ធម្មតា ។
2. ពិនិត្យកាលបរិច្ឆេទផុតកំណត់ប្រើ ដើម្បីប្រាកដថា វានៅតែមានសុពលភាព ។
3. ពិនិត្យមើលសារជាតុស្រូបសំណើម ។ ប្រសិនបើវាឡើងពណ៌បៃតង សូមប្រើឃីតតេស្តផ្សេងមួយទៀត ។
4. សរសេរលេខកូដតេស្តនៅលើបន្ទះតេស្ត ហើយយកស្រទាប់គ្របតេស្តចេញ ។
5. ជ្រើសរើសយកម្រាមដៃ និងម៉ាស្សាបាតដៃដើម្បីឱ្យឈាមហូរស្រួល, សម្អាតកន្លែងដែលត្រូវចាក់ដោយប្រើអាល់កុល ។ ទុកឱ្យស្ងួតដោយពេញលេញ ។ តេស្តនេះអាចនឹងមិនមានប្រសិទ្ធភាព ប្រសិនបើអាល់កុលមិនស្ងួតល្អ ។
6. ចាក់ម្រាមដៃដោយប្រើម្ជុលស្តេរីល ហើយប្រើបំពង់ពីប៉េតកាប់ពីលែដើម្បីប្រមូលឈាម ។
7. បន្ថែមសូលុយស្យុង ៣ តំណក់ ចូលក្នុងរន្ធសំណាកដែលមានរាងមូល ។
8. រង់ចាំរយៈពេល ១៥ នាទី (មិនលើសពី ២០ នាទី) ដើម្បីអានលទ្ធផល ។
9. បន្ទាត់ត្រួតពិនិត្យ (control line) គួរតែលេចចេញឡើងសម្រាប់គ្រប់លទ្ធផលទាំងអស់ ។ ប្រសិនបើវាមិនលេចចេញឡើងទេ លទ្ធផលគឺមិនយកជាបានការ ហើយគួរតែធ្វើម្តងទៀត ។
10. ប្រសិនបើមើលឃើញតែបន្ទាត់ត្រួតពិនិត្យ ហើយមិនមានបន្ទាត់ដែលគូសសម្គាល់ "Syp" និង "HIV", លទ្ធផលគឺអវិជ្ជមានទាំងសម្រាប់មេរោគអេដស៍និងមេរោគស្វាយ ។ ប្រសិនបើមានបន្ទាត់ដែលវាបង្ហាញថា "Syp" នោះ មានន័យថា វិជ្ជមានចំពោះមេរោគស្វាយ ។ ប្រសិនបើមានបន្ទាត់មួយដែលបង្ហាញថា HIV មានន័យថា តេស្តនេះមានប្រតិកម្មចំពោះមេរោគអេដស៍ ។
11. កត់ត្រាលទ្ធផលនៅលើប័ណ្ណលទ្ធផលមន្ទីរពិសោធន៍, សៀវភៅកំណត់ត្រាថៃទាំផ្ទៃពោះមុនពេលសម្រាលឬសម្ភព និងប័ណ្ណសុខភាពម្តាយ ។
12. ផ្តល់ការប្រឹក្សាក្រោយពេលធ្វើតេស្ត ដូចមានរៀបរាប់ក្នុងផ្នែក ២.១.២ ។

## ប្រអប់ទី ៤ ៖ ទម្រង់ធ្វើតេស្តម្រាមដៃសម្រាប់ HBsAg

ទទួលការយល់ព្រមដោយផ្ទាល់មាត់ពីស្ត្រីមានផ្ទៃពោះ ក្រោយពេលផ្តល់ប្រឹក្សាមុនពេលធ្វើតេស្ត ។

1. រៀបចំប្រតិករនិងសម្ភារធ្វើតេស្ត, យកតេស្តមួយចេញពីឃីតតេស្ត ។ យកចេញពីផ្នែកខាងស្តាំ ។
2. ត្រូវដាក់តេស្តក្នុងសីតុណ្ហភាពបន្ទប់ធម្មតា ។
3. ពិនិត្យកាលបរិច្ឆេទផុតកំណត់ប្រើ ដើម្បីប្រាកដថា វានៅតែមានសុពលភាព ។
4. ពិនិត្យមើលសារធាតុស្រូបសំណើម ។ ប្រសិនបើវាឡើងពណ៌បៃតង សូមប្រើឃីតតេស្តផ្សេងមួយទៀត ។
5. សរសេរលេខកូដតេស្តនៅលើបន្ទះតេស្ត ហើយយកស្រទាប់គ្របតេស្តចេញ, ដាក់បន្ទះតេស្តនៅលើផ្ទៃរាបស្មើ ។
6. ជ្រើសរើសយកម្រាមដៃ និងម៉ាស្សាបាតដៃដើម្បីឱ្យឈាមហូរស្រួល, សម្អាតកន្លែងដែលត្រូវចាក់ដោយប្រើអាល់កុល ។ ទុកឱ្យស្ងួតដោយពេញលេញ ។
7. ចាក់ម្រាមដៃដោយប្រើម្ជុលស្ទេរីល ឬម្ជុលលេខតូច ។
8. ប្រមូលឈាមដក់ក្នុងបំពង់ពីប៉ែតកាប់ពីលែ ហើយប្រើបំពង់ដើម្បីផ្ទេរឈាមដាក់ត្រង់ចំណុចកណ្តាលនៃបន្ទះទ្រសំណាក ។ ប្រើឈាមទាំងអស់ក្នុងបំពង់កាពីលែ ។
9. ភ្លាមៗ បន្ទាប់ពីផ្ទេរឈាមអស់រួចហើយ ត្រូវដាក់សូលុយស្យុងមួយតំណក់នៅលើបន្ទះទ្រសំណាក ។
10. រង់ចាំរយៈពេល ១៥ នាទី (មិនលើសពី ៣០ នាទី) ដើម្បីអានលទ្ធផល ។
11. បន្ទាត់ត្រួតពិនិត្យ (control line) គួរតែលេចចេញឡើងសម្រាប់គ្រប់លទ្ធផលទាំងអស់ ។ ប្រសិនបើវាមិនលេចចេញឡើងទេ លទ្ធផលគឺមិនយកជាបានការ ហើយគួរតែធ្វើម្តងទៀត ។
12. លទ្ធផលវិជ្ជមានបង្ហាញបន្ទាត់ពីរ, បន្ទាត់មួយគឺជាបន្ទាត់ត្រួតពិនិត្យ និងបន្ទាត់មួយទៀតគឺសម្រាប់អ្នកជំងឺ ។ បកស្រាយបន្ទាត់ដែលមើលឃើញ (សូម្បីតែព្រាលៗក្តី) នៅលើបន្ទះតេស្ត ជាលទ្ធផលវិជ្ជមានយកជាបានការ ។ ប្រសិនបើមើលឃើញតែបន្ទាត់ត្រួតពិនិត្យ មានន័យថា លទ្ធផលគឺអវិជ្ជមាន ។
13. កត់ត្រាលទ្ធផលនៅលើប័ណ្ណលទ្ធផលមន្ទីរពិសោធន៍, សៀវភៅកំណត់ត្រាថៃទាំផ្ទៃពោះមុនពេលសម្រាល ឬសម្ភព និងប័ណ្ណសុខភាពម្តាយ ។
14. ផ្តល់ការប្រឹក្សាក្រោយពេលធ្វើតេស្ត ដូចមានរៀបរាប់ក្នុងផ្នែក ២.១.២ ។

នីតិវិធីត្រួតពិនិត្យគុណភាពដែលបានបង្កើតឡើងដោយ NCHADS សម្រាប់ការធ្វើតេស្តមេរោគអេដស៍និងមេរោគស្វាយ គួរតែត្រូវបានអនុវត្តតាមគ្រប់ពេលវេលា ។ នីតិវិធីទាំងនេះរួមមានការត្រួតពិនិត្យគុណភាពសម្រាប់ការប្រមូលសំណាក, ការរក្សាទុក និងការធ្វើតេស្ត ។ អ្នកអភិបាលនៅមន្ទីរពិសោធន៍ថ្នាក់ខេត្ត ឬមន្ទីរពិសោធន៍ថ្នាក់ជាតិ ទទួលខុសត្រូវក្នុងការត្រួតពិនិត្យតាមដានគុណភាពនៃការធ្វើតេស្ត និងលទ្ធផលរៀងរាល់ត្រីមាស[14] ។

**ប្រអប់ទី ៥ ៖ ការផ្គត់ផ្គង់និងការរក្សាទុកប្រតិករនិងសម្ភារ**

1. សម្ភារដើម្បីគាំទ្រតេស្ត គួរតែមានគ្រប់គ្រាន់នៅនឹងទីតាំងផ្ទាល់ និងរក្សាទុកឱ្យបានល្អ ។
2. ប្រតិករគួររក្សាទុកក្នុងសីតុណ្ហភាពពី ២ ទៅ ៣០ អង្សារសេ ។ សម្ភារតេស្តមិនគួរដាក់ក្នុងកន្លែងសើម ឬដាក់ឱ្យត្រូវពន្លឺថ្ងៃឡើយ ។
3. កុំប្រើតេស្តភ្លាមៗក្រោយពេលយកចេញពីទូទឹកកក ពីព្រោះតេស្តគួរត្រូវរក្សាទុកក្នុងសីតុណ្ហភាពបន្ទប់ (២០ នាទី ) មុនពេលប្រើ ។
4. ពិនិត្យកាលបរិច្ឆេទផុតកំណត់ប្រើរៀងរាល់ពេល មុនពេលធ្វើតេស្ត និងមិនត្រូវប្រើតេស្តដែលផុតកំណត់ប្រើឡើយ ។
5. ពិនិត្យមើលសីតុណ្ហភាពជាប្រចាំក្នុងទូទឹកកក ប្រអប់ត្រជាក់ និងក្នុងបន្ទប់ ។
6. គួរអនុវត្ត IQC សម្រាប់ឃីតតេស្តដែលបើកថ្មីនីមួយៗ មុននឹងធ្វើតេស្តអ្នកជំងឺទីមួយ ។

តេស្តមេរោគអេដស៍/មេរោគស្វាយ, HbsAg និងតេស្តអេម៉ូក្លូប៊ីនដោយ Hemocue ត្រូវបានអនុវត្តដោយប្រើឈាមទាំងមូល ជាធម្មតាដោយជួសឈាមម្រាមដៃ ។ ដើម្បីកាត់បន្ថយការលំបាកចំពោះអ្នកជំងឺ សូមព្យាយាមបូមឈាមឱ្យបានគ្រប់គ្រាន់សម្រាប់តេស្តទាំង ៣ ពីម្រាមដៃតែមួយ ដោយប្រើម្ជុលដែលយកចេញពីឃីតតេស្តមេរោគអេដស៍/មេរោគស្វាយ ។

ប្រសិនបើ ANC ត្រូវបានផ្តល់ជូននៅមន្ទីរពេទ្យដែលមានមន្ទីរពិសោធន៍ ដែលអាចធ្វើការវិភាគអេម៉ូក្លូប៊ីនបាននោះ គេអាចបូមឈាមតាមសរសៃវ៉ែនជំនួសឱ្យម្រាមដៃ ដើម្បីទទួលបានឈាមគ្រប់គ្រាន់សម្រាប់ធ្វើតេស្តមន្ទីរពិសោធន៍ ។ ក្នុងករណីនេះ សូមបូមឈាមពីសឺរ៉ាំងសម្រាប់ធ្វើតេស្តមេរោគអេដស៍/មេរោគស្វាយ និង HBsAg មុនពេលដាក់ឈាមដែលនៅសល់ចូលក្នុងទីបសម្រាប់មន្ទីរពិសោធន៍ ។

[14]សៀវភៅណែនាំសម្រាប់ការធានាគុណភាពក្នុងកម្មវិធីសេវាតេស្តមេរោគអេដស៍ ។ NCHADS 2018.

### *3.2.2 ការធ្វើតេស្តមេរោគអេដស៍និងស្វាយក្នុងពេលឈឺពោះសម្រាល*

- មន្ទីរពេទ្យជាតិ ខេត្ត និងបង្អែក និងមណ្ឌលសុខភាព គួរផ្តល់ការប្រឹក្សានិងការធ្វើតេស្តមេរោគអេដស៍ និងស្វាយ ក្នុងអំឡុងឈឺពោះសម្រាលដល់ស្ត្រីដែលមិនដឹងស្ថានភាព

ក្នុងអំឡុងពេលឈឺពោះសម្រាល អ្នកផ្តល់សេវាគួរពិនិត្យប័ណ្ណសុខភាពម្តាយរបស់ស្ត្រីមានផ្ទៃពោះ រកមើលលទ្ធផលនៃតេស្តរកមេរោគអេដស៍និងមេរោគស្វាយដែលបានធ្វើក្នុងអំឡុងពេលទទួលសេវា ANC ។ ស្ត្រីដែលមិនដឹងស្ថានភាពមេរោគអេដស៍និងមេរោគស្វាយ គួរតែត្រូវបានផ្តល់ជូននូវការប្រឹក្សានិងធ្វើតេស្ត ។ ប្រសិនបើស្ត្រីត្រូវបានធ្វើតេស្តរួចហើយនៅឯសេវា ANC ប៉ុន្តែមិនបានយកប័ណ្ណឬលទ្ធផលតេស្តរបស់នាងមកជាមួយ សូមឱ្យនាងឬក្រុមគ្រួសាររបស់នាង យកលទ្ធផលតេស្តមក ប្រសិនបើផ្ទះរបស់ពួកគេនៅជិត ។ ប្រសិនបើពួកគេរស់នៅឆ្ងាយ ហើយមិនអាចឱ្យលទ្ធផលនោះមក ត្រូវតេស្តមេរោគអេដស៍និងមេរោគស្វាយម្តងទៀត ។

- ទោះបីមានភាពប្រសើរក្នុងការទទួលបានតេស្តមេរោគអេដស៍មុនពេលសម្រាលចំពោះស្ត្រីមានផ្ទៃពោះនៅឯសេវា *ANC* ក៏ដោយ ក៏នៅតែមានស្ត្រីដែលមកមូលដ្ឋានសុខាភិបាលក្នុងអំឡុងពេលឈឺពោះសម្រាលមិនដឹងស្ថានភាពមេរោគអេដស៍និងមេរោគស្វាយរបស់ពួកគេ ឬបានធ្វើតេស្តតែក្នុងអំឡុងពេលមានផ្ទៃពោះលើកមុនប៉ុណ្ណោះ ។
- ប្រសិនបើស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ ដែលមិនដឹងស្ថានភាពមេរោគអេដស៍នៅពេលសម្រាលមិនត្រូវបានកំណត់អត្តសញ្ញាណទេនោះ ឱកាសសម្រាប់ផ្តល់ឱ្យម្តាយនិងទារករបស់នាងនូវថ្នាំ *ARV* និងសេវា *PMTCT* ផ្សេងទៀតដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងពីម្តាយទៅកូននូវមេរោគអេសដ៍ ត្រូវបានបាត់បង់ ។
- ប្រសិនបើស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគស្វាយ ដែលមិនដឹងពីស្ថានភាពមេរោគស្វាយនៅពេលសម្រាល មិនត្រូវបានកំណត់អត្តសញ្ញាណ ឱកាសដើម្បីព្យាបាលទារកដែលមានមេរោគស្វាយពីកំណើត ត្រូវបានបាត់បង់ ។
- ដើម្បីកាត់បន្ថយឱកាសដែលបាត់បង់ទាំងនេះ គេគួរកត់ត្រាព័ត៌មានអំពីការធ្វើតេស្តមេរោគអេដស៍និងមេរោគស្វាយដាក់ក្នុងប័ណ្ណសុខភាពមាតា ដើម្បីកំណត់អត្តសញ្ញាណស្ត្រីដែលមិនដឹងពីស្ថានភាព ។ គេគួររំលឹកស្ត្រីនិងក្រុមគ្រួសាររបស់នាង ឱ្យយកប័ណ្ណសុខភាពពេលមកសម្រាលកូន ។

- នៅមូលដ្ឋានសុខាភិបាល ប្រសិនបើស្ត្រីមានផ្ទៃពោះដែលមិនដឹងពីស្ថានភាពមេរោគអេដស៍ ចូលមកសម្រាលកូន ហើយមាត់ស្បូននាងបើកតិចជាង ៤ សម នាងគួរតែទទួលបានការប្រឹក្សាពីឆ្មប ហើយបន្ទាប់ពីទទួលបានការយល់ព្រមផ្ទាល់មាត់ពីនាង ផ្តល់ជូននូវការធ្វើតេស្តមេរោគអេដស៍/ស្វាយភ្លាមៗ ។ ប្រសិនបើការឈឺសម្រាលវិវឌ្ឍលឿនពេក ឬទារកកើតចេញមកហើយ ស្ត្រីគួរតែទទួលការប្រឹក្សានិងការធ្វើតេស្តឱ្យបានឆាប់បំផុតក្រោយពេលសម្រាល ។

**ទម្រង់ការសម្រាប់ស្ត្រីដែលធ្វើតេស្តមេរោគអេដស៍មានប្រតិកម្មនៅពេលឈឺពោះសម្រាល/ការសម្រាល នឹងអាស្រ័យលើទីកន្លែងសម្រាលដូចខាងក្រោម ៖**

1. ការសម្រាលកូនកើតនៅមន្ទីរពេទ្យដែលមានទីតាំងស្ថិតនៅជាមួយ VCCT និងសេវា ART ៖

- ការធ្វើតេស្តបញ្ជាក់ គួរត្រូវបានរៀបចំឡើងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅទីតាំង VCCT ។
- ខណៈពេលរង់ចាំលទ្ធផលតេស្តបញ្ជាក់ ស្ត្រីគួរត្រូវបានផ្តល់ជូន ART **ភ្លាមៗ** (ជ្រើស B+), (**ត្រូវធានាថា មាន ARV នៅអគារសម្ភព**), ដោយចាប់ផ្តើមឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ក្នុងអំឡុងឈឺពោះសម្រាល និងបន្តពេញមួយជីវិត លើកលែងតែមានការបញ្ជាក់ថាអវិជ្ជមាន (សូមមើលបន្ថែមក្នុងជំពូកទី ៤) ។

- ប្រសិនបើរោគវិនិច្ឆ័យមេរោគអេដស៍ត្រូវបាន បញ្ជាក់ ៖
    - **ទារកត្រូវបានចាត់ទុកថា ប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍ ដោយសារម្តាយមិនបានទទួលការព្យាបាល ART ក្នុងអំឡុងពេលមានផ្ទៃពោះ ។ ពួកគេគួរតែចាប់ផ្តើមការព្យាបាលបង្ការភ្លាមៗដោយ ARV សម្រាប់ស្ថានភាពដែលមានប្រឈមមុខខ្ពស់ ជាមួយ** NVPandAZT ប្រចាំថ្ងៃ ដោយអនុវត្តតាមអនុសាសន៍ថ្មីរបស់អង្គការសុខភាពពិភពលោក (សូមមើលជំពូកទី ៤) ។.
    - ទារកដែលប្រឈមមុខនឹងមេរោគអេដស៍ (HEIs) គួរទទួលតេស្តមេរោគអេដស៍ DNA PCR ភ្លាមៗក្រោយពេលកើត មុនពេលចេញពីមន្ទីរពេទ្យ ។
    - តេស្តនេះអាចត្រូវបានធ្វើដោយឆ្មប ប្រសិនបើមានប័ណ្ណ ហើយឆ្មបនោះបានទទួលការបណ្តុះបណ្តាល បើមិនដូច្នេះទេ ត្រូវទាក់ទងអ្នកផ្តល់ប្រឹក្សាផ្នែកថែទាំជំងឺអេដស៍កុមារ (PAC) ដើម្បីធ្វើតេស្ត PCR មុនពេលចេញពីពេទ្យ ។
    - គួរផ្តល់ប្រឹក្សាឱ្យម្តាយវិលត្រឡប់ទៅ PAC វិញ ជាមួយកូនរបស់គាត់ នៅអាយុ ៦ សប្តាហ៍ ដើម្បីទទួលថ្នាំបង្ការ និងលទ្ធផលតេស្ត PCR បន្ថែមមួយទៀត ។
    - គួរផ្តល់ប្រឹក្សាដល់ស្ត្រី អំពីការចិញ្ចឹមទារក (សូមមើលជំពូកទី ៦) ។

- ប្រសិនបើតេស្តបញ្ជាក់អវិជ្ជមាន ចូរជានាដល់ស្ត្រីថា នាងមិនឆ្លងទេ ហើយផ្តល់ការថែទាំក្រោយពេលសម្រាលតាមធម្មតា ។
- ប្រសិនបើដោយហេតុផលណាមួយ គេមិនអាចធ្វើតេស្តបញ្ជាក់បាន ចូរធ្វើតាមសេចក្តីណែនាំខាងក្រោម ។

2. ការសម្រាលកូននៅមណ្ឌលសុខភាព ឬនៅមន្ទីរពេទ្យបង្អែក ដែលមានទីតាំងមិនស្ថិតនៅជាមួយសេវា VCCT/ART ៖

- ប្រសិនបើតេស្តរហ័សដំបូង មានប្រតិកម្ម គួររៀបចំធ្វើតេស្តបញ្ជាក់ឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាននៅទីតាំង VCCT (ដោយបញ្ជូនសំណាកឈាមទៅ VCCT)
- ខណៈពេលរង់ចាំលទ្ធផលតេស្តបញ្ជាក់ **អ្នកផ្តល់សេវាគ្រប់គ្រងករណី (CMP) នៅមណ្ឌលសុខភាព គួរទាក់ទង CMC/CMA ឬអ្នកសម្របសម្រួលកម្មវិធីអេដស៍/សុខភាពមាតានិងទារកថ្នាក់ស្រុក** ដើម្បីរៀបចំ និងទាក់ទងតួអង្គសំខាន់ៗ **ក្នុងការផ្តល់ការព្យាបាល ART (ពីអគារសម្ភពនៃមន្ទីរពេទ្យបង្អែក) នៅមណ្ឌលសុខភាពសម្រាប់ម្តាយ និង ARV សម្រាប់កូនដើម្បីទទួលវិធីបង្ការការចម្លងពីម្តាយទៅកូន (PMTCT) ។** អ្នកសម្របសម្រួលថ្នាក់ស្រុកប្រតិបត្តិ គួររៀបចំទម្រង់ការនេះសម្រាប់មណ្ឌលសុខភាពដែលពួកគេទទួលខុសត្រូវ ។
- ស្ត្រីគួរតែបានទទួលប្រឹក្សា និងបញ្ជូនទៅគ្លីនិក ART និង PAC ជាមួយទារកដើម្បីធ្វើតេស្តបញ្ជាក់ និង (ប្រសិនបើបញ្ជាក់ថា វិជ្ជមាន) ធ្វើតេស្ត PCR សម្រាប់ទារក និងចុះឈ្មោះទាំងម្តាយទាំងកូនឱ្យបានឆាប់បំផុតក្រោយពេលកើត ។
- ស្ត្រីគួរទទួលប្រឹក្សាអំពីការចិញ្ចឹមទារក (សូមមើលជំពូកទី ៦)
- ឆ្មបគួរតែតែតាមដានបន្តដើម្បីឱ្យប្រាកដថា ស្ត្រីនោះបានទទួល ART/PAC និងជម្រាបដល់អ្នកសម្របសម្រួលស្រុកប្រតិបត្តិ/មន្ទីរសុខាភិបាល ឬ CMA អំពីករណីបាត់ខ្លួនមិនបានមកតាមដានបន្ត ។

## ក្នុងករណីស្ត្រី ដែលតេស្តស្វាយមានប្រតិកម្មនៅពេលឈឺពោះសម្រាល/ពេលសម្រាលកូន ៖

1. គួរដាក់ទារកក្នុងអគារជំងឺកុមារនៃមន្ទីរពេទ្យបង្អែកដើម្បីទទួលការព្យាបាលសន្មត (presumptive treatment) នូវជំងឺស្វាយពីកំណើត (សូមមើមលផ្នែកទី 4.2) ។

2. ម្តាយនិងដៃគូរបស់គាត់ គួរទទួលការព្យាបាលសម្រាប់ជំងឺស្វាយដូចមានពិពណ៌នាក្នុងផ្នែកទី ៤.២ ។

### *3.2.3 ការធ្វើតេស្តមេរោគអេដស៍សម្រាប់ទារកដែលប្រឈមមុខនឹងមេរោគអេដស៍*

ទារកដែលប្រឈមនឹងមេរោគអេដស៍ (HEI) គួរធ្វើតេស្ត HIV-DNA PCR នៅពេលកើត ប្រសិនបើការសម្រាលធ្វើឡើងនៅមន្ទីរពេទ្យ ដូចរៀបរាប់ខាងលើ និងចុះឈ្មោះក្នុងការថែទាំជំងឺអេដស៍កុមារ (PAC) ដើម្បីធ្វើតេស្តបន្ថែមទាំងឡាយដូចខាងក្រោម ដោយមានការយល់ព្រមដោយផ្ទាល់មាត់ពីម្តាយ ៖

- តេស្ត HIV DNA PCR នៅអាយុ ៦ សប្តាហ៍ ។
- ប្រសិនបើបៅដោះម្តាយ ហើយតេស្ត PCR អវិជ្ជមាន នៅ ៦ សប្តាហ៍, ត្រូវធ្វើ HIV DNA PCR ម្តងទៀត នៅ ៦ សប្តាហ៍ ក្រោយពេលឈប់បៅដោះម្តាយ ។
- តេស្តអង្គបដិបក្ខប្រាណ HIV នៅអាយុ ១៨ ខែ (បើ PCRs អវិជ្ជមាន), ដោយធ្វើ PCR បញ្ជាក់ ប្រសិនបើតេស្តអង្គបដិបក្ខប្រាណ វិជ្ជមាន ៖
- ប្រសិនបើតេស្ត HIV DNA PCR ឬ (ក្រោយ ១៨ ខែ) តេស្តអង្គបដិបក្ខប្រាណ វិជ្ជមាន ចាប់ផ្តើម ART ភ្លាមៗ (ក្នុងអំឡុងពេល ២ សប្តាហ៍)

សូមមើលតារាងលំហូរសម្រាប់រោគវិនិច្ឆ័យចំពោះទារកដែលប្រឈមនឹងមេរោគអេដស៍ដែលបានដឹង អាយុ < ១៨ ខែនៅក្នុង *គោលការណ៍ណែនាំរបស់* NHCADS *ស្តីពីការគ្រប់គ្រងគ្លីនិកមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យ ។*

អ្នកផ្តល់សេវា ANC, ART, និងការសម្រាល គួរផ្តល់ប្រឹក្សាដល់ម្តាយដែលផ្ទុកមេរោគអេដស៍នៅគ្រប់ពេលមកជួប អំពីសារៈសំខាន់នៃការធ្វើតេស្តទាំងនេះសម្រាប់ទារករបស់ពួកគេ ។ សូមមើលផងដែរជំពូកទី ៦ សម្រាប់ការពិពណ៌នាអំពីសេវាផ្សេងទៀតសម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍ (HEI) ។

### *3.2.4 ការធ្វើតេស្តមេរោគរលាកថ្លើមប្រភេទបេសម្រាប់ទារកដែលប្រឈមមុខនឹងមេរោគនេះ*

ទារកដែលកើតពីម្តាយទាំងអស់ដែលមាន HBsAg វិជ្ជមាន គួរតែត្រូវបានគេធ្វើតេស្ត HBsAg នៅអាយុប្រហែល ៦ ខែ ទៅ ១ ឆ្នាំ (ហើយយ៉ាងហោចណាស់ ១ ខែ បន្ទាប់ពីការចាក់វ៉ាក់សាំង HBV ពេញលេញ) ។

## 3.3ព័ត៌មាន ការអប់រំ និងការប្រាស្រ័យទាក់ទង (IEC)

- សារនិងយុទ្ធនាការផ្សព្វផ្សាយព័ត៌មាន ការអប់រំ និងប្រាស្រ័យទាក់ទង (IEC) ជួយបង្កើនចំណេះដឹង និងភាពអាចទទួលយកបាននៃសេវា PMTCT និងអាចជួយកាត់បន្ថយការមាក់ងាយនិងការរើសអើង ដែលទាក់ទងនឹងការឆ្លងមេរោគអេដស៍ ។ យុទ្ធសាស្ត្រប្រាស្រ័យទាក់ទងដែលផ្តល់ព័ត៌មានអំពីមេរោគអេដស៍/ជំងឺអេដស៍ គួរសង្កត់ធ្ងន់លើ PMTCT ផងដែរ ។

- គេគួរខិតខំប្រឹងប្រែងដើម្បីបញ្ជ្រាប PMTCT IEC ទៅក្នុងសកម្មភាពសុខភាពមាតានិងកុមារដែលមានស្រាប់នៅគ្រប់កម្រិតទាំងអស់ ដើម្បីបង្កើនលទ្ធផលជាអតិបរមា និងរួមចំណែកកាត់បន្ថយការមាក់ងាយនិងការរើសអើង ។ សម្ភារៈ IEC សមស្រប ដូចជា ផ្ទាំងរូបភាព ខិត្តប័ណ្ណ និងវីដេអូ ដែលមានគោលដៅផ្លាស់ប្តូរចំណេះដឹង, អាកប្បកិរិយា និងការអនុវត្តរបស់អតិថិជន និងអ្នកផ្តល់សេវា គឺជាសមាសភាគរួមមួយនៃការផ្តល់សេវា ហើយគួរតែត្រូវបានប្រើប្រាស់នៅពេលណាដែលអាចធ្វើទៅបាន ។
- ការគាំទ្រនៅក្នុងសហគមន៍និងការទំនាក់ទំនងយ៉ាងរឹងមាំរវាងសហគមន៍និងសេវាសុខភាព មានសារៈសំខាន់យ៉ាងខ្លាំងដើម្បីឱ្យបុគ្គលដែលឆ្លងមេរោគអេដស៍និងគ្រួសាររបស់ពួកគេ ទទួលបានអត្ថប្រយោជន៍ពីអន្តរាគមន៍ដែលមាន ។ អង្គការគាំទ្រនៅថ្នាក់សហគមន៍ គឺជាសមាសភាគដ៏សំខាន់នៃល្បាក់នៃការថែទាំ (CoC) ។ ស្ត្រីទាំងអស់ដែលត្រូវបានរកឃើញថា ឆ្លងមេរោគអេដស៍គួរតែត្រូវបានលើកទឹកចិត្តឱ្យចូលរួមជាមួយការគាំទ្រដែលមាននៅតាមសហគមន៍ នៅក្នុងតំបន់ក្បែរផ្ទះរបស់ពួកគេ ។

### *3.3.1 ព័ត៌មានសុខភាពបន្តពូជសម្រាប់ស្ត្រីផ្ទុកមេរោគអេដស៍*

ស្ត្រីផ្ទុកមេរោគអេដស៍និងដៃគូរបស់ពួកគេ មានសិទ្ធិធ្វើការសម្រេចចិត្តដោយសេរីនិងផ្អែកលើព័ត៌មានដែលមាន អំពីថាតើត្រូវមានកូនឬទេ និងនៅពេលណា ។

- **ស្ត្រីដែលឆ្លងមេរោគអេដស៍ ដែលកំពុងពិចារណាយកកូន** ត្រូវការដឹងពីមធ្យោបាយដើម្បីកាត់បន្ថយហានិភ័យដែលទាក់ទងនឹងការមានកូន រួមទាំងកម្រិតប្រើឱសថ ARV ដែលសមស្រប, សេវាសម្រាលកូនដោយសុវត្ថិភាព, ការព្យាបាលបង្ការដោយថ្នាំ ARV សម្រាប់ទារក និងរបៀបចិញ្ចឹមទារកប្រកបដោយសុវត្ថិភាព ។ ផ្តល់ដំបូន្មានដល់ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ថា ពេលវេលានៃការយកកូនដ៏បំផុត សម្រាប់ទាំងសុខភាពផ្ទាល់ខ្លួនរបស់នាង និងហានិភ័យទាបបំផុតនៃការចម្លងពីម្តាយទៅកូន គឺបន្ទាប់ពីនាងបានប្រើថ្នាំ ARV រយៈពេលពី ៦-១២ ខែ, មានបន្ទុកមេរោគ (VL) ដែលមិនអាចរកឃើញ និងមានចំនួន CD4 ធម្មតា ។ (គោលការណ៍ណែនាំរបស់ NCHADs ស្តីពីការគ្រប់គ្រងគ្លីនិកនៃ មេរោគអេដស៍ ឆ្នាំ ២០២០)
    - មានរបាយការណ៍ពីការសិក្សាបែបសង្កេតមួយនៅក្នុងប្រទេសបុតស្វាណា អំពីការកើនឡើងនៃអាំងស៊ីដង់បញ្ហាខួរក្បាលនិងឆ្អឹងកងបិទមិនជិត (neural tube defects) ចំពោះទារកដែលកើតពីស្ត្រីដែលប្រើឱសថប្រឆាំងវីរុស dolutegravir (DTG) នៅពេលមានគភ៌ ។ មិនមានសញ្ញាបង្ហាញពីការកើនឡើងនូវហានិភ័យទេ នៅពេលចាប់ផ្តើមប្រើ DTG បន្ទាប់ពីស្ត្រីមានផ្ទៃពោះ ។ គេមិនឃើញមានទំនាក់ទំនងស្រដៀងគ្នានេះនៅក្នុងប្រទេសដទៃទៀតទេរហូតមកដល់បច្ចុប្បន្ននេះ ហើយការស្រាវជ្រាវបន្ថែមទៀតកំពុងដំណើរការ ។ ហានិភ័យផ្អែកលើការវិភាគថ្មីៗនៃទិន្នន័យរបស់ប្រទេសបុតស្វាណា គឺមិនមានទំហំធំនោះទេ ៖ បញ្ហាខួរក្បាលនិងឆ្អឹងកងបិទមិនជិត បានកើតឡើងនៅក្នុងអត្រាតែ 0,៣% ប៉ុណ្ណោះចំពោះទារកដែលកើតពីស្ត្រីដែលប្រើថ្នាំ

DTG ក្នុងពេលមានផ្ទៃពោះ ។ DTG មានអត្ថប្រយោជន៍យ៉ាងធំធេង បើប្រៀបធៀបទៅនឹងថ្នាំប្រឆាំងនឹងវីរុសដទៃទៀត រួមទាំង ប្រសិទ្ធភាពដ៏ខ្ពស់ដែលធ្វើឱ្យបន្ទុកវីរុសថយចុះយ៉ាងរហ័ស (ជាពិសេស សំខាន់សម្រាប់ PMTCT), ភាពស៊ាំរបស់មេរោគតិចជាង និងមានផលរំខានតិចជាង ។ ដូច្នេះ DTG នៅតែជាឱសថ ART ជួរទីមួយដែលត្រូវបានណែនាំ ចំពោះស្ត្រីមានផ្ទៃពោះ ។ ស្ត្រីផ្ទុកមេរោគអេដស៍ដែលមានបំណងយកកូន*ថ្មី* គួរតែទទួលការណែនាំអំពីហានិភ័យនិងអត្ថប្រយោជន៍ដែលអាចមាននៃ DTG និងទទួលការគាំទ្រក្នុងការសម្រេចចិត្តដោយផ្អែកលើព័ត៌មានដែលមាន ។ គ្មានហេតុផលអ្វីដែលត្រូវបញ្ឈប់ឬមិនប្រើ DTG ចំពោះស្ត្រីមានផ្ទៃពោះរួចទៅហើយនោះទ្បើយ ។[15][16][17]

- ស្ត្រីដែលឆ្លងមេរោគអេដស៍ដែលមិនចង់មានផ្ទៃពោះ គួរតែទទួលការប្រឹក្សាអំពីការការពារការមានផ្ទៃពោះដោយអចេតនា ។ សូមមើលជំពូកទី ៧ សម្រាប់ព័ត៌មានអំពីវិធីសាស្ត្រដែលមាន ។ មានអ្នកផ្តល់ប្រឹក្សាដែលបានទទួលការបណ្តុះបណ្តាលអំពីការពន្យារកំណើតនៅគ្លីនិក *ART* និងមានវិធីមធ្យោបាយពន្យារកំណើតទំនើបមួយចំនួន (ស្រោមអនាម័យ, ថ្នាំគ្រាប់ និងថ្នាំចាក់) នៅតាមគ្លីនិក *ART* និង *FHCs* ក៏ដូចជា នៅមណ្ឌលសុខភាព ផងដែរ ។
- ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ ដែលបានរួមភេទដោយមិនបានការពារក្នុងរយៈពេល ៤ ថ្ងៃកន្លងមក ឬតិចជាងនេះ ហើយមិនចង់មានផ្ទៃពោះ គួរត្រូវបានផ្តល់ជូននូវមធ្យោបាយពន្យារកំណើតបន្ទាន់ ។ ស្ត្រីដែលប្រើ *ART* ដែលរួមបញ្ចូល *NNRTI* ឬ *PI* និងស្ត្រីដែលប្រើថ្នាំ *rifampacin* សម្រាប់ជំងឺរបេង ត្រូវប្រើថ្នាំពន្យារកំណើតបន្ទាន់ទ្វេដង, ពោលគឺ *levonorgesterol* ៣ មក្រ មិនមែន ១,៥ មក្រ ទេ ។[18]
- **ស្ត្រីដែលរស់នៅជាមួយមេរោគអេដស៍ ដែលមានផ្ទៃពោះដោយអចេតនា** គួរបានទទួលប្រឹក្សាអំពីជម្រើសរបស់ពួកគេ រួមទាំងការបន្តមានគភ៌រហូតដល់កើត ឬការរំលូតកូនដោយសុវត្ថិភាព ។ សូមបញ្ជូនទៅកាន់សេវារំលូតកូនដោយសុវត្ថិភាព ប្រសិនបើស្ត្រីសម្រេចចិត្តបញ្ឈប់ការមានផ្ទៃពោះនោះ ឬផ្តល់ប្រឹក្សាអំពី PMTCT ប្រសិនបើគាត់សម្រេចចិត្តទុកកូន ។

ស្ត្រីមានផ្ទៃពោះដែលមានមេរោគអេដស៍ គួរទទួលបានការប្រឹក្សាច្បាស់លាស់អំពីហានិភ័យនៃការចម្លងចំពោះទារក និងវិធីនានាដើម្បីបង្ការការចម្លងពីម្តាយទៅកូន ជាពិសេសសារៈសំខាន់នៃការបន្តទទួល ART ក្នុងអំឡុងពេលមានផ្ទៃពោះទាំងមូល, ការសម្រាលកូននៅអគារសម្ភពនៃមន្ទីរពេទ្យ ដែលមានទីតាំងស្ថិតនៅជាមួយទីតាំង ART, ការព្យាបាលបង្ការដោយ ARV សម្រាប់ទារក, ការចិញ្ចឹមទារកប្រកបដោយសុវត្ថិភាព និងការតាមដានបន្តសម្រាប់ទារកនៅសេវា PAC ។

---

[15] Statement on DTG. WHO May 18 2018.
[16] WHO News Release 22 July 2019.
[17] NCHADs HIV Management Guidelines 2020.
[18] NCHADs HIV Management Guidelines 2020.

# ជំពូកទី ៤ ៖ ការព្យាបាលស្ត្រីមានផ្ទៃពោះ និងស្ត្រីបំបៅកូន ដែលមានមេរោគអេដស៍ ស្វាយ ឬមេរោគរលាកថ្លើមប្រភេទបេ សម្រាប់បង្ការការចម្លងពីម្តាយទៅកូន

## 4.1 ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូនដែលផ្ទុកមេរោគអេដស៍

ការគ្រប់គ្រងកម្រិតបន្ទុកវីរុសក្នុងខ្លួនម្តាយតាមរយៈការព្យាបាលដោយ ART អាចកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ពីម្តាយទៅកូន ពី ៣៥% ប្រសិនបើគ្មានអន្តរាគមន៍ មកត្រឹមតិចជាង ៥% ចំពោះក្រុមស្ត្រីដែលបំបៅដោះកូន ។

**គួរចាប់ផ្តើម ART សម្រាប់ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅកូនទាំងអស់ដែលរស់នៅជាមួយមេរោគអេដស៍ ដោយមិនគិតពីដំណាក់កាលគ្លីនិកតាម WHO និងចំពោះចំនួនកោសិកា CD4 ណាក៏ដោយ ព្រមទាំងបន្តពេញមួយជីវិត ។**

*(សេចក្តីសង្ខេបគោលនយោបាយនៃគោលការណ៍ណែនាំសំយោគស្តីពីការប្រើឱសថប្រឆាំងវីរុសសម្រាប់ព្យាបាលនិងបង្ការការឆ្លងមេរោគអេដស៍ ។ WHO 2015)*

- ទោះបីជាការឆ្លងមេរោគអេដស៍ត្រូវបានរកឃើញយឺតនៅពេលមានផ្ទៃពោះ ឬអំឡុងពេលក្រោយសម្រាលក្តី ក៏គួរចាប់ផ្តើមប្រើ ART **ជាបន្ទាន់** ចំពោះស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះទាំងអស់ ។
- ជាការពិត វិធីដ៏មានប្រសិទ្ធិភាពបំផុតដើម្បីបង្ការការឆ្លងមេរោគអេដស៍ពីម្តាយទៅកូន គឺត្រូវកាត់បន្ថយបន្ទុកមេរោគក្នុងខ្លួនម្តាយឱ្យបានរហ័ស ។
- កត្តាកំណត់ចម្បងនៃហានិភ័យនៃការចម្លងក្នុងអំឡុងពេលប្រើ ART គឺកម្រិតនៃបន្ទុកវីរុសរបស់ម្តាយ និងរយៈពេលនៃការព្យាបាយដោយ ART ក្នុងពេលមានផ្ទៃពោះ ។
- នៅពេលណាអាចធ្វើទៅបាន គេគួរខិតខំប្រឹងប្រែងកំណត់អត្តសញ្ញាណស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ឱ្យបានឆាប់បំផុតក្នុងអំឡុងពេលមានផ្ទៃពោះ ដើម្បីគ្រប់គ្រងបន្ទុកមេរោគបានឆាប់រហ័ស និងកាត់បន្ថយហានិភ័យនៃការចម្លង ។
- ការធ្វើតេស្តរកមេរោគអេដស៍ និងការចាប់ផ្តើមប្រើ ART យឺត ក្នុងអំឡុងពេលមានផ្ទៃពោះ ឬក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះម្តាយ ធ្វើឱ្យមានហានិភ័យកាន់តែច្រើនបំពោះការចម្លងមេរោគអេដស៍ទៅទារក ដោយសារតែមានការពិបាកគ្រប់គ្រងបន្ទុកវីរុស ហើយត្រូវការវិធានការព្យាបាលបង្ការកាន់តែខ្លាំងថែមទៀត ។

នីតិវិធីដូចខាងក្រោមនេះទាក់ទងនឹងការប្រើប្រាស់ ART គួរតែត្រូវបានអនុវត្តសម្រាប់ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះដែលផ្ទុកមេរោគអេដស៍ទាំងអស់ ៖

- ប្រសិនបើស្ត្រីមានផ្ទៃពោះធ្វើតេស្តវិជ្ជមានមេរោគអេដស៍ ទាំងនៅពេលមានផ្ទៃពោះ, ពេលឈឺពោះសម្រាល និង/ឬ ពេលបំបៅដោះកូន គេគួរតែបញ្ជូននាងទៅរកសេវា ART ជាបន្ទាន់ ដើម្បីចុះឈ្មោះ និងទទួលការព្យាបាលដោយ ART បានរហ័ស ។
- ការចាប់ផ្តើមប្រើ ART ពេញមួយជីវិត ត្រូវបានណែនាំជាបន្ទាន់សម្រាប់ស្ត្រីមានផ្ទៃពោះ និងស្ត្រីដែលបំបៅដោះកូនដែលឆ្លងមេរោគអេដស៍ទាំងអស់ ដោយមិនគិតពីដំណាក់កាលរបស់អង្គការសុខភាពពិភពលោក និងការមានចំនួនកោសិកា CD4 ណាមួយនោះឡើយ ។
- ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ គួរទទួលការប្រឹក្សានិងការគាំទ្រភ្លាមៗដើម្បីរៀបចំសម្រាប់ការសម្រាលកូននៅអគារសម្ភពនៃមន្ទីរពេទ្យបង្អែក ដែលមានឱសថ ARV សម្រាប់ការព្យាបាលបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅទារក ។

បន្ថែមពីលើការទទួលការព្យាបាលដោយ ART, ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ក៏គួរតែទទួលបានអន្តរាគមន៍បន្ថែមទាំងនេះផងដែរ ជាផ្នែកមួយនៃកញ្ចប់ថែទាំផ្ទៃពោះដែលបានណែនាំ ៖

- ការធ្វើតេស្តពិនិត្យរកមេរោគស្វាយនិងរលាកថ្លើមប្រភេទបេ ។
- ការគាំទ្រដោយអាហារូបត្ថម្ភ
- ការពិនិត្យរកភាពស្លេកស្លាំង
- ការវាយតម្លៃសញ្ញាគ្រោះថ្នាក់ ( ការហើម ការធ្លាក់ឈាម សម្ពាធឈាមខ្ពស់ ។ល។ )
- ការផ្តល់ប្រឹក្សាអំពីការចិញ្ចឹមទារក
- ការណែនាំអំពីការពន្យារកំណើត
- ការត្រួតពិនិត្យតាមដានដោយយកចិត្តទុកដាក់ចំពោះកើតជំងឺលើសសម្ពាធឈាមដោយសារការមានផ្ទៃពោះ សញ្ញាគ្រោះថ្នាក់ និងបម្រុងក្រឡាភ្លើង ជាពិសេស ចំពោះស្ត្រីដែលបានប្រើ ART មុនពេលមានផ្ទៃពោះ ។
- ការព្យាបាលបង្ការដោយ ARV សម្រាប់ទារក
- ការថែទាំតាមដានបន្តសម្រាប់ទារកនៅកន្លែងថែទាំជំងឺអេដស៍កុមារ ។

ក្នុងអំឡុងពេលមានផ្ទៃពោះរបស់ស្ត្រីដែលផ្ទុកមេរោគអេដស៍ គោលការណ៍សំខាន់ៗនិងការអនុវត្តមាតុភាពគ្មានគ្រោះថ្នាក់ គួរតែត្រូវបានអនុវត្ត ដោយរួមបញ្ចូល ៖

- ការពង្រឹងការទៅពិនិត្យថែទាំផ្ទៃពោះមុនសម្រាលទៀងទាត់តាមការណែនាំ ។

- ការរៀបចំត្រៀមសម្រាប់ការសម្រាលកូននៅមូលដ្ឋានសុខាភិបាល ដោយបុគ្គលិកជំនាញដែលបានទទួលការបណ្តុះបណ្តាល ។ ការសម្រាលនេះគួរតែធ្វើឡើងនៅសេវាសម្ភពក្នុងមន្ទីរពេទ្យបង្អែកដែលនៅជិតគ្លីនិក ART ដែលមានសេវាព្យាបាលបង្ការដោយ ARV សម្រាប់ទារក ។
- ការជៀសវាងការប្រើប្រាស់ឧបករណ៍សម្រាប់ជំនួយការសម្រាលកូនតាមទ្វារមាស ដូចជា កែវបូម ឬដង្កៀប លើកលែងតែចាំបាច់ខានពុំបានសម្រាប់ការសម្រាលនោះ ។
- ការសម្អាតទារកទើបនឹងកើតដែលប្រឡាក់ឈាមភ្លាមៗក្រោយពេលកើត និងការប្រើបច្ចេកទេសដែលមិនប្រើឧបករណ៍ដាក់បញ្ចូលក្នុងខ្លួនជាមួយទារកទើបនឹងកើត តាមដែលអាចធ្វើទៅបាន។
- ដូចជាសម្រាប់ការសម្រាលទាំងអស់ដែរ បុគ្គលិកថែទាំសុខភាពគួរអនុវត្តការប្រុងប្រយ័ត្នជាសកលរួមទាំងការសម្រាលចំពោះស្ត្រីផ្ទុកមេរោគអេដស៍ផងដែរ ។
- ការខិតខំប្រឹងប្រែងពិសេសគួរធ្វើឡើង ដើម្បីធានាថា ការផ្តល់ការថែទាំពេលសម្រាលដល់ស្ត្រីដែលផ្ទុកមេរោគអេដស៍ក្នុងលក្ខណៈមិនមាក់ងាយ និងប្រកបដោយការគាំទ្រ ។

### *4.1.1 ឱសថប្រឆាំងវីរុសសម្រាប់ស្ត្រីមានផ្ទៃពោះនិងក្រោយសម្រាលដែលផ្ទុកមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍*

អនុសាសន៍សម្រាប់ការព្យាបាលដោយ ARV សម្រាប់កម្ពុជា ដូចបង្ហាញខាងក្រោម គឺស្របតាមការណែនាំដែលចេញដោយអង្គការសុខភាពពិភពលោក ក្នុងឆ្នាំ ២០១៩[19] ។

**តារាងទី ២ ៖ ការព្យាបាលដោយ ART សម្រាប់ស្ត្រីមានផ្ទៃពោះ/ស្ត្រីបំបៅដោះកូន**

| របមន្តព្យាបាលជួរទីមួយជាអនុសាសន៍ | របមន្តព្យាបាលជួរទីមួយជម្រើសជំនួស |
|---|---|
| Tenofovir (TDF) 300 mg + Lamivudine (3TC) 300mg + Dolutegravir (DTG) 50mg<br>ជាដូសរួមបញ្ចូលគ្នា មួយដងក្នុងមួយថ្ងៃ | TDF 300 mg +3TC 300 mg +Efavirenz (EFV) 400<br><br>Abacavir (ABC) 600 mg + 3 TC 300 mg + DTG50 or EFV 400 |

*<u>ប្រភព</u> ៖ គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់មនុស្សពេញវ័យ និងយុវវ័យ, NCHADS 2020 ។*

[19] Update on recommendations for first- and second- line antiretroviral regimens. WHO 2019

*សម្រាប់ព័ត៌មានលម្អិតអំពីរូបមន្ត ART សូមមើលគោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមេរោគអេដស៍បច្ចុប្បន្នរបស់ NCHADS ។*

**TDF (300mg) + 3TC (300mg) + DTG (50 mg)** ថ្នាំគ្រាប់ដូសរួមបញ្ចូលគ្នា (FDC) លេបមួយដងក្នុងមួយថ្ងៃ គឺជារូបមន្តព្យាបាលជួរទីមួយដោយ ART ដរាបណាគ្មានការហាមប្រើ ។ រូបមន្តនេះគឺសមស្របសម្រាប់មនុស្សពេញវ័យនិងយុវវ័យ រួមទាំង ស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូន ។ គេអាចប្រើក្នុងករណីមានជំងឺរបេងរួមជាមួយមេរោគអេដស៍ផងដែរ ប៉ុន្តែក្នុងករណីនេះ គេត្រូវបង្កើនដូស DTG ទ្វេដង រហូតដល់រយៈពេល ២ សប្តាហ៍ ក្រោយពេលឈប់ប្រើ rifampicin ។

TDF និង 3TC នឹងព្យាបាលជំងឺរលាកថ្លើមប្រភេទបេ ក្នុងពេលតែមួយផងដែរ ។

**ការហាមប្រើចំពោះ TDF + 3TC + DTG**

- TDF គឺហាមប្រើ ក្នុងករណីខូចតម្រងនោម ហើយមិនគួរចាប់ផ្តើមប្រើប្រសិនបើ eGFR < 50 ml/min ។
    - ប្រើ ABC 600 mg ជំនួសប្រចាំថ្ងៃវិញ ។

ដូចដែលបានកត់សម្គាល់ក្នុងផ្នែកទី ៣.៣.១ មានរបាយការណ៍មួយចំនួនដែលបានលើកឡើងអំពីការកើនឡើងនូវហានិភ័យនៃបញ្ហាលលាដ៍ក្បាលនិងឆ្អឹងកងមិនជិតចំពោះស្ត្រីដែលបានប្រើថ្នាំ DTG នៅពេលមានផ្ទៃពោះ ។ បញ្ហានេះមិនត្រូវបានគេពិនិត្យបញ្ជាក់នៅឡើយទេ ហើយការសិក្សាបន្ថែមទៀតកំពុងបន្ត ។ DTG នៅតែអាចប្រើបានចំពោះស្ត្រីដែលមានបំណងយកកូន ដរាបណាពួកគេបានទទួលព័ត៌មានអំពីហានិភ័យនិងអត្ថប្រយោជន៍របស់ថ្នាំនេះ ហើយបានធ្វើការសម្រេចចិត្តដោយផ្អែកលើព័ត៌មានដែលមាន ។ មិនមានហានិភ័យកាន់តែខ្ពស់ក្នុងការប្រើថ្នាំ DTG នេះ ចំពោះស្ត្រីដែលមានផ្ទៃពោះរួចហើយនោះទេ ។ [20][21]

## ការព្យាបាលបង្ការទារក

ការព្យាបាលបង្ការដោយទារកគួរចាប់ផ្តើមឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន នៅពេលកើត ឬពេលណាដឹងថាមានការប្រឈមនឹងមេរោគអេដស៍ក្រោយពេលសម្រាល ។ ថ្នាំបង្ការដំបូងគួរផ្តល់ជូនក្នុងអំឡុងពេល ៦ ម៉ោងក្រោយពេលសម្រាល (ឬឆាប់ជាងនេះ ប្រសិនបើអាចធ្វើទៅបាន) ព្រោះវាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការការពារបន្ទាន់ ។ ការព្យាបាលបង្ការដោយ ARV ត្រូវបានផ្តល់ដល់ទារក យោងតាមស្ថានភាពប្រឈមរបស់ពួកគេ ដូចមានរៀបរាប់ខាងក្រោម ៖

[20] សេចក្តីថ្លែងការណ៍របស់អង្គការសុខភាពពិភពលោក WHO ស្តីពី DTG ខែឧសភា ឆ្នាំ ២០១៨ ។

[21] មគ្គុទេសក៍ជាតិស្តីពីការគ្រប់គ្រងគ្លីនិកនៃមេរោគអេដស៍សម្រាប់មនុស្សពេញវ័យ និងយុវវ័យ, NCHADS ២០២០ ។

**តារាងទី ៣ ៖ គោលការណ៍ណែនាំស្តីពីការព្យាបាលបង្ការដោយប្រើ ARV ឬទារកដែលប្រឈមនឹងមេរោគអេដស៍**

1. **ទារកដែលប្រឈមមុខខ្ពស់ចំពោះមេរោគអេដស៍ ៖** ត្រូវបានកំណត់ថាជាទារកដែលកើតពីម្តាយដែលទើបរកឃើញថាមានផ្ទុកមេរោគអេដស៍នៅពេលសម្រាល ឬក្នុងរយៈពេលក្រោយសម្រាល ឬម្តាយដែលបានព្យាបាលដោយ ART រយៈពេលតិចជាង ៤ សប្តាហ៍ គិតត្រឹមថ្ងៃសម្រាល ឬម្តាយដែលមានបន្ទុកវីរុស >1,000 copies/ml ក្នុងអំឡុងពេល ៤ សប្តាហ៍នៃការសម្រាល (ប្រសិនបើមានបន្ទុកវីរុស VL) ។.
   1.1. ទារកដែលប្រឈមមុខខ្ពស់នឹងមេរោគអេដស៍ទាំងអស់ ដែលបៅដោះម្តាយ គួរទទួលបានថ្នាំព្យាបាលពីរមុខ (AZT និង NVP) ក្នុងអំឡុងពេល ៦ សប្តាហ៍ដំបូងនៃជីវិត ហើយបន្តប្រើតែ NVP មួយមុខសម្រាប់រយៈពេល ៦ សប្តាហ៍ទៀត ។ *(សរុប ១២ សប្តាហ៍)*
   1.2. ទារកដែលប្រឈមមុខខ្ពស់នឹងមេរោគអេដស៍ទាំងអស់ ដែលមិនបៅដោះម្តាយ គួរទទួលបានថ្នាំព្យាបាលបង្ការពីរមុខ គឺ AZT និង NVP ក្នុងអំឡុងពេល ៦ សប្តាហ៍ដំបូងនៃជីវិត ។
2. **ទារកដែលប្រឈមមុខទាបចំពោះមេរោគអេដស៍ ៖** ត្រូវបានកំណត់ថាជាទារកដែលកើតពីម្តាយដែលបានព្យាបាលដោយ ART រយៈពេល ៤ សប្តាហ៍ឡើងទៅ មុនពេលសម្រាល និងមានបន្ទុកមេរោគក្នុងរយៈពេល ៤ សប្តាហ៍មុនការសម្រាលនោះ (ប្រសិនបើដឹង) ចំនួន <1,000 copies/ml ។
   2.1. ទារកដែលប្រឈមមុខទាបចំពោះមេរោគអេដស៍ទាំងអស់ ដោយមិនគិតពីកំពុងបៅដោះឬមិនបៅដោះនោះទេ គួរទទួលបាន NVP តែមួយមុខគត់ ជាការបង្ការក្នុងអំឡុងពេល ៦ សប្តាហ៍ដំបូងនៃជីវិត ។

*<u>ផ្អែកលើ៖</u> គោលការណ៍ណែនាំជាតិស្តីពីគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់មនុស្សពេញវ័យនិងយុវវ័យ, NCHADS ២០២០ ។*

**កំណត់សម្គាល់ ៖** អនុសាសន៍សម្រាប់ការចិញ្ចឹមទារក និងការតាមដានបន្តចំពោះទារកដែលប្រឈមនឹងមេរោគអេដស៍ មានពិពណ៌នាក្នុងជំពូកទី ៦ ។

**តារាងទី ៤ ៖ ដូស ARV សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍**

| **អាយុទារក**<br>**ពីកំណើតដល់ ៦ សប្តាហ៍**<br>(ទារកដែលបៅឬមិនបៅដោះម្តាយ ) | **ដូស NVP** | **ដូស AZT** |
|---|---|---|
| –ទម្ងន់ពីកំណើត៖<br>(2000–2499 ក្រាម) | 10 mg ម្តង/ថ្ងៃ<br>(1ml ស៊ីរ៉ូ ម្តង/ថ្ងៃ) | 10 mg ពីរដង/ថ្ងៃ<br>(1ml ស៊ីរ៉ូ ពីរដង/ថ្ងៃ) |
| –ទម្ងន់ពីកំណើត<br>( ≥2500g ) | 15 mg ម្តង/ថ្ងៃ<br>(1.5ml ស៊ីរ៉ូ ម្តង/ថ្ងៃ) | 15 mg ពីរដង/ថ្ងៃ<br>(1.5ml ស៊ីរ៉ូ ពីរដង/ថ្ងៃ) |

| | | |
|---|---|---|
| **ពី ៦ សប្តាហ៍ ទៅ ១២ សប្តាហ៍** (សម្រាប់ទារកដែលបៅដោះម្តាយដែលប្រឈមមុខខ្ពស់តែប៉ុណ្ណោះ) | 20 mg ម្តង/ថ្ងៃ (2ml ស៊ីរ៉ូ ម្តង/ថ្ងៃ ឬ ½ 50mg កន្លះគ្រាប់ ម្តង/ថ្ងៃ) | |

*Source: គោលការណ៍ណែនាំជាតិស្តីពីគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យ, NCHADS ២០២០ ។*

- សម្រាប់ទារកដែលមានទម្ងន់ <2000 ក្រាម និងអាយុលើស ៣៥ សប្តាហ៍ ដូសដែលបានណែនាំគឺ ៖ NVP 2mg/kg ក្នុងមួយដូស ម្តង/ថ្ងៃ និង Zidovudine (ZDV) 4mg/kg ក្នុងមួយដូស ម្តង/ថ្ងៃ ។
- ទារកដែលកើតមិនគ្រប់ខែ អាយុក្រោម ៣៥ សប្តាហ៍ គួរប្រើកម្រិតដូសតាមការណែនាំរបស់អ្នកជំនាញ ។

**តារាងទី ៥ ៖ សង្ខេបការព្យាបាលបង្ការដោយ ART សម្រាប់ម្តាយ និង ARV សម្រាប់ទារក**

| ម្តាយ | ស្ថានភាពហានិភ័យរបស់ទារកដែលប្រឈមនឹងមេរោគអេដស៍ | ស្ថានភាពចិញ្ចឹមទារក | Infant prophylaxis |
|---|---|---|---|
| **ចាប់ផ្តើមជាបន្ទាន់**<br>TDF +3TC + DTG *(ការរួមបញ្ចូលគ្នាតែមួយ)* ដោយមិនគិតពីដំណាក់កាលរបស់ WHO និងការរាប់ CD4 និងបន្តពេញមួយជីវិត | **ហានិភ័យខ្ពស់៖**<br>***-លក្ខណវិនិច្ឆ័យ៖***<br>*1- ម្តាយព្យាបាលដោយ ART រយៈពេលតិចជាង ៤ សប្តាហ៍ គិតត្រឹមថ្ងៃសម្រាល*<br>*ឬ*<br>*2- ម្តាយធ្វើតេស្តវិជ្ជមាននៅពេលសម្រាល ឬក្នុងអំឡុងពេលក្រោយសម្រាល។*<br>*ឬ*<br>3- ម្តាយមាន VL>1,000/ml ក្នុងអំឡុងពេល ៤ សប្តាហ៍នៃការសម្រាល | បៅទឹកដោះគោ | ពីរមុខ NVP* និង AZT រយៈពេល ៦ សប្តាហ៍ |
| | | បៅដោះម្តាយ | ពីរមុខ NVP* និង AZT រយៈពេល ៦ សប្តាហ៍ និងបន្តប្រើតែ NVP សម្រាប់រយៈពេល ៦ សប្តាហ៍ទៀត |
| | **ហានិភ័យទាប៖**<br>***-លក្ខណវិនិច្ឆ័យ៖*** មិនស្ថិតក្នុងលក្ខណវិនិច្ឆ័យដែលមានហានិភ័យខ្ពស់។ | បៅដោះ ឬបៅទឹកដោះគោ | NVP* រយៈពេល ៦ សប្តាហ៍ |

* ក្នុងករណីប្រតិកម្ម NVP, ចូរពិភាក្សាជាមួយគ្លីនិក ART

*ប្រភព៖ គោលការណ៍ណែនាំជាតិស្តីពីគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យ, NCHADS ២០២០ ។*

## 4.2. ការបង្ការការចម្លងពីម្តាយទៅកូននៃជំងឺស្វាយ

ជំងឺស្វាយរបស់ម្តាយដែលមិនបានព្យាបាល អាចបង្កផលប៉ះពាល់ដល់លទ្ធផលនៃការមានផ្ទៃពោះ ដូចជាការកើតស្លាប់ ឬការរលូតកូន (២១%), ការស្លាប់របស់ទារកទើបនឹងកើត (៩%), ទារកឆ្លងមេរោគស្វាយ (១៥%), ទារកកើតមិនគ្រប់ខែឬទម្ងន់ពីកំណើតទាប (៦%)[22] ។ ស្ត្រីដែលធ្វើតេស្តវិជ្ជមានចំពោះមេរោគស្វាយ គួរទទួលការព្យាបាលភ្លាមៗ និងជម្រាបប្រាប់ពីសារៈសំខាន់នៃការព្យាបាលសម្រាប់ខ្លួនពួកគេ, ដៃគូ និងទារករបស់ពួកគេ ។

នៅពេលដែលត្រូវបានផ្តល់ជូននៅដំណាក់កាលដំបូងនៃការមានផ្ទៃពោះ សូម្បីតែថ្នាំ benzathine penicillin តែមួយដូសគត់ ក៏អាចបង្ការការចម្លងមេរោគដល់ទារកក្នុងផ្ទៃចំពោះស្ត្រីដែលមានជំងឺស្វាយដែលមានរយៈពេលយូរ បានដែរ ។

### *4.2.1 ការព្យាបាលជំងឺស្វាយចំពោះម្តាយ ៖*

បន្ទាប់ពីបានផាត់ចេញអាឡែរស៊ីទៅនឹង ប៉េនីស៊ីលីន (penicillin) ការព្យាបាលត្រូវបានបង្ហាញនៅក្នុងតារាងទី ៦ ខាងក្រោម ។ Benzathine penicillin គួរតែ ផ្តល់ជូនឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីបានធ្វើតេស្តវិជ្ជមានដោយតេស្តរហ័ស លើកលែងតែធ្លាប់មានប្រវត្តិព្យាបាលពីមុនច្បាស់លាស់ (តេស្តរហ័សនឹងនៅតែវិជ្ជមាន សូម្បីតែបន្ទាប់ពីការឆ្លង មេរោគស្វាយត្រូវបានព្យាបាលរួចហើយក្តី) ។

ការព្យាបាលអាចត្រូវបានផ្តល់ជូននៅសេវាសម្ភពនៃមន្ទីរពេទ្យបង្អែកដែលនៅជិតបំផុត ។ គេមិនចាំបាច់ក្នុងការរង់ចាំតេស្ត *RPR* មុននឹងព្យាបាលនោះទេ ។ បន្ទាប់ពីព្យាបាលរួច សូមបញ្ជូនទៅគ្លីនិកសុខភាពគ្រួសារ (FHC) ដើម្បីធ្វើតេស្ត RPR ដើម្បីវាយតម្លៃការឆ្លើយតបទៅនឹងការព្យាបាល ។ *មានតែក្នុងករណីដែលស្ត្រីមានវិជ្ជមានដោយតេស្តរហ័ស និងធ្លាប់មានប្រវត្តិព្យាបាលយ៉ាងពេញលេញពីអតីតកាលប៉ុណ្ណោះ ដែលគួរពន្យារពេលការព្យាបាលដោយរង់ចាំតេស្ត RPR ។*

**រូបភាពទី ១ ៖ ការធ្វើតេស្តមេរោគស្វាយ និងយុទ្ធសាស្ត្រព្យាបាល**

---

[22] GOMEZ, et al.WHO Bulletin,2013




## តារាងទី ៦ ៖ ការព្យាបាលជំងឺស្វាយសម្រាប់ស្ត្រីមានផ្ទៃពោះ

| ជំងឺស្វាយ | ការព្យាបាលដែលបានណែនាំ | ជម្រើសជំនួស | ជម្រើសជំនួស សម្រាប់អាឡែរស៊ីប៉េនីស៊ីលីន (penicillin-allergic) |
|---|---|---|---|
| **ជំងឺស្វាយដំណាក់កាលថ្មីៗ** * ជំងឺស្វាយដំណាក់កាលទីមួយ, ទីពីរ និង សម្ងំដំបូង (**រយៈពេល** < 2 **ឆ្នាំ**) | Benzathine benzylpenicillin, 2.4 million IU មួយដង ដោយចាក់សាច់ដុំ, នៅពេលប្រើតែម្តងគត់។ ដោយសារបរិមាណចែកចេញជាការចាក់ពីរដង នៅត្រង់កន្លែងខុសគ្នា | Procaine benzylpenicillin, 1.2 million IU ដោយចាក់សាច់ដុំ, រាល់ថ្ងៃ រយៈពេល ១០ ថ្ងៃជាប់ៗគ្នា | Erythromycin, 500 mg លេប, 4 ដងក្នុងមួយថ្ងៃ រយៈពេល 14 ថ្ងៃ * * |
| **ជំងឺស្វាយដំណាក់កាលយូរ** * ការឆ្លងរយៈពេលលើសពីពីរឆ្នាំ | Benzathine benzylpenicillin, 2.4 million IU ដោយចាក់សាច់ដុំ, ម្តង រាល់សប្តាហ៍ រយៈពេល 3 សប្តាហ៍ជាប់គ្នា។ ដោយសារ | Procaine benzylpenicillin, 1.2 million IU ដោយចាក់សាច់ដុំ, ម្តង រាល់ថ្ងៃ រយៈពេល 20 ថ្ងៃជាប់ៗ | Erythromycin, 500 mg លេប, 4 ដង រាល់ថ្ងៃ រយៈពេល 30 ថ្ងៃ * * ឬ |

| | | | |
|---|---|---|---|
| (សម្ងំយូរ និងដំណាក់កាលទីបី)<br>ឬ មិនដឹងរយៈពេល | តែពាក់ព័ន្ធនឹងបរិមាណ, ត្រូវបែងចែកដូសនីមួយៗជាការចាក់ពីរដងនៅត្រង់កន្លែងផ្សេងគ្នា | គ្នា | Ceftriaxone 1 g IMម្តង រាល់ថ្ងៃ រយៈពេល 10–14 ថ្ងៃ*** |
| **ជំងឺស្វាយដែលប៉ះពាល់ដល់សរសៃប្រសាទ (Neurosyphilis) និង ជំងឺស្វាយប៉ះពាល់ភ្នែក (Ocular syphilis)** | Aqueous crystalline penicillin G, 18–24 million IU ដោយចាក់សាច់ដុំ រាល់ថ្ងៃ ក្នុងដូស 3–4 million units IV រៀងរាល់ 4 ម៉ោងម្តង ឬ ដាក់សេរ៉ូមជាបន្តរយៈពេល 10- 14 ថ្ងៃ | Procaine penicillin G 2.4 million units IM មួយដង រាល់ថ្ងៃ បូក probenecid 500 mg, លេប បួនដងក្នុងមួយថ្ងៃ, ទាំងពីរ សម្រាប់ 10-14 ថ្ងៃ | |

*ប្រភព៖ គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងករណីជំងឺកាមរោគនិងជំងឺឆ្លងតាមផ្លូវបន្តពូជ, NCHADS មិថុនា ២០១៩*

* ក្នុងករណី មិនអាចកំណត់រយៈពេលនៃការឆ្លង, ចូរព្យាបាលជា "ជំងឺស្វាយដំណាក់កាលយូរ" ("Late Syphilis") ។

** Erythromycin មិនឆ្លងកាត់របាំងសុកទេ ដូច្នេះ ក្នុងករណីដែលម្តាយត្រូវបានព្យាបាលដោយ erythromycin ទារកក៏ត្រូវព្យាបាលដោយពេញលេញសម្រាប់ជំងឺស្វាយពីកំណើតនៅពេលកើតដែរ ។

*** ទោះបីជា ceftriaxone ឆ្លងកាត់របាំងសុកស្តី មិនមានភស្តុតាងគ្រប់គ្រាន់ដើម្បីកំណត់ថាតើថ្នាំនេះព្យាបាលទារកក្នុងផ្ទៃដោយប្រសិទ្ធភាពឬទេ ដូច្នេះ ប្រសិនបើ ceftriaxone ត្រូវបានគេប្រើដើម្បីព្យាបាលម្តាយ ទារកត្រូវតែព្យាបាលឱ្យបានពេញលេញសម្រាប់ជំងឺស្វាយពីកំណើតនៅពេលកើតដែរ ។

*4.2.2. ការព្យាបាលជំងឺស្វាយសម្រាប់ដៃគូ ៖*

ដៃគូរបស់ស្ត្រីដែលត្រូវបានព្យាបាលជំងឺស្វាយក្នុងពេលមានផ្ទៃពោះ គួរត្រូវបានព្យាបាលដោយសន្មត ដើម្បីបង្ការការចម្លងឡើងវិញចំពោះស្ត្រីមានផ្ទៃពោះ ។ ការធ្វើតេស្តដៃគូជាមុនមិនមែនជាការចាំបាច់ទេ ។ ដៃគូអាចត្រូវបានព្យាបាលនៅមូលដ្ឋានសុខាភិបាលពេលតែមួយនឹងព្យាបាលស្ត្រីមានផ្ទៃពោះ និងគួរត្រូវបានព្យាបាលដោយពិធីសារដូចគ្នានឹងស្ត្រីនោះដែរ ។

*4.2.3 ការប្រើ Benzathine ឬ Procaine Penicillin:*

1. **សាកសួរប្រវត្តិ ៖** សួរស្ត្រីតើនាងធ្លាប់មានប្រតិកម្មអាឡែរស៊ីឬទេ (កន្ទួល, រមាស់, ការអេះដាច់រលាត់, ការហើមមុខឬដៃនិងជើង) បន្ទាប់ពីប្រើថ្នាំ penicillin, ampicillin, amoxicillin, augmentin

(amoxicillin/clavulonate) ឬ dicloxacillin ។ ប្រសិនបើមានដូសទីពីរឬបី សួរថាតើនាងមានកន្ទួលក្រោយពីប្រើដូសពីមុនទាំងនោះឬទេ ។

ប្រសិនបើនាងមានកន្ទួល កុំប្រើការព្យាបាលជួរទីមួយ ។ ត្រូវប្រើការព្យាបាលជម្រើសផ្សេងដូចមានរៀបរាប់ក្នុងតារាងទី ៦ ។

- ✓ ប្រតិកម្មអាឡែរស៊ីមិនដូចគ្នានឹងផលរំខានទេ ។ ប្រសិនបើស្ត្រីរាយការណ៍បញ្ហា ដូចជា ចង្អោរ/ក្អួត រាករូស ធ្លាក់ស ឈឺក្បាល ។ល។ វាមិនមែនជាសញ្ញានៃអាឡែរស៊ីទេ ហើយនាងអាចព្យាបាលដោយថ្នាំប៉េនីស៊ីលីន បាន ។
- ✓ Penicillin គឺជាឱសថតែមួយគត់ដែលអាចព្យាបាលទារក ក៏ដូចជាម្តាយបាន ដូច្នេះ គេគួរប្រើថ្នាំនេះនៅពេលណាដែលអាចធ្វើទៅបាន ។ ការព្យាបាលក្រៅពីនេះ គឺបានសម្រាប់តែម្តាយប៉ុណ្ណោះ ប៉ុន្តែមិនអាចព្យាបាលទារកនោះទេ ហើយទារកនៅតែអាចនៅតែអាចកើតស្លាប់ ឬកើតមកដោយមានរោគស្វាយពីកំណើត ។ ដូច្នេះ *គេមិនគួរជៀសវាង penicillin នោះទេ លើកលែងតែមានហេតុផលខ្លាំងក្លាណាមួយដែលត្រូវគិតថាស្ត្រីមានអាឡែរស៊ីទៅនឹងថ្នាំនេះ ។*

**2. រៀបចំដូចខាងក្រោមជាស្រេច មុនពេលផ្តល់ថ្នាំ penicillin:**

- ✓ អាដ្រេណាលីន Adrenaline (epinephrine) **1:1000**
- ✓ សឺរ៉ាំង 1 ml និងម្ជុលលេខ 23G
- ✓ កាតេទែរសេរ៉ូម និងសូលុយស្យុងសេរ៉ូមសាលីនធម្មតា

គេមិនចាំបាច់បូម adrenaline ចូលទៅក្នុងសឺរ៉ាំងនោះទេ ព្រោះវាកម្រនឹងត្រូវការប្រើណាស់ ប៉ុន្តែត្រូវត្រៀមដបថ្នាំនេះ, ម្ជុល និងសឺរ៉ាំង នៅក្បែរខ្លួនជាស្រេចសម្រាប់ការប្រើពេលត្រូវការបន្ទាន់ ។ គេក៏មិនចាំបាច់ក្នុងការចាប់ផ្តើមដាក់សេរ៉ូមដែរ ប៉ុន្តែគួររៀបចំសម្ភារជាស្រេចនៅក្បែរដៃ ក្នុងករណីត្រូវការសង្គ្រោះបន្ទាន់ ។

3. **លាយ** the BPG ជាមួយទឹកស្ទេរីល (ប្រហែល 4 ml) ។ ក្រឡុកឱ្យសព្វ ។

- ✓ កុំលាយ រហូតដល់ពេលអ្នកត្រូវចាក់ ពីព្រោះថ្នាំដែលលាយរួចត្រូវតែប្រើក្នុងអំឡុងពេល ២៤ ម៉ោង ។

**4. បូមចូលក្នុង ២ សឺរ៉ាំង** ដោយប្រើម្ជុលលេខ 19 ឬ 20 (1/2 ទៅក្នុងសឺរ៉ាំងនីមួយៗ) ។

- ✓ បរិមាណគឺច្រើនពេកសម្រាប់ចាក់ចូលមួយកន្លែង ដូច្នេះ ត្រូវចាក់ពីរដងសម្រាប់ដូសនីមួយៗ ។
- ✓ ល្បាយថ្នាំនេះមានលក្ខណៈខាប់ ដូច្នេះ គេត្រូវការម្ជុលលេខធំ ។

**5. ចាក់សឺរ៉ាំងនីមួយទៅក្នុងសាច់ដុំត្រគាក** (មួយភាគបួនផ្នែកខាងលើ) នៅសងខាង -- ២ ម្ជុល, មួយសឺរ៉ាំងប្រមាណ 1.4 mill unit, ចូលទៅក្នុងកំប៉េះគូទខាងស្តាំងនិងខាងឆ្វេង ។

- ✓ ការចាក់ត្រូវតែឱ្យជ្រៅចូលទៅក្នុងសាច់ដុំ ។ មិនអាចចាក់ក្រោមស្បែកនោះឡើយ ពីព្រោះវាធ្វើឱ្យលោកជាលិកា ។
- ✓ ក្នុងករណីស្ត្រីស្គមខ្លាំង ប្រសិនបើសាច់ដុំត្រគាកតូចពេក អ្នកអាចប្រើសាច់ដុំភ្លៅ បើវាធំជាង ។
- ✓ ជានិច្ចជាកាល ត្រូវបូមម្ជុលបន្តិចមុនពេលចាក់ ដើម្បីឱ្យប្រាកដថា អ្នកមិនចាក់ចំសរសៃឈាមដោយច្រឡំ។ ថ្នាំនេះសម្រាប់ប្រើចាក់តែសាច់ដុំទេ មិនមែនសរសៃវ៉ែនទេ ។
- ✓ កុំម៉ាស្សាក្រោយពេលចាក់រួច ។
- ✓ ដោយសារម្ជុលមានទំហំធំ ហើយបរិមាណថ្នាំចាក់ច្រើន អាចនឹងមានការឈឺចាប់នៅកន្លែងចាក់ក្រោយមកទៀត ។ ប្រសិនបើឈឺ ស្អំទឹកកក ។

6. **សង្កេតមើលស្ត្រីរយៈពេលយ៉ាងតិចមួយម៉ោង** មុនពេលឱ្យគាត់ទៅផ្ទះ ។

7. **កត់ត្រា** ការព្យាបាលដែលបានផ្តល់ និងថ្ងៃខែឆ្នាំនៅលើប័ណ្ណសុខភាពម្តាយ ។

8. **ផ្តល់សេចក្តីណែនាំមុនពេលចេញពីពេទ្យ ៖**

- ✓ ប្រាប់ស្ត្រីថា នាងអាចនឹងមានគ្រុនក្តៅ, ញាក់, មិនស្រួលខ្លួន និងឈឺក្បាលក្នុងរយៈពេល ២៤ ម៉ោងបន្ទាប់ ស្រដៀងនឹងជំងឺផ្តាសាយដែរ ។ ជាធម្មតា វាកើតឡើងរយៈពេលតែពីរបីម៉ោងប៉ុណ្ណោះ ហើយមិនមែនជាសញ្ញានៃអាឡែរស៊ីទេ ។ វាបណ្តាលមកពីបាក់តេរីជំងឺស្វាយបញ្ចេញជាតិពុលនៅពេលវាស្លាប់ ។ ប្រសិនបើបញ្ហានេះកើតឡើង ស្ត្រីគួរប្រើថ្នាំប៉ារ៉ាសេតាមុល ហើយកុំបារម្ភ ។
- ✓ អាចមានការឈឺចាប់ខ្លះនិងហើមនៅកន្លែងចាក់ផងដែរ ។ ប្រសិនបើមានបញ្ហាបែបនេះ សូមស្អំទឹកកក ។
- ✓ ជម្រាប់ដល់ស្ត្រី ពីពេលវេលាដែលត្រូវវិលត្រឡប់មកវិញ (ប្រសិនបើត្រូវការ ៣ ដូស) ។
- ✓ ប្រសិនបើដៃគូស្ត្រីមិនបានរួមដំណើរមកជាមួយស្ត្រីទេ ចូរពន្យល់ពីសារៈសំខាន់នៃការឱ្យគាត់មកព្យាបាល ។
- ✓ ប្រសិនបើស្ត្រីមានផ្ទៃពោះ ៦ ខែឬលើសពីនេះ ត្រូវប្រាប់នាងថា នាងគួរតែសម្រាលកូននៅមន្ទីរពេទ្យ ។ ប្រសិនបើទារកកើតក្នុងរយៈពេល 30 ថ្ងៃឬតិចជាង គិតចាប់ពីថ្ងៃដែលម្តាយបានទទួលការព្យាបាល ជាការចាំបាច់ដែលត្រូវឱ្យទារកគេងពេទ្យភ្លាមៗ ដើម្បីទទួលការព្យាបាលជំងឺស្វាយពីកំណើតដោយសន្មត (សូមមើលផ្នែកទី 4.2.5) ។ ការព្យាបាលនេះគឺមិនចាំបាច់ទេ ប្រសិនបើការព្យាបាលត្រូវបានផ្តល់ជូនយ៉ាងឆាប់ក្នុងពេលមានផ្ទៃពោះ ។

### *4.2.4 ប្រតិកម្មអាឡែរស៊ីចំពោះ Penicillin*

ប្រភេទប្រតិកម្មអាឡែរស៊ីដែលធ្ងន់ធ្ងរបំផុត គឺអាណាហ្វីឡាក់ទិក ។ អ្វីដែលល្អ គឺប្រតិកម្មបែបនេះកម្រកើតមានណាស់ ។ ប្រតិកម្មអាណាហ្វីឡាក់ទិក នឹងកើតមានភ្លាមៗបន្ទាប់ពីចាក់រួច ជាញឹកញាប់ គឺក្នុងរយៈ

ពេលពីរបីនាទីក្រោយពេលចាក់ ។ ដូច្នេះហើយបានជាគេត្រូវធ្វើការសង្កេតមើលស្ត្រី រយៈពេលមួយម៉ោងសិនក្រោយពេលចាក់រួច ។

ប្រអប់ទី ៦ ៖ ការពិនិត្យរកនិងការគ្រប់គ្រងប្រតិកម្មអាណាហ្វីឡាក់ទិកចំពោះថ្នាំ Penicillin

**សញ្ញានៃប្រតិកម្មអាណាហ្វីឡាក់ទិក ៖**

- ដង្ហើមញាប់ឮសូរខ្លាំង – ពិបាកដកដង្ហើម
- ហើម – ហើមមុខ, បបូរមាត់ ឬអណ្តាត
- ពណ៌ស្វាយ – បបូរមាត់និងម្រាមដៃស្វាយ
- ជីពចរញាប់
- សម្ពាធឈាមទាប (អ្នកជំងឺអាចត្អូញរិលមុខ ឬសន្លប់)
- កន្ទួល – រមាស់,ចាប់ផ្តើមរហ័ស អាចពាក់ព័ន្ធជាមួយសញ្ញាខាងលើ

**ការគ្រប់គ្រងប្រតិកម្មអាណាហ្វីឡាក់ទិក ៖ *អន្តរាគមន៍ដោយរហ័ស*** ដោយហេតុថា បញ្ហានេះអាចវិវឌ្ឍយ៉ាងរហ័សទៅជាស្ទះដង្ហើម ឬគាំងបេះដូង ។

- ✓ ចាក់អាដ្រេណាលីន (adrenaline) 0.5 ml *ភ្លាមៗ* តាមសាច់ដុំជ្រៅ (សាច់ដុំណាក៏បាន) ។ ចាក់ឡើងវិញរៀងរាល់ ៥ នាទីម្តង រហូតដល់ស្ថានភាពប្រសើរឡើងវិញ ។
- ✓ ដាក់អុកស៊ីសែន ។
- ✓ ដាក់សេរ៉ូមសាលីនធម្មតា ។
- ✓ តាមដានមើលបំពង់ខ្យល់ និងសញ្ញាជីវិត ។
- ✓ ប្រសិនបើសម្ពាធឈាមចុះ ចូរដាក់បញ្ចូលសេរ៉ូមសាលីនធម្មតារហ័ស ។
- ✓ ប្រសិនបើអ្នកជំងឺមិនមានភាពប្រសើររហ័សទេ អាចចាំបាច់ត្រូវប្រើ corticosteroids តាមសរសៃវ៉ែន និង H-1 antagonist antihistamines (loratadine, cetirizine)
- ✓ បញ្ជូនអ្នកជំងឺទៅកាន់ ICU ដើម្បីទទួលការគ្រប់គ្រងនិងសង្កេតមើលបន្ថែមទៀត ។

ទោះបីជាប្រតិកម្មអាណាហ្វីឡាក់ទិកមានលក្ខណៈធ្ងន់ធ្ងរខ្លាំងក៏ដោយ ក៏វាកម្រកើតមានណាស់ ហើយជាធម្មតា វាបាត់ទៅវិញប្រសិនបើមានការព្យាបាលទាន់ពេលវេលា ។ អ្នកជំងឺអាចធូរស្បើយក្នុងរយៈពេលដ៏ខ្លី បន្ទាប់ពីបានទទួល epinephrine ។ ទោះជាយ៉ាងណាក៏ដោយ អ្នកជំងឺគួរត្រូវបានបញ្ជូនទៅមន្ទីរពេទ្យសម្រាប់រយៈពេលយ៉ាងហោចណាស់ ២៤ ម៉ោង ដើម្បីតាមដានមើលឱ្យបានជិតដល់ ។

**ប្រតិកម្មអាឡែរស៊ីយឺត ៖** ជួនកាល អ្នកជំងឺមានប្រតិកម្មអាឡែរស៊ីបន្តិចបន្តួចក្នុងរយៈពេលប៉ុន្មានថ្ងៃក្រោយមកទៀត ។ ជាធម្មតានេះ ប្រតិកម្មបែបនេះមានចេញកន្ទួល ហើយជួនកាលកន្ទាលត្រអាក ដែលអាចរមាស់ ។ ប្រសិនបើបញ្ហានេះកើតឡើង ៖

- កុំឱ្យថ្នាំប៉េនីស៊ីលីន (penicillin) ថែមទៀត ។ ប្រសិនបើស្ត្រីមិនទាន់បានបញ្ចប់ការព្យាបាលជំងឺស្វាយនៅឡើយទេ សូមប្រើ អេរីត្រូម៉ីស៊ីន (erythromycin) ឬថ្នាំ ceftriaxone ដើម្បីបញ្ចប់ការព្យាបាល (សូមមើលតារាងទី ៦) ។
- ណែនាំស្ត្រីថា នាងមានអាឡែរស៊ីទៅនឹងប៉េនីស៊ីលីន ហើយមិនប្រើថ្នាំនេះឬថ្នាំដែលពាក់ព័ន្ធ ដូចជា ampicillin/amoxicillin នោះទេ សូម្បីតែប្រើតាមមាត់ក៏ដោយ ហើយគួរតែប្រាប់បញ្ហានេះដល់គ្រូពេទ្យដែលព្យាបាលនាងនៅពេលអនាគត ។
- ថ្នាំ Antihistamines ដូចជា diphenhydramine ឬ chlorpheniramine អាចជួយបន្ថយរោគសញ្ញា ។ ប្រសិនបើរោគសញ្ញាបង្កបញ្ហាយ៉ាងខ្លាំង ជួនកាល គេអាចពិចារណាឱ្យថ្នាំស្តេរ៉ូអ៊ីត តាមមាត់សម្រាប់រយៈពេលខ្លី ។

### *4.2.5 ការព្យាបាលជំងឺស្វាយសម្រាប់ទារក ៖*

ពិធីសារនៃការព្យាបាលសម្រាប់ទារកដែលប្រឈមនឹងមេរោគស្វាយ គឺអាស្រ័យទៅលើការព្យាបាលដែលម្តាយបានទទួលអំឡុងពេលមានផ្ទៃពោះ និងបានទទួលពីពេលណាមក ដូចខាងក្រោម ៖

- ប្រសិនបើម្តាយបានទទួលការព្យាបាលពេញលេញជាមួយថ្នាំប៉េនីស៊ីលីន (benzathine ឬ procaine) ហើយបានបញ្ចប់រយៈពេល ៣០ ថ្ងៃឡើងទៅ មុនពេលសម្រាលកូន គេគួរធ្វើការតាមដានមើលទារកឱ្យបានជិតដល់ ប៉ុន្តែមិនត្រូវការការព្យាបាលភ្លាមៗទេ លើកលែងតែមានរោគសញ្ញាគ្លីនិកនៃជំងឺស្វាយ ។

- ក្នុងករណីផ្សេងទៀត ព្យាបាលទារកដោយប្រើថ្នាំ aqueous benzylpenicillin 100 000–150 000 IU/kg/day តាមសរសៃវ៉ែន ដោយចែកជា ២ ដូស រៀងរាល់ ១២ ម៉ោងម្តងសម្រាប់រយៈពេលសរុប ១០-១៥ ថ្ងៃ ។ ប្រសិនបើមិនអាចព្យាបាលតាមសរសៃវ៉ែនទេ, Procaine benzylpenicillin 50 000 IU / kg ដោយចាក់តាមសាច់ដុំ អាចត្រូវបានផ្តល់ជាដូសប្រចាំថ្ងៃតែមួយដងគត់ រយៈពេល ១០-៥ ថ្ងៃ ។ *ទារកទើបនឹងកើតមិនប្រឈមនឹងអាឡែរស៊ីចំពោះ penicillin ទេ ដោយសារតែប្រព័ន្ធភាពស៊ាំរបស់ពួកគេមិនទាន់ពេញវ័យ ។*

- វិធីនេះត្រូវបានអនុវត្តចំពោះករណីដែលម្តាយមិនត្រូវបានព្យាបាលអំឡុងពេលមានផ្ទៃពោះ ឬត្រូវបានព្យាបាលដោយមិនពេញលេញ ឬម្តាយត្រូវបានព្យាបាលពេញលេញ ប៉ុន្តែការព្យាបាលនេះគឺ ៣០ ថ្ងៃឬតិចជាងនេះ មុនពេលសម្រាលកូន ឬម្តាយត្រូវបានព្យាបាលដោយថ្នាំក្រៅពីថ្នាំប៉េនីស៊ីលីន ។

•បើគ្មានកំណត់ត្រាច្បាស់លាស់ដែលបង្ហាញថា ម្តាយបានទទួលការព្យាបាលពេញលេញជាមួយ benzathine ឬ procaine benzylpenicillin រយៈពេលច្រើនជាង ៣០ ថ្ងៃមុនពេលសម្រាលកូន ត្រូវសន្មតថា ការព្យាបាលមិនត្រូវបានផ្តល់ ឬមិនពេញលេញ ហើយព្យាបាលទារកទៅតាមនោះ ។

•ការសម្រាកព្យាបាលនៅមន្ទីរពេទ្យនៅផ្នែកជំងឺកុមារ គឺជាការចាំបាច់ប្រសិនបើដូសត្រូវបានផ្តល់ឱ្យតាមសរសៃវ៉ែន ។ ដូសតាមសាច់ដុំ អាចត្រូវបានផ្តល់សម្រាប់អ្នកជំងឺក្រៅ ប្រសិនបើគេប្រាកដថា ម្តាយពិតជាអាចនាំទារកមករៀងរាល់ថ្ងៃ រយៈពេលយ៉ាងហោចណាស់ 10 ថ្ងៃ ។

•គេគួរឱ្យដូសដំបូងឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ក្រោយពេលកើត ជាពិសេស នៅក្នុងបន្ទប់សម្រាល ។

•ក្នុងករណីដែលស្ថានភាពមេរោគស្វាយរបស់ម្តាយ ត្រូវបានរកឃើញតែនៅពេលសម្រាលកូន, ការព្យាបាលដូសលើកដំបូងសម្រាប់ទាំងម្តាយនិងទារក គួរតែត្រូវបានផ្តល់ជូនភ្លាមៗ ដោយផ្អែកលើការធ្វើតេស្តរហ័ស ។ គេមិនចាំបាច់រង់ចាំ RPR ដើម្បីព្យាបាលម្តាយនិងទារកនោះទេ លើកលែងតែម្តាយមានប្រវត្តិច្បាស់លាស់នៃការព្យាបាលជំងឺស្វាយពីមុនមក ។

**តារាងទី ៧ ៖ ការព្យាបាលសម្រាប់ទារកដែលប្រឈមនឹងមេរោគស្វាយ**

| ការណែនាំ | ជម្រើសទីមួយ | ជម្រើសជំនួស |
|---|---|---|
| ទារកទាំងអស់ដែលកើតពីម្តាយដែល៖<br>• មានជំងឺស្វាយដោយមិនបានព្យាបាល<br>• ជំងឺស្វាយដែលបានព្យាបាលតែមិនគ្រប់គ្រាន់/មិនចប់សព្វគ្រប់<br>• ជំងឺស្វាយបានព្យាបាលដោយថ្នាំផ្សេងក្រៅពី penicillin<br>• ជំងឺស្វាយដែលបានព្យាបាលតិចជាង ៣០ ថ្ងៃ មុនពេលសម្រាលកូន | Aqueous Benzyl Penicillin 100,000-150,000 Unit/គក/ថ្ងៃ តាមសរសៃ ចែកជា ២ ដូស ១២ ម៉ោងម្តង រយៈពេល ១០-១៥ ថ្ងៃ | Procaine Penicillin 50,000 units/គក/ថ្ងៃ ដូសតែមួយគត់ តាមសាច់ដុំ សម្រាប់រយៈពេល ១០-១៥ ថ្ងៃ |

*<u>ប្រភព:</u> គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងករណីជំងឺកាមរោគនិងជំងឺឆ្លងតាមផ្លូវបន្តពូជ, NCHADS មិថុនា ២០១៩*

4.3 ការបង្ការការចម្លងពីម្តាយទៅកូននៃជំងឺរលាកថ្លើមប្រភេទបេ

តេស្តទាំងឡាយខាងក្រោមនេះត្រូវធ្វើឡើងដើម្បីកំណត់ថា តើស្ត្រីមានហានិភ័យខ្ពស់ចំពោះការចម្លងជុំវិញការសម្រាលឬទេ ហើយត្រូវការការព្យាបាលដោយថ្នាំប្រឆាំងវីរុស ដើម្បីបង្ការការចម្លងមេរោគរលាកថ្លើមប្រភេទបេ ទៅទារក ។

- បន្ទុកមេរោគ DNA ឬ
- HBeAg និង ALT

ស្ត្រីដែលធ្វើតេស្តវិជ្ជមានចំពោះ HBV surface antigen (HBsAg) ដោយតេស្តរហ័ស គួរបញ្ជូនទៅមន្ទីរពេទ្យ, ឬមន្ទីរពេទ្យបង្អែកដែលមានសមត្ថភាពធ្វើបន្ទុកវីរុស DNA ឬ តេស្តរហ័សសម្រាប់ HBV "e" antigen (HBeAg) ។

ស្ត្រីទាំងអស់គួរត្រូវបានពិនិត្យរាងកាយ ដើម្បីចង់ដឹងថា តើពួកគេមានថ្លើមឬអណ្តើករីកធំ ឬមានទឹកក្នុងស្រោមពោះ ។ គេអាចស្នើសុំតេស្តបន្ថែមទៀត ដូចជា ការរាប់គ្រាប់ឈាមពេញលេញ (អេម៉ូក្រាម) ដែលមានប្លាកែត, AST និង ក្រេអាទីនីន ។ ពិន្ទុ APRI ត្រូវបានគណនាចេញពី AST: ផលធៀបប្លាកែត ។ កម្រិតលើសពី ២ បង្ហាញពីជំងឺក្រិនថ្លើមដែលអាចកើតមាន និងតម្រូវការចាំបាច់ក្នុងការព្យាបាលជាបន្ទាន់ និងពេញមួយជីវិតដើម្បីការពារសុខភាពរបស់ស្ត្រីនិងទារក ។

## ការព្យាបាលម្តាយ ៖

ស្ត្រីដែលមានបន្ទុកមេរោគ HBV DNA ≥ 200,000 IU/ml មានការប្រឈមនឹងការចម្លង ហើយគួរចាប់ផ្តើមការព្យាបាលដោយថ្នាំប្រឆាំងវីរុសនៅអាយុគភ៌ ២៤ – ២៨ សប្តាហ៍, បន្តរហូតដល់ការសម្រាល ហើយបន្ទាប់មក វាយតម្លៃឡើងវិញ ។

នៅពេលមិនមានការធ្វើតេស្តបន្ទុកមេរោគ (VL) គេអាចធ្វើតេស្តរហ័សសម្រាប់ HB"e" antigen ជាវិធីជំនួសសម្រាប់បន្ទុកមេរោគ ។ រាល់ស្ត្រីដែលមានផ្ទៃពោះវិជ្ជមាន HBeAg ទាំងអស់ ត្រូវបានសន្មតថា មានបន្ទុកមេរោគខ្ពស់ ហើយគួរតែចាប់ផ្តើមការព្យាបាលដោយថ្នាំប្រឆាំងវីរុសនៅអាយុគភ៌ ២៤ ទៅ ២៨ សប្តាហ៍ ហើយបន្តរហូតដល់ក្រោយពេលសម្រាល ហើយបន្ទាប់មក ត្រូវវាយតម្លៃឡើងវិញ ។

ស្ត្រីមានផ្ទៃពោះអវិជ្ជមាន HBeAg ដែលមាន ALT> 40 ក៏ត្រូវបានសន្មតថា មានបន្ទុកវីរុសខ្ពស់ដែរ ហើយគួរតែចាប់ផ្តើមព្យាបាលដោយថ្នាំប្រឆាំងវីរុសនៅអាយុគភ៌ ២៤ ទៅ ២៨ សប្តាហ៍ ហើយបន្តរហូតដល់ក្រោយពេលសម្រាល បន្ទាប់មក វាយតម្លៃម្តងទៀត ។

ស្ត្រីមានផ្ទៃពោះអវិជ្ជមាន HBeAg ដែលមាន ALT ធម្មតា មិនត្រូវការឱសថសម្រាប់ PMTCT ទេ ប៉ុន្តែ ALT របស់ពួកគេ គួរត្រូវបានធ្វើការតាមដានរៀងរាល់ ៣ ខែម្តង ក្នុងអំឡុងពេលមានផ្ទៃពោះ និងចាប់ផ្តើមប្រើថ្នាំប្រឆាំងវីរុស ប្រសិនបើ ALT កើនឡើងលើសពី ៤០ និងបន្តរហូតដល់ក្រោយពេលសម្រាល បន្ទាប់មក ត្រូវធ្វើការវាយតម្លៃឡើងវិញ ។

*ការព្យាបាលដោយថ្នាំប្រឆាំងវីរុសសម្រាប់ស្ត្រីមានផ្ទៃពោះ ដែលមានជំងឺរលាកថ្លើមប្រភេទបេរ៉ាំរ៉ៃ* នៅពេលណែនាំឱ្យប្រើយោងតាមលក្ខណវិនិច្ឆ័យខាងលើ គឺ Tenofovir (TDF) 300 mg មួយដងក្នុងមួយថ្ងៃ ។

ស្ត្រីដែលប្រើ ART សម្រាប់មេរោគអេដស៍រួចទៅហើយ មិនត្រូវការការព្យាបាលបន្ថែមទៀតក្នុងអំឡុងពេលមានផ្ទៃពោះនោះទេ ប្រសិនបើរូបមន្ត ART របស់ពួកគេ រួមបញ្ចូល Tenofovir ។ បើមិនដូច្នោះទេ សូមពិគ្រោះជាមួយគ្លីនិក ART ។

*ក្រោយពេលសម្រាលកូន ៖* ស្ត្រីដែលប្រើថ្នាំ Tenofovir ដើម្បីការពារការចម្លងពីម្តាយទៅកូននៃ HBV គួរទទួលការវាយតម្លៃមុខងារថ្លើមរបស់ពួកគេក្រោយពេលសម្រាល មុនពេលបញ្ឈប់ការប្រើថ្នាំ ។ អ្នកដែលមានរោគសញ្ញាគ្លីនិកក្រិនថ្លើម ឬ ពិន្ទុ APRI > ២ ឬ ALT កើនឡើងជាប្រចាំ (កើនឡើង ២ កម្រិត រយៈពេលយ៉ាងតិច ៣ ខែ) ត្រូវការការព្យាបាលដោយឱសថប្រឆាំងវីរុសពេញមួយជីវិតដើម្បីសុខភាពខ្លួនឯង, ដើម្បីកាត់បន្ថយហានិភ័យនៃការខូចថ្លើម ឬមហារីកថ្លើម នៅពេលក្រោយមកទៀត ។ អ្នកដែលមាន ALT ធម្មតា, មិនមានរោគសញ្ញាគ្លីនិកក្រិនថ្លើម និងពិន្ទុ APRI < 2 អាចបញ្ឈប់ការប្រើថ្នាំក្រោយពេលសម្រាល ប៉ុន្តែត្រូវតែទៅពិនិត្យតាមដានជាប្រចាំ (រៀងរាល់ ៦ ខែម្តង ឬតាមការណែនាំរបស់គ្រូពេទ្យ) ដោយហេតុថា ពួកគេអាចនឹងត្រូវចាប់ផ្តើមព្យាបាលនៅពេលក្រោយ ។ សម្រាប់ព័ត៌មានបន្ថែម សូមមើលគោលការណ៍ណែនាំរបស់ក្រសួងសុខាភិបាលកម្ពុជាស្តីពីការគ្រប់គ្រងព្យាបាល សម្រាប់ជំងឺរលាកថ្លើមប្រភេទបេដែលបង្កដោយវីរុស ឆ្នាំ ២០១៩ ។

## ការព្យាបាលទារកទើបនឹងកើត ៖

ទារកទាំងអស់ត្រូវការវ៉ាក់សាំង**ជំងឺរលាកថ្លើមប្រភេទបេ**មួយដូសនៅពេលកើតក្នុងរយៈពេល ២ ម៉ោងបន្ទាប់ពីសម្រាល ។ ក្នុងករណីទារកដែលម្តាយមានវិជ្ជមាន HBsAg គេចាំបាច់ត្រូវ**ផ្តល់ដូសថ្នាំបង្ការនេះ*ភ្លាមៗក្រោយពេលសម្រាលរួច*** ។ ស្ត្រីដែលវិជ្ជមាន HBsAg គួរត្រូវបានណែនាំឱ្យសម្រាលកូននៅអគារសម្ភពនៃមន្ទីរពេទ្យបង្អែក ហើយសេវាសម្ភពនៃមន្ទីរពេទ្យបង្អែក គួររក្សាវ៉ាក់សាំងរលាកថ្លើមប្រភេទបេក្នុងស្តុក ដើម្បីផ្តល់ជូនបានភ្លាមៗ ។

### តារាងទី ៨ ៖ ការព្យាបាលស្ត្រីមានផ្ទៃពោះ ដែលវិជ្ជមាន HBsAg

| របកគំហើញតេស្តផ្សេងទៀត | ការគ្រប់គ្រងក្នុងពេលមានផ្ទៃពោះ | ការគ្រប់គ្រងក្រោយពេលសម្រាល |
|---|---|---|
| DNA VL ≥200,000 IU/ml * <br> ឬ <br> វិជ្ជមាន HBeAg <br> ឬ <br> អវិជ្ជមាន HBeAg + ALT >40 | Tenofovir ( TDF ) 300 mg មួយថ្ងៃ: ចាប់ផ្តើមនៅអាយុ 24 – 28th សប្តាហ៍ក្រោយពេលសម្រាល | វាយតម្លៃតម្រូវការដើម្បីបន្ត TDF ។ តាមដានបន្តរៀងរាល់ ៦ ខែ ឬ តាមការណែនាំពីគ្រូពេទ្យ។ <br> ធ្វើតេស្តទារករក HBsAg នៅអាយុ ៧-១២ ខែ |
| DNA VL < 200,000 IU/ml * *OR* <br> HBeAg Negative + ALT≤40 | តាមដានកម្រិត ALT រៀងរាល់ ៣ ខែ ម្តង ។ ប្រសិនបើវាកើនឡើង >40 ព្យាបាលដូចខាងលើ | ការវាយតម្លៃតាមពេលកំណត់ ( កម្រិត ALT, ពិន្ទុ APRI, ពិនិត្យគ្លីនិក ) រៀងរាល់ ៦ ខែ ម្តង ឬតាមការណែនាំរបស់គ្រូពេទ្យ <br> តេស្តទារករក HBsAg នៅអាយុ ៧-១២ ខែ ។ |

* ប្រសិនបើមានតេស្ត IF DNA មិនចាំបាច់ធ្វើតេស្តរក HBeAg ទេ ។

*<u>ប្រភព</u> ៖(1) គោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងព្យាបាលជំងឺរលាកថ្លើមប្រភេទបេដែលបង្កដោយវីរុស, MoH 2019 និង (2) Segeral et. al. តេស្តរហ័ស HBeAg និង alanine aminotransferase level-based algorithm ដើម្បីកំណត់អត្តសញ្ញាណស្ត្រីមានផ្ទៃពោះដែលប្រឈមនឹងការចម្លងពីម្តាយទៅកូននៃមេរោគរលាកថ្លើម ៖ ការសិក្សា ANRS 12345 TA PROHM ។*

### ដៃគូ និងបុគ្គលប៉ះពាល់ផ្សេងទៀតនៅក្នុងគ្រួសារ ៖

ដៃគូនិងបុគ្គលប៉ះពាល់ជិតស្និទ្ធក្នុងគ្រួសារជិតស្និទ្ធផ្សេងទៀត គួរត្រូវបានពិនិត្យរក **HBsAg** ហើយចាក់វ៉ាក់សាំងប្រសិនបើអវិជ្ជមាន ។ ត្រូវតាមដាន/ព្យាបាលដៃគូ/សមាជិកគ្រួសារដែលឆ្លង យោងគោលការណ៍ណែនាំជាតិស្តីពីការព្យាបាលជំងឺរលាកថ្លើមប្រភេទបេ ប្រសិនបើវិជ្ជមាន ។

4.4. ផលរំខាននៃឱសថប្រឆាំងនឹងវីរុស ត្រូវបានប្រើប្រាស់ក្នុងពេលមានផ្ទៃពោះ និងស្ត្រីបំបៅដោះកូន

ស្ត្រីដែលកំពុងទទួលថ្នាំប្រឆាំងវីរុសសម្រាប់មេរោគអេដស៍ ឬ HBV ត្រូវបានប្រាប់អំពីផលរំខានដែលអាចកើតមាន ហើយត្រូវបានស្នើសុំឱ្យរាយការណ៍ទៅគ្លីនិក ART ឬគ្រូពេទ្យក្នុងករណីមានបញ្ហា ។ បុគ្គលិកផ្នែកសុខភាពមាតានិងទារក គួរដឹងអំពីផលរំខាននៃថ្នាំ ARV ហើយគួរតែបញ្ជូនស្ត្រីមានផ្ទៃពោះនិងស្ត្រីបំបៅដោះកូន ដែលពួកគេឃើញថាមានផលរំខានទៅកាន់គ្លីនិក ART ជាបន្ទាន់ ឬក្នុងករណី HBV គ្រូពេទ្យដែលគ្រប់គ្រងជំងឺរលាកថ្លើមរបស់ពួកគេជាអ្នកបញ្ជូន ។

ផលរំខានទូទៅបំផុតដែលទាក់ទងនឹងថ្នាំប្រឆាំងនឹងវីរុស គឺការចង់ក្អួត និងក្អួត ។ បញ្ហានេះកើតឡើងជាទូទៅ ជាពិសេសនៅពេលទើបចាប់ផ្តើម ART ថ្មី ហើយជារឿយៗ បានបាត់ទៅវិញក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយ ។ ផលរំខានដែលធ្ងន់ធ្ងរជាងនេះ ត្រូវបានរៀបរាប់ក្នុងតារាងទី ៩ ។ ស្ត្រីមានផ្ទៃពោះណាដែលប្រើ ART ដែលចេញរោគសញ្ញានៃការពុលទាំងនេះ គួរតែត្រូវបានបញ្ជូនទៅទីតាំង ART ជាបន្ទាន់ដើម្បីទទួលការគ្រប់គ្រងសមស្រប និងការប្តូរថ្នាំបើចាំបាច់ ។

### ការពុល ARV ចំពោះទារក ៖

- អាចនឹងមានហានិភ័យដោយការពុល NVP ប្រសិនបើម្តាយបានទទួលរូបមន្ត ART ដែលមាន NVP ក្នុងអំឡុងពេលបំបៅដោះកូន ( NVP អាចឆ្លងកាត់ខ្លះទៅដល់ទារកតាមរយៈទឹកដោះម្តាយ) ។ បញ្ហានេះទំនងជាមិនកើតឡើងទេ ដោយហេតុថា NVP កំពុងត្រូវបានដកចេញពីការប្រើប្រាស់នៅក្នុង ART នៅកម្ពុជា ។
- ជួនកាល AZT អាចបង្កឱ្យមានភាពស្លេកស្លាំង ប៉ុន្តែបើបញ្ហានេះកើតឡើង គេអាចគ្រប់គ្រងបាន ។

### 4.5. ការពិចារណាពិសេសអំពីសុវត្ថិភាពនៃ ART មុនពេលមានគភ៌

- មានរបាយការណ៍អំពីការកើនឡើងនូវហានិភ័យនៃបញ្ហាលលាដ៏ក្បាលនិងឆ្អឹងកងបិទមិនជិត ចំពោះស្ត្រីដែលប្រើថ្នាំ DTG នៅពេលមានផ្ទៃពោះ ។ របាយការណ៍នេះគឺមកពីប្រទេសមួយប៉ុណ្ណោះ ហើយរហូតមកដល់ពេលនេះ មិនមានការបញ្ជាក់ពីទិន្នន័យផ្សេងទៀតទេ ។ ការសិក្សាបន្ថែមទៀងកំពុងដំណើរការ ។ ស្ត្រីផ្ទុកមេរោគអេដស៍ ដែលមានបំណងចង់បានកូន គួរតែត្រូវបានណែនាំអំពីហានិភ័យ និងអត្ថប្រយោជន៍ យោងទៅតាមព័ត៌មានថ្មីៗបំផុតដែលមាននៅពេលនោះ និងទទួលបានការគាំទ្រក្នុងការសម្រេចចិត្តដោយផ្អែកលើព័ត៌មានដែលមាន ។ សូមមើលផ្នែកទី ៣.៣.១ សម្រាប់ការពិភាក្សាលម្អិតជាងនេះ និងឯកសារយោង ។

- ភ័ស្តុតាងបង្ហាញថា ស្ត្រីដែលប្រើ ART តាំងពីមុនមានផ្ទៃពោះ មានការប្រឈមកាន់តែខ្ពស់ចំពោះ ៖
  - ការសម្រាលកូនមិនគ្រប់ខែ
  - ទារកទម្ងន់ទាបពីកំណើត
  - ទារកកើតស្លាប់;
  - រលូតកូន និង
  - បញ្ហាឡើងសម្ពាធឈាមដោយសារផ្ទៃពោះ និងបម្រុងក្រឡាភ្លើង ។

- ទោះបីជាយ៉ាងណាក្តី ភាពធ្ងន់ធ្ងរនៃទារកកើតមិនគ្រប់ខែ និងទម្ងន់ទារកទាបពេលកើត ដែលទាក់ទងនឹងការប្រើ ART មុនពេលមានគភ៌ មិនត្រូវបានលើកឡើងនៅក្នុងឯកសារដែលមានកន្លងមកនោះទេ ។

- ដោយសារជំងឺលើសសម្ពាធឈាមដែលបណ្តាលមកពីការមានផ្ទៃពោះនិងជំងឺបម្រុងក្រឡាភ្លើង ត្រូវបានកំណត់ថា ជាកត្តាព្យាករណ៍កំណត់ពីលទ្ធផលអវិជ្ជមាននៃការមានផ្ទៃពោះ **ការពិនិត្យស្រាវជ្រាវរក និងគ្រប់គ្រងសកម្មនៃជំងឺលើសសម្ពាធឈាមដែលបណ្តាលមកពីការមានផ្ទៃពោះ គួរត្រូវបានផ្តល់អាទិភាពសម្រាប់ស្រ្តីដែលមានហានិភ័យខ្ពស់ រួមទាំងអ្នកដែលប្រើ** ART **និងជាពិសេសអ្នកដែលទទួល** ART **មុនពេលមានគភ៌ ។** សកម្មភាពទាំងនេះ រួមបញ្ចូលទាំងការពិនិត្យសម្ពាធឈាមនៅរាល់ពេលមកទទួលសេវា **ANC,** ការពិនិត្យទឹកនោមរកសារធាតុប្រូតេអ៊ីន និងការប្រាប់ដល់ស្រ្តីអំពីសញ្ញាគ្រោះថ្នាក់ ។ ប្រសិនបើសង្កេតឃើញមានជាតិប្រូតេអ៊ីនក្នុងទឹកនោម ឬជំងឺលើសសម្ពាធឈាម គេគួរធ្វើការគ្រប់គ្រងយោងតាមពិធីសារស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ ។

## តារាងទី ៩ ៖ ការពុលដែលទាក់ទងនឹង ARVs (បញ្ជូនទៅគ្លីនិក ART បើសង្ស័យ)[23]

| ថ្នាំ ARV | ភាពពុល | កត្តាហានិភ័យ | ការតាមដាន និងការគ្រប់គ្រង |
|---|---|---|---|
| AZT | ភាពស្លេកស្លាំងមូលដ្ឋាន ឬគ្រាប់ឈាមសណើត្រូហ្វីល ធ្លាក់ចុះ (neutropenia) | ភាពស្លេកស្លាំងមូលដ្ឋាន ឬគ្រាប់ឈាមស ធ្លាក់ចុះ | ជៀសវាង AZT បើ Hb<8g/dl<br>ពិនិត្យ Hb នៅ D0, M1, M3, និងក្រោយមកទៀត រៀងរាល់ ៦ ខែ ម្តង |
| | វិបត្តិសាច់ដុំ (Myopathy) | | មានរោគសញ្ញា, បើឈឺឬខ្សោយសាច់ដុំ ចូរពិនិត្យសេរ៉ូម CK |
| | កង្វះជាតិខ្លាញ់ក្រោមស្បែក (Lipoatrophy) | ART រយៈពេលវែង | រោគសញ្ញាថយចុះខ្លាញ់លើមុខ អវយវៈ កំប៉េះគូទ |
| AZT, TDF | វិបត្តិអាស៊ីដឡាក់ទិក (Lactic acidosis), ឬថ្លើមរីកធុនធ្ងរ និង ខ្លាញ់រុំថ្លើម (steatosis) | ពន្យារពេល > ៦ ខែ NRTI<br>High BMI | រោគសញ្ញា ៖ ប្រសិនបើចង់ក្អួតចង្អោរ/ក្អួត, ឈឺពោះ, ដង្ហើមញាប់, អស់កម្លាំង ចូរពិនិត្យ៖ ប៊ីកាបូណាត bicarbonate, AST/ALT, CK, ឡាក់តាត lactate |
| TDF | បំពង់ច្រោះទឹកម៉ូតខូចដំណើរការ | អាយុចាស់, BMI ទាប, HIV កម្រិតខ្ពស់, មុខងាយតម្រង់នោមចុះខ្សោយពីមុនមក, មានជំងឺផ្សេងទៀតក្នុងពេលតែមួយ (ទឹកនោមផ្អែម, លើសឈាម, ឆ្លង HCV ជាមួយគ្នា) ខ្សោយតម្រង់នោមដោយសារការប្រើថ្នាំ និងថ្នាំបញ្ចេញតាមទឹកនោម ឬ PI | ជៀសវាង TDF if eGFR< 50ml/min, ឬជំងឺទឹកនោមផ្អែម, ជំងឺលើសម្ពាធឈាមដែលមិនបានគ្រប់គ្រង (HTN)។<br>វាយតម្លៃ និងព្យាបាលមូលហេតុដទៃទៀតនៃរបួសតម្រងនោម (ខ្សោះជាតិទឹក, HTN, ។ល។)<br>*ឈប់ប្រើថ្នាំដែលធ្វើឱ្យពុលតម្រងនោម – ជាពិសេស NSAIDS*<br>ពិនិត្យ Cr + dipstick នៅ D0, M1, M3, រៀងរាល់ ១២ ខែ ក្រោយ |

---

[23] *ប្រភព: គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងព្យាបាលមេរោគអេដស៍សម្រាប់មនុស្សពេញវ័យនិងយុវវ័យ, NCHADS ឆ្នាំ ២០២០ ។*

| | | | |
|---|---|---|---|
| | កំហាប់រ៉ែក្នុងឆ្អឹងធ្លាក់ចុះ | អាយុ > 40, BMI ទាប, កង្វះសកម្មភាពផ្លូវកាយ , ការជក់បារី, IDU ។ ទឹកនោមផ្អែម ជំងឺថ្លើមពុំរ៉ៃ<br>ការប្រើ Corticosteroid | មានរោគសញ្ញា<br>បាក់ឆ្អឹង បាត់បង់កម្ពស់<br><br>វាយតម្លៃដោយឧបករណ៍វាយតម្លៃហានិភ័យបាក់ឆ្អឹង (FRAX) |
| ABC | ប្រតិកម្មប្រព័ន្ធភាពស៊ាំខ្លាំងហួស (Hypersensitivity reaction) | វត្តមានហ្សែន HLA-B*5701 | មិនត្រូវសាកល្បង ABC ម្តងទៀតឡើយ |
| 3TC | ផលរំខានថ្នាក់ NNRTI ដោយកម្រ | | |
| EFV | CNS – វិលមុខ, យល់សប្តិខុសធម្មតា, វង្វេងវង្វាន់, បាក់ទឹកចិត្ត, ប្រកាច់ | ប្រវត្តិបាក់ទឹកចិត្ត ឬប្រកាច់ | ជាទូទៅ បាត់ទៅវិញក្នុងរយៈពេលពីរបីសប្តាហ៍ក្រោយ ប៉ុន្តែអាចនៅយូរ |
| | ដោះឡើងធំខុសធម្មតាចំពោះបុរស | | |
| EFV and NVP | ពុលថ្លើម | ជំងឺរលាកថ្លើមប្រចាំកាយ, ថ្នាំដែលធ្វើឱ្យពុលថ្លើម NVP តែមួយ: CD4 > 250 | ពិនិត្យ AST/ALT នៅ D0, M1, M3<br>តាមដានរោគសញ្ញា |
| | កន្ទួល និងរោគសញ្ញាប្រព័ន្ធភាពស៊ាំឆ្លើយតបខ្លាំងហួស (Stevens Johnson) | | |
| Protease inhibitors (RTV, RTV/r, DRV, LPV/r) | ពុលថ្លើម | ជំងឺរលាកថ្លើមប្រចាំកាយ, ថ្នាំដែលធ្វើឱ្យពុលថ្លើម | ពិនិត្យ AST/ALT នៅ D0, M1, M3<br>តាមដានរោគសញ្ញា |
| | រាករូស និងធ្វើទុក្ខផ្លូវរំលាយអាហារ (ខ្លាំងបំផុតជាមួយ LPV/r) | | |

| | | | |
|---|---|---|---|
| | ចង្កោមរោគសញ្ញាមេតាបូលីស (LPV/r អាក្រក់បំផុត), ទឹកនោមផ្អែម, កូឡេស្តេរ៉ុលប្លាស្មាឡើងខ្ពស់ (dyslipidemia), រលាកលំពែង (pancreatitis) | កត្តាហានិភ័យពូជ និងកត្តាហានិភ័យដែលអាចកែប្រែបាន | តេស្តទឹកនោមផ្អែម និងតេស្តជាតិខ្លាញ់ប្រចាំឆ្នាំ ។ BP រាល់ពេលមកជួប។ ដំបូន្មានអំពីរបៀបរស់នៅ ។ |
| DRV/r | ស្បែកនិងប្រតិកម្មប្រព័ន្ធភាពស៊ាំខ្លាំងហួសហេតុ | អាឡែរស៊ីស៊ុលហ្វូណាមីដ (Sulfonamide) | |
| | ការពុល CNS: អត់ងងុយគេង, យល់សប្តិខុសធម្មតា, បាក់ទឹកចិត្ត, រង្វេងវង្វាន់ | បញ្ហាសុខភាពផ្លូវចិត្តពីមុនមក | កំណត់ដូសប្រើពេលថ្ងៃ |
| LPV/r | ចង្វាក់បេះដូងខុសប្រក្រតីលើម៉ាស៊ីន ECG (ចន្លោះពេលវែងរវាង PR និង QT, torsade de points) | ជំងឺប្រព័ន្ធចង្វាក់បេះដូងប្រចាំកាយ ( (Pre-existing conduction disease) កង្វះខាតជាតិប៉ូតាស្យូម (Hypokalemia) | ជៀសវាងការប្រើព្រមគ្នានូវថ្នាំផ្សេងទៀត ដែលអាចពន្យារពេលគម្លាត QT ឬ PR |
| | ស្បែកនិងប្រតិកម្មប្រព័ន្ធភាពស៊ាំខ្លាំងហួសហេតុ | | |
| Dolutegravir (DTG) | គេងមិនលក់ និងឈឺក្បាល | | |
| | ការពុលថ្លើម | ជំងឺរលាកថ្លើមប្រចាំកាយ, ថ្នាំដែលធ្វើឱ្យពុលថ្លើម | Check AST/ALT on D0, M1, M3 |
| | ប្រតិកម្មប្រព័ន្ធភាពស៊ាំខ្លាំងហួសហេតុ | | |

## 4.6. ការព្យាបាលបង្ការសម្រាប់ការឆ្លងជំងឺឱកាសនិយម (OI)

### *4.6.1. ការព្យាបាលបង្ការដោយថ្នាំ Co-trimoxazole សម្រាប់ស្ត្រីមានផ្ទៃពោះវិជ្ជមានមេរោគអេដស៍*

- Co-trimoxazole ត្រូវបានផ្តល់ជូនស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ទាំងអស់ នៅទីតាំងសេវា ART ប្រសិនបើពួកគេត្រូវតាមលក្ខណវិនិច្ឆ័យដូចមានបង្ហាញក្នុងតារាងទី ១០ ខាងក្រោម យោងតាមគោលការណ៍ណែនាំជាតិស្តីពីមេរោគអេដស៍សម្រាប់មនុស្សពេញវ័យ ឆ្នាំ ២០២០ ។
- អង្គការសុខភាពពិភពលោក អនុម័តឱ្យប្រើថ្នាំ co-trimoxazole ជាអន្តរាគមន៍អាទិភាពមួយសម្រាប់ស្ត្រីមានផ្ទៃពោះដែលផ្ទុកមេរោគអេដស៍ ដែលត្រូវតាមលក្ខណវិនិច្ឆ័យទាំងនេះ ដោយហេតុថា មិនមានភ័ស្តុតាងច្បាស់លាស់នៃការប៉ះពាល់ទៅលើទារកក្នុងផ្ទៃនោះទេ ហើយអត្ថប្រយោជន៍នៃការព្យាបាលបង្ការដោយថ្នាំ co-trimoxazole គឺលើសពីហានិភ័យដែលអាចកើតមាន ។
- គោលដៅចម្បងនៃការព្យាបាលបង្ការដោយថ្នាំ co-trimoxazole គឺដើម្បីបង្ការ Pneumocystis Jirovecii Pneumonia (PJP) (ដែលពីមុនគេហៅថា PCP), toxoplasmosis, និងជំងឺបាក់តេរីធ្ងន់ធ្ងរ ។
- ការព្យាបាលបង្ការដោយថ្នាំ cotrimoxazole ជាប្រចាំ គួរធ្វើឡើងចំពោះបុគ្គលដែលផ្ទុកមេរោគអេដស៍ទាំងអស់ដែលមានជំងឺរបេងសកម្ម ដោយមិនគិតពីចំនួនកោសិកា CD4 ។

**តារាងទី ១០ ៖ តើត្រូវចាប់ផ្តើមនិងបញ្ឈប់ការព្យាបាលបង្ការដោយថ្នាំ Cotrimoxazole សម្រាប់ស្ត្រីមានផ្ទៃពោះ នៅពេលណា**

| | |
|---|---|
| តើត្រូវចាប់ផ្តើម cotrimoxazole នៅពេលណា | · CD4 ≤350 cells/mm$^3$<br>· អ្នកជំងឺទាំងអស់ដែលមានរបេង<br>· ដំណាក់កាល WHO ទី 3 ឬទី 4 ដោយមិនគិតពីចំនួនកោសិកា CD4 |
| តើត្រូវបន្តថ្នាំ cotrimoxazole នៅពេលណា | · CD4 ≤350 cells/mm$^3$ និង/ឬ នៅពេលព្យាបាលរបេង<br>· បើធ្លាប់មានប្រវត្តិ PCP ដែលមានកោសិកា CD4 > 200 cells/mm$^3$ |
| តើត្រូវបញ្ឈប់ថ្នាំ cotrimoxazole នៅពេលណា | · ការរាប់កោសិកា CD4 > 350 cells/mm$^3$ ពេលវាស់ 2 ដង នៅរយៈពេលយ៉ាងតិច ៦ ខែម្តង និង បន្ទុកមេរោគមិនអាចរកឃើញ *និង* ការព្យាបាលរបេងចប់សព្វគ្រប់ |

*ប្រភព ៖ គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់មនុស្សពេញវ័យក្នុងប្រទេសកម្ពុជា ។ NCHADS ឆ្នាំ ២០២០ ។*

### កម្រិតដូសដែលត្រូវប្រើ និងការប្រើ

- Cotrimoxazole DS x ១ គ្រាប់/មួយថ្ងៃ ឬ cotrimoxazole SS គ្រាប់ x ២ ដង/ថ្ងៃ ។
- ប្រើ cotrimoxazole ពេលបាយ ដើម្បីជៀសវាងការធ្វើទុក្ខក្រពះពោះវៀន ។
    - Cotrimoxazole DS ( double strength ) = TMP 160mg / SMX 800mg ( or 960mg )
    - Cotrimoxazole SS ( single strength ) = TMP 80mg / SMX 400mg ( or 480mg )

### *4.6.2. ការព្យាបាលបង្ការដោយថ្នាំ Co-trimoxazole សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍*

- Cotrimoxazole ( TM/SMX ) ត្រូវបានផ្តល់ដល់ទារកដែលប្រឈមនឹងមេរោគអេដស៍ទាំងអស់ ដោយបុគ្គលិកនៅសេវា PAC ឬ ART, យោងតាមគោលការណ៍ណែនាំជាតិស្តីពីប្រើឱសថប្រឆាំងវីរុសសម្រាប់កុមារ ចាប់ផ្តើមពីអាយុ ៤-៦ សប្តាហ៍ រហូតដល់ការឆ្លងមេរោគអេដស៍ត្រូវបានជម្រុះ ដោយការធ្វើតេស្តនៅអាយុសមស្រប ពោលគឺ ៦ សប្តាហ៍បន្ទាប់ពីការឈប់បំបៅដោះ ( table 11 ) ។
- កុមារទាំងអស់ដែលត្រូវបានរកឃើញថាបានឆ្លងមេរោគអេដស៍ គួរបន្ត ឬចាប់ផ្តើម TM/SMX និងបន្តរហូតដល់កុមារត្រូវបានផ្ទេរចូលកន្លែងថែទាំមនុស្សពេញវ័យ នៅអាយុ ១៥ ឆ្នាំ ។

## តារាងទី ១១ ៖ តើត្រូវចាប់ផ្ដើមនិងបញ្ឈប់ការព្យាបាលថ្នាំ Cotrimoxazole សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍នៅពេលណា

| | | ចាប់ផ្ដើមថ្នាំ Cotrimoxazole | បញ្ឈប់ថ្នាំ Cotrimoxazole |
|---|---|---|---|
| ទារកដែលប្រឈមនឹងមេរោគអេដស៍ | | អាយុ ៤-៦ សប្ដាហ៍ | PCR ឬអង់ទីគ័រអវិជ្ជមាន ៦ សប្ដាហ៍ ក្រោយពីបញ្ឈប់ការបៅដោះ |
| ទារកដែលដែលឆ្លងមេរោគអេដស៍**ទាំងអស់** និងកុមារដោយមិនគិតពីអាយុ ឬដំណាក់កាលគ្លីនិកនៃជំងឺ | | អាយុ ៤-៦ សប្ដាហ៍ ដូចសម្រាប់ទារកដែលប្រឈមដែរ និងបន្ត ក្រោយពេលបញ្ជាក់ថាមានមេរោគអេដស៍<br><br>ភ្លាមៗបន្ទាប់ពីរកឃើញថាមានមេរោគអេដស៍ ចំពោះកុមារដែលមកជាលើកដំបូង នៅអាយុណាមួយ >៤-៦ សប្ដាហ៍<br><br>ចំពោះកុមារដែលមាន PCP, បន្ទាប់ពីចប់ការព្យាបាល PCP | ឈប់ប្រើ cotrimoxazole ប្រសិនបើកុមារស្លេកស្លាំងដោយសារ cotrimoxazole អាចបង្កការប៉ះពាល់ទៅលើខួរឆ្អឹងខ្នង ឬប្រសិនបើមានកន្ទួលដោយសារជាតិពុលកម្រិត 3/4<br><br>**ក្រៅពីនេះ បន្តប្រើ cotrimoxazole រហូតដល់កុមារប្តូរចូលទៅជាការថែទាំសម្រាប់មនុស្សពេញវ័យ ដោយមិនគិតពី ART ឬការកើនឡើងវិញនូវ CD4 នោះទេ** |

<u>ប្រភព</u>: *គោលការណ៍ណែនាំជាតិស្ដីពីការគ្រប់គ្រងព្យាបាលមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យនៅកម្ពុជា។ NCHADS ២០២០ ។*

### តារាងទី ១២ ៖ អនុសាសន៍សម្រាប់ការប្រើការព្យាបាលបង្ការ Cotrimoxazole សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍

| Drug | Strength of tablet or oral liquid (mg or mg/5 ml) | Number of tablets or ml by weight band once daily | | | | | |
|---|---|---|---|---|---|---|---|
| | | 3.0–5.9 kg | 6.0–9.9 kg | 10.0–13.9 kg | 14.0–19.9 kg | 20.0–24.9 kg | 25.0–34.9 kg |
| Co-trimoxazole | Suspension 200/40 mg per 5 ml | 2.5 ml | 5 ml | 5 ml | 10 ml | 10 ml | – |
| | Tablets (dispersible) 100/20 mg | 1 | 2 | 2 | 4 | 4 | – |
| | Tablets (scored) 400/80 mg | – | 0.5 | 0.5 | 1 | 1 | 2 |
| | Tablets (scored) 800/160 mg | – | – | – | 0.5 | 0.5 | 1 |

*ប្រភព ៖ គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យនៅកម្ពុជា។ NCHADS ២០២០ ។*

**កំណត់សម្គាល់ ៖** សម្រាប់ទារកនិងកុមារតូច សេរ៉ូ ឬថ្នាំគ្រាប់ដូសតូច (មិនមែន 800/160) ត្រូវបានប្រើ ជាធម្មតា ។
សម្រាប់កុមារដែលមានទម្ងន់លើសពី ២៥ គក ប្រើថ្នាំគ្រាប់ 400/80 ឬប្រើ 800/160 (មិនមែនសេរ៉ូ ឬគ្រាប់ 100/200 ) ។

### ការតាមដានមើលការព្យាបាលបង្ការដោយ cotrimoxazole ៖

ភាពញឹកញាប់ ៖ រាល់ខែ រហូតដល់មានស្ថិរភាព ហើយបន្ទាប់មក រៀងរាល់ ៣ ខែ

- ពិនិត្យមើលការគោរពតាមការព្យាបាល និងការយល់របស់អ្នកជំងឺ ។
- តាមដាមមើលប្រតិកម្មអាឡែរស៊ី; គ្រុនក្តៅ និងកន្ទួល ។
- តាមដានមើលផលរំខានផ្សេងទៀត; ធ្វើទុក្ខក្រពះពោះវៀន, ជាតិប៉ូតាស្យូមឡើងខ្ពស់ (hyperkalemia) (ជាពិសេស ACE inhibitor), ខួរឆ្អឹងខ្នងចុះខ្សោយ (ស្លេកស្លាំង, neutropenia, thrombocytopenia), រលាកថ្លើម, ក្រួសតម្រងនោមដោយកម្រ/ស្ទះទឹកម៉ូត, បញ្ហាសរសៃប្រសាទ ។

*ប្រតិកម្ម Cotrimoxazole*

- ជាធម្មតា កើតឡើងក្នុងអំឡុងពេលពីរបីថ្ងៃ ឬសប្តាហ៍ក្រោយពេលចាប់ផ្តើម; រោគសញ្ញាស្បែកនិងជាប្រព័ន្ធ (ភាគច្រើនកន្ទួល និងគ្រុនក្តៅ)
- ស្បែក ៖ ប្រែពីកន្ទួលស្ងួតទៅសើម, ចង្កោមរោគសញ្ញាស្ទីវិន ចនសាន់ (Stevens-Johnson syndrome), របកស្បែកដោយសារជាតិពុល (necrolysis)
- ជាប្រព័ន្ធ ៖ គ្រុនក្តៅ, ពិបាកដកដង្ហើម និងក្អក, គ្រាប់ឈាមស អេអូសេណូហ្វីលកើនឡើង (eosinophilia), រលាកថ្លើម, រលាកបំពង់ប្រោះទឹកនោម, ចង្កោមរោគសញ្ញាវិបត្តិប្រព័ន្ធភាពស៊ាំដោយសារតែការប្រើថ្នាំពុំរ៉េ (lupus-like syndrome), ចង្កោមរោគសញ្ញាប្រតិកម្មថ្នាំពហុសរីរាង្គ (multi-organ hypersensitivity syndrome), ប្រហោងក្នុង និងជំងឺកង្វះគ្រាប់ឈាមក្រហម គ្រាប់ឈាមស និងប្លាកែត (vacuities and pancytopenia) ។

## ការគ្រប់គ្រងផលរំខានចំពោះ Cotrimoxazole

- កន្ទួលតិចតួច (កន្ទួលស្ងួត) កើតមានជាទូទៅ ហើយជាធម្មតា អាចគ្រប់គ្រងដោយធ្វើការសង្កេតដោយប្រុងប្រយ័ត្ន និងបន្តប្រើ cotrimoxazole ។ បញ្ឈប់ បញ្ហានេះបើមិនបានធូរស្រាល ។
- ឈប់ប្រើ cotrimoxazole ក្នុងករណីមានកន្ទួលធ្ងន់ធ្ងរកាន់តែខ្លាំង(ជាធម្មតា មានលក្ខណៈសើម) រួមទាំងចង្កោមរោគសញ្ញា Stevens Johnson, មានសញ្ញារលាកថ្លើម, ស្លេកស្លាំងធ្ងន់ធ្ងរ ឬជំងឺកង្វះគ្រាប់ឈាមគ្រប់ប្រភេទ (pancytopenia) ។

សម្រាប់ព័ត៌មានលម្អិត សូមមើលគោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងព្យាបាលមេរោគអេដស៍នៅកម្ពុជា

## តារាងទី ១៣ ៖ ការគ្រប់គ្រងកន្ទួលទាក់ទងនឹង Cotrimoxazole

| ភាពធ្ងន់ធ្ងរ | ពិពណ៌នា | ការគ្រប់គ្រង |
|---|---|---|
| កម្រិតទី ១ | ស្បែកក្រហមរដិបរដុបឬដុំៗ<br>អាចរមាស់ | បន្តប្រើ cotrimoxazole<br>តាមដានរយៈពេល ៣-៤ ថ្ងៃក្រោយ<br>ពិចារណាប្រើថ្នាំ antihistamines ដើម្បីបន្ធូររោគសញ្ញា |
| កម្រិតទី ២ | ដំបៅស្បែកស្ងួត<br>អាចលេចចេញកន្ទួលដូចកញ្រ្ជឹល<br>របកកោសិកាស្បែកបន្តិចបន្តួច | បន្តប្រើ cotrimoxazole<br>តាមដានក្នុងរយៈពេល ១-២ ថ្ងៃក្រោយ<br>ពិចារណាប្រើ antihistamines ដើម្បីបន្ធូររោគសញ្ញា |

| | | |
|---|---|---|
| កម្រិតទី ៣ | ដំបៅភ្នាសមុយកឺរ (Early bullae or mucosal ulceration) | ឈប់ប្រើ cotrimoxazole ភ្លាមៗ<br>ឱ្យដេកពេទ្យដើម្បីទទួលការថែទាំ<br>**មិនត្រូវចាប់ផ្តើមប្រើ cotrimoxazole ឡើងវិញឡើយ** |
| កម្រិតទី ៤ | របកស្បែកដោយសារការពុល (Toxic epidermal necrolysis) ឬចង្កោមរោគសញ្ញា Stevens Johnson Syndrome | ឈប់ប្រើ cotrimoxazole ភ្លាមៗ<br>ឱ្យដេកពេទ្យដើម្បីទទួលការថែទាំ<br>**មិនត្រូវចាប់ផ្តើមប្រើ cotrimoxazole ឡើងវិញឡើយ** |

*ប្រភព ៖ គោលការណ៍ណែនាំជាតិស្តីពីការគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យនៅកម្ពុជា។ NCHADS ២០២០ ។*

# ជំពូកទី ៥ ៖ ការសម្រាលកូនដោយសុវត្ថិភាពសម្រាប់ស្ត្រីដែលឆ្លងមេរោគអេដស៍ ស្វាយ និងរលាកថ្លើមប្រភេទបេ

ស្ត្រីមានផ្ទៃពោះ**ទាំងអស់**នៅក្នុងប្រទេសកម្ពុជា ត្រូវបានលើកទឹកចិត្តឱ្យសម្រាលកូននៅក្នុងមូលដ្ឋានសុខាភិបាលដើម្បីទទួលការថែទាំពីបុគ្គលិកជំនាញផ្នែកសម្រាលកូន ។ ស្ត្រីដែលផ្ទុកមេរោគអេដស៍ ឬ HBsAg និងស្ត្រីដែលធ្លាប់មានជំងឺស្វាយក្នុងអំឡុងពេលមានផ្ទៃពោះ មានតម្រូវការពិសេស ហើយ**គួរតែសម្រាលកូននៅក្នុងមូលដ្ឋានសុខាភិបាលដែលមានសមត្ថភាពផ្តល់ការព្យាបាលសមស្របសម្រាប់ទាំងម្តាយនិងទារក - ជាធម្មតា គឺអគារសម្ភពនៅក្នុងមន្ទីរពេទ្យបង្អែក ។ ក្នុងករណីស្ត្រីមានផ្ទុកមេរោគអេដស៍ មូលដ្ឋានសុខាភិបាលនេះគួរតែជាមន្ទីរពេទ្យបង្អែកដែលមានទីតាំងស្ថិតនៅជាមួយសេវា ART ។**

- គួរពង្រឹងការប្រកាន់ខ្ជាប់តាមការព្យាបាលដោយឱសថប្រឆាំងវីរុសសម្រាប់ស្ត្រីមានផ្ទៃពោះដែលវិជ្ជមានមេរោគអេដស៍ និង HBV ក្នុងអំឡុងពេលមានផ្ទៃពោះ និងពេលឈឺពោះសម្រាល (សម្រាប់មេរោគអេដស៍) ក្រោយពេលសម្រាល ក្នុងអំឡុងពេលបំបៅដោះដើម្បីកាត់បន្ថយហានិភ័យនៃការចម្លង ។
- យុទ្ធសាស្ត្រជំរុញខ្លាំងក្លាការគ្រប់គ្រងសកម្មភាពសកម្មសមាហរណកម្ម (B-IACM) ត្រូវជានា និងតាមដានស្ត្រីមានផ្ទៃពោះដែលវិជ្ជមានមេរោគអេដស៍ទាំងនោះ និងស្ត្រីដែលមានមេរោគស្វាយអំឡុងពេលមានផ្ទៃពោះ ឱ្យមកសម្រាលកូននៅក្នុងមន្ទីរពេទ្យបង្អែក ។
- គេគួររំលឹកឱ្យស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ និងរលាកថ្លើមប្រភេទបេទាំងអស់ និងស្ត្រីដែលមានមេរោគស្វាយក្នុងអំឡុងពេលមានផ្ទៃពោះ យកសៀវភៅសុខភាពមាតារបស់ពួកគេ ឯកសារពាក់ព័ន្ធដទៃទៀត និងថ្នាំ ARV មកជាមួយពួកគេ ជាពិសេស នៅពេលពួកគេជិតដល់ពេលសម្រាលកូន ។ គួរប្រាប់ឱ្យពួកគេប្រាប់ពីប្រាប់ពីស្ថានភាពរបស់ពួកគេដល់ឆ្មប ដើម្បីឱ្យទទួលបានការថែទាំសមរម្យ ។

## 5.1 ការប្រុងប្រយ័ត្នជាសកល

បុគ្គលិកសុខាភិបាល (រាប់បញ្ចូលទាំងបុគ្គលិកផ្នែកអនាម័យ) គួរតែអនុវត្តតាមការប្រុងប្រយ័ត្នជាសកលដូចគ្នាក្នុងអំឡុងពេលឈឺពោះសម្រាលកូនរបស់ស្ត្រីដែលផ្ទុកមេរោគអេដស៍និងរលាកថ្លើមប្រភេទបេ ក៏ដូចជាសម្រាប់ស្ត្រីទាំងអស់ ដោយមិនគិតពីស្ថានភាពអេដស៍ និង HBV ។

**ប្រអប់ទី ៧ ៖ ការប្រុងប្រយ័ត្នជាសកល រួមមានការអនុវត្តទាំងឡាយដូចខាងក្រោម ដោយមិនគិតពីស្ថានភាពមេរោគអេដស៍និងរលាកថ្លើមប្រភេទបេ ៖**

- លាងដៃជាមួយសាប៊ូនិងទឹក បន្ទាប់ពីប៉ះជាមួយឈាមនិងវត្ថុរាវក្នុងខ្លួន ។
- រម្ងាប់មេរោគ ឬស្តេរីលឧបករណ៍និងបរិក្ខារទាំងអស់ដែលបានប្រើក្នុងទម្រង់ការដែលមានការដាក់បញ្ចូលក្នុងខ្លួនអ្នកជំងឺ ។
- ជៀសវាងការគ្របម្ជុលឡើងវិញ ដើម្បីកាត់បន្ថយរបួសដោយមុតម្ជុល ។
- ប្រើម្ជុល ឬកាំបិតវះកាត់សម្រាប់អ្នកជំងឺតែម្នាក់គត់ ។
- បោះចោលម្ជុលដោយសុវត្ថិភាពនៅក្នុងប្រអប់សុវត្ថិភាពដែលមិនមុតធ្លាយនិងមិនលិច ។
- ពាក់ស្រោមដៃនៅពេលប៉ះពាល់ជាមួយវត្ថុរាវរាងកាយ, ស្បែកដាច់រលាត់ ឬភ្នាសមុយកឺរ ។
- ប្រើបង់ដែលមិនជ្រាបទឹកដើម្បីរុំស្បែកដែលដាច់រលាត់ឬរបួសចំហ ។
- ពាក់អៀមប្លាស្ទិកដែលមិនជ្រាបទឹក និងវ៉ែនតាការពារភ្នែក ម៉ាស់ មួក និងស្បែកជើងកវែង ក្នុងពេលវះពាល់ និងសម្រាលកូន ។
- សម្អាតភ្លាមៗនិងដោយប្រុងប្រយ័ត្ននូវការកំពប់សារធាតុដែលមានឈាមឬវត្ថុរាវរាងកាយ ។
- ការប្រើប្រាស់ប្រព័ន្ធសមស្របសម្រាប់ការប្រមូលនិងចោលសំណល់ប្រកបដោយសុវត្ថិភាព ។
-

*<u>ដកស្រង់ចេញពី ៖</u> WHO/CDC. 2008 ។ កញ្ចប់បណ្តុះបណ្តាលទូទៅស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន*

## 5.2 ការព្យាបាលបង្ការសម្រាប់មេរោគអេដស៍ និងរលាកថ្លើមប្រភេទបេសម្រាប់បុគ្គលិកសុខាភិបាល

### *5.2.1 ការព្យាបាលបង្ការសម្រាប់មេរោគអេដស៍*

ក្នុងករណីមានការប្រឈមនឹងមេរោគអេដស៍ដោយចៃដន្យក្នុងពេលជួយសម្រាលកូន ឬការថែទាំអ្នកជំងឺផ្សេងទៀត ដូចជា ការមុតម្ជុល, របួសដោយសារឧបករណ៍មុតស្រួច ដែលមើលឃើញប្រឡាក់ឈាម ឬការប៉ះពាល់នៃមុខរបួសចំហ ឬភ្នាសមុយកឺរយៈពេល > ១ នាទី ទៅនឹងឈាមឬទឹករំអិលដែលមានបរិមាណច្រើន ។ បុគ្គលិកដែលប៉ះពាល់នោះ គួរតែរាយការណ៍ទៅផ្នែកសុខភាពមាតានិងទារកនៅស្រុកប្រតិបត្តិ ឬមន្ទីរសុខាភិបាលខេត្ត និងអ្នកសម្របសម្រួលមេរោគអេដស៍ និងមកកាន់គ្លីនិក ART ដើម្បីទទួលការព្យាបាលបង្ការក្រោយពេលប៉ះពាល់ (PEP) ដោយប្រើ ARV ។ ល្អបំផុត ការព្យាបាលគួរចាប់ផ្តើម ៤ ម៉ោង

ប៉ុន្តែ នៅតែមានប្រសិទ្ធភាពរហូតដល់រយៈពេល ៧២ ម៉ោងក្រោយ ។ ការព្យាបាលបង្ការដោយ ARV សម្រាប់ការប៉ះពាល់ជាមួយឈាមឬទឹករំភើះទៅលើស្បែកធម្មតាដែលមិនដាច់រលាត់ មិនត្រូវបានណែនាំឱ្យប្រើនោះឡើយ ។

*5.2.2. ការព្យាបាលបង្ការសម្រាប់មេរោគរលាកថ្លើមប្រភេទបេ*

ធ្នូបទាំងអស់និងបុគ្គលិកថែទាំសុខភាពដទៃទៀត ដែលមានហានិភ័យប្រឈមនឹងការឆ្លងរោគក្នុងពេលធ្វើការងារ គួរចាក់ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ ។ ក្នុងករណីបុគ្គលិកសុខាភិបាលដែលមិនបានទទួលថ្នាំបង្ការ មានការប្រឈមដោយចៃដន្យទៅនឹងឈាមរបស់នរណាម្នាក់ដែលមាន **HBsAg** វិជ្ជមាន តាមរយៈការមុតម្ជុល, ការរងរបួសពីឧបករណ៍មុតស្រួចដែលប្រឡាក់ឈាម ឬការប៉ះពាល់នៃមុខរបួសចំហឬភ្នាសមុយកឺទៅនឹងឈាម បុគ្គលិកដែលប្រឈមនោះ គួរតែទទួលថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេភ្លាមៗ បន្ទាប់មកទទួលដូសជំរុញបន្ថែមនៅ ៦, ១០ និង ១៤ សប្តាហ៍ក្រោយ ។ គេអាចប្រើថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទ Immune Globulin (**HBIG**) (0.06 mL/kgor 500 IU) តាមសាច់ដុំ ។

5.3 វិធីសាស្ត្រជាអនុសាសន៍សម្រាប់ការសម្រាលកូនដោយសុវត្ថិភាពសម្រាប់ស្ត្រីដែលផ្ទុកមេរោគអេដស៍ ឬមេរោគរលាកថ្លើមប្រភេទបេ

- ក្នុងពេលឈឺពោះសម្រាល ស្ត្រីមានផ្ទៃពោះទាំងអស់ រួមទាំងស្ត្រីដែលផ្ទុកមេរោគអេដស៍ និង HBsAg គួរតែទទួលបានការគាំទ្រពេញលេញ ដូចជាការប្រាស្រ័យទាក់ទង, ការធ្វើដំណើរ, ការបត់ជើងតូច, ការបរិភោគនិងការផឹក, បច្ចេកទេសដកដង្ហើម, វិធានការបន្ថយការឈឺចាប់ និងភាពមិនស្រួល និងអ្នកកំដរនៅពេលសម្រាលកូន, និងការថែទាំក្នុងដំណាក់កាលទី ២ នៃការឈឺពោះសម្រាល និងភ្លាមៗបន្ទាប់ពីសម្រាលកូន នៅក្នុងបរិយាកាសប្រកបដោយការលើកទឹកចិត្ត, មានភាពស្អាត និងការគាំទ្រ ។ (សូមមើលពិធីសារមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក) ។
- **ម.ជ.គ.ម.ទ ណែនាំឱ្យធ្វើការសម្រាលកូនតាមបែបធម្មជាតិសម្រាប់ស្ត្រីមានផ្ទៃពោះដែលវិជ្ជមានមេរោគអេដស៍ និង HBsAg ទាំងអស់ លើកលែងតែមានសញ្ញាផ្នែកវេជ្ជសាស្ត្រខ្លាំងផ្សេងទៀតដែលត្រូវការធ្វើការសម្រាលកូនដោយវះកាត់ ។ ការសម្រាលកូនដោយវះកាត់ មិនត្រូវបានណែនាំជាប្រចាំសម្រាប់ស្ត្រីមានផ្ទៃពោះដែលវិជ្ជមានមេរោគអេដស៍ និង HBsAg នោះទេ ។**
- ទោះបីជាការសម្រាលកូនដោយវះកាត់តាមការចង់បាន បានបង្ហាញថា អាចការពារទប់ទល់នឹងការចម្លង បើប្រៀបធៀបទៅនឹងការសម្រាលកូនតាមទ្វារមាស ជាពិសេសក្នុងករណីបន្ទុកមេរោគខ្ពស់ក្តី ប៉ុន្តែវិធីនេះមិនត្រូវបានគេណែនាំឱ្យអនុវត្តនៅក្នុងតំបន់ដែលធនធានមានកម្រិតនោះទេ ជាពិសេស

ដោយសារតែហានិភ័យនៃផលវិបាកដែលកើតឡើង និងការកើនឡើងនូវអត្រាមានជំងឺនិងមរណភាពចំពោះម្តាយនិងកូន ។

- **ការសម្រាលកូនដោយវះកាត់នៅតែត្រូវបានណែនាំឱ្យអនុវត្តសម្រាប់ស្ត្រីមានផ្ទៃពោះដែលវិជ្ជមានមេរោគអេដស៍ និង HBsAg ដែលមានសញ្ញាផ្នែកសម្ភពនិងវេជ្ជសាស្ត្រផ្សេងទៀត ។**
- វិធានការនានាគួរត្រូវបានធ្វើឡើងដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ឬ HBV ដល់ទារកក្នុងអំឡុងពេលសម្រាលកូនតាមទ្វាមាស ដូចបានពិពណ៌នានៅក្នុងប្រអប់ខាងក្រោម ។

**ប្រអប់ទី ៨ ៖ វិធានការដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍និង HBV ក្នុងអំឡុងពេលសម្រាលកូនតាមទ្វារមាស**

- ជៀសវាងបំបែកទឹកភ្លោះដោយសិប្បនិម្មិត លើកលែងតែចាំបាច់បំផុត ។
- ជៀសវាងការកាត់ទ្វារមាស លើកលែងតែចាំបាច់បំផុត ។
- ជៀសវាងការជំរុញការឈឺពោះសម្រាល លើកលែងតែចាំបាច់បំផុត ។
- កាត់បន្ថយការប្រើដង្កៀប ឬឧបករណ៍បូម ។
- កាត់បន្ថយហានិភ័យនៃការធ្លាក់ឈាមក្រោយសម្រាល ។
- អនុវត្តការប្រុងប្រយ័ត្នជាសកល ។

*ដកស្រង់ចេញពី ៖ WHO/CDC. 2008. WHO/CDC. 2008 ។ កញ្ចប់បណ្តុះបណ្តាលទូទៅស្តីពីការបង្ការការចម្លងមេរោគអេដស៍ពីម្តាយទៅកូន*

## 5.4 ការថែទាំក្រោយពេលសម្រាល និងការគាំទ្រដោយផ្តល់ការអប់រំ

<u>ម្តាយនិងទារកទើបនឹងកើតទាំងអស់</u>

- តាមដានរៀងរាល់ ១៥ នាទី រយៈពេល ១ ម៉ោង ក្រោយពេលទម្លាក់សុក, បន្ទាប់មក រៀងរាល់ ៣០ នាទីម្តងក្នុងអំឡុងពេល ២ ម៉ោងលើកទីពីរ, រៀងរាល់ម៉ោងនៅម៉ោងទី ៣ និងទី ៤ ម៉ោង និងរៀងរាល់ ៤ ម៉ោងម្តង រហូតដល់ពេលចេញពីពេទ្យ ។
- ទុកម្តាយ (និងទារក) នៅក្នុងមូលដ្ឋានសុខាភិបាលយ៉ាងហោចណាស់ ២៤ ម៉ោងក្រោយពេលសម្រាល ។ វាយតម្លៃម្តាយនិងទារកមុនពេលចេញពីពេទ្យ ។
- ផ្តល់ដល់ទារកនូវថ្នាំបង្ការ HBV មួយដូស ក្នុងអំឡុងពេល ២៤ ម៉ោងក្រោយការសម្រាល និងជាពិសេស *ក្នុងរយៈពេល ២ ម៉ោងក្រោយពេលសម្រាល* ។

- ផ្តល់ដល់ម្តាយនូវជាតិដែក/អាស៊ីតហ្វូលិក (៤២ គ្រាប់) និងថ្នាំមេបង់ដាហ្សុល (mebendazole) ។ ផ្តល់ថ្នាំបង្ការតតាណូស ប្រសិនបើចាំបាច់។
- សង្កេតមើលការបំបៅកូនដោយទឹកដោះម្តាយ និងវាយតម្លៃការដាក់ទីតាំង ការដាក់ផ្អិប និងការជញ្ជក់ដោះ ។ បង្រៀនម្តាយអំពីរបៀបដាក់ទីតាំង និងការដាក់ផ្អិបដែលត្រឹមត្រូវ ។ កុំបញ្ចេញពីពេទ្យត្រូវរង់ចាំរហូតដល់ទារកចេះបំបៅដោះបានល្អសិន ។
- ផ្តល់ប្រឹក្សាអំពីការឱ្យបៅទឹកដោះដំបូង (colostrum), ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ និងគ្រោះថ្នាក់នៃឱ្យបំបៅលាយគ្នា ដោយសារតែការរៀបចំធុងទឹកដោះគោមិនមានអនាម័យ ។ (សូមមើលជំពូកទី ៦) ។
- ផ្តល់ដំបូន្មានអំការថែទាំនិងអនាម័យក្រោយពេលសម្រាល
- ផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភសម្រាប់ម្តាយ
- ផ្តល់ប្រឹក្សាអំពីការពន្យារកំណើត និងផែនការគ្រួសារ (សូមមើលជំពូកទី ៧) ។
- ផ្តល់ដំបូន្មានអំពីពេលវេលាដែលត្រូវស្វែងរកការថែទាំ និងការមកជួបក្រោយពេលសម្រាលនៅពេលបន្ទាប់ ។
- ធ្វើការវាយតំលៃមុនពេលចេញពីពេទ្យ ។ ប្រសិនបើមានបញ្ហាណាមួយត្រូវបានរកឃើញនៅពេលវាយតម្លៃមុនពេលចេញពីពេទ្យ សូមរក្សាទុកម្តាយនិងទារកនៅក្នុងមន្ទីរពេទ្យ និងវាយតម្លៃឡើងវិញមុនពេលអនុញ្ញាតឱ្យចេញ ។
- បន្តការព្យាបាលណាដែលបានចាប់ផ្តើមរួចហើយ ។
- ផ្តល់ដំបូន្មានអំពីកការថែទាំសម្រាប់ទារកទើបនឹងកើតក្រោយពេលចេញពីពេទ្យ ដូចជា ការរក្សាកម្តៅ, ការថែរក្សាទងផ្ចិត, ការគេង, អនាម័យ, ការមកជួបតាមធម្មតា, សញ្ញាគ្រោះថ្នាក់ និងប្រាប់ម្តាយឱ្យត្រឡប់មកវិញជាបន្ទាន់ប្រសិនបើគាត់ឬទារករបស់គាត់ មានសញ្ញាគ្រោះថ្នាក់ ។
- ណែនាំឲ្យម្តាយយកប័ណ្ណសុខភាពម្តាយនិងទារកមកជាមួយ រាល់ពេលមកជួប ។

*<u>ប្រភព៖</u> ពិធីសារមាតុភាពគ្មានគ្រោះថ្នាក់សម្រាប់មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក, មជគមទ ២០១៦ ។*

បន្ថែមពីលើអ្វីដែលបានរៀបរាប់ខាងលើ រាល់ស្ត្រីដែលឆ្លងមេរោគអេដស៍និង HBsAg ទាំងអស់ គួរទទួលបានការថែទាំក្រោយពេលសម្រាល និងការអប់រំសម្រាប់ខ្លួនពួកគេ និងទារករបស់ពួកគេ ដូចពិពណ៌នាខាងក្រោម ៖

### ប្រអប់ទី ៩ ៖ ការថែទាំក្រោយពេលសម្រាលពិសេសសម្រាប់ស្ត្រីដែលឆ្លងមេរោគអេដស៍ ៖

- ធានាថា ម្តាយទទួលការព្យាបាល *ART* ។ ប្រសិនបើមិនទាន់បានចាប់ផ្តើមទេ សូមទទួលការព្យាបាលភ្លាមៗពីទីតាំង *ART* និងចាប់ផ្តើមខណៈពេលដែលកំពុងស្ថិតនៅក្នុងអគារសម្ភព ។ នេះរួមបញ្ចូលទាំងស្ត្រីដែលមានតេស្តប្រតិកម្មថ្មីៗក្នុងពេលសម្រាលកូន ប្រសិនបើការធ្វើតេស្តបញ្ជាក់ឃើញវិជ្ជមាន ឬប្រសិនបើតេស្តបញ្ជាក់មិនអាចធ្វើបានភ្លាមៗ ។
  - ប្រមូលយកសំណាកឈាមស្ងួត (DBS) ពីទារកដើម្បីធ្វើតេស្ត DNA-PCR *មុនពេលចេញពីសេវាសម្ភព ។* ប័ណ្ណ DBS គួររក្សាទុកក្នុងអគារសម្ភពសម្រាប់គោលបំណងនេះ ។ (សូមមើលប្រអប់ទី ៩ ខាងក្រោម) ។
- ផ្តល់ការព្យាបាលបង្ការដល់ទារកដោយប្រើ *ARV* សម្រាប់រាល់ទារកដែលប្រឈមមុខនឹងមេរោគអេដស៍ទាំងអស់ រួមទាំងទារកដែលកើតពីស្ត្រីដែលមានតេស្តប្រតិកម្មថ្មីៗ ដែលកំពុងរង់ចាំតេស្តបញ្ជាក់ ។ *(ប្រសិនបើតេស្តបញ្ជាក់អវិជ្ជមាន, គេអាចបញ្ឈប់ការប្រើ ARV នៅពេលក្រោយ )* ។
- ធានាថា ទារកត្រូវបានចុះឈ្មោះក្នុង *PAC* ដើម្បីទទួលបាន ៖
- ការព្យាបាលបង្ការដោយប្រើ *Co-trimoxazole* ។
- ការធ្វើតេស្តរោគវិនិច្ឆ័យមេរោគអេដស៍ទាន់ពេលវេលា ។
- *ART* សម្រាប់កុមារដែលឆ្លងមេរោគអេដស៍ នៅពេលមានការណែនាំ ។
- ការតាមដានមើលការព្យាបាលសម្រាប់កុមារទាំងអស់ដែលទទួល *ART* ។
- ការផ្តល់ថ្នាំបង្ការដល់ទារកមានសារៈសំខាន់ជាពិសេស សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍ ។ *ត្រូវធានាថា ទារកបានទទួលដូសថ្នាំបង្ការពីកំណើតសម្រាប់ HBV ក្នុងអំឡុងពេល ២៤ ម៉ោង* រួមជាមួយថ្នាំបង្ការជំងឺផ្សេងៗទៀត និងទទួលបានថ្នាំបង្ការតាមកាលវិភាគកំណត់ជាបន្តបន្ទាប់នៅពេលក្រោយមកទៀត ។
- ផ្តល់ប្រឹក្សាអំពីអាហារូបត្ថម្ភសម្រាប់ម្តាយនិងការចិញ្ចឹមទារក (សូមមើលជំពូកទី ៦) ។
- ផ្តល់ប្រឹក្សាដល់ម្តាយអំពីការប្រកាន់ខ្ជាប់តាមការព្យាបាល *ART* ។
- ផ្តល់ការគាំទ្រផ្នែកចិត្តសង្គម ។
- ផ្តល់ប្រឹក្សាអំពីសញ្ញានិងរោគសញ្ញានៃការឆ្លងរោគក្រោយពេលសម្រាល និងសញ្ញាគ្រោះថ្នាក់ផ្សេងៗទៀត រួមទាំងផលរំខាននៃ *ARV* ចំពោះម្តាយនិងទារកដែលទើបនឹងកើតរបស់ពួកគេ ។
- ផ្តល់ប្រឹក្សានិងការគាំទ្រដើម្បីលើកទឹកចិត្តដល់ការធ្វើតេស្តដៃគូ, ការកាត់បន្ថយហានិភ័យ និងការបង្ហាញពីស្ថានភាព ។
- ផ្តល់ប្រឹក្សាអំពីការបង្ការវិជ្ជមាន តាមរយៈការពន្យារកំណើត (សូមមើលជំពូកទី ៧)
- អ្នកផ្តល់សេវាគួរជូនដំណឹងឱ្យបានឆាប់បំផុតដល់ក្រុមការងារ *CMC/CMS/CAA* ឬអ្នកសម្របសម្រួល *OD PMTCT* អំពីស្ត្រីផ្ទុកមេរោគអេដស៍ទាំងអស់ដែលសម្រាលកូន ជាពិសេសចំពោះស្ត្រី

**ប្រអប់ទី ១០ ៖ ការប្រមូលសំណាកឈាមស្ងួត (DBS) នៅពេលសម្រាល ៖**

- ពន្យល់ពីនីតិវិធីដល់ម្ដាយនិងទទួលការយល់ព្រមដោយផ្ទាល់មាត់ ។
- បំពេញឈ្មោះនិងថ្ងៃខែឆ្នាំលើប័ណ្ណ DBS ។ ជៀសវាងការប៉ះរង្វង់នៅលើកាត ។
- ឱ្យម្ដាយឬសាច់ញាតិផ្សេងទៀតអង្គុយ ហើយទប់ទារក ដោយដាក់ជើងទារកចុះក្រោម ។
- កម្ដៅកែងជើងទារក ដោយម៉ាស្សាកន្លែងនោះដោយប្រើដៃរបស់អ្នក ។
- ជូតជ្រុងម្ខាងនៃកែងជើងម្ខាង ដោយប្រើអាល់កុល ហើយទុកឱ្យស្ងួត ។
- ចាប់ជើងទារកដោយដៃរបស់អ្នក និងច្របាច់ថ្នមៗជុំវិញកែងជើងដោយម្រាមដៃរបស់អ្នក ។
- ចាក់ផ្នែកម្ខាងនៃកែងជើងនោះ ដោយប្រើម្ជុលជួសឈាមស្ទេរីល ហើយជូតតំណក់ឈាមដំបូងចេញដោយប្រើកុំប្រែសស្ទេរីល ។
- នៅពេលតំណក់ឈាមទីពីរចេញមក សូមកាន់កាតដាក់ពីក្រោមតំណក់ឈាមនោះ ដើម្បីឱ្យឈាមធ្លាក់ក្នុងរង្វង់ ។ កុំដាក់កាតប៉ះដោយផ្ទាល់ទៅនឹងស្បែកទារក គ្រាន់តែទុកឱ្យតំណក់ឈាមហូរធ្លាក់លើវាហើយបង្ហូរវាចូលឱ្យជោគ ។ បើចាំបាច់ ច្របាច់កែងជើងដោយថ្នមៗដើម្បីជួយឱ្យឈាមចេញមកក្រៅ ។ ត្រូវដាក់ឱ្យតំណក់ឈាមបំពេញក្នុងរង្វង់ទាំងស្រុង ។
- បន្ទាប់ពីរង្វង់ត្រូវបានបំពេញរួចហើយ សូមបន្ទុរសម្ពាធរយៈពេលមួយវិនាទីដើម្បីឱ្យតំណក់ឈាមមួយទៀតធ្លាក់ចុះមក បន្ទាប់មក ធ្វើម្ដងទៀតរហូតដល់រង្វង់ទាំងអស់នៅលើកាតត្រូវបានបំពេញដោយឈាម ។ ត្រូវមានយ៉ាងហោចណាស់ ៣ រង្វង់ ដែលត្រូវបានបំពេញទាំងស្រុង ។
- ដាក់កាតទុកមួយឡែកសិនដោយប្រុងប្រយ័ត្ន, ដាក់មុខឡើងលើ, កុំឱ្យអ្វីប៉ះរង្វង់ឈាម ។
- សង្កត់លើកន្លែងចាក់ដោយប្រើបង់រុំស្ទេរីល រហូតដល់ឈប់ហូរឈាម ។
- យកកាតទៅកាន់ទីតាំង *ART* ដើម្បីដឹកជញ្ជូនទៅមន្ទីរពិសោធន៍ក្នុងរាជធានីភ្នំពេញ ។ ប្រសិនបើទីតាំង *ART* មិនបើកធ្វើការទេ សូមទុកកាតនៅក្នុងកន្លែងដែលមានសុវត្ថិភាពស្អាតដើម្បីសម្ងួត

**ប្រអប់ទី ១១ ៖ ការថែទាំក្រោយពេលសម្រាលពិសេសសម្រាប់ស្ត្រីដែលឆ្លង HBsAg ៖**

- ធានាថា ទារកទទួលបានដូសថ្នាំបង្ការ HBV ពេលកើត*ក្នុងរយៈពេលពីរម៉ោងក្រោយសម្រាល* ។
- ផ្ដល់ប្រឹក្សាអំពីសារៈសំខាន់នៃការបំពេញកាលវិភាគទទួលថ្នាំបង្ការពេញលេញសម្រាប់ HBV និងថ្នាំបង្ការផ្សេងទៀតសម្រាប់ទារក ។
- ប្រសិនបើកំពុងព្យាបាលដោយ ARV, សូមណែនាំឱ្យបន្តរហូតដល់មានការណែនាំផ្សេងពីនេះដោយគ្រូពេទ្យ។
- បញ្ជាក់កាលវិភាគណាត់ជួបដល់ម្ដាយសម្រាប់ការតាមដានបន្តជំងឺរលាកថ្លើមប្រភេទបេ ។
- ប្រាប់ម្ដាយថា ទារកគួរធ្វើតេស្តរក HBsAg នៅអាយុ ៧-១២ ខែ (១ ខែឡើងទៅ ក្រោយពីបញ្ចប់ការទទួលថ្នាំបង្ការរលាកថ្លើមប្រភេទបេបានពេញលេញ) ។
- ធានាឡើងវិញថា ការបំបៅដោះគឺមានសុវត្ថិភាព និងផ្ដល់ប្រឹក្សាអំពីការចិញ្ចឹមទារក និងអាហារូបត្ថម្ភម្ដាយ ។

## ការបំបៅកូនដោយទឹកដោះម្ដាយសម្រាប់ទារកដែលកើតពីម្ដាយដែលមានមេរោគអេដស៍ រលាកថ្លើមប្រភេទបេ និងស្វាយ

ភ្លាមៗក្រោយពេលសម្រាលកូន ម្ដាយដែលឆ្លងមេរោគអេដស៍គួរតែទទួលបានការប្រឹក្សាយ៉ាងយកចិត្តទុកដាក់ពីសំណាក់ឆ្មបដែលបានបណ្ដុះបណ្ដាល អំពីវិធីចិញ្ចឹមខ្លួនឯងនិងអំពីជម្រើសនៃការចិញ្ចឹមនានាសម្រាប់ទារករបស់ពួកគេ ។ ពួកគេគួរតែទទួលបានគាំទ្រដើម្បីចាប់ផ្ដើមអនុវត្តវិធីចិញ្ចឹមដែលពួកគេបានជ្រើសរើស ខណៈពេលដែលពួកគេកំពុងស្ថិតនៅក្នុងមន្ទីរពេទ្យនៅឡើយ ។ ទោះបីជាមានការកើនឡើងនូវហានិភ័យនៃការចម្លងពីម្ដាយទៅកូននៃមេរោគអេដស៍ក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះម្ដាយក៏ដោយ ប៉ុន្តែគ្រោះថ្នាក់នៃការចិញ្ចឹមដោយទឹកគោដែលមិនត្រឹមត្រូវ ឬការឱ្យបៅលាយគ្នា គឺមានទំហំធំជាង ហើយ ម.ជ.គ.ម.ទ ណែនាំឱ្យបំបៅកូនដោយទឹកដោះម្ដាយតែមួយមុខគត់សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍ទាំងអស់ ( សូមមើលជំពូកទី ៦ ) ។

ចំពោះម្ដាយដែលវិជ្ជមាន HBsAg មិនមានភ័ស្តុតាងដែលបង្ហាញថា ការបំបៅកូនដោយទឹកដោះម្ដាយបង្កើនហានិភ័យនៃការចម្លងពីម្ដាយទៅកូននោះនូវមេរោគរលាកថ្លើមប្រភេទបេនោះទេ ដូច្នេះ ការបំបៅដោះដោយទឹកដោះម្ដាយដែលមួយមុខគត់ គួរតែត្រូវបានលើកទឹកចិត្ត ។

មិនមានភ័ស្តុតាងណាមួយដែលបញ្ជាក់ពីការឆ្លងមេរោគស្វាយតាមរយៈទឹកដោះម្ដាយទេ ដូច្នេះ សូម្បីតែម្ដាយដែលទើបតែចាប់ផ្ដើមការព្យាបាលជំងឺស្វាយ ក៏គួរតែត្រូវបានលើកទឹកចិត្តឱ្យបំបៅកូនដោយទឹកដោះរបស់គាត់ដែរ ។

## ការពន្យារកំណើតសម្រាប់ស្ត្រីក្រោយសម្រាល

ព័ត៌មាននិងសេវាគួរតែត្រូវបានផ្ដល់ជូនក្នុងអំឡុងក្រោយពេលសម្រាលកូនដល់ស្ត្រីទាំងអស់ ដើម្បីចៀសវាងការមានផ្ទៃពោះដោយអចេតនាក្នុងពេលអនាគត ។ ក្នុងករណីស្ត្រីឆ្លងមេរោគអេដស៍និង HBsAg និងស្ត្រីដែលប្រឈមនឹងការឆ្លងជំងឺកាមរោគ/មេរោគអេដស៍ គេគួរលើកទឹកចិត្តដល់ការការពារពីរមុខ ( ស្រោមអនាម័យបូកនឹងវិធីសាស្ត្រមួយផ្សេងទៀត ) ។

ការផ្ដល់ប្រឹក្សាដំបូងគួរត្រូវបានធ្វើឡើងក្រោយពេលសម្រាល មុនពេលចេញពីពេទ្យ ។ លើសពីនេះទៀត ស្ត្រីដែលមកពិនិត្យសុខភាពក្រោយពេលសម្រាលរយៈពេល ៦ សប្ដាហ៍ក្រោយ គួរតែទទួលបានការប្រឹក្សា និងសេវាពន្យារកំណើតសមស្រប ។

សូមមើលជំពូកទី ៧ សម្រាប់ព័ត៌មានអំពីវិធីសាស្ត្រជាក់លាក់ និងព័ត៌មានលម្អិតផ្សេងទៀត ។

# ជំពូកទី ៦ ៖ ការចិញ្ចឹមទារក និងការតាមដានបន្ត

ស្ត្រីទាំងអស់មានសិទ្ធិជ្រើសរើសវិធីចិញ្ចឹមទារករបស់ពួកគេ ប៉ុន្តែ**ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់គឺជាជម្រើសចម្បង** ដែលត្រូវបានលើកទឹកចិត្ត ។

## ចាប់ពីពេលកើតរហូតដល់អាយុប្រាំមួយខែ ៖

ស្ត្រីទាំងអស់ត្រូវបានលើកទឹកចិត្តឱ្យបំបៅទារករបស់ពួកគេដោយទឹកដោះម្តាយតែមួយមុខគត់ ក្នុងរយៈពេលប្រាំមួយខែដំបូងនៃជីវិត ។ ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ មានន័យថា ផ្តល់ឱ្យទារកតែទឹកដោះម្តាយប៉ុណ្ណោះ ។ គេមិនគួរឱ្យទារកនូវអាហារឬភេសជ្ជៈផ្សេងទៀតទេ សូម្បីតែទឹក ក្នុងអំឡុងពេលប្រាំមួយខែនៃការបំបៅកូនដោយទឹកដោះតែមុខគត់ ។

## បន្ទាប់ពីអាយុប្រាំមួយខែ ៖

- ស្ត្រីទាំងអស់គួរផ្តល់អាហារបន្ថែមដល់ទារក និងបន្តបំបៅដោះរហូតដល់អាយុ ២៤ ខែ ឬលើសពីនេះ ។

**កំណត់សម្គាល់ ៖** ការបញ្ឈប់ការបំបៅកូនដោយទឹកដោះម្តាយភ្លាមៗ មិនត្រូវបានណែនាំឱ្យធ្វើនោះទេ ព្រោះវាអាចមានផលវិបាកអវិជ្ជមានសម្រាប់ទារក ដូចជាការមិនលូតលាស់ និងការកើនឡើងអត្រារាករូស ។ ផ្ទុយទៅវិញ ម្តាយគួរតែបញ្ឈប់ការបំបៅកូនដោយទឹកដោះម្តាយបន្តិចម្តងៗក្នុងរយៈពេលមួយខែ ។

## ស្ត្រីដែលវិជ្ជមាន HBsAg ៖

មិនមានការកើនឡើងនូវហានិភ័យនៃការចម្លងពីម្តាយទៅកូនទេ នៅពេលស្ត្រីដែលមានមេរោគរលាកថ្លើមប្រភេទបេ បំបៅកូនដោយទឹកដោះម្តាយ ។ ប្រសិនបើពួកគេកំពុងប្រើថ្នាំ Tenofovir ថ្នាំនេះមានសុវត្ថិភាពសម្រាប់ទារក ។

**ស្ត្រីដែលវិជ្ជមានមេរោគស្វាយ ៖** មេរោគស្វាយមិនចម្លងតាមទឹកដោះម្តាយទេ ។ ស្ត្រីដែលមានមេរោគស្វាយត្រូវការការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិកដើម្បីព្យាបាលជំងឺនេះឱ្យជាដាច់ ប៉ុន្តែពួកគេអាចចាប់ផ្តើមការបំបៅកូន នៅមុនពេលពួកគេត្រូវបានការព្យាបាលផងដែរ ។ ទារកដែលមានរោគស្វាយពីកំណើត ត្រូវការការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក ប៉ុន្តែពួកគេអាចចាប់ផ្តើមបៅដោះម្តាយភ្លាមៗ សូម្បីតែមុនពេលបញ្ចប់ការព្យាបាលដោយថ្នាំអង់ទីប៊ីយ៉ូទិក ផងដែរ ។

**ស្ត្រីដែលវិជ្ជមានមេរោគអេដស៍** ត្រូវបានពិភាក្សាដូចខាងក្រោម ៖

## 6.1 ការចិញ្ចឹមទារកក្នុងបរិបទមេរោគអេដស៍

ដើម្បីបង្កើនជាអតិបរមានូវឱកាសរស់រានមានជីវិតរបស់កូនពួកគេដោយគ្មានមេរោគអេដស៍ ម្តាយដែលឆ្លងមេរោគអេដស៍ត្រូវការការប្រឹក្សាដោយប្រុងប្រយ័ត្ន ដើម្បីជួយពួកគេក្នុងការជ្រើសរើសយកជម្រើសចិញ្ចឹមទារកដែលផ្អែកលើព័ត៌មានដែលមាន និងសមស្របនឹងស្ថានភាពជាក់លាក់របស់ពួកគេ ព្រមទាំងផ្តល់ការគាំទ្រជាបន្តដើម្បីជួយពួកគេអនុវត្តជម្រើសរបស់ពួកគេ ។ ទោះបីជាការចម្លងពីម្តាយទៅកូននៃមេរោគអេដស៍ អាចកើតមានក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះម្តាយក៏ដោយ ប៉ុន្តែទារកដែលមិនបានបៅដោះម្តាយ អាចប្រឈមនឹងជំងឺរាកធ្ងន់ធ្ងរ កង្វះអាហារូបត្ថម្ភ និង/ឬការឆ្លងជំងឺតាមផ្លូវដង្ហើម ដោយសារតែការរៀបចំទឹកដោះគោមិនមានសុវត្ថិភាព ឬការផ្តល់អាហារបន្ថែមមិនគ្រប់គ្រាន់ឬមិនត្រឹមត្រូវ និងដោយសារតែទារកមិនទទួលបានទទួលអង្គបដិបក្ខប្រាណពីម្តាយ និងអត្ថប្រយោជន៍អាហារូបត្ថម្ភនៃទឹកដោះម្តាយ ។

នៅពេលណាអាចធ្វើទៅបាន អ្នកផ្តល់ប្រឹក្សាគួរតែលើកទឹកចិត្តដល់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍ ដើម្បីបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់ក្នុងរយៈពេល ៦ ខែដំបូង ហើយបន្ទាប់មក ត្រូវបន្តបំបៅដោះរួមជាមួយអាហារបន្ថែម រហូតដល់អាយុយ៉ាងតិច ១២ ខែ និងរហូតដល់អាយុ ២៤ ខែ ឬយូរជាងនេះ ។ ការបំបៅកូនដោយទឹកដោះម្តាយតែមួយមុខគត់កាត់បន្ថយទាំងហានិភ័យនៃការចម្លងមេរោគអេដស៍ និងការស្លាប់ដោយសារជំងឺរាករូស, រលាកសួត និងកង្វះអាហារូបត្ថម្ភ ។ វាក៏ជួយធ្វើឱ្យប្រសើរឡើងនូវការអភិវឌ្ឍ និងសតិបញ្ញារបស់កុមារផងដែរ ។ ការស្រាវជ្រាវជាអន្តរជាតិបានបង្ហាញថា ART ដែលផ្តល់ឱ្យម្តាយ និងការព្យាបាលបង្ការដោយប្រើ ARV ចំពោះទារកក្នុងអំឡុងពេលបំបៅដោះ កាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ឱ្យនៅកម្រិតទាបបំផុត ។[24]

- ទោះបីជាគេផ្តល់អនុសាសន៍ឱ្យបន្តបំបៅកូនដោយទឹកដោះម្តាយរហូតដល់អាយុយ៉ាងតិច ១២ ខែ ម្តាយដែលមិនអាចបន្តរហូតដល់រយៈពេលនេះ គួរតែត្រូវបានគេធានាថា ការបំបៅដោះកូនរយៈពេលខ្លីវាប្រសើរជាងការមិនបានបំបៅសោះ ។
- បុគ្គលិកសុខាភិបាលគួរតែគាំទ្រម្តាយដែលរស់ជាមួយមេរោគអេដស៍ដើម្បីបំបៅកូនដោយទឹកដោះម្តាយតែមួយមុខ និងជៀសវាងការឱ្យបៅលាយគ្នា ។ ទោះយ៉ាងណាក៏ដោយ ប្រសិនបើម្តាយមិនបំបៅកូនដោយទឹកដោះតែមួយមុខទេដោយហេតុផលណាមួយ គេអាចធានាដល់បុគ្គលិកសុខាភិបាលនិងម្តាយដែលរស់នៅជាមួយមេរោគអេដស៍ ថា ការព្យាបាលដោយប្រើ ARV មានប្រសិទ្ធភាព

[24]បច្ចុប្បន្នភាពស្តីពីមេរោគអេដស៍និងការចិញ្ចឹមទារក ។ WHO ២០១៦ ។

ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងមេរោគអេដស៍ក្រោយពេលសម្រាល[25] ។ ដូច្នេះ ការឱ្យបៅលាយគ្នាមិនមែនជាហេតុផលដើម្បីបញ្ឈប់ការបំបៅកូនដោយទឹកដោះម្តាយទេ ដរាបណាម្តាយប្រើការព្យាបាលដោយ ART បានជាប់លាប់ ។

- ម្តាយផ្ទុកមេរោគអេដស៍ទាំងអស់ដែលបំបៅដោះកូន គួរតែប្រើ ART ក្នុងអំឡុងពេលបំបៅកូនដោយទឹកដោះម្តាយទាំងមូល ហើយបន្តពេញមួយជីវិតដើម្បីសុខភាពផ្ទាល់ខ្លួនរបស់ពួកគេ និងដើម្បីបង្ការការចម្លងមេរោគអេដស៍តាមរយៈទឹកដោះម្តាយ ។ សូមធានាដល់ម្តាយថា ការព្យាបាលដោយ ART នឹងមិនបង្កគ្រោះថ្នាក់ដល់ទារកទេ ។
- រាល់ទារកដែលប្រឈមនឹងមេរោគអេដស៍ទាំងអស់ គួរទទួលបានការព្យាបាលបង្ការដោយ ARV សម្រាប់រយៈពេល ៦ ឬ ១២ សប្តាហ៍ ក្រោយពេលកើត ផ្អែកលើស្ថានភាពនៃការប្រឈមរបស់ពួកគេ (សូមមើលផ្នែកទី ៤.១.១.) ។

- កុមារដែលប្រឈមនឹងមេរោគអេដស៍ដែលគ្មានឪពុកម្តាយ គួរតែត្រូវបានគាំទ្រដោយវិធីចិញ្ចឹមជំនួសឱ្យបានយ៉ាងហោចណាស់ ១២ ខែ តាមរយៈការបញ្ជូនទៅអង្គការពាក់ព័ន្ធ ។ ការអនុវត្តវិធីចិញ្ចឹមជំនួសមិនគួរត្រូវបានលើកទឹកចិត្តចំពោះចំណោមប្រជាជនទូទៅនោះទេ ។ បើទោះបីជាបែបនេះក្តី ក្នុងករណីម្តាយជ្រើសរើសមិនបំបៅកូនដោយទឹកដោះរបស់គាត់ គាត់គួរតែទទួលបានការប្រឹក្សាលម្អិតនិងការគាំទ្រអំពីវិធីចិញ្ចឹមជំនួសទឹកដោះម្តាយប្រកបដោយសុវត្ថិភាព និងទទួលបានការបណ្តុះបណ្តាលអំពីរបៀបរៀបចំឱ្យបានត្រឹមត្រូវនិងមានអនាម័យ (សូមមើលខាងក្រោម) ។

## ការចិញ្ចឹមតាមវិធីជំនួសទឹកដោះម្តាយ

- នៅពេលពិចារណាអំពីការចិញ្ចឹមទារកដោយវិធីជំនួសទឹកដោះម្តាយ អ្នកផ្តល់សេវាថែទាំសុខភាពត្រូវយកចិត្តទុកដាក់ ធានាថា ការផ្គត់ផ្គង់ទឹកដោះគោមិនមានការអាក់ខានសម្រាប់ទារកសម្រាប់រយៈពេលយ៉ាងហោចណាស់ ១២ ខែ ហើយថា ស្ត្រីយល់ច្បាស់អំពីវិធីរៀបចំឆុងទឹកដោះគោដោយត្រឹមត្រូវ ។

---

[25]គោលការណ៍ណែនាំសំយោគស្តីពីការប្រើប្រាស់ឱសថប្រឆាំងវីរុសសម្រាប់ព្យាបាល និងបង្ការការឆ្លងមេរោគអេដស៍, WHO, 2016

- ទឹកដោះគោស្រស់ ទឹកសណ្តែក ឬទឹកដោះគោខាប់ មិនគួរផ្តល់ឱ្យទារកឡើយ ។ ម្តាយដែលជ្រើសរើសយកការមិនបំបៅកូនដោយទឹកដោះម្តាយ គួរតែផ្តល់តែម្សៅទឹកដោះគោដែលមានស្តង់ដារអន្តរជាតិ

**ប្រអប់ទី ១២ ៖ លក្ខខណ្ឌតម្រូវសម្រាប់ការចិញ្ចឹមដោយទឹកដោះគោម្សៅដែលមានសុវត្ថិភាព ៖**

- ទឹកដែលមានសុវត្ថិភាព (ទឹកដាំពុះ) និងអនាម័យ ត្រូវបានធានានៅថ្នាក់គ្រួសារនិងសហគមន៍
- ម្តាយ/អ្នកថែទាំអាចផ្តល់ទឹកដោះគោម្សៅដល់ទារកបានគ្រប់គ្រាន់ដើម្បីគាំទ្រដល់ការលូតលាស់និងការអភិវឌ្ឍធម្មតារបស់ទារក
- អ្នកម្តាយ/អ្នកថែទាំអាចរៀបចំសម្ភារ (ដបទឹកដោះគោ) ឱ្យបានស្អាត (លាងសម្អាតជាមួយទឹកក្តៅ ទឹកសាប៊ូ និងលាងជម្រះជាមួយទឹកស្អាត) និងអាចស្ងោរដបនិងក្បាលដោះដើម្បីរម្ងាប់មេរោគ ។
- ម្តាយឬអ្នកថែទាំ ត្រូវឱ្យទារកបៅទឹកដោះគោដែលឆុងរួចឱ្យអស់ក្នុងរយៈពេលពីរម៉ោង ឬបោះចោលប្រសិនបើមិនបានឱ្យបៅហើយមិនបានដាក់ក្នុងទូទឹកកកក្នុងរយៈពេល ២ ម៉ោងក្រោយការឆុង (ឬយកឱ្យបៅក្នុងរយៈពេល ២៤ ម៉ោង ប្រសិនបើ បានរក្សាទុកក្នុងទូទឹកកក ប៉ុន្តែត្រូវឱ្យបៅមិនលើសពី ២ ម៉ោង បន្ទាប់ពីការកម្តៅឡើងវិញ)
- ក្នុងរយៈពេល ៦ ខែដំបូង ម្តាយ/អ្នកថែទាំអាចផ្តល់ទឹកដោះគោម្សៅតែមួយមុខគត់ដល់ទារក និងមានការគាំទ្រពីគ្រួសារគាំទ្រសម្រាប់ការអនុវត្តនេះ។

- ដូចជា ផលិតផលជំនួសទឹកដោះម្តាយ (*replacement feed*) ។

## 6.2 ការតាមដានទារកដែលប្រឈមនឹងមេរោគអេដស៍

### *6.2.1.ការផ្តល់ថ្នាំបង្ការ និងសេវាបង្ការជាប្រចាំផ្សេងទៀត*

ការផ្តល់ថ្នាំបង្ការជាប្រចាំសម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍ គឺដូចគ្នានឹងកុមារដែលមិនប្រឈមនឹងមេរោគអេដស៍ដែរ ។ ការផ្តល់ថ្នាំបង្ការគួរតែចាប់ផ្តើមនៅពេលកើត ជាមួយ BCG និងដូសពេលកើតនៃថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ ក្នុងរយៈពេល ២ ម៉ោងក្រោយពេលកើត ។ បន្ទាប់មក ម្តាយគួរតែទទួលប្រឹក្សាឱ្យយកទារករបស់ពួកគេទៅទទួលថ្នាំបង្ការបន្ថែមទៀត នៅឯមណ្ឌលសុខភាពក្នុងមូលដ្ឋានរបស់ពួកគេ ឬនៅមន្ទីរពេទ្យដែលមានទីតាំងសេវា OI/ART ឬសេវាថែទាំជំងឺអេដស៍កុមារនៅទីនោះ ដោយចាប់ផ្តើមពីអាយុ ៦ សប្តាហ៍ ផ្អែកអនុសាសន៍នៃគោលនយោបាយផ្តល់ថ្នាំបង្ការរបស់កម្មវិធីជាតិផ្តល់ថ្នាំបង្ការ ។ លើសពីនេះទៀត ការប្រើជាប្រចាំនូវវិធីបង្ការដោយប្រើថ្នាំគ្រាប់កាប់ស៊ុលវីតាមីនអា (VAC) និងមេបង់ដាហ្សុល (mebendazole) គួរចាប់ផ្តើមនៅអាយុ ៦ ខែ ដូចគ្នានឹងកុមារដែលមិនប្រឈមនឹងផ្ទុកមេរោគអេដស៍ដែរ

និងបន្តរៀងរាល់ ៦ ខែរហូតដល់អាយុ ៥ ឆ្នាំ ។ ការតាមដានការលូតលាស់ក៏នឹងត្រូវបានធ្វើឡើងផងដែរក្នុងអំឡុងពេលទទួលថ្នាំបង្ការ និងវីតាមីនអា ។

### *6.2.2. ការតាមដានទារកដែលប្រឈមចំពោះមេរោគអេដស៍*

បន្ថែមលើវិធានការតាមធម្មតាដែលបានពិពណ៌នាខាងលើសម្រាប់ទារកទាំងអស់, ទារកដែលប្រឈមនឹងមេរោគអេដស៍គួរតែទទួលបានសេវាដូចខាងក្រោម ៖

## ភ្លាមៗបន្ទាប់ពីសម្រាល

- ធ្វើតេស្ត DNA PCR ( សូមមើលជំពូកទី ៣ ), និង
- ទទួលការព្យាបាលបង្ការ ARV ដោយប្រើ NVP តែមួយមុខ (សម្រាប់ស្ថានភាពដែលមានការប្រឈមទាប ) ឬប្រើសេរ៉ូ NVP និង AZT ពីរមុខ ( សម្រាប់ស្ថានភាពដែលមានការប្រឈមខ្ពស់ ) ។ ( សូមមើលជំពូកទី ៤ ), និង
- ចុះឈ្មោះជាមុននៅគ្លីនិក PAC ឬ ART មុនពេលចេញពីមន្ទីរពេទ្យដើម្បីតាមដានបន្តទៀត រួមទាំងការធ្វើរោគវិនិច្ឆ័យទារកនៅអាយុ ៦ សប្តាហ៍, ការព្យាបាលបង្ការដោយប្រើថ្នាំ cotrimoxazole និងការធ្វើរោគវិនិច្ឆ័យមេរោគអេដស៍ចុងក្រោយ។

ទម្រង់បែបបទបញ្ជូនទារកដែលប្រឈមមេរោគអេដស៍ (សាលកបត្រ ) គួរតែត្រូវបានបំពេញនៅអគាសម្ភព (លេខកូដទារក ត្រូវបានផ្តល់ដោយអគារសម្ភព ឬ PAC ) ភ្ជាប់ទៅនឹងប័ណ្ណចាក់ថ្នាំបង្ការរបស់ទារក និងយកទៅកាន់គ្លីនិក ART ឬ PAC ។

## ត្រឹមអាយុ ៦ សប្តាហ៍ ទារកដែលប្រឈមនឹងមេរោគអេដស៍ទាំងអស់ គួរទទួលបាន៖

- តេស្ត HIV-DNA PCR បន្ថែម ។ កំណត់សម្គាល់៖ ប្រសិនបើ DNA-PCR មិនត្រូវបានធ្វើឡើងនៅពេលកើតទេ គេគួរធ្វើនៅពេលណាមានឱកាស ជាជាងរង់ចាំរហូតដល់អាយុ ៦ សប្តាហ៍ ។
- Cotrimoxazole សម្រាប់បង្ការ OI ( សូមមើលផ្នែកទី 4.6.2 សម្រាប់ព័ត៌មានលម្អិត )

## ពី ៦ សប្តាហ៍ ដល់ ១៧ ខែ

- ទារកដែលប្រឈមនឹងមេរោគអេដស៍ ដែលមិនធ្លាប់បៅដោះម្តាយ អាចឈប់ប្រើ Co-trimaxazole ( CTX ) ប្រសិនបើតេស្ត DNA-PCR នៅ ៦ សប្តាហ៍ អវិជ្ជមាន ហើយមិនត្រូវការតេស្តបន្ថែមទៀតទេ រហូតដល់អាយុ ១៨ ខែ ។

- ទារកដែលប្រឈមនឹងមេរោគអេដស៍ (HEI) ដែលបៅដោះម្ដាយ ត្រូវបន្ត CTX ដោយមានការត្រួតពិនិត្យប្រចាំខែនៅ PAC និងធ្វើតេស្តមេរោគអេដស៍ម្តងទៀត នៅអាយុ ៦ សប្ដាហ៍ បន្ទាប់ពីការបញ្ឈប់ការបំបៅដោះ ។ ប្រសិនបើទារកមានអាយុក្រោម ៩ ខែ គេត្រូវធ្វើតេស្ត PCR មួយទៀត ។ ប្រសិនបើអាយុលើស 9 ខែ គេត្រូវធ្វើតេស្តអង្គបដិបក្ខប្រាណ ។ ប្រសិនបើតេស្តអង្គបដិបក្ខប្រាណឃើញវិជ្ជមាន ត្រូវធ្វើ PCR ដើម្បីបញ្ជាក់ ។
    - ប្រសិនបើនៅពេលណាមួយ ទារកដែលប្រឈមនឹងមេរោគអេដស៍ដែលបៅដោះម្ដាយ បង្ហាញពីរោគសញ្ញាដែលទាក់ទងនឹងមេរោគអេដស៍ ពេលនៅ ត្រូវធ្វើតេស្តមេរោគអេដស៍ភ្លាមៗ (ធ្វើតេស្ត PCRT បើ < ៩ ខែ បើមិនដូច្នោះទេ ធ្វើតេស្តអង្គបដិបក្ខប្រាណ បន្ទាប់មក PCR បើតេស្តអង្គបដិបក្ខប្រាណវិជ្ជមាន) ។
    - ទារកដែលបៅដោះម្ដាយអាចឈប់ CTX នៅអាយុ ៦ សប្ដាហ៍ បន្ទាប់ពីឈប់បៅដោះម្ដាយ ប្រសិនបើតេស្តមេរោគអេដស៍អវិជ្ជមាន ។

### អាយុ ១៨ ខែ ៖

- all HIV-exposed infantsទារកដែលប្រឈមនឹងមេរោគអេដស៍ទាំងអស់ ត្រូវធ្វើតេស្តអង្គបដិបក្ខប្រាណមេរោគអេដស៍ ។ ប្រសិនបើនៅបំបៅដោះនៅពេលនោះ ទារកនោះត្រូវធ្វើតេស្តអង្គបដិបក្ខប្រាណមួយដងទៀតនៅអាយុ ៦ សប្ដាហ៍ ក្រោយពីឈប់បៅដោះម្ដាយទាំងស្រុង ។

ការតាមដានបន្តខាងលើសន្មតថា តេស្តមេរោគអេដស៍គឺអវិជ្ជមាន ។ សូមមើលគោលការណ៍ណែនាំស្ដីពីការគ្រប់គ្រងនិងព្យាបាលមេរោគអេដស៍សម្រាប់ទារក កុមារ និងយុវវ័យ សម្រាប់ព័ត៌មានលម្អិតអំពីការគ្រប់គ្រងទារកដែលប្រឈមនឹងមេរោគអេដស៍ ដែលមានតេស្តមេរោគអេដស៍វិជ្ជមាន ។

## 6.3 ការតាមដានសម្រាប់ទារកដែលប្រឈមនឹងមេរោគស្វាយ

នៅពេលសម្រាលកូនចំពោះម្ដាយបានធ្វើតេស្តវិជ្ជមានចំពោះមេរោគស្វាយដោយប្រើតេស្តរហ័ស គួរពិនិត្យមើលកំណត់ត្រាឯកសាររបស់ម្ដាយដើម្បីរកភ័ស្តុតាងនៃការព្យាបាល ។ ប្រសិនបើម្ដាយបានទទួលថ្នាំ dose of benzathine penicillin យ៉ាងតិចមួយដូស ក្នុងពេលមានផ្ទៃពោះ ។ មិនមានការណែនាំឱ្យព្យាបាលចំពោះទារកឡើយ លើកលែងតែមានសញ្ញាជំងឺស្វាយពីកំណើតដូចខាងក្រោម ៖

សញ្ញាគ្លីនិកពីដំបូង (អាយុតិចជាង ២ ឆ្នាំ)

- កន្ទួលចាប់ផ្ដើមពីពងតូចៗ ជាពិសេស នៅលើបាតដៃ និងបាតជើង ហើយក្រោយមកទៀត ប្ដូរទៅជាពណ៌ទង់ដែង សំប៉ែត ឬកន្ទួលប៉ោងរដិបរដុប ។

- រលោកច្រមុះ (សំឡេងក្រងួរ)
- ហៀរសំបោរពុំរ៉ែ
- គ្រុនក្តៅ
- មួម៉ៅ
- lymphadenopathy ជាទូទៅ (កូនកណ្តុររីកធំ)
- Hepatosplenomegaly (ថ្លើមរីកធំ និង/ឬអណ្តើករីក ដុំក្នុងពោះ)
- គ្រោងឆ្អឹង (ឆ្អឹង) ខុសប្រក្រតី
- រឹងចុងដៃជើង (មិនអាចកំរើកដៃជើង ហើយឈឺ)
- មិនអាចលូតលាស់ ឬសម្រេចបានដំណាក់កាលអភិវឌ្ឍន៍សំខាន់ៗ

ចំពោះទារកធំ និងកុមារតូច

- ធ្មេញ
- ធ្មេញរាងអក្សរវីនិងដង្កៀបខុសប្រក្រតី ហៅថា ធ្មេងហ៊ុចជីនសាន់ (Hutchinson)
- ឈឺឆ្អឹង
- ងងឹតភ្នែក
- កែវភ្នែកស្រអាប់ (គម្របគ្រាប់ភ្នែក)
- ស្តាប់មិនសូវឮ ឬថ្លង់
- ខូចរាងច្រមុះ ដោយខ្ទង់ច្រមុះសំប៉ែត (ច្រមុះបាក់ខ្ទង់)
- បន្ទះពណ៌ប្រផេះដូចក្នាសមុយកឹជុំវិញរន្ធគូទនិងទ្វារមាស
- ហើមឈឺ
- ស្មងជើងប៉ោង (បញ្ហាឆ្អឹងជើងខាងក្រោម)
- សំលាកស្បែកជុំវិញមាត់ ប្រដាប់ភេទ និងរន្ធគូទ

ប្រសិនបើមានសញ្ញាណាមួយខាងលើនៅពេលកើត ឬកត់សម្គាល់ឃើញក្នុងកំឡុងពេលតាមដានជាបន្តបន្ទាប់ គេគួរព្យាបាលទារកសម្រាប់ជំងឺជំងឺស្វាយពីកំណើតដូចដែលបានពិពណ៌នានៅក្នុងតារាងទី ៧ នៃផ្នែកទី ៤.២ ។

ប្រសិនបើម្តាយមិនត្រូវបានព្យាបាលអំឡុងពេលមានផ្ទៃពោះទេ ឬបានព្យាបាលដោយថ្នាំក្រៅពីថ្នាំប៉េនីស៊ីលីន ឬបានព្យាបាលតិចជាង ៣០ ថ្ងៃមុនពេលសម្រាលនោះ ទារកក៏ត្រូវទទួលការព្យាបាលសម្រាប់ជំងឺស្វាយពីកំណើតផងដែរ ទោះបីជាមិនមានរោគសញ្ញាក៏ដោយ។

សូមមើលគោលការណ៍ណែនាំព្យាបាលជំងឺស្វាយពីកំណើតក្នុងផ្នែកទី ៤.២

**ប្រអប់ទី ១៣ ៖ ការណែនាំសម្រាប់ការព្យាបាលជំងឺស្វាយពីកំណើត**

1. **មេរោគស្វាយវិជ្ជមាន * ម្តាយដែលមិនបានទទួលការព្យាបាលក្នុងពេលមានផ្ទៃពោះ**

2. **មេរោគស្វាយវិជ្ជមាន * ម្តាយដែលត្រូវបានព្យាបាលក្នុងអំឡុងពេលមានផ្ទៃពោះប៉ុន្តែថ្នាំក្រៅពីប៉េនីស៊ីលីន** (penicillin)

3. **មេរោគស្វាយវិជ្ជមាន * ម្តាយដែលត្រូវបានព្យាបាលដោយថ្នាំប៉េនីស៊ីលីន ប៉ុន្តែតិចជាង ៣០ ថ្ងៃ មុនពេលសម្រាល**

4. **មេរោគស្វាយវិជ្ជមាន * ម្តាយដែលត្រូវបានព្យាបាលដោយថ្នាំប៉េនីស៊ីលីន លើសពី ៣០ ថ្ងៃ មុនពេលសម្រាល ប្រសិនបើទារកបង្ហាញសញ្ញាគ្លីនិកនៃជំងឺស្វាយពីកំណើត ។**

** វិជ្ជមានតាមរយៈការធ្វើតេស្តរហ័ស TPHA ដោយមិនមានធ្វើតេស្ត RPR, ឬ តេស្តរហ័ស TPHA វិជ្ជមាន ដែលមានប្រតិកម្ម RPR ។*

6.4 ការតាមដានទារកដែលប្រឈមនឹងមេរោគរលាកថ្លើមប្រភេទបេ

## ការផ្តល់ថ្នាំបង្ការ

បន្ថែមពីលើដូសបង្ការ HBV ភ្លាមៗពេលកើត ទារកទាំងអស់គួរតែទទួលបានថ្នាំបង្ការនេះចំនួន ៣ ដូសបន្ថែមទៀត និងថ្នាំបង្ការផ្សេងៗទៀតតាមកាលវិភាគជម្មតា ។ ចំពោះទារកដែលកើតពីម្តាយវិជ្ជមាន HBsAg ត្រូវទទួលដូសបង្ការ HBV ពេលកើត ក្នុងអំឡុងពេលពីរម៉ោងក្រោយពេលសម្រាល ជាពិសេសខណៈពេលកំពុងស្ថិតក្នុងបន្ទប់សម្រាលកូន ។

## ការតាមដានទារក

នៅអាយុ ៧ ទៅ ១២ ខែ (ហើយយ៉ាងហោចណាស់ ១ ខែ បន្ទាប់ពីបានទទួលថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេពេញលេញ) ទារកដែលម្តាយមានវិជ្ជមាន HBsAg ក្នុងពេលមានផ្ទៃពោះ (ដោយមិនគិតថា ម្តាយបានទទួលថ្នាំ ARV នោះទេ) គួរតែធ្វើតេស្ត HBsAg ។ ប្រសិនបើវិជ្ជមាន ទារកគួរតែត្រូវបានវាយតម្លៃដោយគ្រូពេទ្យដែលទទួលបានទទួលការបណ្តុះបណ្តាលផ្នែកការគ្រប់គ្រង HBV ។

# ជំពូកទី ៧ ៖ ផែនការគ្រួសារ

សេវាផែនការគ្រួសារ គឺជាសមាសភាគសារវន្តមួយនៃកញ្ចប់សកម្មភាពបង្ការនិងថែទាំសម្រាប់ការបង្ការការចម្លងពីម្តាយទៅកូន ។ ការការពារការមានគភ៌ដែលមិនចង់បានក្នុងចំណោមស្ត្រីដែលឆ្លងមេរោគអេដស៍ និងមេរោគរលាកថ្លើមប្រភេទបេ អាចកាត់បន្ថយអត្រាមរណភាពមាតានិងទារក ហើយជាពិសេស ក្នុងចំណោមស្ត្រីដែលមានហានិភ័យខ្ពស់, កាត់បន្ថយចំនួននៃករណីឆ្លងថ្មីដែលកើតឡើងតាមរយៈការចម្លងពីម្តាយទៅកូន ។ ប្រសិនបើប្រើជាប់លាប់និងត្រឹមត្រូវ ស្រោមអនាម័យអាចការពារបានទាំងការមានផ្ទៃពោះ និងជំងឺឆ្លងនានា រួមទាំងជំងឺរលាកថ្លើមប្រភេទបេ, ជំងឺកាមរោគ និងមេរោគអេដស៍ ។ វិធីសាស្ត្រពីរមុខ - ពោលគឺ ការប្រើស្រោមអនាម័យជាមួយវិធីពន្យារកំណើតទំនើបមួយទៀត ដើម្បីការពារទាំងការឆ្លងរោគ និងការមានផ្ទៃពោះដោយអចេតនា - គួរតែត្រូវបានជំរុញ ។

សេវាផែនការគ្រួសារ/ពន្យារកំណើត គួរតែផ្តល់ព័ត៌មាននិងសេវាប្រកបដោយគុណភាពខ្ពស់និងដែលផ្តោតលើអតិថិជន ព្រមទាំងផ្តល់នូវមធ្យោបាយពន្យារកំណើតទំនើបៗ ដល់ស្ត្រីនិងដៃគូរបស់ពួកគេ (ជាពិសេសក្រុមដែលមានហានិភ័យខ្ពស់) រួមទាំង បុគ្គលដែលមិនទាន់រៀបការនិងយុវវ័យ ។ ស្ត្រីគួរតែត្រូវបានផ្តល់ជូននូវព័ត៌មានឱ្យបានគ្រប់គ្រាន់ដើម្បីធ្វើការជ្រើសរើសមធ្យោបាយពន្យារកំណើតដែលផ្អែកលើព័ត៌មានដែលមាននិងស្ម័គ្រចិត្ត ។

សេវាពន្យារកំណើតគួរតែត្រូវបានផ្តល់ជូនម្តាយគ្រប់រូប ដោយមិនគិតពីស្ថានភាពមេរោគអេដស៍ ឬមេរោគរលាកថ្លើមប្រភេទបេ ក្នុងអំឡុងពេលថែទាំផ្ទៃពោះមុនពេលសម្រាល និងក្រោយពេលសម្រាល និង (សម្រាប់ម្តាយដែលផ្ទុកមេរោគអេដស៍) ក្នុងអំឡុងពេលមកពិនិត្យនៅទីតាំង ART ដើម្បីជួយឱ្យស្ត្រីធ្វើការជ្រើសរើសយកមធ្យោបាយពន្យារកំណើតដែលសមស្របបំផុត សម្រាប់ស្ថានភាពជាក់លាក់របស់ពួកគេ ដោយផ្អែកលើព័ត៌មានដែលមាន ។ ព័ត៌មានដែលផ្តល់ដល់អតិថិជន គួររួមបញ្ចូលយ៉ាងហោចណាស់ ៖

- ការយល់អំពីប្រសិទ្ធភាពនៃមធ្យោបាយពន្យារកំណើត ។
- ការប្រើប្រាស់មធ្យោបាយពន្យារកំណើតបានត្រឹមត្រូវ
- ផលរំខានទូទៅ
- ហានិភ័យចំពោះសុខភាព និងអត្ថប្រយោជន៍នៃមធ្យោបាយពន្យារកំណើត
- សញ្ញានិងរោគសញ្ញាដែលត្រូវវិលត្រឡប់មកគ្លីនិកវិញ
- ព័ត៌មានអំពីការវិលត្រឡប់ទៅរកការមានកូន បន្ទាប់ពីការឈប់ប្រើមធ្យោបាយពន្យារកំណើត និង
- ព័ត៌មានស្តីពីការបង្ការជំងឺកាមរោគ។

ស្ត្រីដែលផ្ទុកមេរោគអេដស៍ អាចទទួលបានមធ្យោបាយរយៈពេលខ្លី (ស្រោមអនាម័យ, ថ្នាំគ្រាប់ និងថ្នាំចាក់) នៅឯសេវា ART ដោយមិនគិតថ្លៃ ហើយទីតាំង ART គួរតែបញ្ជូនពួកគេទៅកាន់មូលដ្ឋានសុខាភិបាលដែលមានមធ្យោបាយកងដាក់ដៃ កងដាក់ក្នុងស្បូន និងវិធីអចិន្ត្រៃយ៍ ។ គ្រូពេទ្យ (ប្រធានក្រុម) និងអ្នកផ្តល់ប្រឹក្សានៅគ្លីនិក ART គួរតែត្រូវបានបណ្តុះបណ្តាលអំពីការដាក់បញ្ចូលគ្នានូវផែនការគ្រួសារ-មេរោគអេដស៍ ។ ស្ត្រីដែលគ្មានមេរោគអេដស៍អាចទទួលបានសេវាពន្យារកំណើតនៅមណ្ឌលសុខភាព និងមន្ទីរពេទ្យបង្អែក ។

7.2 ផលិតផល និងសម្ភារពន្យារកំណើត

- បន្ថែមពីលើស្រោមអនាម័យ, មធ្យោបាយរយៈពេលខ្លីផ្សេងទៀត ដូចជា ថ្នាំគ្រាប់លេបតាមមាត់និងថ្នាំចាក់ប្រូជេស្តេរ៉ូន ត្រូវតែមាននៅតាមគ្លីនិក ART ដើម្បីធានាថា ស្ត្រីផ្ទុកមេរោគអេដស៍អាចទទួលបានសេវាពន្យារកំណើតកាន់តែងាយស្រួលនិងដោយមិនគិតថ្លៃ ។
- ស្រោមអនាម័យ, ថ្នាំគ្រាប់និងថ្នាំចាក់ ក៏មាននៅតាមមណ្ឌលសុខភាពផងដែរ ដោយផ្តល់ជូនក្នុងតម្លៃទាប ។ កងដាក់ក្នុងស្បូន អាចរកបាននៅតាមមណ្ឌលសុខភាពជាច្រើន ប៉ុន្តែមិនទាំងអស់ទេ និងមាននៅតាមមន្ទីរពេទ្យផងដែរ ។ កងដាក់ដៃមាននៅតាមមន្ទីរពេទ្យ ។

7.3 មធ្យោបាយពន្យារកំណើត និងការការពារពីរមុខ

- ព័ត៌មានទូលំទូលាយទាក់ទងនឹងគុណសម្បត្តិនិងគុណវិបត្តិនៃវិធីពន្យារកំណើតផ្សេងៗ គួរតែត្រូវបានផ្តល់ជូនស្ត្រីទាំងអស់ ដោយមិនគិតពីស្ថានភាពអេដស៍ ឬ HBV ។
- នៅពេលមានការប្រឈមចំពោះការចម្លងជំងឺកាមរោគ/មេរោគអេដស៍ ឬ HBV ជាការសំខាន់ដែលអ្នកផ្តល់សេវាថែទាំសុខភាពត្រូវណែនាំឱ្យប្រើវិធី**ការពារពីរមុខ** តាមរយៈការប្រើស្រោមអនាម័យជាប់លាប់ព្រមពេលជំណាលគ្នាជាមួយនឹងវិធីផ្សេងទៀតសម្រាប់ការពារការមានផ្ទៃពោះដោយអចេតនា និងការឆ្លងរោគផ្សេងៗ ។
- អ្នកផ្តល់សេវាថែទាំសុខភាពគួរតែរំលឹកគូស្វាមីភរិយាដែលឆ្លងមេរោគអេដស៍និង HBV អំពីសារៈសំខាន់នៃការប្រើប្រាស់ស្រោមអនាម័យត្រឹមត្រូវនិងជាប់ជាប្រចាំ និងបង្រៀនពួកគេអំពីការប្រើប្រាស់ស្រោមអនាម័យត្រឹមត្រូវ និងជំនាញចរចាប្រើស្រោមអនាម័យ ។
- សម្រាប់ព័ត៌មានលម្អិតអំពីវិធីពន្យារកំណើតដែលមាន សូមមើលតារាងទី ១៣ ខាងក្រោម ។
- លើកលែងតែការចងបំពង់មេជីវិតបុរសនិងការចងដៃស្បូនស្ត្រី ការប្រើមធ្យោបាយពន្យារកំណើតមិនបណ្តាលឱ្យមានការគ្មានកូននោះទេ ។ ការវិលត្រឡប់ទៅរកភាពមានកូន គឺកើតឡើងវិញភ្លាមៗ

សម្រាប់គ្រប់វិធីសាស្ត្រទាំងអស់ លើកលែងតែការចាក់ DMPA (Depot medroxy progesterone acetate, or Depo-Provera) ។ មធ្យោបាយនេះមិនបណ្តាលឱ្យការគ្មានកូនជាអចិន្ត្រៃយ៍នោះទេ ប៉ុន្តែការវិលត្រឡប់ទៅរកភាពមានកូនវិញចំពោះវិធីសាស្ត្រនេះ គឺយឺតជាងវិធីផ្សេងទៀត ហើយអាចត្រូវការពេលពី ៦ ទៅ ៩ ខែ គិតចាប់ពីថ្ងៃចាក់ចុងក្រោយ ដោយមិនគិតពីរយៈពេលនៃការប្រើប្រាស់ ។

- វិធីអចិន្ត្រៃយ៍ (ការចងដៃស្បូន ឬការវះចងបំពង់មេជីវិតឈ្មោល) គឺជាវិធីអចិន្ត្រៃយ៍ ។ គូស្វាមីភរិយាទាំងអស់ដែលពិចារណាវិធីសាស្ត្រទាំងនេះ គួរទទួលការប្រឹក្សា និងទម្រង់ការដែលអនុវត្តដោយអ្នកផ្តល់សេវាដែលបានទទួលការបណ្តុះបណ្តាល ។
- ចំពោះ**ស្ត្រីដែលផ្ទុកមេរោគអេដស៍ ដែលកំពុងប្រើ ART ដែលរួមបញ្ចូល NNRTI** (ឧទា. EFV) **ឬ PI**, ត្រូវកត់សម្គាល់ថា **ប្រសិទ្ធភាពនៃថ្នាំគ្រាប់ដែលរួមបញ្ចូលពីរមុខ (CoCs) ដូសទាប ត្រូវធ្លាក់ចុះ** ។ CoCs នឹងនៅតែផ្តល់ការការពារបានខ្លះ ហើយប្រសើរជាងការមិនប្រើវិធីពន្យារកំណើតសោះ ប៉ុន្តែ **អត្រានៃការបរាជ័យនឹងខ្ពស់ជាង**ចំពោះស្ត្រីដែលប្រើ ART ។ ដូច្នេះ ស្ត្រីដែលប្រើ ART ដែលចង់ជៀសវាងឬពន្យារពេលការមានផ្ទៃពោះ ត្រូវបានណែនាំឱ្យប្រើវិធីសាស្ត្រផ្សេងមួយទៀត ដូចជា ថ្នាំចាក់, កងដាក់ដៃ ឬកងដាក់ក្នុងស្បូន ។ (គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងមេរោគអេដស៍របស់ NCHADS ឆ្នាំ ២០២០) ។
- គេមិនដឹងថា ស្ត្រីដែលមាន HBV ដែលប្រើថ្នាំ Tenofovir មានការប៉ះពាល់លើប្រសិទ្ធភាពរបស់មធ្យោបាយពន្យារកំណើតទេ ។
- **វិធីសាស្ត្របែបបុរាណ ដូចជា វិធីសាស្ត្រប្រតិទិន (ការតមតាមពេលវេលា "rhythm") និងវិធីដកលិង្គចេញ មិនត្រូវបានណែនាំសម្រាប់ស្ត្រីដែលមានផ្ទុកមេរោគអេដស៍/HBV នោះទេ ដោយសារតែអត្រាបរាជ័យខ្ពស់ ។ គេក៏មិនត្រូវពឹងផ្អែកលើការបំបៅកូនដោយទឹកដោះម្តាយដែរ (វិធីសាស្ត្របំបៅដោះកូនដើម្បីឱ្យរាំងរដូវ ឬ LAM) តែមួយមុខនោះឡើយ ពីព្រោះស្ត្រីអាចមានផ្ទៃពោះមុនពេលមានឈាមរដូវរបស់នាងវិលត្រឡប់មកវិញ ទោះបីជាបំបៅដោះកូនតែមួយមុខគត់ក៏ដោយ ។**

**Table 14: Birth Spacing and Family Planning Methods**

| មធ្យោបាយ | សកម្មភាព | គុណសម្បត្តិ | គុណវិបត្តិ | ភាពសមស្រប | ពេលណាត្រូវចាប់ផ្តើម |
|---|---|---|---|---|---|
| **វិធីរបាំង (ស្រោមអនាម័យបុរស)** | ធ្វើការដោយបង្កើតរបាំងដែលទប់ស្កាត់ទឹកកាមមិនឱ្យចូលក្នុងទ្វារមាស ការពារការមានផ្ទៃពោះនិងការឆ្លងរោគ | • ការពារពីការចម្លងជំងឺកាមរោគ/មេរោគអេដស៍ HBV និងការមានផ្ទៃពោះ ប្រសិនបើប្រើត្រឹមត្រូវ<br>• ងាយស្រួលប្រើនិងរកបាន<br>• មិនមានផលរំខានអ្វីទេ, គ្មានគ្រោះថ្នាក់<br>• មិនត្រូវការវេជ្ជបញ្ជាឬការពិនិត្យសុខភាពទេ<br>• ជួយបង្ការជំងឺមហារីកមាត់ស្បូន | • ត្រូវប្រើស្រោមអនាម័យថ្មីនៅពេលរួមភេទម្តងៗ<br>• ប្តីប្រពន្ធអាចមានអារម្មណ៍មិនស្រួលក្នុងការប្រើវា<br>• អាចមានផ្ទៃពោះឬឆ្លងរោគប្រសិនបើប្រើមិនត្រឹមត្រូវនិងមិនជាប់លាប់<br>• ការប្រើប្រាស់ស្រោមអនាម័យជាប់លាប់គឺជាការពិបាក | • អតិថិជនទាំងអស់និងដៃគូ<br>• អាចប្រើបានតែមួយមុខ ឬរួមជាមួយវិធីពន្យារកំណើតផ្សេងមួយទៀត (វិធីពីរមុខ) | • អាចប្រើបានគ្រប់ពេល<br>• អាចប្រើក្នុងពេលមានផ្ទៃពោះ ដើម្បីបង្ការការឆ្លងមេរោគអេដស៍/ជំងឺកាមរោគ ឬការឆ្លងឡើងវិញ |

| | | | | | |
|---|---|---|---|---|---|
| **ថ្នាំគ្រាប់ COC (វិធីពន្យារកំណើតលេបតាមមាត់រួមបញ្ចូល)** | បង្ការការបញ្ចេញពងពីដៃស្បូន (ការបង្កើតអូវុល)<br><br>ធ្វើឱ្យភ្នាសមុយកឺឡើងក្រាស់, ធ្វើឱ្យទឹកកាមពិបាកចូលក្នុងស្បូន<br><br>ធ្វើឱ្យជញ្ជាំងស្បូនស្តើង ដែលធ្វើឱ្យពងពិបាកបង្កកំណើត | • មានប្រសិទ្ធភាពប្រសិនបើប្រើត្រឹមត្រូវសម្រាប់ស្ត្រីដែលមិនប្រើ ART<br>• មានឈាមរដូវទៀងទាត់<br>• ជួយបង្ការជំងឺមហារីកអណ្តាស័យ, មហារីកជញ្ជាំងស្បូន និងភាពស្លេកស្លាំង<br>• មានការឈឺចាប់តិចក្នុងពេលមានរដូវ និងការបញ្ចេញអូវុល<br>• អាចមានផ្ទៃពោះភ្លាមៗនៅពេលឈប់ប្រើ។ | • ប្រសិទ្ធភាពថយចុះចំពោះស្ត្រីដែលប្រើ ART ដែលរួមបញ្ចូល NNRTI ឬ PI ។<br>• មិនការពារពីការឆ្លងជំងឺកាមរោគ/មេរោគអេដស៍<br>• ត្រូវតែប្រើប្រចាំថ្ងៃនិងដោយជាប់លាប់<br>• ផលរំខានទូទៅនៅពេលចាប់ផ្តើម៖ ឈឺដោះ, ឈឺក្បាល ប្រែប្រួលទម្ងន់ ចង់ក្អួត<br>• កាត់បន្ថយបរិមាណទឹកដោះ | • ស្ត្រីដែលមិនប្រើថ្នាំ ART ដែលរួមបញ្ចូល NNRTI ឬ PI ។<br>• ស្ត្រីដែលប្រើ NNRTI ឬ PI ក៏អាចប្រើបានដែរ, ប៉ុន្តែអត្រាបរាជ័យនឹងខ្ពស់ជាងសម្រាប់ប្រជាជនទូទៅ<br>• មានសុវត្ថិភាពសម្រាប់ស្ត្រីដែលមាន HBV រ៉ាំរ៉ៃ លើកលែងតែមុខងារថ្លើមខ្សោយ។[26]<br>• សូមមើលបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការហាមប្រើទូទៅ | • ចាប់ផ្តើមនៅថ្ងៃណាមួយ ចន្លោះពីថ្ងៃទី១ និងទី៥ នៃការមកឈាមរដូវ។ ប្រសិនបើថ្នាំគ្រាប់ត្រូវបានលេបនៅក្រោយថ្ងៃទី៥ ត្រូវប្រាកដថា ស្ត្រីនោះមិនមានផ្ទៃពោះ ហើយនាងគួរប្រើស្រោមអនាម័យរយៈពេល ៧ថ្ងៃ ប្រសិនបើរួមភេទ។<br>• ចាប់ផ្តើមភ្លាមៗ ឬនៅថ្ងៃណាមួយក្នុងអំឡុងពេល ៧ ថ្ងៃ ក្រោយពេលរំលូតដោយសុវត្ថិភាព<br>• ប្រសិនបើបំបៅកូនដោយទឹកដោះម្តាយ សូមចាប់ផ្តើមនៅខែទី ៦ ហើយត្រូវជានាថា ស្ត្រីមិនមានផ្ទៃពោះ<br>• ប្រសិនបើមិនបំបៅកូនទេ សូមចាប់ផ្តើមនៅសប្តាហ៍ទី ៦ បន្ទាប់ពីសម្រាលកូន ហើយត្រូវប្រាកដថា ស្ត្រីមិនមានផ្ទៃពោះ |

[26] Kapp et al. The effects of hormonal contraceptive use among women with viral hepatitis or cirrhosis of the liver: a systematic review . *Contraception.* Volume 80 Issue 4. October 2009

| METHOD | ACTION | ADVANTAGES | DISADVANTAGES | Eligibility | WHEN to START |
|---|---|---|---|---|---|
| POPs<br>**(ថ្នាំគ្រាប់ពន្យារកំណើតដែលមានប្រូជេស្តេរ៉ូនតែមួយមុខគត់)** | ទប់ស្កាត់ការបញ្ចេញពងពីអណ្ឌាស័យ (ធ្លាក់អូវុល)<br><br>ធ្វើឱ្យមុយកឺមាត់ស្បូនឡើងក្រាស់, ធ្វើឱ្យទឹកកាមពិបាកចូលទៅក្នុងស្បូន<br><br>ធ្វើឱ្យជញ្ជាំងស្បូនស្តើង ដែលធ្វើឱ្យពងពិបាកបង្កកំណើត | • មានប្រសិទ្ធភាព ប្រសិនបើប្រើត្រឹមត្រូវ<br>• មានឈាមរដូវទៀងទាត់<br>• ជួយការពារជំងឺមហារីកអណ្ឌាស័យ, មហារីកជញ្ជាំងស្បូន និងជំងឺស្លេកស្លាំង<br>• មានការឈឺចាប់តិចក្នុងពេលមានរដូវ និងការបញ្ចេញអូវុល<br>• អាចមានផ្ទៃពោះបានភ្លាមៗនៅពេលឈប់ប្រើ។<br>• អាចប្រើបានដោយស្ត្រីដែលមិនអាចប្រើ COC បាន ។<br>• អាចប្រើបានក្នុងពេលកំពុងបំបៅដោះកូន។ | • មិនអាចការពារការចម្លងកាមរោគ/មេរោគអេដស៍/HBV<br>• មានប្រសិទ្ធភាពតិចជាង COC<br>• ទំនងជាមានផ្ទៃពោះច្រើនជាង COC ប្រសិនបើភ្លេចលេបថ្នាំ គឺក្អួត ។ | • ស្ត្រីដែលប្រើ ART អាចប្រើមធ្យោបាយនេះដោយសុវត្ថិភាព និងប្រសិទ្ធភាព<br>• មានប្រសិទ្ធភាពសម្រាប់ស្ត្រីដែលមាន HBV រ៉ាំរ៉ៃ លើកលែងតែមុខងារថ្លើមខ្សោយ។<br>• សមស្របសម្រាប់ម្តាយដែលបំបៅកូនដោយទឹកដោះតែមួយមុខ<br>• សូមមើលបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការហាមប្រើទូទៅ។ | • ចាប់ផ្តើមប្រើថ្នាំគ្រាប់ទីមួយ នៅថ្ងៃណាមួយ ចន្លោះពីថ្ងៃទី១ និងទី៥ នៃការមកឈាមរដូវ។ ប្រសិនបើលេបថ្នាំនេះក្រោយថ្ងៃទី៥ ត្រូវប្រាកដថា ស្ត្រីមិនមានផ្ទៃពោះ ហើយគួរប្រើស្រោមអនាម័យរយៈពេល ៧ ថ្ងៃ បើរួមភេទ។<br>• អាចចាប់ផ្តើមភ្លាមៗ ឬនៅថ្ងៃណាមួយក្នុងអំឡុងពេល ៧ ថ្ងៃ និងក្រោយពេលរំលូតដោយសុវត្ថិភាព<br>• ប្រសិនបើបំបៅកូនដោយទឹកដោះ, POP អាចប្រើចន្លោះពីសប្តាហ៍ទី ៦ និងខែទី ៦ ក្រោយពេលជានាថា ស្ត្រីមិនមានផ្ទៃពោះ។ |

| | | | | | |
|---|---|---|---|---|---|
| ECPs<br>**( ថ្នាំគ្រាប់ពន្យារកំណើតបន្ទាន់ )**<br><br>**កំណត់សម្គាល់៖ មិនអាចប្រើ ECPs ជាវិធីអចិន្ត្រៃយ៍ ឬជាទម្រង់នៃការរំលូតកូនទេ** | ថ្នាំគ្រាប់ការពារមិនឱ្យមានកូនបន្ទាន់ ជួយទប់ស្កាត់ការមានផ្ទៃពោះនៅពេលប្រើក្នុងអំឡុង ៣ ថ្ងៃ ( ៧២ ម៉ោង ) ក្រោយពេលរួមភេទដោយគ្មានការពារ។<br><br>កាលណាប្រើកាន់តែឆាប់ កាន់តែប្រសើរ។<br><br>មានមុខងារទប់ស្កាត់ឬពន្យារពេលការបញ្ចេញពងពីអណ្ដាស័យ ( ការបញ្ចេញអូវុល ). | • មានប្រសិទ្ធភាពក្នុងការបង្ការការមានផ្ទៃពោះ ប្រសិនបើប្រើភ្លាមៗ ក្នុងរយៈពេល ៧២ ម៉ោងបន្ទាប់ពីរួមភេទដោយមិនបានការពារ<br>• អាចមានផ្ទៃពោះភ្លាមៗក្រោយពេលឈប់ប្រើ ECPs | • មិនអាចការពារការចម្លងកាមរោគ/មេរោគអេដស៍/HBV<br>• ប្រើតែមួយដងគត់ក្នុងអំឡុងពេលមករដូវ។ មិនអាចទប់ស្កាត់ការមានផ្ទៃពោះបានទេ ប្រសិនបើរួមភេទដោយមិនបានការពារលើសពី ៧២ ម៉ោង<br>• ផលរំខានច្រើនជាង COC. | • ស្ត្រីដែលប្រើ ART អាចប្រើវិធីនេះបានដោយសុវត្ថិភាពនិងប្រសិទ្ធភាព ប៉ុន្តែ ប្រសិនបើ ART រួមបញ្ចូល NNRTI ឬ PI, ត្រូវការបង្កើនដូសទ្វេដង ពោលគឺ ៣ មក្រ មិនមែនដូសធម្មតានៃ levonorgesterol1.5 mg[27] ទេ<br>• មានសុវត្ថិភាពសម្រាប់ស្ត្រីដែលមាន HBV រ៉ាំរ៉ៃ លើកលែងតែមុខងារថ្លើមខ្សោយ។<br>• សូមមើលបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការហាមប្រើទូទៅ។ | • ប្រើបន្ទាប់ពី៖ ការរំលោភសេពសន្ថវៈ ការរួមភេទមិនបានការពារ ឬមិនបានប្រើ/ភ្លេចមធ្យោបាយពន្យារកំណើតផ្សេងទៀត<br>• ប្រើភ្លាមៗក្រោយប្រឈម និងមិនត្រូវលើសពី ៧២ ម៉ោងក្រោយទេ។ |

[27] NCHADs. HIV Management Guidelines 2020.

| METHOD | ACTION | ADVANTAGES | DISADVANTAGES | Eligibility | WHEN to START |
|---|---|---|---|---|---|
| **ថ្នាំចាក់ (DMPA)**<br>(ប្រូជេស្ទីនតែមួយមុខគត់) | ទប់ស្កាត់ការបញ្ចេញពងពីអណ្ឌាស័យ (ធ្លាក់អូវុល)<br><br>ធ្វើឱ្យមុយកឺមាត់ស្បូនឡើងក្រាស់, ធ្វើឱ្យទឹកកាមពិបាកចូលទៅក្នុងស្បូន<br><br>ធ្វើឱ្យជញ្ជាំងស្បូនស្តើង ដែលធ្វើឱ្យពងពិបាកបង្កកំណើត | • ងាយស្រួលចងចាំ (រៀងរាល់ ៣ ខែម្តង)<br>• មានប្រសិទ្ធភាពខ្លាំង បើប្រើបានត្រឹមត្រូវ<br>• មិនបន្ថយគុណភាពទឹកដោះម្តាយ<br>• អាចកាត់បន្ថយភាពស្លេកស្លាំង<br>• អាចទប់ស្កាត់មហារីកអណ្ឌាស័យ និងមហារីកជញ្ជាំងស្បូន<br>• ភាពសម្ងាត់ | • មិនការពារទប់ទល់នឹងការចម្លងកាមរោគ/មេរោគអេដស៍/HBV<br>• សម្រាប់ស្ត្រីមួយចំនួន ត្រូវការពេលពី ៦ ទៅ ៩ ខែ ឬយូរជាងនេះ ដើម្បីមានផ្ទៃពោះបន្ទាប់ពីឈប់ប្រើ<br>• ផលរំខានទូទៅបំផុតរួមមាន៖ ការហូរឈាមច្រើន និងធ្លាក់ឈាមដុំៗពេលដំបូង បន្ទាប់មកគ្មានឈាមរដូវ, វដ្ត, ឡើងទម្ងន់។<br>• ផលរំខានអាចអូសបន្លាយរហូតដល់ ៣ ខែ ក្រោយពេលឈប់ប្រើ | • ស្ត្រីដែលប្រើ ART អាចប្រើវិធីនេះដោយសុវត្ថិភាពនិងប្រសិទ្ធភាព<br>• មានសុវត្ថិភាពសម្រាប់ស្ត្រីដែលមានជំងឺរលាកថ្លើមប្រភេទបេព្រំរ៉ៃ លើកលែងតែមុខងារថ្លើមចុះខ្សោយ។<br>• អាចប្រើដោយម្តាយដែលបំបៅដោះកូន<br>• សូមមើលបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការហាមប្រើទូទៅ | • ចាប់ផ្តើមប្រើនៅថ្ងៃណាមួយចន្លោះពីថ្ងៃទី១ និងទី៥ នៃការមកឈាមរដូវ។ ប្រសិនបើចាក់ក្រោយថ្ងៃទី៥ ត្រូវប្រាកដថាស្ត្រីមិនមានផ្ទៃពោះ ហើយនាងគួរប្រើស្រោមអនាម័យរយៈពេល ៧ ថ្ងៃ បើរួមភេទ។<br>• អាចចាប់ផ្តើមភ្លាមៗ ឬនៅថ្ងៃណាមួយក្នុងអំឡុងពេល ៧ ថ្ងៃ ក្រោយពេលរំលូតដោយសុវត្ថិភាព<br>• អាចចាប់ផ្តើមនៅសប្តាហ៍ទី ៦ ក្រោយពេលសម្រាល បន្ទាប់ពីធានាថា ស្ត្រីមិនមានផ្ទៃពោះ។ |
| **កងដាក់ដៃមានប្រសិទ្ធភាពរយៈពេលវែង**<br>បំពង់ប្លាស្ទិកតូច ដែលមានប្រូជេស្តូហ្សែនក្នុងក្រោមស្បែកនៃដើមដៃ | ទប់ស្កាត់ការបញ្ចេញពងពីអណ្ឌាស័យ (ធ្លាក់អូវុល)<br><br>ធ្វើឱ្យមុយកឺមាត់ស្បូនឡើងក្រាស់, ធ្វើឱ្យទឹកកាមពិបាកចូលទៅក្នុងស្បូន<br><br>ធ្វើឱ្យជញ្ជាំងស្បូនស្តើង ដែលធ្វើឱ្យពងពិបាកបង្កកំណើត | • មានប្រសិទ្ធភាពរយៈពេលវែង រហូតដល់ ៣-៥ ឆ្នាំ<br>• មានប្រសិទ្ធភាពក្នុងអំឡុងពេល ៨ ម៉ោងក្រោយពេលដាក់<br>• សមស្របសម្រាប់ស្ត្រីដែលមិនអាចប្រើថ្នាំគ្រាប់ដែលមានអ៊ីស្ត្រូហ្សែន<br>• មិនប៉ះពាល់ដល់ទឹកដោះ<br>• ទប់ស្កាត់ភាពស្លេកស្លាំង<br>• អាចបង្ការមហារីកអណ្ឌាស័យនិងមហារីកជញ្ជាំងស្បូន<br>• អាចដកចេញនៅពេលណាក៏បាន និងស្ត្រីអាចមានផ្ទៃពោះជាថ្មី។ | • មិនអាចការពារទប់ទល់នឹងការចម្លងកាមរោគ/មេរោគអេដស៍/HBV<br>• ស្ត្រីមិនអាចដាក់បញ្ចូលឬដកចេញកងដាក់ដៃដោយខ្លួនឯងបានទេ។ វាមានតែអ្នកផ្តល់សេវាសុខភាពដែលបានទទួលការបណ្តុះបណ្តាលប៉ុណ្ណោះទើបអាចធ្វើបាន។<br>• មានផលរំខានស្រដៀងគ្នា ដូចជា COC ឬ POP និងមធ្យោបាយពន្យារកំណើត ចាក់ដែរ។ | • ស្ត្រីដែលប្រើ ART អាចប្រើវិធីនេះដោយសុវត្ថិភាពនិងប្រសិទ្ធភាព<br>• មានសុវត្ថិភាពសម្រាប់ស្ត្រីដែលមានជំងឺរលាកថ្លើមប្រភេទបេព្រំរ៉ៃ លើកលែងតែមុខងារថ្លើមចុះខ្សោយ។<br>• អាចប្រើដោយម្តាយដែលបំបៅដោះកូន<br>• សូមមើលបញ្ជីផ្ទៀងផ្ទាត់សម្រាប់ការហាមប្រើទូទៅ | • ចាប់ផ្តើមប្រើនៅថ្ងៃណាមួយចន្លោះពីថ្ងៃទី១ និងទី៥ នៃការមកឈាមរដូវ។<br>• អាចចាប់ផ្តើមភ្លាមៗ ឬនៅថ្ងៃណាមួយក្នុងអំឡុងពេល ៧ ថ្ងៃ ក្រោយពេលរំលូតដោយសុវត្ថិភាព<br>• អាចចាប់ផ្តើមនៅសប្តាហ៍ទី ៦ ក្រោយពេលសម្រាល បន្ទាប់ពីធានាថា ស្ត្រីមិនមានផ្ទៃពោះ។<br>• អាចចាប់ផ្តើមភ្លាមៗ បើផ្លាស់ប្តូរមធ្យោបាយពន្យារកំណើតណាមួយ។ |

| METHOD | ACTION | ADVANTAGES | DISADVANTAGES | Eligibility | WHEN to START |
|---|---|---|---|---|---|
| **កងដាក់ក្នុងស្បូនទង់ដែង** ឧបករណ៍ទន់តូចដែលដាក់ចូលក្នុងស្បូន | ធ្វើសកម្មភាពជាចម្បងដោយបង្កឱ្យមានការផ្លាស់ប្តូរជាតិគីមីដែលបំផ្លាញមេជីវិតបុរសនិងពងអូវុលមុនជួបគ្នា<br><br>ធ្វើឱ្យពងដែលបង្កកំណើតពិបាកតោងជាប់ស្បូន | • ស្ត្រីដែលមានមេរោគអេដស៍ និង HBV អាចប្រើកងដាក់ស្បូនដោយសុវត្ថិភាព បើគ្មានហានិភ័យនៃជំងឺកាមរោគ<br>• មានប្រសិទ្ធភាពរហូតដល់ ១០ ឆ្នាំ<br>• មិនប៉ះពាល់ដល់ការរួមភេទ។ ដៃគូមិនដឹងថាមានកងក្នុងស្បូន<br>• សមស្របសម្រាប់ម្តាយដែលបំបៅដោះកូន<br>• អាចដោះចេញនៅពេលចង់ដោះចេញ ហើយនាងអាចមានផ្ទៃពោះភ្លាមៗ | • មិនអាចការពារទប់ទល់នឹងការចម្លងកាមរោគ/មេរោគអេដស៍/HBV<br>• អាចបង្កការឆ្លងរោគត្រង់អាងត្រគាក<br>• អាចមានឈឺបន្តិចបន្តួចក្នុងពេលឬភ្លាមៗក្រោយពេលដាក់កងក្នុងស្បូន (ការឈឺចាប់នឹងកើតឡើងក្នុងរយៈពេល ២៤ ទៅ ៤៨ ម៉ោង)<br>• ឈឺពោះក្នុងពេលមកឈាមរដូវ<br>• អាចបង្កើនលំហូរឈាមក្នុងពេលមករដូវ (បរិមាណច្រើនជាងមុននិងរយៈពេលមករដូវយូរជាងមុន)<br>• អាចមានធ្លាក់ឈាមម្តងម្កាល (ចន្លោះពេលមករដូវ) | • ជាជម្រើសល្អសម្រាប់ស្ត្រីផ្ទុកមេរោគអេដស៍និង HBV ដែលមានសុខភាពល្អ<br>• មិនត្រូវបានណែនាំសម្រាប់អតិថិជនដែលមានកាមរោគ និងអ្នកជំងឺអេដស៍ដំណាក់កាលទី ៤ ។<br>• មិនត្រូវបានណែនាំសម្រាប់ស្ត្រីដែលប្រឈមមុខខ្ពស់នឹងជំងឺកាមរោគថ្មី | • ចាប់ផ្តើមប្រើពីថ្ងៃទី១ ដល់ថ្ងៃទី ១២ នៃការមកឈាមរដូវ ក្រោយពេលធានាថា ស្ត្រីមិនមានផ្ទៃពោះ។<br>• អាចចាប់ផ្តើមភ្លាមៗ បើផ្លាស់ប្តូរមធ្យោបាយពន្យារកំណើតណាមួយ។<br>• អាចចាប់ផ្តើមក្នុងអំឡុងពេល ១២ ថ្ងៃ ក្រោយពេលរំលូតដោយសុវត្ថិភាព<br>• អាចចាប់ផ្តើមនៅសប្តាហ៍ទី ៦ ក្រោយពេលសម្រាល និងខែទី៦ ក្រោយពេលសម្រាលកូនដោយវះកាត់ បន្ទាប់ពីធានាថា ស្ត្រីមិនមានផ្ទៃពោះ។ |

| | | | | | |
|---|---|---|---|---|---|
| **មធ្យោបាយអចិន្ត្រៃយ៍៖** ការចងដៃស្បូន និងការវះកាត់ចងបំពង់មេជីវិតបុរស | ការវះចងបំពង់មេជីវិតបុរស៖ បិទឬចងផ្តាច់បំពង់ផលិតទឹកកាមនីមួយៗ រក្សាមេជីវិតពីទឹកកាម<br><br>ការចងដៃស្បូន៖ បិទឬចងផ្តាច់ដៃស្បូន។ | • ទម្រង់ការវះកាត់ប្រកបដោយសុវត្ថិភាព ប្រសិនបើអនុវត្តបានត្រឹមត្រូវ<br>• មិនចាំបាច់ចងចាំពេលវេលាដូចវិធីផ្សេងទៀត<br>• មិនបារម្ភអំពីការមានផ្ទៃពោះពេលរួមភេទ<br>• សមស្របសម្រាប់ស្ត្រីឬគូដែលមិនចង់បានកូនទៀត<br>• គ្មានផលរំខានរយៈពេលវែង។ | • មិនអាចការពារទប់ទល់នឹងការចម្លងកាមរោគ/មេរោគអេដស៍/HBV<br>• វិធីអចិន្ត្រៃយ៍ មិនអាចត្រលប់ក្រោយបានទេប្រសិនបើគូស្វាមីភរិយាផ្លាស់ប្តូរចិត្តរបស់ពួកគេនៅពេលក្រោយ<br>• សម្រាប់ការវះចងបំពង់មេជីវិតបុរស ប្តីប្រពន្ធត្រូវការប្រើស្រោមអនាម័យ ឬមធ្យោបាយពន្យារកំណើតផ្សេងទៀតរយៈពេលយ៉ាងតិច ៣ ខែ | • ប្តីប្រពន្ធដែលប្រាកដថាពួកគេមិនចង់បានកូនទៀត<br>• ពន្យារពេលធ្វើទម្រង់ការនេះនៅពេលមានជំងឺទាក់ទងនឹងជំងឺអេដស៍។<br>• ប្រើស្រោមអនាម័យពីរបីខែបន្ទាប់ពីវះចងបំពង់មេជីវិតបុរស | • អាចធ្វើបានគ្រប់ពេលនៅពេលដែលប្រាកដថាគ្មានផ្ទៃពោះ<br>• អាចធ្វើបានក្នុងរយៈពេល ៤៨ ម៉ោងបន្ទាប់ពីការរំលូតកូនដោយសុវត្ថិភាព<br>• អាចធ្វើបានក្នុងរយៈពេល ៧ ថ្ងៃបន្ទាប់ពីសម្រាលកូន ឬសប្តាហ៍ទី ៦ បន្ទាប់ពីសម្រាលកូនដោយប្រាកដថា គ្មានផ្ទៃពោះ<br>• ការចងដៃស្បូនអាចធ្វើឡើងក្នុងពេលជាមួយគ្នានៃការសម្រាលកូនដោយវះកាត់ ដោយមានការយល់ព្រមផ្អែកលើព័ត៌មានដែលមាន<br>• ការវះចងបំពង់មេជីវិតអាចធ្វើឡើងនៅពេលណាមួយ |

# ជំពូកទី ៨ ៖ ទិដ្ឋភាពរួមនៃកម្មវិធីបង្ការការចម្លងពីម្ដាយទៅកូន (PMTCT) រួមបញ្ចូលទាំងការគ្រប់គ្រងនិងការតភ្ជាប់គ្នារវាងកម្មវិធីសុខភាពមាតានិងទារក និងកម្មវិធីមេរោគអេដស៍/ជំងឺអេដស៍

## 8.1 ការគ្រប់គ្រងកម្មវិធី PMTCT

ការគ្រប់គ្រងសកម្មភាព PMTCT អនុវត្តតាមប្រព័ន្ធបីកម្រិតថ្នាក់របស់ក្រសួងសុខាភិបាល ។ នៅថ្នាក់ជាតិ កម្មវិធី PMTCT ទទួលខុសត្រូវក្នុងការសម្របសម្រួលការកំណត់ចំណុចដៅជាតិ, អភិវឌ្ឍនិងកែសម្រួលគោលការណ៍ណែនាំជាតិ, សម្របសម្រួលការបណ្ដុះបណ្ដាលនិងការអភិបាល, ការគ្រប់គ្រងការប្រមូលទិន្នន័យនិងការត្រួតពិនិត្យតាមដាន, ការគាំទ្រដល់ថ្នាក់ខេត្តដើម្បីអភិវឌ្ឍយុទ្ធសាស្ត្រសម្រាប់កែលម្អកម្មវិធី និងផ្ដល់ការណែនាំបច្ចេកទេសជាបន្តដល់ថ្នាក់ខេត្ត ។

នៅថ្នាក់ខេត្ត ប្រធានផ្នែកសុខភាពមាតានិងទារក/អ្នកសម្របសម្រួល PMTCT ខេត្ត សហការជាមួយប្រធានកម្មវិធីអេដស៍និងកាមរោគខេត្ត (PASP) និងប្រធានផ្នែកប្រយុទ្ធនឹងជំងឺឆ្លងនៃមន្ទីរសុខាភិបាលខេត្ត ទទួលបន្ទុកសម្របសម្រួលការអនុវត្តកម្មវិធី PMTCT នៅទូទាំងស្រុកប្រតិបត្តិទាំងអស់ក្នុងខេត្ត ដើម្បីធានាការសម្រេចបានគោលដៅនិងចំណុចដៅជាតិ ។ ប្រធានផ្នែកសុខភាពមាតានិងទារកខេត្ត ត្រួតពិនិត្យលើប្រធានផ្នែកសុខភាពមាតានិងទារកស្រុកប្រតិបត្តិ ដើម្បីធានាថា ស្ត្រីមានផ្ទៃពោះទទួលបានសេវាសុខភាពបន្តពូជ, មាតា, ទារកទើបនឹងកើត និងកុមារ និងសេវាមេរោគអេដស៍/កាមរោគ/HBV ។ អ្នកសម្របសម្រួលផ្នែកសុខភាពមាតានិងទារក, ប្រធានកម្មវិធីអេដស៍និងកាមរោគខេត្ត និងបុគ្គលិកផ្សេងទៀត ចូលរួមកិច្ចប្រជុំសម្របសម្រួលមេរោគអេដស៍ប្រចាំត្រីមាស ដែលរៀបចំឡើងដោយប្រធានស្រុកប្រតិបត្តិ ។ អ្នកសម្របសម្រួលសុខភាពមាតានិងទារក ក៏ធ្វើការជាមួយប្រធានផ្នែកប្រយុទ្ធនឹងជំងឺឆ្លងនៃមន្ទីរសុខាភិបាលខេត្ត ដើម្បីកំណត់មាគ៌ាបញ្ជូនសមស្របសម្រាប់ស្ត្រីដែលធ្វើតេស្តវិជ្ជមានចំពោះ HBsAg ។

**អ្នកសម្របសម្រួលសុខភាពមាតានិងទារកស្រុកប្រតិបត្តិ** មានភារកិច្ចធានាថា ការអនុវត្តសកម្មភាពសុខភាពបន្តពូជ មាតា ទារកទើបនឹងកើត និងកុមារ រួមទាំង PMTC នៅក្នុងស្រុកប្រតិបត្តិ អនុវត្តតាមអាទិភាពថ្នាក់ជាតិ និងធ្វើការសម្របសម្រួលជាមួយដៃគូ ជាពិសេស អ្នកសម្របសម្រួល HIV/STI CoPCT ដើម្បីធានាការអនុវត្តកម្មវិធីដោយរលូន និងសម្រេចបានគោលដៅដែលបានកំណត់ ។ ក្រោមការដឹកនាំរបស់ប្រធានស្រុកប្រតិបត្តិ អ្នកសម្របសម្រួលសុខភាពមាតានិងទារកថ្នាក់ស្រុកប្រតិបត្តិ និងបុគ្គលិកផ្នែកសុខភាពមាតានិងទារកនៅមណ្ឌលសុខភាព និងអគារសម្ភពនៃមន្ទីរពេទ្យបង្អែក ធ្វើការយ៉ាងជិតស្និទ្ធជាមួយ**អ្នកសម្របសម្រួលការគ្រប់គ្រងករណីសកម្មប្រចាំស្រុកប្រតិបត្តិ (CMC)** ដើម្បីធានាថា ស្ត្រីមានផ្ទៃពោះទាំងអស់ដែលធ្វើតេស្តមេរោគអេដស៍មានប្រតិកម្ម ទទួលបានការធ្វើតេស្តបញ្ជាក់នៅ VCCT ហើយប្រសិនបើត្រូវបានបញ្ជាក់ថាវិជ្ជមាន ត្រូវបានចុះឈ្មោះភ្លាមៗនៅគ្លីនិក ART និងធ្វើការតាមដានបន្តជាទៀងទាត់ ។ កិច្ចប្រជុំ

សម្របសម្រួលនៅថ្នាក់ស្រុកប្រតិបត្តិ គឺជាវេទិកាមួយដែលអាចពិភាក្សាអំពីយន្តការបញ្ជូនរវាងសេវា ANC/សម្ភព/PNC និងសេវាមេរោគអេដស៍/កាមរោគ ក៏ដូចជាសេវាថែទាំតាមផ្ទះនិងសហគមន៍ និងសេវាគាំទ្រផ្សេងទៀត ។

**អ្នកសម្របសម្រួលសុខភាពមាតានិងទារកថ្នាក់ស្រុកប្រតិបត្តិ និងអ្នកសម្របសម្រួលការគ្រប់គ្រងករណីសកម្មប្រចាំស្រុកប្រតិបត្តិ** ក៏ត្រូវជានាផងដែរថា ស្ត្រីទាំងអស់ដែលធ្វើតេស្តឃើញមានប្រតិកម្មចំពោះជំងឺស្វាយ ចាប់ផ្តើមការព្យាបាលភ្លាមៗ ហើយបន្ទាប់មក ធ្វើតេស្ត RPR និងទទួលការព្យាបាលបន្ត/តាមដាននៅ FHC ។ សុខភាពមាតានិងទារកថ្នាក់ស្រុកប្រតិបត្តិ ត្រូវជានាថា មូលដ្ឋានសុខាភិបាលដែលផ្តល់សេវា ANC និងផ្តល់សេវាសម្រាលកូននៅក្នុងស្រុកប្រតិបត្តិ ទទួលបានការណែនាំច្បាស់លាស់អំពីទីកន្លែងដែលត្រូវបញ្ជូនស្ត្រីដែលវិជ្ជមាន HBsAG+ និងជានាថា ស្ត្រីទាំងនេះទទួលការធ្វើតេស្តនិងការព្យាបាលបន្ថែមទៀតនៅមន្ទីរពេទ្យដែលនៅជិតបំផុតដែលមានសមត្ថភាពអាចផ្តល់សេវានេះបាន ។ អាស្រ័យលើទីតាំង មន្ទីរពេទ្យបែបនេះ អាចជាមន្ទីរពេទ្យជាតិ មន្ទីរពេទ្យខេត្ត មន្ទីរពេទ្យបង្អែក ឬគ្លីនិក ART ក្នុងមន្ទីរពេទ្យបង្អែក ។

នៅថ្នាក់មូលដ្ឋានសុខាភិបាល (មន្ទីរពេទ្យបង្អែក និងមណ្ឌលសុខភាព) **ប្រធានមន្ទីរពេទ្យបង្អែក និងប្រធានមណ្ឌលសុខភាព** ទទួលខុសត្រូវក្នុងការសម្របសម្រួល និងអនុវត្តសកម្មភាពទាំងអស់ដែលមាននៅក្នុងកញ្ចប់សេវា CPA និង MPA ។ សកម្មភាព PMTCT ត្រូវបានដាក់បញ្ចូលទៅក្នុងសេវាសុខភាពមាតានិងទារក និងមេរោគអេដស៍ ។ សេវា ANC, សម្ភព និង PNC ត្រូវបានគ្រប់គ្រងដោយកម្មវិធីសុខភាពមាតានិងទារក ។ សេវា VCCT, ART, PAC និងកាមរោគ ត្រូវបានគ្រប់គ្រងដោយកម្មវិធីមេរោគអេដស៍ ។
កម្មវិធីសុខភាពមាតានិងទារក ត្រូវជានាការផ្តល់ការថែទាំមុនពេលសម្រាល, ពេលសម្រាល និងក្រោយសម្រាលតាមធម្មតា យោងតាមពិធីសារស្តីពីមាតុភាពគ្មានគ្រោះថ្នាក់ រួមទាំង IEC, ការផ្តល់ប្រឹក្សាទាំងមុនពេលសម្រាលនិងក្រោយពេលសម្រាល, ការធ្វើតេស្តពិនិត្យរកមេរោគអេដស៍, HBV និងស្វាយ, សេវាផែនការគ្រួសារ, ការសម្រាល, យន្តការបញ្ជូនទៅរកសេវាសុខភាពនៅមូលដ្ឋានសុខាភិបាលផ្សេងទៀត និងការផ្សារភ្ជាប់ជាមួយអង្គការនៅតាមសហគមន៍នានា ។ កម្មវិធីមេរោគអេដស៍ ត្រូវជានានិងរៀបចំសម្ភារតេស្តរកមេរោគអេដស៍និងមេរោគស្វាយនៅសេវា ANC និងសម្ភពទាំងអស់ និង ARV នៅគ្រប់សេវាសម្ភពដែលមានទីតាំងរួមគ្នាជាមួយទីតាំង ART ។ កម្មវិធីមេរោគអេដស៍ ក៏ត្រូវជានាឱ្យមានសម្ភារនិងសេវាគ្រប់គ្រាន់នៅទីតាំង ART ផងដែរ។

ការព្យាបាលដោយ ARV ចំពោះស្ត្រីវិជ្ជមាន HBsAg ត្រូវបានគេរកឃើញថាមានហានិភ័យខ្ពស់ចំពោះការចម្លងជុំវិញការសម្រាល ស្ថិតនៅក្រោមការណែនាំរបស់កម្មវិធីប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល (MoH-CDC) ។ ការព្យាបាលអាចត្រូវបានផ្តល់ជូននៅមន្ទីរពេទ្យជាតិ ខេត្ត ឬមន្ទីរពេទ្យបង្អែក ។ ARV ដែលចាំបាច់ អាចទទួលបានពីឱសថស្ថាននៅក្នុងមូលដ្ឋានសុខាភិបាលដែលពាក់ព័ន្ធ ក៏ដូចជា តេស្តហ៊ីសរកអង់ទីហ្សែន HB "e" ។

8.2 កញ្ចប់សេវា PMTCT ទាំងមូល

កម្មវិធី PMTCT នៅក្នុងប្រទេសកម្ពុជា ផ្តល់អន្តរាគមន៍ទាំងឡាយដូចខាងក្រោម ៖

- ការផ្តល់ប្រឹក្សានិងការធ្វើតេស្តមេរោគអេដស៍, HBV និងមេរោគស្វាយក្នុងពេលទទួលសេវា ANC, ឈឺពោះសម្រាល និងក្រោយសម្រាល ។
- ការផ្តល់ថ្នាំប្រឆាំងវីរុស (ARV) ដល់ម្តាយដែលផ្ទុកមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍
- ការព្យាបាលជំងឺស្វាយ
- ថ្នាំប្រឆាំងវីរុស (TDF) សម្រាប់ស្ត្រីដែលវិជ្ជមាន HBsAg ដែលប្រឈមមនឹងការចម្លងជុំវិញការសម្រាល
- ការអនុវត្តការសម្រាលកាន់តែមានសុវត្ថិភាព
- ព័ត៌មានអំពីការចិញ្ចឹមទារក ការផ្តល់ប្រឹក្សា និងការគាំទ្រ
- ការបញ្ជូនទៅរកការព្យាបាល ការថែទាំ និងការគាំទ្រផ្នែកសង្គមគ្រប់ជ្រុងជ្រោយសម្រាប់ម្តាយ និងគ្រួសារដែលឆ្លងមេរោគអេដស៍

**រូបភាពទី ២ 2: វដ្តនៃការបង្ការការចម្លងពីម្តាយទៅកូនសម្រាប់មេរោគអេដស៍, HBV និងស្វាយ**




## 8.3. ការឆ្លើយតបរួមគ្នានៅក្នុងល្បាក់សេវា PMTCT

### *8.3.1 កម្មវិធីមេរោគអេដស៍/កាមរោគ និងសុខភាពមាតានិងទារក*

ការតភ្ជាប់គ្នារវាងសេវាសុខភាពមាតានិងទារក និងមេរោគអេដស៍/កាមរោគ មានសារៈសំខាន់បំផុតដើម្បីធ្វើឱ្យប្រសើរឡើងនូវលទ្ធផលនៃល្បាក់សេវា PMTCT ។ វិធីសាស្រ្តសមាហរណកម្មគ្រប់គ្រងករណីសកម្ម (IACM) មានគោលដៅធានាការទទួលបានសេវាគ្រប់ជ្រុងជ្រោយ សម្រាប់ស្រ្តីដែលឆ្លងមេរោគអេដស៍, ដៃគូ និងទារករបស់ពួកគេ តាមរយៈយន្តការបញ្ជូននិងតាមដានយ៉ាងរឹងមាំនិងមានប្រសិទ្ធភាពនៅថ្នាក់មន្ទីរសុខាភិបាលខេត្ត/ស្រុកប្រតិបត្តិរវាងសេវាសុខភាពមាតានិងទារកនិងមេរោគអេដស៍ ក៏ដូចជា អង្គការនៅថ្នាក់សហគមន៍ ។ វាក៏ជានាផងដែរថា ជំងឺស្វាយក្នុងពេលមានផ្ទៃពោះត្រូវបានព្យាបាលយ៉ាងពេញលេញ រួមទាំងការធ្វើតេស្តនិងការព្យាបាលដៃគូ ។

អ្នកផ្តល់សេវាឯកជននិងអង្គការក្រៅរដ្ឋាភិបាលទាំងអស់ ដែលផ្តល់សេវាដល់ស្រ្តីមានផ្ទៃពោះនិងទារករបស់ពួកគេ គួរតែធ្វើតេស្តពិនិត្យស្រ្តីមានផ្ទៃពោះរកមើលមេរោគអេដស៍ និងមេរោគស្វាយ ហើយភ្ជាប់រាល់ករណីស្រ្តីមានផ្ទៃពោះដែលវិជ្ជមានមេរោគអេដស៍ឬស្វាយ និងទារកដែលប្រឈម ទៅសេវាមេរោគអេដស៍/កាមរោគ ដើម្បីទទួលបានកញ្ចប់សេវា PMTCT ពេញលេញ ។

•

• រូបភាពទី ៣៖ ការផ្តល់សេវានិងការឆ្លើយតបរួមគ្នាសម្រាប់មេរោគអេដស៍/ស្វាយ រួមជាមួយល្បាក់សេវា *PMTCT*



*8.3.2 កម្មវិធីសុខភាពមាតានិងទារក និងសេវាមន្ទីរពេទ្យសម្រាប់ជំងឺរលាកថ្លើម*

ដោយពិគ្រោះយោបល់ជាមួយមន្ទីរសុខាភិបាលខេត្ត អ្នកសម្របសម្រួលសុខភាពមាតានិងទារកថ្នាក់ស្រុកប្រតិបត្តិ ទទួលខុសត្រូវក្នុងការកំណត់មន្ទីរពេទ្យដែលល្អបំផុតសម្រាប់ការបញ្ជូន ឬស្ត្រីដែលធ្វើតេស្តវិជ្ជមានចំពោះ HBsAg នៅ ANC និងជូនដំណឹងដល់អ្នកផ្តល់សេវា ANC ទាំងអស់ ។ មន្ទីរពេទ្យនឹងធ្វើតេស្តរហ័ស HBeAg និង ALT (ឬបន្ទុកមេរោគ ប្រសិនបើមាន) ។ ប្រសិនបើ HBeAg វិជ្ជមាន ឬប្រសិនបើ HBeAg អវិជ្ជមាន ដែលមាន ALT > 40 ឬ VL > 200,000 IU/ml មន្ទីរពេទ្យត្រូវចាប់ផ្តើមព្យាបាលដោយ Tenofovir ។ នៅពេលដែលការបណ្តុះបណ្តាល HBV ត្រូវបានដាក់ឱ្យអនុវត្ត អន្តរាគមន៍ទាំងនេះនឹងមាននៅគ្រប់មន្ទីរពេទ្យបង្អែកទាំងអស់ ប៉ុន្តែក្នុងអំឡុងពេលចាប់ផ្តើមដំបូង ពេលខ្លះវាជាការចាំបាច់ដែលត្រូវបញ្ជូនទៅមន្ទីរពេទ្យនៅខាងក្រៅស្រុកប្រតិបត្តិនេះ ។ ក្រោយពេលសម្រាលកូនរួច ស្ត្រីត្រូវការការវាយតម្លៃដោយគ្រូពេទ្យដែលបានទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រងជំងឺរលាកថ្លើម ដើម្បីកំណត់ថាតើនាងត្រូវបន្តប្រើថ្នាំប្រឆាំងវីរុសដើម្បីសុខភាពផ្ទាល់ខ្លួនដែរឬទេ ហើយនេះអាចតម្រូវឱ្យបញ្ជូនទៅមន្ទីរពេទ្យខេត្តឬមន្ទីរពេទ្យថ្នាក់ជាតិ ។

8.4. ធនធានមនុស្សដែលពាក់ព័ន្ធក្នុងការផ្តល់សេវា PMTCT ៖

បុគ្គលិកទាំងឡាយខាងក្រោមនេះ ទទួលខុសត្រូវក្នុងការសម្របសម្រួលនិងអនុវត្តសកម្មភាព PMTCT ៖

- ប្រធានផ្នែកសុខភាពមាតានិងទារកខេត្ត និង/ឬអ្នកសម្របសម្រួល *PMTCT* (នៅក្នុងខេត្តខ្លះ ប្រធានផ្នែកសុខភាពមាតានិងទារក និងអ្នកសម្របសម្រួល *PMTCT* គឺជាបុគ្គលតែមួយ*)*
- ប្រធានកម្មវិធីអេដស៍និងកាមរោគខេត្ត *(PASP)*
- ផ្នែកសុខភាពមាតានិងទារក និងប្រធានកម្មវិធីអេដស៍ថ្នាក់ស្រុកប្រតិបត្តិ
- បុគ្គលិកផ្នែកសុខភាពមាតានិងទារកនៅមណ្ឌលសុខភាព
- បុគ្គលិកផ្នែកសម្ភពនៃមន្ទីរពេទ្យបង្អែក
- បុគ្គលិកផ្នែកមេរោគអេដស៍នៅ *VCCT, ART* និង *PAC*
- បុគ្គលិកនៅគ្លីនិកសុខភាពគ្រួសារ
- គ្រូពេទ្យនិងនិងមន្ទីរពិសោធន៍នៅមន្ទីរពេទ្យ *(សម្រាប់ HBV)*
- *PHD/OD CMC* **និង** *CMA* **សម្រាប់** *B-IACM*

8.5. ការបណ្តុះបណ្តាល

បុគ្គលិកដែលពាក់ព័ន្ធក្នុងការផ្តល់សេវា PMTCT គួរតែទទួលបានការបណ្តុះបណ្តាលដំបូងអំពីមេរោគអេដស៍/ជំងឺអេដស៍, ល្បាក់សេវា MTCT និង PMTCT ការចិញ្ចឹមទារកនិងការផ្តល់អាហារបន្ថែម, PEP, PrEP, ការប្រុងប្រយ័ត្នជាសកល, ផែនការគ្រួសារ, មេរោគស្វាយ, HBV, ការបញ្ជូនទៅរកការថែទាំ, ការព្យាបាល និងការគាំទ្រ និងការគ្រប់គ្រងទិន្នន័យ យោងតាមកម្មវិធីសិក្សាសម្រាប់ការបណ្តុះបណ្តាលស្តីពី PMTCT របស់ក្រសួងសុខភិបាល ។ ការបណ្តុះបណ្តាលផ្សេងទៀតអាចត្រូវបានផ្តល់ជូនតាមតម្រូវការ ។ វគ្គបណ្តុះបណ្តាលនឹងត្រូវធ្វើឡើងដោយកិច្ចសហការរវាង NCHADS និង ម.ជ.គ.ម.ទ ។

8.6. ការអភិបាល

ការអភិបាលរួមគ្នារវាងកម្មវិធីសុខភាពមាតានិងទារក និងកម្មវិធីអេដស៍ គឺជាមានសារៈសំខាន់ក្នុងការតាមដានមើលការអនុវត្តកម្មវិធី PMTCT និងផ្តល់មតិត្រឡប់ឱ្យចំគោលដៅសម្រាប់ការកែលំអកម្មវិធី ។ ដើម្បីធានាបាននូវគុណភាពនៃការផ្តល់សេវា PMTCT, ការអភិបាលរួមគ្នានឹងត្រូវធ្វើឡើងរៀងរាល់ត្រីមាសដោយក្រុមគ្រប់គ្រងកម្មវិធីសុខភាពមាតានិងទារកនិងមេរោគអេដស៍ថ្នាក់ស្រុក ខេត្ត និងជាតិ ។ ការចុះអភិបាលមិនគួរផ្តោតតែទៅលើការកាត់បន្ថយបញ្ហាប៉ុណ្ណោះទេ ប៉ុន្តែត្រូវកំណត់ពីចំណុចខ្លាំងនិងជោគជ័យផងដែរ ដោយប្រើបញ្ជីផ្ទៀងផ្ទាត់អភិបាលស្តង់ដារ ។

គោលបំណងសំខាន់នៃការអភិបាល គឺដើម្បីកែលម្អលទ្ធផលនៃល្បាក់សេវា PMTCT នៅថ្នាក់ស្រុកប្រតិបត្តិ ៖

- ការសម្របសម្រួលបរិស្ថានគាំទ្រ ។
    - **ការធានាថា ការផ្តល់ប្រឹក្សានិងការធ្វើតេស្តដោយសម្ងាត់ប្រកបដោយគុណភាពខ្ពស់ ត្រូវបានផ្តល់ដល់ស្ត្រីមានផ្ទៃពោះទាំងអស់ និងដៃគូរបស់ពួកគេនៅក្នុងស្រុកប្រតិបត្តិ ។**
    - **ការធានាថា ករណីមានប្រតិកម្មមេរោគអេដស៍ ស្វាយ និង HBsAg ត្រូវបានបញ្ជូនភ្លាមៗទៅកាន់មូលដ្ឋានសុខាភិបាលត្រឹមត្រូវ និងត្រូវបានតាមដាននៅក្នុងល្បាក់នៃថែទាំទាំងមូល ។**
    - ការធានាថា ឱសថ ARV សមស្របសម្រាប់ទារកដែលប្រឈមមុខនឹងមេរោគអេដស៍ អាចរកបាន និងផ្តល់ជូនដោយត្រឹមត្រូវដល់ស្ត្រីនៅអគារសម្ភពនៃមន្ទីរពេទ្យបង្អែក ។
- ធានាថា មានការព្យាបាលដោយ *ART* សមស្របសម្រាប់ម្តាយដែលវិជ្ជមានមេរោគអេដស៍ ដែលទាន់ត្រៀមរួចរាល់សម្រាប់ *ART* ក្នុងពេលមានផ្ទៃពោះ និងផ្តល់ជូនស្ត្រីដោយត្រឹមត្រូវនៅអគារសម្ភពនៃមន្ទីរពេទ្យបង្អែក ។
- ការរៀបចំដើម្បីផ្គត់ផ្គង់ថ្នាំ *ARV* និង *ART* ដល់មណ្ឌលសុខភាព ក្នុងករណីស្ត្រីវិជ្ជមានមេរោគអេដស៍ត្រូវបានរកឃើញក្នុងអំឡុងពេលសម្រាលកូននៅមណ្ឌលសុខភាព ។

- ការធានាការត្រួតពិនិត្យការចម្លងមេរោគឱ្យបានត្រឹមត្រូវ រួមទាំងការអនុវត្តការប្រុងប្រយ័ត្នជាសកលនិង *PEP* ក្នុងអំឡុងពេលសម្រាល ។
- ការធានាថា ម្តាយដែលវិជ្ជមានមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍ទាំងអស់ ត្រូវបានបញ្ជូនភ្លាមៗនិងដោយត្រឹមត្រូវទៅកាន់គ្លីនិកនៅក្បែរ/*ART* និង *PAC* ។
- ការធានាថា ម្តាយដែលវិជ្ជមានមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍ទាំងអស់ត្រូវបានបញ្ជូនទៅក្រុមថែទាំនិងគាំទ្រនៅសហគមន៍ដោយត្រឹមត្រូវនៅពេលណាអាចធ្វើទៅបាន ។
- ការធានាថា ស្ត្រីដែលមានតេស្តប្រតិកម្មមេរោគស្វាយទាំងអស់ទទួលការព្យាបាល និងការតាមដាន រួមទាំងការធ្វើតេស្តនិងការព្យាបាលដៃគូ ដើម្បីចៀសវាងការឆ្លងឡើងវិញ ។
    - ការធានាថា ទារកទាំងអស់ទទួលបានដូសថ្នាំបង្ការពីកំណើតសម្រាប់ *HBV* ជាពិសេស ក្នុងអំឡុងពេល ២ ម៉ោងក្រោយពេលសម្រាល និងយ៉ាងហោចណាស់ក្នុងរយៈពេល ២៤ ម៉ោង ។
    - ការធានានីតិវិធីប្រមូលទិន្នន័យនិងរាយការណ៍ដោយត្រឹមត្រូវ ។
    - ការកែលម្អជំនាញរបស់បុគ្គលិក ។
    - កាត់បន្ថយបញ្ហា និងការដាក់ចេញនូវដំណោះស្រាយ ។
- 
- ការផ្តល់មតិត្រឡប់ភ្លាមៗនិងការបង្វឹក គួរត្រូវបានផ្តល់ជូនដល់បុគ្គលិកនៅពេលចុះទៅដល់ទីកន្លែងផ្ទាល់ ហើយការពិភាក្សាឡើងវិញភ្លាមៗគួរតែត្រូវធ្វើឡើងជាមួយក្រុមគ្រប់គ្រងមណ្ឌលសុខភាពនៅពេលចុងបញ្ចប់នៃការដំណើរចុះអភិបាលនីមួយៗ ។ ផែនការសកម្មភាពមួយគួរត្រូវបានរៀបចំឡើងរួមគ្នាជាមួយក្រុមអ្នកគ្រប់គ្រងកម្មវិធីមេរោគអេដស៍ និងសុខភាពមាតានិងទារក សម្រាប់ការតាមដាន និងកែលម្អនៅពេលចុះអភិបាលលើកក្រោយ ។
- ការអភិបាលមន្ទីរពិសោធន៍និងគ្រូពេទ្យដែលផ្តល់សេវាតេស្តជំងឺរលាកថ្លើម នឹងត្រូវធ្វើឡើងដោយនាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ។

## 8.7. ការត្រួតពិនិត្យគុណភាព

ការត្រួតពិនិត្យគុណភាពសម្រាប់ការធ្វើតេស្តមេរោគអេដស៍និងមេរោគស្វាយ និងថ្នាំ ARV សម្រាប់មេរោគអេដស៍ នឹងត្រូវគ្រប់គ្រងដោយ NCHADS និងវិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) ។ សម្រាប់ព័ត៌មានលម្អិតបន្ថែម សូមមើលសៀវភៅណែនាំរបស់ NCHADs ស្តីពីការធានាគុណភាពនៅក្នុងកម្មវិធីសេវាធ្វើតេស្តមេរោគអេដស៍ ។

ការត្រួតពិនិត្យគុណភាពសម្ភារតេស្ត HBV និងថ្នាំ (Tenofovir) នឹងត្រូវគ្រប់គ្រងដោយកម្មវិធីជំងឺរលាកថ្លើមរបស់នាយកដ្ឋានប្រយុទ្ធនឹងជំងឺឆ្លងនៃក្រសួងសុខាភិបាល ។

8.8. ភ័ស្តុភារ និងការផ្គត់ផ្គង់សម្ភារ

*8.8.1. ARV សម្រាប់មេរោគអេដស៍*

- នៅថ្នាក់កណ្តាល កិច្ចព្រមព្រៀងរួមគ្នាដែលចុះហត្ថលេខាដោយ *NMCHC* និង *NCHADS* បង្ហាញយ៉ាងច្បាស់អំពីតួនាទីនិងទំនួលខុសត្រូវចំពោះការគ្រប់គ្រងសម្ភារភ័ស្តុភារទាក់ទងនឹងមេរោគអេដស៍ ។ រាល់សម្ភារទាំងអស់គួរតែទទួលតាមរយៈប្រព័ន្ធរបស់ក្រសួងសុខាភិបាល *(*ឃ្លាំងឱសថកណ្តាល, ឱសថស្ថានខេត្ត និងឱសថស្ថានស្រុកប្រតិបត្តិ) ។
- អគារសម្ភពដែលមានទីតាំងស្ថិតនៅជាមួយសេវា *ART* នឹងទទួលបានថ្នាំ *ARV* ដោយផ្ទាល់ពីសេវា *ART* ឬឱសថស្ថានមន្ទីរពេទ្យបង្អែក តាមការស្នើសុំជាផ្លូវការទៅកាន់មន្ទីរពេទ្យបង្អែក ។
- ជារៀងរាល់ត្រីមាស ឱសថការីក្នុងមន្ទីរពេទ្យបង្អែកដែលធ្វើការនៅគ្លីនិក *ART* ធ្វើរបាយការណ៍អំពីការប្រើប្រាស់ឱសថក្នុងអំឡុងពេលរាយការណ៍ និងធ្វើការស្នើសុំថ្នាំ *ARV* សម្រាប់ត្រីមាសបន្ទាប់ទៅ *NCHADS* តាមរយៈស្រុកប្រតិបត្តិ ឬមន្ទីរពេទ្យខេត្ត ។ ឱសថទាំងនេះនឹងត្រូវបានដឹកជញ្ជូនដោយឃ្លាំងឱសថកណ្តាលទៅកាន់ឃ្លាំងឱសថស្រុកប្រតិបត្តិ ។
- ក្នុងករណីខ្វះខាតឱសថ ឱសថការីនៃគ្លីនិក *ART* អាចធ្វើសំណើសុំជាបន្ទាន់ពិសេសទៅកាន់ *NCHADS* ដើម្បីទទួលបានការផ្គត់ផ្គង់ថ្មីពីឃ្លាំងបម្រុងរបស់ *NCHADS* ។
- ក្នុងករណីស្ត្រីសម្រាលកូនវិជ្ជមានមេរោគអេដស៍នៅមណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែក ដែលមិនមានទីតាំងនៅជាមួយគ្លីនិក *ART* ឆ្មបគួរជូនដំណឹងជាបន្ទាន់ដល់អ្នកសម្របសម្រួល *PMTCT* នៅស្រុកប្រតិបត្តិឬខេត្ត ដើម្បីជួយក្នុងការទទួលបានការផ្គត់ផ្គង់ថ្នាំ *ARV* ពីទីតាំង *ART* ដែលនៅជិតបំផុត ។
- 

*8.8.2 ប្រអប់តេស្តមេរោគអេដស៍/ស្វាយ និង HBV*

- មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក នឹងទទួលបានប្រអប់តេស្តពីឱសថស្ថានស្រុកប្រតិបត្តិ និងធ្វើរបាយការណ៍អំពីការប្រើប្រាស់ជាប្រចាំ និងសំណើសុំតេស្តថ្មី ។

- សំណើសុំតេស្តថ្មីគួរផ្អែកលើចំនួនអតិថិជនថ្មីបំផុតនៃ *ANC1* មិនមែនផ្អែកលើការប្រើប្រាស់ពីមុនមកនោះទេ ពីព្រោះថា ការធ្វើបែបនេះអាចធ្វើឱ្យមូលដ្ឋានសុខាភិបាលដែលមានអតិថិជនតិច មិនអាចបង្កើនអត្រាគ្របដណ្តប់របស់ពួកគេបាន ។
- មូលដ្ឋានសុខាភិបាលគួរធានាថា សេវា *ANC* និងសេវាសម្រាលកូន ជានិច្ចជាកាល មានស្តុកបម្រុងសម្រាប់រយៈពេល ១ ខែ គ្រប់ពេល ។
- មូលដ្ឋានសុខាភិបាលគួរតែយកចិត្តទុកដាក់ដើម្បីអនុវត្តតាមគោលការណ៍ **"ផុតកំណត់ប្រើមុនចេញមុន** *(FEFO)"* ហើយប្រើប្រអប់តេស្តនៅមុនកាលបរិច្ឆេទផុតកំណត់ប្រើ ។
- ក្នុងករណីមានការដាច់ស្តុកធ្ងន់ធ្ងរ មណ្ឌលសុខភាពឬមន្ទីរពេទ្យបង្អែក គួរជូនដំណឹងដល់ *NMCH* ភ្លាមៗ ហើយ *NMCH* នឹងសម្របសម្រួលជាមួយ *NCHADs* និង *CMS* ដើម្បីទទួលបានការផ្គត់ផ្គង់បន្ទាន់ ។

- *8.8.3* ប្រអប់តេស្តសំណាកឈាមស្ងួត *(DBS)*
- ប័ណ្ណ *DBS* ត្រូវបានផ្គត់ផ្គង់ដោយ *NCHADs* ដល់ទីតាំង *PAC* ។ អគារសម្ភពនៅក្នុងមន្ទីរពេទ្យបង្អែកដែលមានទីតាំងស្ថិតនៅជាមួយសេវា *ART* អាចទទួលបានប័ណ្ណពីទីតាំង *PAC* ឬការិយាល័យអេដស៍ខេត្ត ។ សេវាសម្ភពនៅមន្ទីរពេទ្យគួរតែរក្សាទុកប័ណ្ណពីរបីសន្លឹកនៅអគារសម្ភពសម្រាប់ប្រើក្នុងករណីដែលស្ត្រីវិជ្ជមានមេរោគអេដស៍ សម្រាលកូនក្រៅម៉ោងធ្វើការរបស់ *PAC* ។

- *8.8.4 Benzylpenicillin និង Aqueous Benzylpenicillin*
  - គ្លីនិកសុខភាពគ្រួសារនឹងទទួលបានថ្នាំទាំងនេះ និងថ្នាំសម្រាប់ជំងឺកាមរោគផ្សេងទៀត តាមរយៈបណ្តាញផ្គត់ផ្គង់ធម្មតា, ធ្វើរបាយការណ៍ប្រចាំត្រីមាសអំពីការប្រើប្រាស់ថ្នាំ និងការស្នើសុំថ្មីតាមរយៈឱសថស្ថានស្រុកប្រតិបត្តិ ។
  - សេវាសម្ភពអាចទទួលបាន *benzylpenicillin* តាមរយៈឱសថស្ថានមន្ទីរពេទ្យបង្អែក ។
  - សេវាសម្ភពគួររក្សាទុក *benzathine penicillin* និង *aqueous benzylpenicillin* នៅនឹងកន្លែងគ្រប់ពេលដើម្បីឱ្យស្ត្រីដែលធ្វើតេស្តមេរោគស្វាយមានប្រតិកម្ម និងទារកដែលប្រឈមនឹងមេរោគស្វាយ អាចចាប់ផ្តើមការព្យាបាលភ្លាមៗ ។

- *8.8.5* ថ្នាំបង្ការជំងឺរលាកថ្លើមប្រភេទបេ
- មណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកទាំងអស់ ទទួលបានថ្នាំបង្ការនេះតាមរយៈសង្វាក់ផ្គត់ផ្គង់ថ្នាំបង្ការធម្មតា ។ ថ្នាំបង្ការនេះគួរតែមាននៅក្នុងសេវាសម្ភព ដើម្បីធានាការផ្តល់ជូនទាន់ពេលវេលាក្រោយពេលសម្រាល ។

## រូបភាពទី ៤ ៖ អង្គការលេខសម្រាប់ការគ្រប់គ្រងសម្រាប់ PMTCT នៃមេរោគអេដស៍និងស្វាយ




*នៅក្នុងខេត្តខ្លះ ប្រធាន MCH និងអ្នកសម្របសម្រួល PMTCT គឺជាបុគ្គលតែមួយ

# ជំពូកទី ៩ ៖ ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

## 9.1 ការកត់ត្រា ការប្រមូលទិន្នន័យ និងការរាយការណ៍

មូលដ្ឋានសុខាភិបាល ទទួលខុសត្រូវក្នុងការកត់ត្រារាល់ការធ្វើតេស្តមេរោគអេដស៍, HBV និងមេរោគស្វាយ នៅក្នុងសៀវភៅកំណត់ត្រា, ប័ណ្ណបញ្ជូន, ទម្រង់មន្ទីរពិសោធន៍ និងទម្រង់តាមដានម្តាយនិងទារក ។ មូលដ្ឋានសុខាភិបាលក៏ទទួលខុសត្រូវផងដែរក្នុងការចងក្រងទិន្នន័យដែលបានកត់ត្រានៅក្នុងសៀវភៅកំណត់ត្រារបស់ខ្លួន ទៅក្នុងទម្រង់របាយការណ៍ប្រចាំខែ ដែលត្រូវបានបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ HMIS, PMTCT និងមូលដ្ឋានទិន្នន័យ NCHAD ដែលពាក់ព័ន្ធ ។

ទិន្នន័យ HMIS និង PMTCT ត្រូវបានបញ្ចូលតាមអនឡាញ ។ ជាធម្មតា កិច្ចការនេះត្រូវបានធ្វើឡើងដោយមូលដ្ឋានសុខាភិបាល ប៉ុន្តែ ក្នុងករណីខ្លះ អាចធ្វើឡើងដោយបុគ្គលិកផ្នែកសុខភាពមាតានិងទារកស្រុកប្រតិបត្តិ និងបុគ្គលិក HIS ប្រសិនបើមូលដ្ឋានសុខាភិបាលមិនមានអ៊ីនធឺណិត ។

ទិន្នន័យ VCCT, ART និង PAC ដែលទាក់ទងនឹង PMTCT ត្រូវបានចងក្រងដោយបុគ្គលិក VCCT/ART និងដាក់ជូនទៅ NCHADs ។

បញ្ជីពេញលេញនៃទិន្នន័យដែលប្រមូលបានដោយសេវាសម្ភពនៅថ្នាក់មូលដ្ឋានសុខាភិបាល មាននៅក្នុងទម្រង់មន្ទីរពិសោធន៍ (សូមមើលឧបសម្ព័ន្ធទី ១), ប័ណ្ណបញ្ជូន PMTCT (ឧបសម្ព័ន្ធទី ២), សៀវភៅកំណត់ត្រា និងប័ណ្ណតាមដានបន្តដើម្បីតាមដានម្តាយដែលឆ្លងមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍ (ឧបសម្ព័ន្ធទី ៣), សៀវភៅកំណត់ត្រាសមាហរណកម្មការពន្យារកំណើត-មេរោគអេដស៍ (ឧបសម្ព័ន្ធទី ៤), បញ្ជីត្រួតពិនិត្យ (ឧបសម្ព័ន្ធទី ៥) និងទម្រង់របាយការណ៍ (សូមមើលឧបសម្ព័ន្ធទី ៦) ។

## 9.2 សូចនាករថ្នាក់ជាតិនៃ PMTCT

សូចនាករជាតិត្រូវបានរៀបចំឡើង និងធ្វើបច្ចុប្បន្នភាពដោយក្រុមការងារបច្ចេកទេស PMTCT ដើម្បីតាមដានមើលសមិទ្ធផលនៃកម្មវិធី PMTCT ថ្នាក់ជាតិ និងដើម្បីវាស់វែងវឌ្ឍនភាពធៀបនឹងចំណុចដៅជាតិ និងអន្តរជាតិ ។ សូចនាករទាំងនេះគឺផ្អែកលើទិន្នន័យដែលបានប្រមូល និងរាយការណ៍ដោយមូលដ្ឋានសុខាភិបាល ។ ការិយាល័យកម្មវិធី PMTCT នៃ ម.ជ.គ.ម.ទ ទទួលខុសត្រូវក្នុងការរាយការណ៍ទៅក្រសួងសុខាភិ

បាល និងផ្តល់យោបល់ត្រឡប់ប្រចាំឆ្នាំដល់អ្នកសម្របសម្រួលសុខភាពមាតានិងទារក/មេរោគអេដស៍ថ្នាក់ខេត្តនិងស្រុកប្រតិបត្តិ ទាក់ទងនឹងវឌ្ឍនភាព និងការសម្រេចបានសូចនាករសំខាន់ៗ ដែលបានវាស់វែងធៀបនឹងចំណុចដៅ ។ យោបល់ត្រឡប់នេះត្រូវបានប្រើដើម្បីកំណត់ពីផ្នែកនានាសម្រាប់ការកែលម្អកម្មវិធី ។ សូចនាករ PMTCT សំខាន់ៗ និងចំណុចដៅរបស់កម្មវិធី ត្រូវបានបង្ហាញនៅក្នុងតារាងទី ១៥ រួមជាមួយភាគយក និងភាគបែង ដែលត្រូវបានប្រើប្រាស់ដើម្បីគណនាសូចនាករនីមួយៗ ។

## 9.3 ការវាយតម្លៃ

កម្មវិធី PMTCT ថ្នាក់ជាតិ ត្រូវបានវាយតម្លៃជារៀងរាល់ឆ្នាំដោយក្រសួងសុខាភិបាល, កម្មវិធីជាតិ, មន្ទីរសុខាភិបាលខេត្ត និងដៃគូអភិវឌ្ឍន៍ តាមរយៈសិក្ខាសាលាបូកសរុបប្រចាំឆ្នាំ ។ ការវាយតម្លៃគឺផ្អែកលើទិន្នន័យរបាយការណ៍ និងបទពិសោធន៍ដែលមានស្រាប់ ។ កិច្ចប្រជុំក្រុមការងារមន្ទីរសុខាភិបាលខេត្តនិងស្រុកប្រតិបត្តិជាទៀងទាត់ គួរត្រូវបានប្រើប្រាស់ដើម្បីពិនិត្យឡើងវិញ និងប្រើប្រាស់ទិន្នន័យ PMTCT ដែលប្រមូលបាននៅមូលដ្ឋានសុខាភិបាល ដើម្បីកែលម្អការអនុវត្ត PMTCT និងដើម្បីកំណត់ពីវឌ្ឍនភាពទាក់ទងនឹងការអនុវត្តនិងគុណភាពសេវា បញ្ហាប្រឈម និងដំណោះស្រាយ ព្រមទាំងដើម្បីជានាការតាមដានរកអ្នកជំងឺ ។

## តារាងទី ១៥៖ សូចនាករសំខាន់ៗនៃ PMTCT

| សូចនាករ | | | ភាគយក | ភាគបែង<br>PW= ស្ត្រីមានផ្ទៃពោះ | ប្រភពទិន្នន័យ និង ភាពញឹកញាប់នៃការរាយការណ៍ |
|---|---|---|---|---|---|
| | | | សូចនាករ = (ភាគរយ/ភាគបែង) x 100 | | |
| 1 | សមាមាត្រ (%) នៃស្ត្រីមានផ្ទៃពោះដែលដឹងស្ថានភាពមេរោគអេដស៍របស់ពួកគេ | | ចំនួនស្ត្រីមានផ្ទៃពោះដែលត្រូវបានធ្វើតេស្តក្នុងពេលមានផ្ទៃពោះនេះ ប្លូក ចំនួនស្ត្រីមានផ្ទៃពោះដែលបានដឹងស្ថានភាពមេរោគអេដស៍រួចហើយមុនពេលមានផ្ទៃពោះនេះ ប្លូក ចំនួនស្ត្រីមានផ្ទៃពោះដែលបានធ្វើតេស្តនៅពេល L&D. | ចំនួនប៉ាន់ស្មាននៃស្ត្រីមានផ្ទៃពោះ | មូលដ្ឋានទិន្នន័យ NMCHC PMTCT និងការប៉ាន់ស្មានវិសាលគម ប្រចាំឆ្នាំ |
| | 1.1 | % ស្ត្រីមានផ្ទៃពោះដែលមិនដឹងស្ថានភាពមេរោគអេដស៍ ដែលមករកសេវា ANC ដែលត្រូវបានធ្វើតេស្តរកមេរោគអេដស៍និងបានទទួលលទ្ធផល | ចំនួនស្ត្រីមានផ្ទៃពោះដែលមិនដឹងស្ថានភាពមេរោគអេដស៍ ដែលបានធ្វើតេស្តនិងបានទទួលលទ្ធផលតេស្តនៅ ANC | ចំនួនអតិថិជន ANC 1 ដែលមិនដឹងស្ថានភាពមេរោគអេដស៍ (អតិថិជន ANC1 ទាំងអស់ - អតិថិជនដែលបានដឹងស្ថានភាពមេរោគអេដស៍វិជ្ជមានរួចហើយ ឬបានធ្វើតេស្តអវិជ្ជមានក្នុងពេលមានផ្ទៃពោះនេះ) | មូលដ្ឋានទិន្នន័យ NMCHC PMTCT ប្រចាំឆ្នាំ |
| | 1.2 | % ស្ត្រីមានផ្ទៃពោះដែលមិនដឹងស្ថានភាពមេរោគអេដស៍នៅពេលឈឺពោះសម្រាលនិងពេលសម្រាល ដែលត្រូវបានធ្វើតេស្តរកមេរោគអេដស៍ និងបានទទួលលទ្ធផលតេស្ត | ចំនួនស្ត្រីមានផ្ទៃពោះដែលមិនដឹងស្ថានភាពមេរោគអេដស៍នៅពេលឈឺពោះសម្រាលនិងពេលសម្រាល ដែលត្រូវបានធ្វើតេស្តរកមេរោគអេដស៍ និងបានទទួលលទ្ធផលតេស្ត | ចំនួនករណីសម្រាលដែលមិនដឹងស្ថានភាពមេរោគអេដស៍ (ចំនួនករណីសម្រាលសរុប - ករណីសម្រាលដែលដឹងស្ថានភាពមេរោគអេដស៍) | មូលដ្ឋានទិន្នន័យ NMCHC PMTCT ប្រចាំឆ្នាំ |
| 2 | % ស្ត្រីមានផ្ទៃពោះដែលធ្វើតេស្តរហ័សមេរោគអេដស៍មានប្រតិកម្មក្នុងពេល ANC ឬ L&D ដែលបានទទួលតេស្តបញ្ជាក់ | | ចំនួនស្ត្រីមានផ្ទៃពោះ ដែលធ្វើតេស្តរហ័សមានប្រតិកម្មសម្រាប់មេរោគអេដស៍ក្នុងពេល ANC ឬ L&D ដែលបានទទួលតេស្តបញ្ជាក់ | ចំនួនស្ត្រីមានផ្ទៃពោះដែលតេស្តរហ័សមានប្រតិកម្មក្នុងពេល ANC ឬ L&D | មូលដ្ឋានទិន្នន័យ NMCHC PMTCT ប្រចាំឆ្នាំ |

| | | | | |
|---|---|---|---|---|
| 3 | **% នៃស្ត្រីមានផ្ទៃពោះ ដែលត្រូវបានធ្វើតេស្តរកមេរោគអេដស៍ ស្វាយ** | ចំនួនស្ត្រីមានផ្ទៃពោះ ដែលត្រូវបានធ្វើតេស្តពិនិត្យរកមេរោគស្វាយ និងបានទទួលលទ្ធផលរបស់ពួកគេ | ចំនួនអតិថិជន ANC 1 ដែលបានកែតម្រូវសម្រាប់ការរាយការណ៍លើស[28] | មូលដ្ឋានទិន្នន័យ NMCHC PMTCT ប្រចាំឆ្នាំ |
| 4 | **% ស្ត្រីមានផ្ទៃពោះដែលមានជំងឺស្វាយ ដែលបានទទួលការព្យាបាលដោយថ្នាំ penicillin** | ចំនួនស្ត្រីមានផ្ទៃពោះដែលមានមេរោគស្វាយ ដែលបានព្យាបាលដោយថ្នាំ benzathine penicillin យ៉ាងតិចមួយដូស (ឬយ៉ាងតិច ១០ ថ្ងៃ ដោយប្រើ procaine penicillin) | ចំនួនស្ត្រីមានផ្ទៃពោះដែលមានតេស្តប្រតិកម្មមេរោគស្វាយវិជ្ជមាន ដែល (1) វិជ្ជមាន RPR ឬ (2) មិនបានធ្វើតេស្ត RPR (ឧទា. មិនរាប់បញ្ចូលករណីមានប្រតិកម្មដែលមាន RPR អវិជ្ជមានពីភាគបែង) | មូលដ្ឋានទិន្នន័យ NMCHC PMTCT ប្រចាំឆ្នាំ |
| 5 | **% ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ ដែលបានទទួល ART ក្នុងអំឡុងពេលមានផ្ទៃពោះដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងពីម្តាយទៅកូន** | - ចំនួនស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ បានទទួល ART ។ រួមបញ្ចូលទាំងអ្នកដែលបានចាប់ផ្តើមព្យាបាលមុនពេលផ្ទៃពោះ ក្នុងពេលមានផ្ទៃពោះ ឬនៅពេលឈឺពោះសម្រាល និងពេលសម្រាល | ចំនួនប៉ាន់ស្មាននៃស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ | មូលដ្ឋានទិន្នន័យ NMCHC PMTCT និងការប៉ាន់ស្មានវិសាលគម ប្រចាំឆ្នាំ |
| 6 | **% ទារកដែលកើតពីស្ត្រីដែលឆ្លងមេរោគអេដស៍ ដែលបានទទួលការព្យាបាលបង្ការដោយ ARV ដើម្បីកាត់បន្ថយហានិភ័យនៃការចម្លងពីម្តាយទៅកូន** | ចំនួនទារកដែលកើតពីម្តាយដែលឆ្លងមេរោគអេដស៍ ដែលបានទទួលការព្យាបាលបង្ការដោយ ARV ដើម្បីកាត់បន្ថយការចម្លងពីម្តាយ (MTCT) | ចំនួនប៉ាន់ស្មាននៃទារកដែលប្រឈមនឹងមេរោគអេដស៍ (ចំនួនប៉ាន់ស្មាននៃស្ត្រីមានផ្ទៃពោះវិជ្ជមាន ដកចំនួនទារកដែលប្រឈមមេរោគអេដស៍ដែលបានដឹង ស្លាប់កើត/កើតស្លាប់) | មូលដ្ឋានទិន្នន័យ NMCHC PMTCT និងការប៉ាន់ស្មានវិសាលគម ប្រចាំឆ្នាំ |
| 7 | **% ទារកដែលកើតពីម្តាយដែលឆ្លងមេរោគអេដស៍ ដែលបានទទួលតេស្ត DNA PCR សម្រាប់មេរោគអេដស៍ពេលកើត** | ចំនួនទារកដែលកើតពីស្ត្រីដែលឆ្លងមេរោគអេដស៍ ដែលបានទទួលតេស្ត DNA PCR ពេលកើត | ចំនួនប៉ាន់ស្មាននៃទារកដែលប្រឈមនឹងមេរោគអេដស៍ (ចំនួនប៉ាន់ស្មាននៃស្ត្រីមានផ្ទៃ | មូលដ្ឋានទិន្នន័យ NMCHC PMTCT និងការប៉ាន់ស្មានវិសាល |

[28]ដកចំនួនករណី ANC1 ដែលបានរាយការណ៍ជា "បានធ្វើតេស្តអវិជ្ជមានមេរោគអេដស៍សម្រាប់ការមានផ្ទៃពោះនេះរួចហើយ" ដោយប្រើតួលេខនេះជាតំណាងឱ្យករណី ANC 1 ដែលបានរាប់ស្ទួន

| | | | | |
|---|---|---|---|---|
| | | | ពោះវិជ្ជមាន ដកចំនួនទារកដែលប្រឈមមេរោគអេដស៍ដែលបានដឹង ស្លាប់កើត/កើតស្លាប់ ) | គម ប្រចាំឆ្នាំ |
| 8 | **% ទារកដែលកើតពីស្ត្រីដែលឆ្លងមេរោគអេដស៍ ដែលបានទទួលតេស្ត DNA PCR សម្រាប់មេរោគអេដស៍ក្នុងអំឡុងពេល ២ ខែ ក្រោយពេលកើត** | ចំនួនទារកដែលកើតពីស្ត្រីដែលឆ្លងមេរោគអេដស៍ ដែលបានទទួលតេស្ត DNA PCR ត្រឹមអាយុ ៨ សប្តាហ៍។ (រួមបញ្ចូលតេស្ត DNA PCR ពេលកើត និង/ឬ PCR នៅ ៦ សប្តាហ៍ - ប៉ុន្តែជៀសវាងការរាប់ស្ទួនចំពោះទារកដែលបានធ្វើតេស្តទាំងពីរ)។ | ចំនួនប៉ាន់ស្មាននៃទារកដែលប្រឈមនឹងមេរោគអេដស៍ (ចំនួនប៉ាន់ស្មាននៃស្ត្រីមានផ្ទៃពោះវិជ្ជមាន ដកចំនួនទារកដែលប្រឈមមេរោគអេដស៍ដែលបានដឹង ស្លាប់កើត/កើតស្លាប់ ) | មូលដ្ឋានទិន្នន័យ NCHADS និងការប៉ាន់ស្មានវិសាលគម ប្រចាំឆ្នាំ |
| 9 | **% ទារកដែលកើតពីម្តាយដែលឆ្លងមេរោគអេដស៍ ដែលបានទទួលតេស្តមេរោគអេដស៍ ៦ សប្តាហ៍ ក្រោយពេលឈប់បៅដោះម្តាយ** | ចំនួនទារកដែលប្រឈមនឹងមេរោគអេដស៍ដែលបៅដោះម្តាយ ដែលបានទទួលតេស្តមេរោគអេដស៍ (PCR ឬអង្គបដិបក្ខប្រាណ) ៦ សប្តាហ៍ក្រោយពេលឈប់បៅដោះ | ចំនួនទារកដែលប្រឈមនឹងមេរោគអេដស៍ដែលត្រូវបានឱ្យបៅដោះ (ពីមូលដ្ឋានទិន្នន័យ EID) | មូលដ្ឋានទិន្នន័យ NCHADS ប្រចាំឆ្នាំ |
| 10 | **% ទារកដែលកើតពីម្តាយដែលឆ្លងមេរោគអេដស៍ ដែលបានទទួលតេស្តអង្គបដិបក្ខប្រាណមេរោគអេដស៍នៅអាយុ ១៨ ខែ** | ចំនួនទារកដែលកើតពីម្តាយដែលឆ្លងមេរោគអេដស៍ ដែលបានទទួលតេស្តអង្គបដិបក្ខប្រាណមេរោគអេដស៍ ចាប់ពី ១៨ ខែឡើងទៅ | ចំនួនប៉ាន់ស្មាននៃទារកដែលប្រឈមមេរោគអេដស៍ (ចំនួនប៉ាន់ស្មាននៃស្ត្រីវិជ្ជមានមេរោគអេដស៍ ដក ទារកដែលប្រឈមមេរោគអេដស៍ ករណីស្លាប់កើត/កើតស្លាប់ (ករណីស្លាប់របស់ទារកទើបនឹងកើត) | មូលដ្ឋានទិន្នន័យ NCHADS និងការប៉ាន់ស្មានវិសាលគម ប្រចាំឆ្នាំ |
| 11 | **អត្រាប៉ាន់ស្មាននៃការចម្លងពីម្តាយទៅកូនសម្រាប់មេរោគអេដស៍ HIV** | ការប៉ាន់ស្មានដោយប្រើគំរូ | | ការប៉ាន់ស្មានវិសាលគម (Spectrum) ប្រចាំឆ្នាំ |

| | | | | |
|---|---|---|---|---|
| 12 | **% ទារកដែលបានទទួលថ្នាំបង្ការ HBV ក្នុងអំឡុងពេល ២ ម៉ោង និង ២៤ ម៉ោង ក្រោយពេលកើត** | ចំនួនទារកដែលបានទទួលថ្នាំបង្ការ HBV ក្នុងអំឡុងពេល ២ ម៉ោង និង ២៤ ម៉ោងក្រោយពេលកើត | ចំនួនករណីសម្រាលដែលបានរាយការណ៍ | HMIS<br>ប្រចាំឆ្នាំ |
| 13 | **% អតិថិជន ANC ដែលបានធ្វើតេស្តរក HBsAg** | អតិថិជន ANC ត្រូវបានធ្វើតេស្តសម្រាប់ HBsAg | ចំនួនអតិថិជន ANC1, ដែលបានកែតម្រូវសម្រាប់ការរាយការណ៍លើស[29] | មូលដ្ឋានទិន្នន័យ NMCHC PMTCT<br>ប្រចាំឆ្នាំ |
| 14 | **% ស្ត្រីមានផ្ទៃពោះដែលវិជ្ជមាន HBsAg បានទទួលការធ្វើតេស្តបន្ថែមដើម្បីកំណត់ពីហានិភ័យនៃការចម្លងជុំវិញពេលសម្រាល** | ចំនួនស្ត្រីមានផ្ទៃពោះដែលបានធ្វើតេស្តវិជ្ជមានចំពោះ HBsAg ដែលបានត្រូវបានធ្វើតេស្តសម្រាប់ HBeAg និង ALT ឬ HBV DNA VL | ចំនួនស្ត្រីមានផ្ទៃពោះ ដែលត្រូវបានធ្វើតេស្តវិជ្ជមាន HBsAg | មូលដ្ឋានទិន្នន័យ NMCHC PMTCT<br>ប្រចាំឆ្នាំ |
| 15 | **% ស្ត្រីមានផ្ទៃពោះដែលបានរកឃើញថាប្រឈមនឹងការចម្លងជុំវិញការសម្រាលចំពោះ HBV ដែលបានទទួល ARV** | ចំនួនស្ត្រីមានផ្ទៃពោះដែលវិជ្ជមានចំពោះ HBsAg និង HBV DNA > 5.3 Log $_{10}$ IU/mLorHBeAg +or with ALT>40 ដែលបានទទួល TDF ដើម្បីកាត់បន្ថយការចម្លង HBV | ចំនួនស្ត្រីមានផ្ទៃពោះដែលវិជ្ជមាន HBsAg និង HBV DNA > 5.3 Log $_{10}$ IU/mLorHBeAg + ឬ ដែលមាន ALT>40 | មូលដ្ឋានទិន្នន័យ NMCHC PMTCT<br>ប្រចាំឆ្នាំ |
| 16 | **% ទារកដែលប្រឈមនឹង HBV ដែលឆ្លង HBV ពីម្តាយ (MTCT)** | ចំនួនទារកដែលប្រឈមនឹង HBV ដែលធ្វើតេស្តវិជ្ជមានចំពោះ HBsAg មួយខែក្រោយពេលបញ្ចប់ការទទួលថ្នាំបង្ការគ្រប់មុខ | ចំនួនទារកដែលប្រឈមនឹង HBV ដែលបានធ្វើតេស្តរក HBsAg មួយខែក្រោយពេលបញ្ចប់ការទទួលថ្នាក់បង្ការគ្រប់មុខ | MoH-CDC |

[29]ដកចំនួនករណី ANC1 ដែលបានរាយការណ៍ថា "បានតេស្តរកមេរោគអេដស៍អវិជ្ជមានក្នុងពេលមានផ្ទៃពោះនេះ", ដោយប្រើវាជាតំណាងសម្រាប់ករណី ANC 1 ដែលបានរាប់ស្ទួន

# សេចក្តីបន្ថែម

## សេចក្តីបន្ថែមទី ១ ៖ ទម្រង់ធ្វើតេស្តមេរោគអេដស៍/ស្វាយ

1.1 លទ្ធផលតេស្តមេរោគអេដស៍/ស្វាយនៅមណ្ឌលសុខភាព (ANC) និងអគារសម្ភព

**ក្រសួងសុខាភិបាល**

**លទ្ធផលតេស្តមេរោគអេដស៍/ស្វាយ**

1-សេវា៖ VCCT ▢TB▢ ANC ▢ សម្ភព▢ OPD▢ IPD▢ ផ្សេងទៀត▢..............................................

2-ឈ្មោះទីតាំង៖....................................លេខកូដទីតាំង...............................លេខកូដអតិថិជន .......................

3-ថ្ងៃខែឆ្នាំធ្វើតេស្ត ..........................................................................................................................

| លទ្ធផលតេស្តមេរោគអេដស៍ | លទ្ធផលតេស្តស្វាយ | |
|---|---|---|
| Determine (តេស្តទីមួយ) ▢ | Determine (តេស្តទីមួយ) ▢ | |
| Stat-Pat (តេស្តទីពីរ) ▢ | RPR បរិមាណ ▢ | ឈ្មោះនិងហត្ថលេខារបស់អ្នកធ្វើតេស្ត |
| Uni-Gold (តេស្តទីបី) ▢ | RPR បរិមាណ | ឈ្មោះ៖........................................... |
| លទ្ធផលតេស្ត ▢ | Titre:...................................... | ហត្ថលេខា៖...................................... |

## 1.2 លទ្ធផលតេស្តមេរោគអេដស៍ (VCCT)



ក្រសួងសុខាភិបាល

**ប័ណ្ណលទ្ធផលតេស្តមេរោគអេដស៍ - ស្វាយ (HIV / Syphilis Test Result)**

1.សេវា HTS-ART ☐ STI ☐ TB ☐ ANC ☐ Maternity ☐ OPD ☐ IPD ☐ NGO ☐ NBTC ☐ **Others**..............

2.ឈ្មោះទីកន្លែងធ្វើតេស្ត: .........................លេខកូដទីកន្លែង.............................លេខកូដអតិថិជន..........................................

លេខកូដអតិថិជនប្រតិកម្មដែលបញ្ជូនមក(សំរាប់HTS-ART): ..........................................

RTRI= Recent => VL Test

3.ថ្ងៃខែឆ្នាំធ្វើតេស្ត : ថ្ងៃ ☐☐ ខែ ☐☐ ឆ្នាំ ☐☐☐☐

| 4.លទ្ធផលតេស្តមេរោគអេដស៍ (HIV) : | | | | 5.លទ្ធផលតេស្តស្វាយ (Syphilis) | | | |
|---|---|---|---|---|---|---|---|
| លទ្ធផលតេស្តហ៊ីសទី១ | Alere HIV/Syphilis Duo | NR | R | តេស្តរហ័ស : Rapid Test | - | R | |
| | Determine HIV 1/2 | NR | R | | | | |
| លទ្ធផលតេស្តហ៊ីសទី២: (តេស្ត Stat-Pak HIV 1/2) | | NR | R | តេស្ត RPR qualitative | - | + | |
| លទ្ធផលតេស្តហ៊ីសទី៣ : (តេស្ត Uni GoldHIV 1/2) | | NR | R | តេស្ត RPR quantitative (Titer) : | | | **6.ឈ្មោះ និងហត្ថលេខាអ្នកធ្វើតេស្ត**<br>ឈ្មោះ : ..........................<br>ហត្ថលេខា : .......................... |
| លទ្ធផលតេស្តកំណត់មិនបាន : + - លទ្ធផលតេស្ត : | | - | + | | | | |

* [illegible] (NCHADS)

## 1.3 ប័ណ្ណបញ្ជូនសម្រាប់ការធ្វើតេស្តបញ្ជាក់មេរោគអេដស៍និងស្វាយនៅទីតាំង VCCT /FHC

**ប័ណ្ណបញ្ជូនសម្រាប់ការធ្វើតេស្តបញ្ជាក់មេរោគអេដស៍និងស្វាយនៅ VCCT/FHC** លេខ:...........................

1-បញ្ជូនពី (ឈ្មោះនិងលេខកូដមណ្ឌលសុខភាព/RH/NGO):.............................................................
ឈ្មោះស្រុក............................................. ខេត្ត.........................................................
2-លេខកូដអតិថិជន...................................... លេខទូរស័ព្ទ.........................................
3-ឈ្មោះអតិថិជន......................................................... ភេទ.................. អាយុ......................
4-បញ្ជូនទៅកាន់ (គូសរង្វង់លើ) មេរោគអេដស៍ និង ស្វាយ៖

- ឈ្មោះ និងលេខកូដ VCCT:.............................................................................
- ឈ្មោះ និងលេខកូដ FHC :.............................................................................

5-ថ្ងៃខែឆ្នាំនៃតេស្តលើកទីមួយដែលមានប្រតិកម្មសម្រាប់មេរោគអេដស៍ ស្វាយ (លទ្ធផលប្រតិកម្ម):............
6-ជូនដំណឹងដល់ CMC/CMA: ▢ បាទ/ចាស ▢ ទេ
7- ហត្ថលេខានិងឈ្មោះរបស់អ្នកបញ្ជូន៖ .................................... លេខទូរស័ព្ទ................................

# សេចក្តីបន្ថែមទី ២ ៖ ប័ណ្ណកំណត់ត្រាមុនពេលចុះឈ្មោះ PMTCT (សាលកបត្រ)

## 2.1 ការចុះឈ្មោះជាមុនសម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ លើទម្រង់កំណត់ត្រាសម្ភព (សម្រាប់មន្ទីរពេទ្យបង្អែកដែលមានសេវាសម្ភព)

លេខកូដ PMTCT:______________________

លេខកូដ ART:______________________

1. ឈ្មោះស្ត្រីមានផ្ទៃពោះ ................................អាយុ.............. មុខរបរ..........................................................
   អាសយដ្ឋាន..........................................................................................................................................
   ចំនួនដងនៃការមានផ្ទៃពោះ □ ចំនួនដងនៃការមានកូន □ ចំនួនដងនៃការរំលូត □
   ការមករជួរចុងក្រោយ ...................................... ថ្ងៃខែឆ្នាំនៃការសម្រាលរំពឹងទុក..................................................
   ថ្ងៃខែឆ្នាំនៃការធ្វើតេស្តមេរោគអេដស៍...................................... ថ្ងៃខែឆ្នាំនៃការទទួលលទ្ធផល........................................
   ទីកន្លែងធ្វើតេស្តឈាម.........................................................................................................................
   បញ្ជូនពី: គ្លីនិក ART □ មណ្ឌលសុខភាព □ បញ្ជាក់ឈ្មោះ.......................................ថ្ងៃខែឆ្នាំ..............................

| |
|---|
| ថ្ងៃខែឆ្នាំនៃការសម្រាល.................................................... ពេលវេលានៃការសម្រាល................................................ |
| ភេទ......................... ទម្ងន់............................................ អាប់ហ្គា.................................................................... |
| ប្រភេទនៃការសម្រាល........................................................................................................................... |
| ជម្រើសនៃការចិញ្ចឹម ៖ ការបៅដោះម្តាយ □ ទឹកដោះគោម្សៅ □ ផ្សេងទៀត □ |

2. ឈ្មោះរបស់ប្តី/ដៃគូ................................... អាយុ.............. មុខរបរ......................................................
   អាសយដ្ឋាន.........................................................................................................................................
   ថ្ងៃខែឆ្នាំធ្វើតេស្តមេរោគអេដស៍............................................... លទ្ធផលនៃការធ្វើតេស្តមេរោគអេដស៍.................................
   ទីកន្លែងធ្វើតេស្តឈាម..........................................................................................................................

## 2.2 ព័ត៌មានអំពី ART សម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍

## (សម្រាប់មន្ទីរពេទ្យបង្អែកដែលមានសេវាសម្ភព)

លេខកូដ PMTCT:............................................................លេខកូដ ART:....................................................................

ថ្ងៃខែឆ្នាំចូលសម្រាកពេទ្យ៖........................................ពេលវេលាឈឺពោះសម្រាល......................... ថ្ងៃខែឆ្នាំ.................................

ថ្ងៃខែឆ្នាំសម្រាល៖.............................................................. ទម្ងន់ទារក៖...................................................................

| **សម្រាប់ម្ដាយដែលឆ្លងមេរោគអេដស៍** |
|---|
| ☐គ្មាន ART |
| ☐បានទទួល ART មុនពេលមានផ្ទៃពោះ។ កាលបរិច្ឆេទ៖........................................................... |
| ☐បានទទួល ART (ជម្រើស B+*) ក្នុងពេលមានផ្ទៃពោះ ។ ថ្ងៃខែឆ្នាំ៖ ......................................... |
| ☐បានទទួល ART (ជម្រើស B+) ក្នុងពេលឈឺពោះសម្រាល និងពេលសម្រាល។ កាលបរិច្ឆេទ៖............................... |
| ☐បានទទួល ART (ជម្រើស B+) នៅក្រោយពេលសម្រាល។ កាលបរិច្ឆេទ៖................................... |
| ☐បន្តប្រើ ART មួយជីវិត |
| ជម្រើសនៃការចិញ្ចឹម៖ ការបំបៅដោយទឹកដោះម្ដាយ ☐ ការចិញ្ចឹមដោយទឹកដោះគោម្សៅ ☐ ផ្សេងទៀត៖ ☐ |

| **សម្រាប់ទារកដែលប្រឈមនឹងមេរោគអេដស៍** | | | |
|---|---|---|---|
| ☐គ្មានការព្យាបាលបង្ការដោយ ARV | | | |
| ☐បានទទួលការព្យាបាលបង្ការដោយ ARV | | | |
| ARV Syrup | Quantity | Date and Time given | Others |
| | | | |
| | | | |
| | | | |
| | | | |

- ***ជម្រើស B+: TDF (300mg) + 3TC (300mg) + EFV (600mg) មួយគ្រាប់ក្នុងមួយថ្ងៃ***

## 2.3 ការចុះឈ្មោះជាមុនសម្រាប់ស្ត្រីមានផ្ទៃពោះដែលឆ្លងមេរោគអេដស៍ និងទារកដែលប្រឈមនឹងមេរោគអេដស៍

## ( សម្រាប់ការថែទាំជំងឺកុមារ ភ្ជាប់ជាមួយប័ណ្ណថ្នាំបង្ការ )

លេខកូដ PMTCT៖..........................................................លេខកូដ ART៖...................................................................

អាសយដ្ឋាន..........................................................................................................................................................

ថ្ងៃខែឆ្នាំសម្រាល.................................................................ទីកន្លែងសម្រាល៖..................................................................

